

National Council for Sustainable Development

បរិស្ថាន

## ការសិក្សាលើកទី៣

# ការស្វែងយល់ពីទស្សនៈសាធារណជន ចំពោះការប្រែប្រួលអាកាសធាតុ នៅប្រទេសកម្ពុជា

## ចំណេះដឹង ឥរិយាបថ និងការអនុវត្ត

២០២០



ការសិក្សាលើកទី៣ ស្ដីពី

# ការស្វែងយល់ទស្សនៈសាធារណជនចំពោះ ការប្រែប្រួលអាកាសធាតុនៅកម្ពុជា

## ចំណេះដឹង ឥរិយាបថ និងការអនុវត្ត ( KAP៣ )

ឆ្នាំ២០២០

**២០២០ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៅក្នុងរបាយការណ៍នេះត្រូវបានយកទៅផលិតឡើងវិញ ចម្លងទុក ឬផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាននោះឡើយ។

**ការដកស្រង់៖**

អ.ក.អ.ច./ ប.ស្ថ. ២០២០. *ការសិក្សាលើកទី៣ ស្តីពីការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ចំណេះដឹង ឥរិយាបថ និងការអនុវត្ត.* ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន (អ.ក.អ.ច./ប.ស្ថ). ភ្នំពេញ. កម្ពុជា

# មាតិកា


**អក្សរកាត់ និងពាក្យបំព្រួញ** ........ v
**អារម្ភកថា** ........ vii
**សេចក្តីថ្លែងអំណរគុណ** ........ ix
**វាក្យសព្ទសំខាន់ៗ** ........ xi
**អំពីការសិក្សានេះ** ........ xiii
**សេចក្តីសង្ខេប** ........ xiv
**១. បរិបទនៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា** ........ ១

១.១ ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា ........ ១
១.២ ក្របខ័ណ្ឌគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ ........ ២
១.៣ រចនាសម្ព័ន្ធស្ថាប័នពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ........ ៥
១.៤ កម្មវិធីអន្តរាគមន៍ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ........ ៥
១.៥ គម្លាតរវាងគោលនយោបាយ និងកិច្ចអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុ ........ ៧
១.៦ ចំណេះដឹង ឥរិយាបថ និងការអនុវត្តទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ........ ៨
១.៧ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងបរិបទយេនឌ័រ ........ ១០

**២ . វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ១២

២.១ ការសិក្សាលើឯកសារដែលមានស្រាប់ ........ ១២
២.២ ការសិក្សាបែបបរិមាណវិស័យ ........ ១២
២.៣ ការសិក្សាស្រាវជ្រាវបែបគុណវិស័យ ........ ១៦
២.៤ សិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ ........ ១៧
២.៥ កំណត់ត្រាណែនាំស្តីពីវិធីសាស្ត្រខុសគ្នារវាងការសិក្សានៃKAPទាំងបី ........ ១៧
២.៦ ដែនកំណត់នៃការសិក្សា ........ ២១

**៣ .លទ្ធផលនៃការស្រាវជ្រាវ** ........ ២២

៣.១ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ........ ២២
៣.២ ការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ (ការយល់ដឹង) ........ ២៥
៣.៣ ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ ........ ៣៣
៣.៤ ឥរិយាបថស្តីពីការប្រែប្រួលអាកាសធាតុ ........ ៣៥
៣.៥ ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ ........ ៣៧
៣.៦ ការអនុវត្តក្នុងការឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ ៤១

៣.៧ ការស្វែងយល់អំពីឧបសគ្គ និងកត្តាជំរុញទឹកចិត្តក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ៥៦
៣.៨ ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទង ........................................................ ៦៦
៣.៩ ការវិភាគ បំបែកក្រុម ប្រជាជនទៅតាមភាពងាយរងគ្រោះ .................................................. ៧៤
**៤ . សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........................................................................ ៨៣
៤.១ សេចក្តីសន្និដ្ឋាន ........................................................................................ ៨៣
៤.២ អនុសាសន៍ ............................................................................................... ៨៤
**ឯកសារយោង** ............................................................................................... ៩៤
**ឧបសម្ព័ន្ធ** ................................................................................................... ៩៨
ឧបសម្ព័ន្ធទី១៖ យុទ្ធសាស្រ្តនៃការប្រាស្រ័យទាក់ទង ......................................................... ៩៨
ឧបសម្ព័ន្ធទី២៖ បញ្ជីសំណួរសំខាន់ៗដែលអាចប្រើប្រាស់សម្រាប់សូចនាករនាពេលអនាគត........ ១១១
ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរសម្រាប់ការអង្កេត KAP៣....................................................... ១១៨
ឧបសម្ព័ន្ធទី៤៖ តារាងវិភាគទិន្នន័យសំខាន់របស់KAP៣...................................................... ១៦១

## បញ្ជីរូបភាព


រូបភាពទី ១៖ ការបែងចែកសំណាកតាមតំបន់ភូមិសាស្ត្រនៃការសិក្សាស្រាវជ្រាវ ............ ១៣
រូបភាពទី ២៖ ស្ថានភាពប្រាក់ចំណូលគ្រួសារតាមតំបន់ភូមិសាស្ត្រនីមួយៗ ............ ២៣
រូបភាពទី ៣៖ គុណតម្លៃដែលមានសារៈសំខាន់សម្រាប់ប្រជាជនកម្ពុជា ............ ២៤
រូបភាពទី ៤៖ ការយល់ឃើញពីការប្រែប្រួលលទ្ធភាពទទួលបានធនធាននានា ............ ៥៣
រូបភាពទី ៥៖ ការយល់ឃើញពីការប្រែប្រួលនៃបរិស្ថាន ............ ៣១
រូបភាពទី ៦៖ ការយល់ឃើញពីការប្រែប្រួលធាតុអាកាសតាមតំបន់ភូមិសាស្ត្រនីមួយៗ ............ ៣៣
រូបភាពទី ៧៖ ការស្គាល់ពាក្យ ការប្រែប្រួលអាកាសធាតុ និងការឡើងកម្ដៅភពផែនដី ............ ៣៤
រូបភាពទី ៨៖ ការយល់ឃើញពីកត្តាដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុ ............ ៣៦
រូបភាពទី ៩៖ ការយល់ឃើញពីផលប៉ះពាល់ក្នុងពេលបច្ចុប្បន្ន និងអនាគត ............ ៣៧
រូបភាពទី ១០៖ ផលប៉ះពាល់បច្ចុប្បន្នដែលបង្កឡើងពីការប្រែប្រួលអាកាសធាតុ បរិស្ថាន និងលទ្ធភាពប្រើប្រាស់ទឹក តាមកម្រិតនៃការទទួលបានការអប់រំ ............ ៦៣
រូបភាពទី ១១៖ ចំនួនអ្នកតបសម្ភាសន៍ដែលបានរាយការណ៍ថាបានធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលនានានៃអាកាសធាតុ ............ ៤៦
រូបភាពទី ១២៖ ការផ្លាស់ប្ដូរដែលប្រជាជនបាននិងកំពុងធ្វើនាពេលបច្ចុប្បន្ន និងមានបំណងធ្វើនាពេលអនាគត ............ ៤៧
រូបភាពទី ១៣៖ ការឆ្លើយតបទៅនឹងកង្វះទឹកប្រើប្រាស់នាពេលបច្ចុប្បន្ន ............ ៥០
រូបភាពទី ១៤៖ ការឆ្លើយតបទៅនឹងកង្វះម្ហូបអាហារ ............ ៥១
រូបភាពទី ១៥៖ ចំនួនអ្នកឆ្លើយតបសម្ភាសន៍ដែលបានរាយការណ៍ថាប្រជាជនក្នុងសហគមន៍កំពុងធ្វើសកម្មភាពឆ្លើយតប ............ ៥៣
រូបភាពទី ១៦៖ ការយល់ឃើញរបស់សហគមន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលធនធាន បរិស្ថាន និងអាកាសធាតុ ............ ៥៤
រូបភាពទី ១៧៖ ឥរិយាបថចំពោះការធ្វើសកម្មភាពឆ្លើយតបជាលក្ខណៈបុគ្គល និងរួមគ្នា (ភាគរយអ្នកដែលបានយល់ស្រប) ............ ៥៥
រូបភាពទី ១៨៖ ឧបសគ្គនានាក្នុងការឆ្លើយតប/ធ្វើសកម្មភាពឆ្លើយតប ............ ៥៧
រូបភាពទី ១៩៖ ទំនុកចិត្តទៅលើស្ថាប័ននានាក្នុងការធ្វើសកម្មភាពឆ្លើយតប ............ ៨៥
រូបភាពទី ២០៖ កត្តាជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប ............ ៦២
រូបភាពទី ២១៖ ការយល់ស្របនឹងប្រយោគនានាពាក់ព័ន្ធនឹងតួនាទីយេនឌ័រ ............ ៦៤
រូបភាពទី ២២៖ ប្រព័ន្ធផ្សព្វផ្សាយដែលបានប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំចុងក្រោយ ............ ៦៧
រូបភាពទី ២៣៖ រយៈពេលចំណាយក្នុងការប្រើប្រាស់ទូរស័ព្ទដៃតាមក្រុមអាយុ ............ ៦៨
រូបភាពទី ២៤៖ លទ្ធភាពទទួលបានអ៊ីនធើណេតប្រើប្រាស់តាមក្រុមអាយុ ............ ៧០

រូបភាពទី ២៥៖ ប្រភពព័ត៌មានស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ............................ ១០០
រូបភាពទី ២៦៖ វិធីសាស្ត្ររូបផ្គុំ (jigsaw) នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ............................... ១០០

## បញ្ជីតារាង

តារាងទី ១៖ សំណាកសម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ................................................ ១៤
តារាងទី ២៖ ប្រភេទអ្នកចូលរួមក្នុងការសិក្សាបែបគុណវិស័យ .................................................. ១៦
តារាងទី ៣៖ សេចក្តីសង្ខេបអំពីវិធីសាស្ត្រខុសគ្នារវាងការសិក្សាKAP នីមួយៗ .................................១៩
តារាងទី ៤៖ ការបែងចែកក្រុមនីមួយៗតាមប្រជាសាស្ត្រ........................................................ ៧៥
តារាងទី ៥៖ លក្ខណៈវិនិច្ឆ័យសំខាន់ៗរបស់ក្រុមទាំងបួន ...................................................... ៧៦
តារាងទី ៦៖ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់កសិករ និងអ្នកនេសាទ .................................១០៤
តារាងទី ៧៖ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់ប្រជាជនក្រីក្របំផុត និងក្រីក្រ ....................... ១០៦
តារាងទី ៨៖ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់ប្រជាជនវ័យក្មេង........................................ ១០៨
តារាងទី ៩៖ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់ស្ត្រី..........................................................១០៩
តារាងទី១០៖ បញ្ជីសំណួររបស់ KAP៣ សម្រាប់ការពិចារណាសូចនាករនាពេលអនាគត.............. ១១១

## បញ្ជីករណីសិក្សា

ករណីសិក្សាទី ១៖ ការស្វែងយល់ពីលទ្ធភាពទទួលបានទឹកប្រើប្រាស់នៅទីជនបទ ..........................២៥
ករណីសិក្សាទី ២៖ ប្រជាជនកំពុងជួបប្រទះការថយចុះនូវប្រាក់ចំណូល ......................................៤៤
ករណីសិក្សាទី ៣៖ ការអនុវត្តសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ..............................៤៨
ករណីសិក្សាទី ៤៖ ស្ត្រីមេម៉ាយជាម្តាយម្នាក់និយាយអំពីការដោះស្រាយបញ្ហាកង្វះទឹក .....................៦៦

# អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADPC | មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី |
| BBC | សាជីវកម្មផ្សព្វផ្សាយអង់គ្លេស |
| CAPI | ការសម្ភាសដោយផ្ទាល់តាមរយៈការកត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក |
| CCAPs | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCFF | ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ |
| COVID-19 | ជំងឺកូវីដ-១៩ |
| CSO | អង្គការសង្គមស៊ីវិល |
| DCC | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| FGD | ការពិភាក្សាក្រុម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GSSD | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| KAP | ចំណេះដឹង ឥរិយាបថ និងការអនុវត្ត |
| KAP3 | ការសិក្សាលើកទី៣ ស្តីពីការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ចំណេះដឹង ឥរិយាបថ និងការអនុវត្ត |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoWA | ក្រសួងកិច្ចការនារី |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NAP | ផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NAP-DRR | ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| NCCC | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

| | |
|---|---|
| NCDDS | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NDCs | ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PIC | វិទ្យាស្ថានសភាកម្ពុជា |
| PPS | វិធីសាស្ត្រប្រូបាបសមាមាត្រទៅនឹងទំហំ |
| PSA | សេចក្តីជូនដំណឹងជាសាធារណៈ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDRR | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |

# អារម្ភកថា

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ដែលងាយរងគ្រោះបំផុតនៅលើពិភពលោកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវភាពងាយរងគ្រោះ និងកំណត់នូវវិធានការអាទិភាពជាច្រើន ដើម្បីដោះស្រាយបញ្ហាដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស និងបានចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលក្នុងនោះប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុតាំងពីឆ្នាំ១៩៩៦។ កម្ពុជាបានផ្ដល់សច្ចាប័នពិធីសារក្យូតូនៅ ឆ្នាំ២០០២ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីការប្រែប្រួលអាកាសធាតុ នៅឆ្នាំ២០១៥ ដោយបានផ្ដល់សច្ចាប័នកិច្ចព្រមព្រៀងនេះនៅក្នុង ឆ្នាំ២០១៧។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដែលជាកម្មវិធីពហុជំនួយផ្ដល់មូលនិធិពីសហភាពអឺរ៉ុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងប្រទេសស៊ុយអែត បានរៀបចំការសិក្សាលើកទីបី ស្ដីពីការឈ្វេងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជាដោយផ្ដោតលើ ចំណេះដឹង ឥរិយាបថនិងការអនុវត្ត ហៅកាត់ថា KAP៣ ដើម្បីស្វែងយល់អំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាជនកម្ពុជា។

ប្រទេសកម្ពុជាបានបង្ហាញនូវកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហា នៃការប្រែប្រួលអាកាសធាតុនៅកម្រិតគោលនយោបាយ ជាពិសេសតាមរយៈការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្ដីដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត ការបង្កើនចំណេះដឹង ឥរិយាបថ និងការអនុវត្តឱ្យបានកាន់តែខ្លាំងក្លានៅក្នុងប្រទេសគឺជារឿងចាំបាច់។ ការសិក្សាពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាត្រូវបានរៀបចំឡើងរៀងរាល់ប្រាំឆ្នាំម្ដង ក្នុងគោលបំណងផ្ដល់ព័ត៌មានសម្រាប់ការលើកកម្ពស់ផ្ដល់ចំណេះដឹង ការរៀបចំយន្តការ និងកម្មវិធីអន្តរាគមន៍នានាឱ្យកាន់តែប្រសើរឡើងសម្រាប់ពេលអនាគតដើម្បីជួយគាំទ្រដល់ក្រុមប្រជាជន ដែលស្ថិតក្នុងស្ថានភាពផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជាឱ្យក្លាយជាប្រជាជនដែលមានសមត្ថភាព ភាពជឿជាក់ក្នុងការឆ្លើយតបនឹងឧបសគ្គនៃការប្រែប្រួលអាកាសធាតុកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ការសិក្សាលើកទី១ (KAP១) បានធ្វើឡើងក្នុងឆ្នាំ២០១០ បន្ទាប់មក KAP២ បានធ្វើឡើងនៅក្នុងឆ្នាំ២០១៥ និង KAP៣ នេះ ធ្វើឡើងក្នុងឆ្នាំ២០២០។

ការសិក្សា KAP៣ នេះបានប្រមូលព័ត៌មានតាមរយៈការសម្ភាសតំណាងប្រជាជនកម្ពុជាចំនួន ១.៥៦០នាក់ និងការអង្កេតតាមបែបគុណវិស័យតាមរយៈការសម្ភាសបែបស៊ីជម្រៅ និងការពិភាក្សាជាក្រុមជាមួយអ្នកចូលរួមជាង១០០នាក់ ដោយរួមមានប្រជាជននៅក្នុងកម្រិតសហគមន៍ (បុរស ស្ត្រី ក្រុមងាយរងគ្រោះ បុគ្គលសំខាន់ៗនៅមូលដ្ឋាន មេភូមិ) និងអ្នកពាក់ព័ន្ធសំខាន់ៗដូចជាតំណាងមកពីព្រឹទ្ធសភាជាតិ រដ្ឋសភា ក្រសួង/ស្ថាប័ន រាជរដ្ឋាភិបាល ភ្នាក់ងារសារព័ត៌មាន គ្រឹះស្ថានឧត្ដមសិក្សា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ការសិក្សានេះបានរកឃើញថា ពីរភាគបីនៃប្រជាជនកម្ពុជា

ដែលបានផ្តល់សម្ភាសន៍យល់ថា ជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ជាងនេះទៅទៀតការយល់ដឹងពីពាក្យ «**ការប្រែប្រួលអាកាសធាតុ**» ក្នុងចំណោមប្រជាជនកម្ពុជាមានភាពប្រសើរឡើង។ ប្រជាជនកម្ពុជាភាគច្រើនយល់ថាការប្រែប្រួលអាកាសធាតុកំពុងកើតមានឡើងនៅកម្ពុជា ហើយប្រជាជនប្រមាណបីភាគបួនយល់ថាសីតុណ្ហភាពបានកើនឡើង ហើយគ្រោះរាំងស្ងួតបានកើនឡើងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ប្រជាជនកម្ពុជាបានរៀបរាប់ថាពួកគាត់បានត្រៀមបង្ការសម្រាប់អាកាសធាតុធ្ងន់ធ្ងរដូចជា រលកកម្តៅ ខ្យល់ព្យុះ គ្រោះរាំងស្ងួត និងទឹកជំនន់ ហើយពួកគាត់ក៏មានឆន្ទៈក្នុងការផ្លាស់ប្តូរបន្ថែមទៀតដែរនាពេលអនាគត។ ប្រជាជនកម្ពុជាស្ទើរតែទាំងអស់បានរាយការណ៍ថាពួកគាត់បានធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុយ៉ាងតិចក៏មួយដែរ។

ការជំរុញលើកទឹកចិត្តប្រជាជនឱ្យធ្វើសកម្មភាពបន្ថែមទៀតមានសារសំខាន់ណាស់ ដើម្បីបង្កើនសន្ទុះនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសតាមរយៈការផ្សារភ្ជាប់ផលប្រយោជន៍ដែលអាចមើលឃើញដោយផ្ទាល់ដូចជា ការធ្វើសកម្មភាពឆ្លើយតបដែលអាចជួយលើកកម្ពស់សុខុមាលភាព និងជីវភាពគ្រួសារ ក៏ដូចជាការអប់រំដល់កូនៗពួកគាត់ឱ្យមានភាពប្រសើរឡើង។ ការសិក្សានេះក៏បានរកឃើញដែរថា ការជជែកពិភាក្សា និងការបង្កើនចំណេះដឹងគឺជាធាតុសំខាន់ក្នុងការផ្លាស់ប្តូរឥរិយាបថនៃការប្រាស្រ័យទាក់ទង និងគាំទ្រប្រជាជនឱ្យធ្វើសកម្មភាពឆ្លើយតប ដែលកត្តាទាំងនេះអាចនឹងជួយឱ្យប្រជាជនឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងស្ថានភាពបន្ទាន់ៗនៅថ្ងៃអនាគតបានកាន់តែប្រសើរ។

រាជរដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការឆ្ពោះទៅរកការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបញ្ចេញកាបូនតិច។ តាមរយៈលទ្ធផលពីការសិក្សា KAP៣ នេះយើងអាចនឹងរៀបចំកម្មវិធីអន្តរាគមន៍នានាដើម្បីពង្រឹងបន្ថែមនូវចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបំពេញកាតព្វកិច្ចក្នុងការចូលរួមចំណែកឱ្យការរស់នៅរបស់ប្រជាជនយើង ជាពិសេសក្រុមងាយរងគ្រោះមានភាពល្អប្រសើរ។ យើងសង្ឃឹមយ៉ាងមុតមាំក្នុងការធ្វើការងាររួមគ្នាជាមួយភាគីពាក់ព័ន្ធនានាដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបង្កើនការឆ្លើយតបនៅគ្រប់កម្រិតទាំងអស់។ ជំនួសមុខឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយដែលបានគាំទ្រថវិកា និងបច្ចេកទេស និងអរគុណដល់ភាគីពាក់ព័ន្ធនានាដែលបានគាំទ្រក៏ដូចជាបានសហការក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ។ យើងទាំងអស់គ្នាប្តេជ្ញាចិត្តបន្តការងារទាំងនេះ ដើម្បីជួយដល់ប្រជាជនកម្ពុជាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ៩ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថាន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថាប័ន ព្រឹទ្ធសភាជាតិ រដ្ឋសភា ក្រសួងពាក់ព័ន្ធ វិទ្យាស្ថាន ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងគ្រឹះស្ថានឧត្តមសិក្សានានា ដែលបានចូលរួមចំណែកតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ក្នុងការផ្តល់នូវធាតុចូល និងអនុសាសន៍សំខាន់ៗជួយឲ្យរបាយការណ៍ដ៏មានតម្លៃនេះបានលេចជារូបរាងឡើង។

សូមសម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងការតម្រង់ទិសពីសំណាក់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមចំណែកសំខាន់ នៃក្រសួងបរិស្ថាន រួមមាន **ឯកឧត្តម ទិន ពន្លក** រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន **ឯកឧត្តម វ៉ាន់ មុនីនាថ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង**លោកបណ្ឌិត ហាក់ ម៉ៅ** ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុសម្រាប់ការផ្តល់អនុសាសន៍ដ៏មានខ្លឹមសារអត្ថន័យ។

ក្រសួងបរិស្ថានក៏សូមកោតសរសើរចំពោះការគាំទ្រផ្នែកបច្ចេកទេស និងកិច្ចសហការល្អពីសំណាក់មន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ ជាពិសេស លោកបណ្ឌិត ហេង ចាន់ធឿន និងលោកស្រី ឃ្លោក វិចិត្ររដ្ឋា អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ លោក ស៊ឹម ទូច និង កញ្ញា ទេព សុខបញ្ញា ផងដែរ។ យើងខ្ញុំក៏សូមអរគុណចំពោះ លោក Julien Chevillard និងលោកស្រី Niina Kylliainen ព្រមទាំង លោក សែម សាវុធ លោក សី ពៅ និងបុគ្គលិកពាក់ព័ន្ធក៏ដូចជាទីប្រឹក្សាទាំងអស់នៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដែលបានជួយសម្របសម្រួល និងតាមដាន ក៏ដូចជាបានផ្តល់នូវធាតុចូលសំខាន់ៗសម្រាប់ដំណាក់កាលនីមួយៗនៃការអនុវត្តនៃគម្រោងKAP៣នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ដៃគូ និងអ្នកចូលរួមទាំងឡាយដែលបានរួមចំណែកក្នុងការសិក្សានេះ ជាពិសេសការផ្តល់ធាតុចូលនានាសម្រាប់របាយការណ៍តាមរយៈសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញជាដើម។

ជាចុងក្រោយ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការ ប៊ីប៊ីស៊ី មីឌាអាក់សិន (BBC Media Action) សម្រាប់ការអនុវត្តការស្រាវជ្រាវ KAP៣ និងសរសេររបាយការណ៍នេះឡើង។ ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមអ្នកស្រាវជ្រាវរួមមាន លោក Benedek Paskuj លោកស្រី សៅ វិច្ឆិកា លោក ហោ ឧត្តម និង កញ្ញា Fazila Ismail ព្រមទាំងក្រុមអ្នកត្រួតពិនិត្យ និងកែសម្រួលរបាយការណ៍ស្រាវជ្រាវរួមមាន លោកស្រី Sally Gowland និង លោកស្រី Lorna Fray។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ លោកស្រី Sonia Whitehead ចំពោះការត្រួតពិនិត្យលទ្ធផល និងរបាយការណ៍ស្រាវជ្រាវ និងលោកស្រី Gemma Hayman ចំពោះការរៀបចំយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងនៅក្នុងរបាយការណ៍នេះ ព្រមទាំងការជួយគាំទ្រ និងការទំនាក់ទំនងផ្សេងៗក្នុងដំណើរការសិក្សាស្រាវជ្រាវ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ លោក ទឹម សុភា ដែលបានជួយផ្តល់ធាតុចូលសម្រាប់ការកែលម្អឧបករណ៍ស្រាវជ្រាវ ការចូលរួមក្នុងការប្រមូលទិន្នន័យបែបគុណវិស័យ និងបានផ្តល់ធាតុចូលសម្រាប់ការសរសេររបាយការណ៍ស្រាវជ្រាវ លោក ផូ យ៉ាទី ដែលបានរួមចំណែកជួយត្រួតពិនិត្យ សម្អាត និងវិភាគទិន្នន័យបែបបរិមាណវិស័យ លោកស្រី ហែម មេត្តា ដែលបានជួយរួមចំណែកក្នុងការបកប្រែរបាយការណ៍ស្រាវជ្រាវ ព្រមទាំង កញ្ញា គីម លីស៊ីនឹង ដែលបានដឹកនាំការប្រមូលទិន្នន័យបែបគុណវិស័យនៅមូលដ្ឋាន និងរួមចំណែកក្នុងការវិភាគលទ្ធផលស្រាវជ្រាវបឋមសម្រាប់ទិន្នន័យបែបគុណវិស័យ។

សូមថ្លែងអំណរគុណដល់ក្រុមហ៊ុន KANTAR TNS សម្រាប់ការជួយប្រមូលទិន្នន័យបែបបរិមាណវិស័យ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រាប់ការផ្តល់ធាតុចូលផ្នែកបច្ចេកទេស។

# វាក្យសព្ទសំខាន់ៗ

**សមត្ថភាពបន្សាំ** គឺជាលទ្ធភាពរបស់ប្រព័ន្ធ (អេកូឡូស៊ី សង្គម ។ល។) ស្ថាប័ន មនុស្ស និងសារពាង្គកាយនានា ដើម្បីសម្របទៅនឹងការខូចខាតទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែលអាចកើតមានឡើង និងទាញយកផលប្រយោជន៍ពីកាលានុវត្តភាពឬឆ្លើយតបនឹងផលវិបាកនានា (Intergovernmental Panel on Climate Change [IPCC], ២០១៨)។

**ការប្រែប្រួលអាកាសធាតុ** គឺជាការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់អត្តសញ្ញាណ (តាមរយៈការវិភាគស្ថិតិ) តាមរយៈការប្រែប្រួលតួលេខមធ្យម និងឬតួលេខអថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទស្សវត្សរ៍ ឬយូរជាងនេះ (IPCC, ២០១៨)[1]។

**ផ្នត់គំនិតយេនឌ័រ** គឺជាការទទួលយកកត្តា និងលក្ខណៈទាំងឡាយនៃអត្តសញ្ញាណយេនឌ័ររបស់បុរស និងស្ត្រី នៅចំណុចនៃពេលវេលាជាក់លាក់ណាមួយនៅក្នុងសង្គម ឬសហគមន៍ណាមួយ។ ចំណុចទាំងនេះគឺជាស្តង់ដារ និងការរំពឹងទុកដែលគេយល់ថាអត្តសញ្ញាណយេនឌ័រជាទូទៅមើលឃើញថាស័ក្តិសមនៅក្នុងសង្គម វប្បធម៌ និងសហគមន៍ណាមួយក្នុងពេលវេលាជាក់លាក់ណាមួយ។ ផ្នត់គំនិតយេនឌ័រ គឺជាគំនិតទាំងឡាយដែលកំណត់អំពីរបៀបដែលបុរស និងស្ត្រីគួរបង្ហាញ និងគួរតែប្រព្រឹត្ត។ ចំណុច ទាំងនេះបានចាប់កំណើតតាំងពីនៅក្នុងផ្ទៃ ដោយសារផ្នត់គំនិតយេនឌ័រអាចបង្កើតនៅក្នុងវដ្តនៃសង្គមភាវូបនីយកម្មយេនឌ័រ និងក្នុងផ្នត់គំនិត (United Nations Children's Fund [UNICEF], ២០១៧)។

**តួនាទីយេនឌ័រ** គឺជាបទដ្ឋានសង្គម និងអាកប្បកិរិយា ដែលមាននៅក្នុងវប្បធម៌ជាក់លាក់ណាមួយ ហើយត្រូវបានគេយល់យ៉ាងទូលំទូលាយថាវាសមរម្យសម្រាប់បុគ្គលម្នាក់ៗ នៃភេទជាក់លាក់ណាមួយ។ ចំណុចទាំងនេះជាទូទៅកំណត់បាននូវការទទួលខុសត្រូវ និងសកម្មភាពដែលជាតួនាទីសម្រាប់បុរសស្ត្រី ក្មេងស្រី ឬក្មេងប្រុសតាមបែបប្រពៃណី។ តួនាទីយេនឌ័រត្រូវបានកំណត់ឡើងតាមរយៈ រចនាសម្ព័ន្ធនៅក្នុងគ្រួសារ ការទទួលបានធនធាន ផលប៉ះពាល់នានានៃសេដ្ឋកិច្ចពិភពលោក ការកើតឡើងនៃវិវាទឬគ្រោះមហន្តរាយ និងកត្តាពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងមូលដ្ឋាន ដូចជាលក្ខខណ្ឌអេកូឡូស៊ី (UNICEF, ២០១៧)។

**កម្តៅភពផែនដី** គឺជាការប្រែប្រួលសីតុណ្ហភាពខ្យល់លើផ្ទៃផែនដីហៅថាសីតុណ្ហភាពភពផែនដីដែលបានកើតឡើងដោយសារកំណើនផលផ្ទះកញ្ចក់បង្កឡើងដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងខ្យល់ (IPCC, ២០១៨)។

---

[1] របាយការណ៍នេះបានស្វែងយល់ពីបទពិសោធន៍នានារបស់ប្រជាជនស្តីពីការប្រែប្រួលអាកាសធាតុ។ ដូច្នេះវាមិនមែនជាការកំណត់បែបវិទ្យាសាស្ត្រស្តីពីការផ្លាស់ប្តូរនានានៃអាកាសធាតុនៅក្នុងប្រទេសកម្ពុជានោះឡើយ ហើយវាក៏មិនអាចធ្វើការប្រៀបធៀបការយល់ឃើញជាសាធារណៈជាមួយកំណត់ត្រាទិន្នន័យឧតុនិយមនៅក្នុងប្រទេសកម្ពុជានោះដែរ។

**ការយល់ឃើញអំពីការប្រែប្រួលនៃលទ្ធភាពប្រើប្រាស់ ឬទទួលបានធនធាន** គឺជាការកើនឡើង ឬថយចុះដែលអ្នកតបសម្ភាសន៍បានយល់ឃើញអំពីលទ្ធភាពប្រើប្រាស់ទឹក ការទទួលបានចំណីអាហារ និងការប្រើប្រាស់ថាមពលក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ។

**ការយល់ឃើញអំពីការប្រែប្រួលធាតុអាកាស** គឺជាការកើនឡើង ឬថយចុះដែលអ្នកតបសម្ភាសន៍បានសង្កេតឃើញពីការប្រែប្រួលនានាដូចជា របបទឹកភ្លៀង សីតុណ្ហភាព ខ្យល់ព្យុះ និងធាតុអាកាសធ្ងន់ធ្ងរនានាក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ។

**ការយល់ឃើញអំពីការប្រែប្រួលបរិស្ថាន** គឺជាការកើនឡើង ឬថយចុះដែលអ្នកតបសម្ភាសន៍បានយល់ឃើញពីការប្រែប្រួលជីវៈចម្រុះ ចំនួនកត្តាចង្រៃ និងការបំពុលបរិស្ថានក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ។

**ភាពធន់/ភាពធន់ទ្រាំ** សមត្ថភាពនៃប្រព័ន្ធសង្គម-អេកូឡូស៊ី ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍គ្រោះថ្នាក់ ឬការរំខានណាមួយ ដែលអាចឆ្លើយតបឬចាត់ចែងឡើងវិញតាមវិធីដែលអាចរក្សាបាននូវមុខងារសំខាន់ៗ អត្តសញ្ញាណ និងរចនាសម្ព័ន្ធ ហើយដែលអាចរក្សាបាននូវសមត្ថភាពបន្សាំ ការរៀនសូត្រ និងវិធ្នៃប្រឌិត។ (Organisation for Economic Co-operation and Development [OECD], 2014)។

# អំពីការសិក្សានេះ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថានបាននិងកំពុងតាមដានប្រសិទ្ធភាព នៃកិច្ចខិតខំប្រឹងប្រែងនានានៅថ្នាក់ជាតិចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា ជាពិសេសតាមរយៈការអនុវត្តការស្រាវជ្រាវ ស្តីពីការប្រែប្រួលនានានៃចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP) របស់ប្រជាជនកម្ពុជាចំពោះការប្រែប្រួលអាកាសធាតុដែលជាផ្នែកមួយ នៃអាណត្តិរបស់ខ្លួនក្នុងការសម្របសម្រួលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានអនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលជាកិច្ចផ្តួចផ្តើមពហុភាគីដោយមានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប (EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងប្រទេសស៊ុយអែត។

នាយកដ្ឋានប្រែប្រួលអាកាសធាតុបានសហការជាមួយអង្គការ ប៊ីប៊ីស៊ី មីឌាអាក់សិន (BBC Media Action) ក្នុងការសិក្សា លើកទី៣នេះ។ ក្នុងនោះដែរការសិក្សាលើកទី១ (KAP១) បានធ្វើឡើងនៅក្នុងឆ្នាំ២០១០ និងការសិក្សាលើកទី២ (KAP២) បានធ្វើឡើងនៅឆ្នាំ២០១៥។ ការសិក្សាលើកទី៣ (KAP៣) នេះផ្តល់ឱកាសក្នុងការស្វែងយល់អំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាជនកម្ពុជា។ លទ្ធផលនៃការសិក្សានេះនឹងផ្តល់ជាព័ត៌មានក្នុងការតាក់តែងកិច្ចអន្តរាគមន៍នាពេលអនាគត ក៏ដូចជាជួយកំណត់នូវក្រុមមនុស្សដែលត្រូវការការជួយគាំទ្រជាអាទិភាពក្នុងការឆ្លើយតបនឹងឧបសគ្គនានា ដែលបង្កឡើងដោយអាកាសធាតុដែលពួកគាត់ជួបប្រទះ។

# សេចក្តីសង្ខេប

## សេចក្តីផ្តើម

ការស្រាវជ្រាវនេះគឺជាផ្នែកមួយនៃការសិក្សាជាបន្តបន្ទាប់ ស្តីពីការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជាដែលផ្តោតសំខាន់លើចំណេះដឹង ឥរិយាបថ និងការអនុវត្តនានារបស់ប្រជាជនកម្ពុជា (ហៅកាត់ថាការសិក្សា KAP) ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថាន តាមរយៈនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងដោយការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣។ ការសិក្សាស្រាវជ្រាវទាំងនេះបង្ហាញនិងវិភាគអំពីការយល់ដឹង និងការចូលរួមរបស់ប្រជាជនកម្ពុជាក្នុងការដោះស្រាយបញ្ហាជុំវិញការប្រែប្រួលអាកាសធាតុ។ ការសិក្សាស្រាវជ្រាវស្តីពីចំណេះដឹង ឥរិយាបថ និងការអនុវត្តនេះត្រូវបានរៀបចំឡើងរៀងរាល់ប្រាំឆ្នាំម្តង ឆ្នាំ២០១០ (KAP១) ឆ្នាំ២០១៥ (KAP២) និងឆ្នាំ២០២០ (KAP៣) ក្នុងគោលបំណងប្រមូលព័ត៌មានអំពីបទពិសោធន៍នានារបស់ប្រជាជនកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលទាំងឡាយនៃអាកាសធាតុ និងបរិស្ថាន ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងកិច្ចអន្តរាគមន៍ពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល នាពេលអនាគត។

ការស្រាវជ្រាវ (KAP៣) នេះបានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវចម្រុះក្នុងការប្រមូលទិន្នន័យ។ ក្រុមអ្នកស្រាវជ្រាវបានធ្វើការអង្កេតថ្នាក់ជាតិ (ដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ) ដែលបានសម្ភាសន៍តំណាងប្រជាជន ចំនួន១.៥៦០នាក់ នៅទូទាំងតំបន់សិក្សាទាំងប្រាំ (រាជធានីភ្នំពេញ តំបន់វាលទំនាប តំបន់ភ្នំ តំបន់ទន្លេសាប និងតំបន់ឆ្នេរ) និងខេត្ត/រាជធានីនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀតវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យក៏ត្រូវបានប្រើប្រាស់ផងដែរ តាមរយៈការសម្ភាសបែបស៊ីជម្រៅ និងការពិភាក្សាក្រុមជាមួយសមាជិកសហគមន៍ (បុរស ស្ត្រី ក្រុមងាយរងគ្រោះ បុគ្គលសំខាន់ៗនៅតាមមូលដ្ឋាន និងមេភូមិ) ព្រមទាំងអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើនទៀតដូចជា តំណាងព្រឹទ្ធសភា រដ្ឋសភា ស្ថាប័នរដ្ឋាភិបាល គណៈអភិបាល ខេត្ត ស្រុក មេឃុំ ព្រមទាំងតំណាងពីទីភ្នាក់ងារសារព័ត៌មាន គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានាផងដែរ។

ការស្រាវជ្រាវ KAP៣ នេះបានប្រើប្រាស់បញ្ជីសំណួរដែលមានការអភិវឌ្ឍប្រសើរ បើធៀបនឹងការសិក្សា KAP មុនៗ ដើម្បីស្វែងយល់ឲ្យកាន់តែសុក្រឹត្យអំពីទស្សនៈនានារបស់សាធារណជនជុំវិញការប្រែប្រួលអាកាសធាតុ[2]។ ឧទាហរណ៍ អ្នកតបសម្ភាសន៍ទាំងអស់តម្រូវឲ្យឆ្លុះបញ្ចាំងពីការប្រែប្រួលនានា ដែលពួកគាត់បានជួបប្រទះដូចជា ការប្រែប្រួលអាកាសធាតុ បរិស្ថាន និងធនធានដែលមានស្រាប់ក៏ដូចជាបញ្ជាក់នូវ

[2] កម្រងសំណួរសិក្សា KAP៣ បានប្រើវិធីសាស្ត្រមួយដែលអ្នកឆ្លើយសំណួរត្រូវបានសួរអំពីការផ្លាស់ប្តូរដែលពួកគេកំពុងកត់សម្គាល់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់ ដូចជាការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធាន ជាជាងបង្កើតការស្ទង់មតិទាំងមូលជុំវិញគោលគំនិតនៃ «ការប្រែប្រួលអាកាសធាតុ» ដែលខុសពីការស្ទង់មតិរបស់ KAP ពីមុន។ នេះគឺផ្អែកលើការស្រាវជ្រាវមុនដែលធ្វើឡើងដោយសកម្មភាពរបស់ក្រុមហ៊ុនប៊ីប៊ីស៊ី មីឌាអាក់សិន ដែលបានរកឃើញថា វាច្បាស់ណាស់ថាមនុស្សកំពុងកត់សម្គាល់ការប្រែប្រួលអាកាសធាតុ និងធនធាន ប៉ុន្តែមិនបានដោយផ្ទាល់ភ្ជាប់វាទៅនឹងការប្រែប្រួលអាកាសធាតុ។

បទពិសោធន៍របស់ពួកគាត់ អំពីការធ្វើសកម្មភាពឆ្លើយតបនានាជុំវិញបញ្ហាប្រែប្រួលទាំងនេះផងដែរ។ ដូច្នេះការប្រៀបធៀបរវាងលទ្ធផលស្រាវជ្រាវលើកទីបីនេះ ជាមួយនឹងការសិក្សាដែលបានធ្វើកន្លងមកអាចធ្វើទៅបានតែក្នុងលក្ខខណ្ឌសមស្រប និងសំណួរដូចគ្នាប៉ុណ្ណោះ។

# លទ្ធផលស្រាវជ្រាវសំខាន់ៗ

## ចំណេះដឹងនៃវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ»

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ការយល់ដឹងអំពីវាក្យសព្ទ «**ការប្រែប្រួលអាកាសធាតុ**» ក្នុងចំណោមប្រជាជនកម្ពុជានៅមានកម្រិតនៅឡើយ។ ប្រជាជនកម្ពុជាជិតបីភាគបួន (៧២%) បានលើកឡើងថាពួកគាត់ធ្លាប់បានឮវាក្យសព្ទ «**ការប្រែប្រួលអាកាសធាតុ**» ប៉ុន្តែមានតែប្រជាជនចំនួនមួយភាគបី (៣៣%) ប៉ុណ្ណោះ ដែលបានដឹងពីអត្ថន័យនៃពាក្យនេះ។ ចំណែកប្រជាជនច្រើនជាងមួយភាគបួន (២៨%) គឺមិនដែលធ្លាប់បានឮវាក្យសព្ទនេះទាល់តែសោះ។ ភាគីអ្នកពាក់ព័ន្ធដែលជាតំណាងមកពីស្ថាប័នរាជរដ្ឋាភិបាលនានា ដែលបានចូលរួមក្នុងការសិក្សានេះក៏បានឯកភាពផងដែរថាចំណេះដឹងអំពីពាក្យបច្ចេកទេស «**ការប្រែប្រួលអាកាសធាតុ**»នេះនៅមានកម្រិតពិតមែនក្នុងចំណោមប្រជាជនកម្ពុជា។

ស្រដៀងគ្នានេះដែរ ប្រជាជនកម្ពុជាស្ទើរតែបីភាគបួន(៧១%) បាននិយាយថាពួកគាត់ធ្លាប់បានឮពាក្យ «**កម្ដៅភពផែនដី**»។ មិនខុសគ្នាពីកម្រិតនៃការយល់ដឹងអំពីពាក្យ «**ការប្រែប្រួលអាកាសធាតុ**» នោះទេព្រោះមានតែប្រជាជនចំនួន៣១% ប៉ុណ្ណោះ ដែលបាននិយាយថាពួកគាត់ដឹងពីអត្ថន័យនៃពាក្យ «**កម្ដៅភពផែនដី**» នេះ ចំណែកឯប្រជាជនចំនួន៤០% ផ្សេងទៀតគឺមិនដែលបានដឹងអំពីពាក្យនេះឡើយ។

## ឥរិយាបថស្ដីពីការប្រែប្រួលអាកាសធាតុ

បន្ទាប់ពីបានសួរពីចំណេះដឹងនៃពាក្យការប្រែប្រួលអាកាសធាតុដោយមិនបង្ហើបចម្លើយរួចមក ក្រុមអ្នកស្រាវជ្រាវក៏បានអាននិយមន័យនៃពាក្យ «**ការប្រែប្រួលអាកាសធាតុ**» ទៅកាន់អ្នកតបសម្ភាសន៍ដើម្បីឲ្យគាត់បានយល់ពីអត្ថន័យនៃពាក្យនេះ មុនពេលចាប់ផ្ដើមសួរពួកគាត់ថាតើពួកគាត់គិតថាការប្រែប្រួលអាកាសធាតុកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជាដែរឬទេ។ លទ្ធផលបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើន (៨៤%) គិតថាការប្រែប្រួលអាកាសធាតុកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ហើយប្រជាជនចំនួន ៨១% គិតថាការប្រែប្រួលអាកាសធាតុនឹងផ្ដល់នូវផលប៉ះពាល់ដល់ប្រទេសកម្ពុជានាពេលអនាគតផងដែរ។

ការអង្កេតនេះក៏បានសាកសួរប្រជាជនអំពីមូលហេតុចម្បងៗ នៃការប្រែប្រួលអាកាសធាតុផងដែរ។ ដោយក្នុងនោះនៅពេល ដែលក្រុមអ្នកស្រាវជ្រាវបានអានអំពីចម្លើយមួយចំនួនសម្រាប់ឲ្យពួកគាត់ជ្រើសរើស ប្រជាជនភាគច្រើន (៧៦%) យល់ថាការបាត់បង់ព្រៃឈើគឺជាមូលហេតុចម្បងនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

## ការយល់ឃើញអំពីការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

ប្រជាជនកម្ពុជាដែលបានចូលរួមក្នុងការអង្កេតមានការយល់ដឹងច្រើនពីបទពិសោធន៍នានា នៃការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមាននៅតំបន់ដែលពួកគាត់រស់នៅ។ ពាក់ព័ន្ធនឹងធាតុអាកាស និងអាកាសធាតុ ប្រជាជនកម្ពុជាយល់ថាសីតុណ្ហភាពកាន់តែក្តៅឡើង របបទឹកភ្លៀងកំពុងថយចុះ ហើយភាពធ្ងន់ធ្ងរនៃគ្រោះរាំងស្ងួតក៏កំពុងកើនឡើងផងដែរ។ ប្រជាជនភាគច្រើន (៦៩%) យល់ថារបបទឹកភ្លៀងបានថយចុះក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ចំណែកឯប្រជាជនប្រមាណជាបីភាគបួន (៧៤%) យល់ថាសីតុណ្ហភាពបានកើនឡើងក្នុងមួយទសវត្សរ៍ចុងក្រោយ ហើយប្រជាជនចំនួន ៣៦% យល់ថាគ្រោះរាំងស្ងួតក៏បានកើនឡើងផងដែរ។

ប្រជាជនកម្ពុជាបានកត់សម្គាល់ឃើញពីការថយចុះនៃធនធានបរិស្ថានធម្មជាតិដូចជា ការបាត់បង់ព្រៃឈើ (៧៣%) និងការថយចុះនៃពូជត្រី (៦៤%) ជាដើម។ ពួកគាត់ក៏យល់ថាទិដ្ឋភាពផ្សេងទៀតនៃបរិស្ថាននៅតាមតំបន់ដែលពួកគាត់រស់នៅក៏កំពុងមានការផ្លាស់ប្តូរផងដែរ។ ឧទាហរណ៍ ប្រជាជនចំនួន ៦៩% គិតថាសត្វល្អិតចង្រៃ(រុយ និងមូស) មានការកើនឡើង និងបានរីកសាយចាប់តាំងពី ឆ្នាំ២០១០ មក។ ប្រជាជនប្រមាណជាង ៦១% បានជឿថាបរិមាណសំរាម និងសំណល់ប្លាស្ទិកមានការកើនឡើង ហើយ ៤២% ក៏បានជឿដែរថាមានការបំពុលខ្យល់កើនឡើង ជាពិសេសការលើកឡើងរបស់ប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញ។

ទោះយ៉ាងណាជាទូទៅប្រជាជនកម្ពុជាក៏បានរាយការណ៍ថាមានការកើនឡើងនូវធនធាននានា ដូចជា អគ្គិសនី និងប្រេងឥន្ធនៈជាដើម។ ប្រជាជនកម្ពុជាប្រហែលពាក់កណ្ដាលបាននិយាយថាពួកគាត់បានកត់សម្គាល់ពីការកើនឡើងនៃលទ្ធភាពដែលរកបាននូវម្ហូបអាហារ និងទឹកប្រើប្រាស់ ប៉ុន្តែការសិក្សានេះក៏បានបង្ហាញផងដែរថាប្រជាជនជាច្រើនក៏នៅតែខ្វះខាតលទ្ធភាពក្នុងការទទួលបាននូវតម្រូវការជាមូលដ្ឋានទាំងនេះផងដែរ ជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ជនបទ។

## ឥរិយាបថចំពោះការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

**ឥរិយាបថក្នុងការត្រៀមបង្ការ៖** ប្រជាជនកម្ពុជាជាងពាក់កណ្ដាល (៥៦%) បានអះអាងថាពួកគាត់បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនានាដូចជា រលកកម្ដៅ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ឬទឹកជំនន់ជាដើម។ ក្នុងចំណោមប្រជាជនដែលបានឆ្លើយតបសម្ភាសន៍ទាំងនេះ ប្រជាជន ១៤% គិតថាពួកគាត់បានត្រៀមបង្ការក្នុងកម្រិតខ្ពស់សម្រាប់ព្រឹត្តិការណ៍ទាំងនោះ ចំណែក ៤២% ទៀតគិតថាពួកគាត់បានត្រៀមបង្ការក្នុងកម្រិតបង្គួរប៉ុណ្ណោះ។ ទោះជាយ៉ាងណា ប្រជាជនកម្ពុជាចំនួន ៤៤% នៅតែយល់ថាពួកគាត់មិនទាន់បានត្រៀមបង្ការរួចជាស្រេចសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនៅឡើយទេ។ បន្ថែមលើសពីនេះទៅទៀតលទ្ធផលនៃការសិក្សានេះបង្ហាញថាប្រជាជនជាងមួយភាគបី (៣៨%) មានការព្រួយបារម្ភថាការប្រែប្រួល ដែលពួកគាត់កំពុងតែជួបប្រទះនឹងជះឥទ្ធិពលខ្លាំងដល់ជីវិតរស់នៅរបស់ពួកគាត់នាថ្ងៃអនាគត។ ក្នុងនោះដែរប្រជាជនចំនួនមួយភាគបី (៣៥%) រំពឹងថាវានឹងមានផល

ប៉ះពាល់ក្នុងកម្រិតមធ្យមនាពេលអនាគត ចំណែកឯ ១៤% ទៀត យល់ឃើញថានឹងមានផលប៉ះពាល់ក្នុងកម្រិតទាបប៉ុណ្ណោះចំពោះជីវិតរស់នៅរបស់ពួកគាត់នាពេលអនាគត។

**ឆន្ទៈក្នុងការធ្វើសកម្មភាពឆ្លើយតប៖** នៅពេលអ្នកសម្ភាសន៍សួរអំពីឆន្ទៈរបស់ប្រជាជនកម្ពុជាក្នុងការកែលម្អជីវភាពរស់នៅរបស់ពួកគាត់បន្ថែមទៀតក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនានា នៃធនធាន និងធាតុអាកាសដែលពួកគាត់កំពុងជួបប្រទះ ប្រជាជនចំនួន ៧៩% បាននិយាយថាពួកគាត់មានឆន្ទៈខ្ពស់ក្នុងការធ្វើការផ្លាស់ប្តូរនាពេលអនាគត។ លទ្ធផលនេះបញ្ជាក់ឲ្យឃើញថាប្រជាជនកម្ពុជាមានបំណងក្នុងការត្រៀមបង្ការ និងប្រឹងប្រែងសម្រាប់ការប្រែប្រួលនៃអាកាសធាតុអាកាស បរិស្ថាន និងធនធាននានាដែលជះឥទ្ធិពលដល់ការរស់នៅរបស់ពួកគាត់។

**ឥរិយាបថជុំវិញផលប៉ះពាល់នានាដែលបានជួបប្រទះ៖** ប្រជាជនកម្ពុជាបានបង្ហាញពីការព្រួយបារម្ភអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះសុខភាព និងសកម្មភាពប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់។ ឧទាហរណ៍ ប្រជាជនកម្ពុជាប្រហែលបួននាក់ក្នុងចំណោមប្រាំនាក់ (៧៩%) បានលើកឡើងថាការប្រែប្រួលលទ្ធភាពទាញយក និងប្រើប្រាស់ធនធានដែលមានស្រាប់ និងការប្រែប្រួលធាតុអាកាសបានផ្តល់ផលប៉ះពាល់ដល់សមត្ថភាពក្នុងការស្វែងរកប្រាក់ចំណូលរបស់ពួកគាត់ ឬធ្វើការងារដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ កត្តាដែលអាចជំរុញទឹកចិត្តប្រជាជនកម្ពុជាឲ្យធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុឱ្យខ្លាំងក្លា គឺការទទួលបានសុខភាពល្អ និងការផ្តល់អនាគតល្អសម្រាប់កូនៗរបស់ពួកគាត់ (ប្រជាជន ៩៨% បានលើកឡើងពីហេតុផលទាំងពីរនេះ)។

**ឧបសគ្គរារាំងក្នុងការធ្វើសកម្មភាពឆ្លើយតប៖** ឧបសគ្គដែលរារាំងអ្នកឆ្លើយតបសម្ភាសន៍ក្នុងការចាត់វិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ គឺការគាំទ្រពីស្ថាប័ននៅមានកម្រិត និងការខ្វះខាតធនធាន។ ប្រជាជនចំនួន ៨០% បានលើកឡើងពីការគាំទ្រនៅមានកម្រិតពីសំណាក់រាជរដ្ឋាភិបាល និង ៧៥% លើកឡើងពីបញ្ហាខ្វះការគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល។ ប្រជាជនកម្ពុជាភាគច្រើន (៧០%) បានលើកឡើងពីតម្រូវការនៃធនធាននានាបន្ថែមទៀតដូចជា តម្រូវការបណ្តាញគាំទ្រដែលមានប្រសិទ្ធភាព និងលទ្ធភាពទទួលបានព័ត៌មានហិរញ្ញវត្ថុ ឬកម្លាំងពលកម្ម ដើម្បីធ្វើសកម្មភាពឆ្លើយតប។ ឧបសគ្គផ្នែកសង្គមដែលរារាំងដល់ការធ្វើសកម្មភាពឆ្លើយតបក៏ត្រូវបានប្រជាជនលើកឡើងផងដែរ។ ឧទាហរណ៍ ប្រជាជនចំនួន ៦១% យល់ថាពួកគាត់មិនអាចធ្វើសកម្មភាពឆ្លើយតបបានទេ ដោយសារពួកគាត់មានអាទិភាពផ្សេងៗទៀតដែលត្រូវដោះស្រាយ។

**ឥរិយាបថចំពោះការធ្វើសកម្មភាពឆ្លើយតបរបស់ស្ត្រី៖** នៅក្នុងប្រទេសកម្ពុជាបញ្ហាទាក់ទងនឹងលទ្ធភាពនៃការប្រើប្រាស់ទឹកប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រីច្រើនជាងបុរស។ លទ្ធផលនៃការអង្កេតរកឃើញការប្រែប្រួលធាតុអាកាស និងធនធាននានាបានផ្តល់ផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ស្ត្រី (៨២%) ច្រើនជាងបុរស (៧៥%)។ ប្រជាជនដែលចូលរួមក្នុងការអង្កេតនៅក្នុងសហគមន៍ និងភាគីពាក់ព័ន្ធនានាពីស្ថាប័នរដ្ឋាភិបាល ដែលបានចូលរួមក្នុងការសិក្សានេះក៏បានបង្ហាញថាលទ្ធភាពប្រើប្រាស់ទឹកគឺជាក្តីកង្វល់កាន់តែខ្លាំងសម្រាប់ស្ត្រីនៅពេល ដែលពួកគាត់ជាអ្នកទទួលខុសត្រូវលើការងារក្នុងគ្រួសាររួមមាន ការស្វែងរកទឹកសម្រាប់ការចម្អិនអាហារ ការលាងសម្អាត និងការប្រើប្រាស់ផ្សេងៗក្នុងគ្រួសារ។ អ្នកចូលរួមក្នុង

ការសិក្សាស្រាវជ្រាវនេះយល់ថាទំនួលខុសត្រូវរបស់ស្ត្រីក្នុងការមើលថែទាំកូនចៅ និងចាស់ជរាក្នុងគ្រួសារ បូករួមទាំងការទទួលខុសត្រូវផ្សេងទៀតសម្រាប់គ្រួសារបានធ្វើឲ្យស្ត្រីកាន់តែមានភាពងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ស្ត្រីក៏ទទួលរងឥទ្ធិពលពីបញ្ហាទូទៅជាច្រើនទៀតដែលរារាំងពួកគាត់មិនឲ្យធ្វើសកម្មភាពឆ្លើយតបនានាដោយឯករាជ្យបានផងដែរ។ លទ្ធផលអង្កេតបង្ហាញថាប្រជាជនចំនួន ៧២% យល់ស្របនឹងការលើកឡើងថា «បុរសគួរតែជាអ្នកសម្រេចចិត្តចុងក្រោយនៅក្នុងគ្រួសារពាក់ព័ន្ធនឹងការអនុវត្តការបន្សាំខ្លួននឹងការប្រែប្រួលអាកាសធាតុ»។ តួលេខបានបង្ហាញថាចំនួនបុរស (៧៦%) ច្រើនជាងស្ត្រី (៦៩%) ដែលបានយល់ស្របនឹងការលើកឡើងបែបនេះ។

## ការអនុវត្តដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

**ការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ៖** ក្រុមអ្នកស្រាវជ្រាវបានសួរនូវសំណួរអំពីសកម្មភាពដែលប្រជាជនកម្ពុជាបានធ្វើដើម្បីទប់ទល់ទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ។ ក្នុងនោះដែរការតាមដានព័ត៌មានស្តីពីការព្យាករណ៍អាកាសធាតុគឺជាសកម្មភាព ដែលមានប្រជាជនបានអង្កេតច្រើនជាងគេ (៦៤%) បន្ទាប់មកគឺការសន្សំប្រាក់ (៥៨%) និងការត្រៀមស្បៀងអាហារ (៥៧%)។ ប្រជាជនដែលមានជីវភាពក្រីក្រមានចំនួនត្រឹមតែ ៤០% ប៉ុណ្ណោះ ដែលបានលើកឡើងពីការសន្សំប្រាក់បើធៀបនឹងប្រជាជនដែលមានជីវភាពធូរធារ (៩៦%) ហើយការត្រៀមស្បៀងអាហារក៏មានការអនុវត្តតិចតួចផងដែរចំពោះប្រជាជនក្រីក្រ (មានតែ ៣១% ប៉ុណ្ណោះ បើធៀបនឹងប្រជាជនដែលមានជីវភាពធូរធារ ៨១%)។

**ការឆ្លើយតបទៅនឹងកង្វះស្បៀងអាហារ និងទឹក៖** ប្រជាជនកម្ពុជាបានបង្ហាញពីសកម្មភាពសាមញ្ញៗដែលពួកគាត់បានអនុវត្តដើម្បីដោះស្រាយបញ្ហាកង្វះទឹក និងស្បៀងអាហារ ក្នុងនោះ ប្រជាជនចំនួន ៧៧% បានរាយការណ៍ថាបានធ្វើការស្តុកទុក ឬសន្សំសំចៃទឹក ៧៩% បានកាត់បន្ថយការបោះចោលម្ហូបអាហារ និង៧៦% មានការបង្កើនការដាំដំណាំប្រភេទផ្សេងៗ។ ឧទាហរណ៍ នៅក្នុងភូមិមួយប្រជាជនបានផ្លាស់ប្តូរពូជដំណាំរបស់ពួកគាត់ទៅដាំឪឡឹក ត្រសក់ និងសណ្តែកដី ដោយសារពួកគាត់យល់ថាដំណាំទាំងនេះមានភាពធន់នឹងការប្រែប្រួលធាតុអាកាស និងបរិស្ថានជាងដំណាំដទៃទៀត។

**ការធ្វើសកម្មភាពឆ្លើយតបកាន់តែចាំបាច់ខ្លាំងឡើងសម្រាប់ប្រជាជនកម្ពុជា៖** ការសិក្សា KAP ផ្សេងៗគ្នាបានសាកសួរប្រជាជនកម្ពុជា ថាតើពួកគាត់បានអនុវត្តសកម្មភាពអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ អ្នកឆ្លើយតបភាគច្រើនបានបង្ហាញថា ពួកគាត់កំពុងតែធ្វើសកម្មភាពឆ្លើយតបច្រើនជាងមុន។ ប្រជាជនកម្ពុជាដែលបានតបសម្ភាសន៍ក្នុងការសិក្សា KAP៣ ស្ទើរតែទាំងអស់ (៩១%) បាននិយាយថាពួកគាត់កំពុងធ្វើសកម្មភាពឆ្លើយតបយ៉ាងហោចណាស់ក៏មួយដែរ ដោយក្នុងនោះគេសង្កេតឃើញថាមានបុរស (៩៣%) ច្រើនជាងស្ត្រី (៨៩%) ដែលបានធ្វើសកម្មភាពឆ្លើយតប។ លទ្ធផលនេះមានលក្ខណៈស្របនឹងលទ្ធផលនៃការសិក្សា KAP២ ដែលមានប្រជាជន ចំនួន៩៤% បានធ្វើសកម្មភាពឆ្លើយតប (បើទោះបីជាសំណួរបានរៀបចំខុសគ្នាបន្តិចបន្តួចជុំវិញសកម្មភាពឆ្លើយតបជាលក្ខណៈបុគ្គល ឬក្រុមគ្រួសារក៏ដោយ) ហើយលទ្ធផលនេះក៏បានបង្ហាញអំពីការកើនឡើងនូវចំនួនអ្នកធ្វើសកម្មភាពឆ្លើយ

តបផងដែរដោយលទ្ធផលមានត្រឹមតែ ៧៣% ប៉ុណ្ណោះកាលពីការសិក្សានៅក្នុង KAP១[3]។ ទាំងនេះអាចបង្ហាញឲ្យឃើញថា ការធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងចំណោមប្រជាជនកម្ពុជាគឺកាន់តែកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

អ្នកតបសម្ភាសន៍ក្នុងការសិក្សា KAP៣ ក៏បានលើកឡើងផងដែរថាប្រជាជននៅក្នុងសហគមន៍របស់ពួកគាត់កាន់តែច្រើនឡើងកំពុងធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បើទោះបីជាការរៀបសំណួរនៅក្នុងការសិក្សាទាំង ៣ មានលក្ខណៈខុសគ្នាបន្តិចបន្តួចក៏ដោយ[4] ក៏លទ្ធផលនេះបង្ហាញថាការធ្វើសកម្មភាពឆ្លើយតបមានការកើនឡើងផងដែរ។ ជារួមប្រជាជននៅក្នុងសហគមន៍របស់ពួកគាត់កំពុងធ្វើសកម្មភាពឆ្លើយតបនានាដែលក្នុងនោះគេសង្កេតឃើញថាចំនួនប្រជាជន ដែលបានរាយការណ៍អំពីការឆ្លើយតបជាលក្ខណៈសហគមន៍មានត្រឹមតែ ៥៥% ប៉ុណ្ណោះនៅក្នុងការសិក្សា KAP១ នៅឆ្នាំ ២០១០ និង៨៣% នៅក្នុងការសិក្សា KAP២ នៅឆ្នាំ២០១៥ និងបានឈានដល់ ៩១ % នៅក្នុងការសិក្សា KAP៣ នៅឆ្នាំ២០២០ នេះ។

## ក្រុមអាទិភាពសម្រាប់ការប្រាស្រ័យទាក់ទង

ការវិភាគនៅក្នុងការស្រាវជ្រាវនេះបានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមសំខាន់ៗមួយចំនួនត្រូវការការគាំទ្រដើម្បីធ្វើឲ្យពួកគាត់អាចធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់បាន។ ក្រុមទាំងនេះគួរតែត្រូវបានគេផ្តល់អាទិភាពខ្ពស់នៅក្នុងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងនាពេលអនាគត ឬនៅក្នុងកិច្ចអន្តរាគមន៍នានានៅកម្រិតសហគមន៍ដែលអាចផ្សារភ្ជាប់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមទាំងនេះរួមមាន៖

**ក្រុមកសិករ និងអ្នកនេសាទ៖** ក្រុមនេះកំពុងប្រឈមនឹងកង្វះលទ្ធភាពក្នុងការទទួលបានទឹកប្រើប្រាស់សម្រាប់ការធ្វើកសិកម្ម និងការថយចុះនៃធនធានត្រីធម្មជាតិ។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់មានឆន្ទៈជំរុញក្នុងការធ្វើសកម្មភាពឆ្លើយតប ហើយក៏បានព្យាយាមធ្វើសកម្មភាពឆ្លើយតបផងដែរ ដោយសារពួកគាត់យល់ថាធនធានធម្មជាតិ អាកាសធាតុ និងបរិស្ថាន មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ជីវភាព និងការរស់រានមានជីវិតរបស់ពួកគាត់។ ក្រុមនេះជឿទុកចិត្តលើវិធានការរបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងបញ្ហាទាំងនេះ។ ការជួយគាំទ្រនានាដល់ក្រុមកសិករ និងអ្នកនេសាទអាចជួយឲ្យពួកគាត់អាចធ្វើសកម្មភាពបានកាន់តែច្រើនឡើង និងមានប្រសិទ្ធភាពជាងអ្វីដែលពួកគាត់កំពុងតែធ្វើដូចជាការសន្សំប្រាក់ ឬការស្វែងរកបរបរចិញ្ចឹមជីវិតបន្ទាប់បន្សំផ្សេងទៀត។ ពួកគាត់ពេញ

---

[3] សំណួរដែលប្រើដើម្បីបង្កើតតួលេខទាំងនេះមានភាពខុសគ្នាក្នុង KAPs ទាំងបីនេះ។ KAP១៖ តើអ្នកឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នកបានធ្វើអ្វីមួយ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស? KAP២៖ តើអ្នកឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នកបានធ្វើអ្វីខ្លះ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស? KAP៣៖ តើអ្នកកំពុងធ្វើអ្វីនាពេលនេះ ដើម្បីទប់ទល់/ដោះស្រាយជាមួយនឹងការប្រែប្រួលនៃការផ្គត់ផ្គង់ទឹក អាហារ អគ្គិសនី និង ឥន្ទនៈ និងការប្រែប្រួលនៃធាតុអាកាស?

[4] សំណួរដែលត្រូវបានប្រើដើម្បីវិភាគតួលេខទាំងនេះមានភាពខុសគ្នាបន្តិចបន្តួចទៅតាមការសិក្សានៃ KAPs ទាំងបី។ KAP១៖ «តើប្រជាជនក្នុងសហគមន៍របស់អ្នកបានធ្វើអ្វីមួយដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសដែរឬទេ? KAP២៖ តើប្រជាជនក្នុងភូមិរបស់អ្នកបានឆ្លើយតបអ្វីខ្លះទៅនឹងការប្រែប្រួលអាកាសធាតុ? KAP៣៖ តើប្រជាជនក្នុងសហគមន៍របស់អ្នកកំពុងធ្វើអ្វីខ្លះដើម្បីទប់ទល់/ដោះស្រាយបញ្ហាការប្រែប្រួលនានាដូចជា លទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនីនិងប្រេងឥន្ទនៈប្រើប្រាស់ និងការប្រែប្រួលនៃធាតុអាកាស?»

ចិត្តនឹងទទួលបានព័ត៌មានស្តីពីការបន្សាំខ្លួននឹងការប្រែប្រួលអាកាសធាតុដែលមានប្រសិទ្ធភាពបំផុត ឬទទួលបានការគាំទ្រដើម្បីរៀនពីជំនាញ ឬបច្ចេកទេសថ្មីៗ។

**ក្រុមប្រជាជនក្រីក្រខ្លាំង៖** ក្រុមនេះមានភាពខ្វះខាតខ្លាំងខាងផ្នែកចំណេះដឹងជុំវិញការប្រែប្រួលអាកាសធាតុ ហើយជាទូទៅពួកគាត់មិនដឹងថាតើពួកគាត់អាចធ្វើអ្វីបានខ្លះ ដើម្បីត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនោះឡើយ។ សម្រាប់ប្រជាជនក្រុមនេះ សូម្បីតែការធ្វើសកម្មភាពដ៏សាមញ្ញៗដូចជាការសន្សំប្រាក់ ឬការស្វែងរក និងស្តុកទុកម្ហូបអាហារក៏ជាបញ្ហាប្រឈមសម្រាប់ពួកគាត់ផងដែរ ដោយសារតែកង្វះខាតនូវតម្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃ។ ពួកគាត់ក៏នៅខ្វះការជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប មិនសូវទទួលបានព័ត៌មាន ហើយមិនបានចូលរួមពិភាក្សាអំពីបញ្ហាទាំងនេះជាមួយអ្នកដទៃដែរ ព្រោះពួកគាត់មិនបានដឹងពីភាពងាយរងគ្រោះរបស់ខ្លួន។ ក្រុមនេះនឹងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពផ្សព្វផ្សាយ និងផ្តល់ព័ត៌មានចំគោលដៅ ដើម្បីជួយពួកគាត់ឲ្យយល់កាន់តែច្បាស់អំពីបញ្ហាដែលជះឥទ្ធិពលដល់ការរស់នៅរបស់ពួកគាត់ ក៏ដូចជាផ្តល់គំនិតសម្រាប់ធ្វើសកម្មភាពសាមញ្ញៗ ចំណាយតិចតួចបំផុតដែលអាចលើកស្ទួយជីវភាពរស់នៅរបស់ពួកគាត់បាន។

**ក្រុមប្រជាជននៅតំបន់ឆ្នេរ៖** ប្រជាជនទាំងនេះងាយនឹងទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុជាងគេ។ ពួកគាត់កំពុងព្រះពារដើម្បីមានលទ្ធភាពទទួលបានទឹក និងចំណីអាហារគ្រប់គ្រាន់។ ប្រជាជនតំបន់ឆ្នេរបាន និងកំពុងប្រឈមនឹងបញ្ហានៃការហូរទឹកសមុទ្រចូលទៅក្នុងដីដាំដំណាំរបស់ពួកគាត់។ ពួកគាត់មិនសូវជាមានទំនុកចិត្តក្នុងការត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនោះទេ តែពួកគាត់ហាក់ដូចជាត្រូវការការគាំទ្រពីសំណាក់រដ្ឋាភិបាលច្រើនជាងគេដើម្បីជួយដោះស្រាយបញ្ហាការប្រែប្រួលនានាដែលពួកគាត់កំពុងជួបប្រទះ។ ពួកគាត់មិនសូវបានធ្វើសកម្មភាពឆ្លើយតបច្រើនដោយសារតែមិនសូវដឹងពីរបៀបនៃការឆ្លើយតបបណ្តាលមកពីការខ្វះខាតព័ត៌មានស្តីពីបញ្ហានេះផងដែរ។ ពួកគាត់ត្រូវការការជួយគាំទ្រ និងការទទួលបានព័ត៌មានក្នុងការដោះស្រាយនូវតម្រូវការជាមូលដ្ឋានដូចជា ការទទួលបានទឹក និងចំណីអាហារក្នុងរយៈពេលវែង។ ពួកគាត់ត្រូវការការគាំទ្រច្រើនពីអ្នកដទៃ ហើយក៏មិនសូវមានទំនុកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតបរបស់ខ្លួនដែរ។ ដូចនេះប្រជាជនក្នុងក្រុមនេះទាមទារឲ្យមានការជួយបង្ហាត់បង្ហាញនូវមធ្យោបាយ ដើម្បីជួយឲ្យពួកគាត់អាចធ្វើសកម្មភាពឆ្លើយតបដោយខ្លួនឯងកាន់តែមានប្រសិទ្ធភាពជាងមុន ជាពិសេសការទទួលបានការគាំទ្រ និងព័ត៌មាននានាពីសំណាក់រាជរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

## អនុសាសន៍សម្រាប់ជាយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងស្តីពីការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា

- ពង្រឹងបន្ថែមគន្លឹះ នៃការជំរុញទឹកចិត្តដល់ប្រជាជនក្នុងការធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមរយៈការឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ពីអត្ថប្រយោជន៍ដែលពួកគេនឹងទទួលបានពីការធ្វើសកម្មភាពឆ្លើយតបនានា ទៅនឹងកត្តាសុខភាពនិងការលើកកម្ពស់ជីវភាពគ្រួសារ និងការអប់រំកូនៗរបស់ពួកគាត់ឲ្យប្រសើរឡើង។
- ជំរុញឲ្យមានការពិភាក្សាគ្នាក្នុងសហគមន៍ ឬរវាងសហគមន៍នានាដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ជាពិសេសតាមរយៈការចូលរួមពីសំណាក់អ្នកធ្វើការសម្រេចចិត្តនានា និងមនុស្សដែលមានឥទ្ធិពលសំខាន់ៗផងដែរ។ ការជជែកពិភាក្សាគឺជាកត្តាជំរុញក្នុងការប្រាស្រ័យទាក់ទងដែលអាចជួយជំរុញឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយា។ ប៉ុន្តែប្រជាជនកម្ពុជាភាគច្រើននៅមិនសូវបានជជែកពិភាក្សាផុសផុល ឬចែករំលែកនូវឧត្តមានុវត្តន៍ដែលពួកគាត់កំពុងធ្វើជាមួយអ្នកដទៃនៅឡើយទេ។
- ដោះស្រាយបញ្ហាសំខាន់ៗដែលអូសបន្លាយរយៈពេលវែង និងអាចជះឥទ្ធិពលដល់ប្រជាជនកម្ពុជា ដូចជាគ្រោះរាំងស្ងួត និងកង្វះខាតទឹកប្រើប្រាស់និងជំរុញឲ្យពួកគេចូលរួមចំណែកក្នុងការធ្វើសកម្មភាពឆ្លើយតបនឹងបញ្ហាទាំងនោះ។ យុទ្ធសាស្ត្រនេះនឹងជួយប្រជាជនឲ្យឆ្លើយតបនឹងគ្រោះមហន្តរាយបន្ទាន់ៗ ដែលនឹងអាចកើតមានឡើងនាពេលអនាគត។
- ផ្សារភ្ជាប់វាក្យសព្ទ «**ការប្រែប្រួលអាកាសធាតុ**» ទៅនឹងបទពិសោធន៍នៃការរស់នៅរបស់ប្រជាជនប្រសិនបើវាក្យសព្ទនេះនៅតែត្រូវបានប្រើប្រាស់នៅក្នុងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង។ ការពន្យល់រៀបរាប់អំពីការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនគឺជាឧទាហរណ៍ងាយយល់ ដែលអាចផ្សារភ្ជាប់ផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
- បង្កើនការយល់ដឹងអំពីការប្រែប្រួលធាតុអាកាស និងធនធានក្នុងចំណោមប្រជាជនក្រីក្រ និងប្រជាជនដែលទទួលបានការអប់រំតិចតួចនៅក្នុងប្រទេសកម្ពុជា។ ពួកគាត់គឺជាក្រុមដែលមានការយល់ដឹងតិចតួចបំផុតអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើជីវិតរស់នៅនាពេលបច្ចុប្បន្ន ដែលនេះជាកត្តាមួយដែលធ្វើឲ្យពួកគាត់មិនសូវបានធ្វើសកម្មភាពឆ្លើយតបនោះឡើយ។ ក្រុមមនុស្សទាំងពីរក្រុមនេះបានត្រៀមខ្លួនតិចតួចបំផុតសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនានា បើទោះជាការរស់នៅរបស់ពួកគេ ទទួលរងផលប៉ះពាល់ច្រើនបំផុតដោយសារបញ្ហាការប្រែប្រួលអាកាសធាតុក៏ដោយ។

# ១. បរិបទនៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា

## ១.១ ភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានកំណើនសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតក្នុងទ្វីបអាស៊ីដែលមានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំចំនួន ៧% ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ (World Bank, ២០២០)។ នៅឆ្នាំ២០១៩ វិស័យកសិកម្មបានរួមចំណែកប្រមាណជា ២១% នៃផលិតផលក្នុងស្រុកសរុប និងបានផ្តល់ការងារដល់ប្រជាជនចំនួន ៣៧% នៃកម្លាំងពលកម្មរបស់ប្រទេសកម្ពុជានៅក្នុង ឆ្នាំ២០១៧ (MAFF, ២០២០)។

បើទោះជាមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់យ៉ាងនេះក្តី ប្រទេសកម្ពុជាក៏នៅតែស្ថិតក្នុងចំណោមប្រទេសដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ហើយត្រូវបានចាត់ថ្នាក់ជាប្រទេសងាយរងគ្រោះបំផុតទី១២ ក្នុងអំឡុងឆ្នាំ១៩៩៨-២០១៨ (Eckstein, Kunzel, Schafer, & Winges, ២០២០) និងឈរនៅលំដាប់លេខរៀងទី១៩ ក្នុងអំឡុងឆ្នាំ១៩៩៨-២០១៧។ គិតត្រឹមឆ្នាំ២០១៥ ការខាតបង់បណ្តាលមកពីផលប៉ះពាល់ធាតុអាកាសដ៏អាក្រក់នេះត្រូវបានប៉ាន់ស្មានថាមានចំនួនប្រមាណជា ១,៥ពាន់លានដុល្លារអាមេរិក ស្មើនឹង១០% នៃផលិតផលក្នុងស្រុកសរុប (USAID, ២០១៩)។ យោងតាមការប៉ាន់ស្មានផ្អែកលើការសិក្សាម៉ូដែលស្តីពី ការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ច (ម៉ូដែល CEGIM) ដែលបានធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថាន តាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ការប្រែប្រួលអាកាសធាតុអាចនឹងធ្វើឲ្យផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាថយចុះចំនួន ២,៥% នៅឆ្នាំ២០៣០ និងកើនជិតដល់១០% នៅឆ្នាំ២០៥០ (MEF & GSSD, ២០១៩)។

កម្ពុជាគឺជាប្រទេសដែលងាយនឹងទទួលរងគ្រោះពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុដោយសារតែប្រទេសនេះមានការពឹងផ្អែកខ្លាំងទៅលើធាតុអាកាសសម្រាប់ប្រកបរបរចិញ្ចឹមជីវិត (RGC, ២០១៣) ដូចជា ការពឹងផ្អែកខ្លាំងទៅលើទឹកភ្លៀងសម្រាប់ស្រោចស្រពដំណាំកសិកម្ម បញ្ហាជីខ្វះជីជាតិសម្រាប់ការធ្វើកសិកម្ម (GSSD,២០១៥)។ ផលិតភាពក្នុងវិស័យកសិកម្មងាយនឹងរងគ្រោះខ្លាំងដោយសារតែការកើនឡើងសីតុណ្ហភាព ការប្រែប្រួលរបបទឹកភ្លៀង និងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ។ ភាពងាយរងគ្រោះរបស់ប្រទេសកម្ពុជាចំពោះការប្រែប្រួលអាកាសធាតុគឺបណ្តាលមកពីកម្លាំងពលកម្មយ៉ាងច្រើនបាន និងកំពុងធ្វើការក្នុងវិស័យកសិកម្ម ហើយសមត្ថភាពបន្សាំរបស់ពួកគាត់នៅទាបដែលបណ្តាលមកពីកង្វះខាតហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស (GSSD, ២០១៥)។ ប្រជាជនប្រមាណ៦១% នៃអ្នកដែលរស់នៅទីជនបទភាគច្រើនគឺជាស្ត្រី ដែលងាយនឹងទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដោយសារតែការថយចុះនៃលទ្ធភាពទាញយកអនុផលពីធនធានធម្មជាតិ។ ក្នុងនោះផងដែរកសិករចំនួនប្រមាណជា ៧ លាននាក់ និងកម្មករចំនួន ២៤០.០០០នាក់ ទៀតដែលធ្វើការក្នុងវិស័យឧស្សាហកម្មសំណង់ក៏ទទួលរងផលប៉ះពាល់នេះផងដែរ (Talberth & Reytar, ២០១៤)។

ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុបណ្តាលឲ្យទិន្នផលដំណាំធ្លាក់ចុះ និងខូចខាតទ្រព្យសម្បត្តិ ដែលជាកត្តាជំរុញឲ្យគ្រួសារមួយចំនួនប្រឈមនឹងហានិភ័យនៃការជំពាក់បំណុលគេ។ កត្តានេះអាចបណ្តាលឲ្យបុរសធ្វើចំណាកស្រុកទៅប្រទេសជិតខាងដើម្បីស្វែងរកការងារធ្វើ និងទុកឲ្យស្ត្រីទទួលខុសត្រូវលើការងារដាំដុះដំណាំ មើលថែរក្សាកូនចៅ និងធ្វើកិច្ចការងារផ្ទះ (Goh, ២០១២)។

ស្ត្រីកម្ពុជាក៏ប្រឈមនឹងបញ្ហាផ្សេងៗទៀតផងដែរ ដោយពេលខ្លះស្ត្រីក៏ត្រូវធ្វើចំណាកស្រុកទៅតំបន់ទីក្រុងដើម្បីធ្វើការនៅក្នុងរោងចក្រ ឬធ្វើការនៅតាមផ្ទះដែលកត្តានេះធ្វើឲ្យស្ត្រីងាយទទួលរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទផងដែរ (ADB, ២០១៥)។ ស្ត្រីមានទំនោរប្រឈមនឹងហានិភ័យខ្ពស់ពីកង្វះអាហារូបត្ថម្ភ និងជំងឺនានាដូចជា គ្រុនពោះវៀន ឬគ្រុនផ្តាសាយជាដើម (Oxfam America, ២០១០) ដោយសារតែពួកគាត់ព្យាយាមកាត់បន្ថយការហូបចុកខ្លួនឯងដើម្បីទុកឲ្យប្តី និងកូនៗរបស់ពួកគាត់បានហូបគ្រប់គ្រាន់ (Goh, ២០១២; Oxfam, n.d.)។ សន្ទស្សន៍ភាពជន់ផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (ស្ត្រីមានចំនួន០,៥៩) គឺទាបជាងបុរស (បុរសមានចំនួន០,៦១) ហើយប្រាក់ចំណូលរបស់ស្ត្រីក៏ទាបជាងបុរសចំនួន ៨ ភាគរយផងដែរ (ActionAid Cambodia, ២០២០)។

## ១.២ ក្របខ័ណ្ឌគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ

ដោយមើលឃើញពីការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវគោលជំហរ និងការតាំងចិត្តយ៉ាងមុតមាំក្នុងការ «កសាងកម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិចនិងធន់នឹងអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោលព្រមទាំងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុផងដែរ» (GSSD, ២០១៥)។ លើសពីនេះទៀតការប្តេជ្ញាចិត្តផ្នែកនយោបាយ និងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុត្រូវបានរាជរដ្ឋាភិបាលពង្រឹងបន្ថែមទៀត តាមរយៈកម្មវិធីអន្តរាគមន៍ផ្សេងៗ (GSSD, ២០១៧)។ កម្មវិធីអន្តរាគមន៍ទាំងនោះមានដូចជា៖

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤៖** ត្រូវបានដាក់ឲ្យប្រើប្រាស់នៅក្នុងខែកញ្ញា ឆ្នាំ២០១៨។ យុទ្ធសាស្ត្រនេះបានដាក់ចេញនូវការប្តេជ្ញាចិត្ត និងអាទិភាពដើម្បីពង្រឹងបន្ថែមនូវក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយនានាក៏ដូចជាការសិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ និងបង្កើនសមត្ថភាពស្ថាប័ននៅគ្រប់កម្រិតដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពបរិស្ថានជាតិឆ្នាំ២០១៦-២០២៣ និងផែនការយុទ្ធសាស្ត្រជាតិរេដបូកជាតិ (RGC, ២០១៨)។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) ២០១៩-២០២៣៖** ផែនការនេះត្រូវបានតាក់តែងឡើងដើម្បីអនុវត្តគោលនយោបាយនានាដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងកំណត់យ៉ាងច្បាស់លាស់នូវតួនាទី និងទំនួលខុសត្រូវរបស់ក្រសួងមួយចំនួន ជាពិសេសការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលត្រូវបានក្រសួងមួយចំនួនដាក់បញ្ចូលទៅក្នុងផែនការតាមអនុវិស័យរបស់

ខ្លួនផងដែរ (RGC, ២០១៩)។ នៅតាមក្រសួងសំខាន់ៗមួយចំនួន ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យត្រូវបានបង្កើតឡើង។ ក្នុងនោះដែរក្រសួងស្ថាប័នចំនួន១៤ បានអនុម័តលើផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួន ហើយក៏បានចាប់ផ្តើមអនុវត្តសកម្មភាពអាទិភាពចាប់ពីពេលនោះមក (NCSD, ២០១៩b)។

**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)២០១៤-២០២៣៖** ផែនការនេះត្រូវបានតាក់តែងឡើងក្នុងឆ្នាំ២០១៣ ដើម្បីបញ្ជ្រាបគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងជំរុញការចូលរួម និងការអនុវត្តការងារពីភាគីពាក់ព័ន្ធនានា (RGC, ២០១៣a)។ ផែនការយុទ្ធសាស្ត្រនេះផ្តល់នូវក្រេបខ័ណ្ឌដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ (NCSD, ២០១៩b) និង «កសាងកម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតងបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល» (បានដកស្រង់ចេញពី Käkön et al., ២០១៤)។ គោលបំណងសំខាន់ៗនៃផែនការយុទ្ធសាស្ត្រនេះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងពាក់ព័ន្ធនានា។

**ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (NAP-DRR) ២០១៤ - ២០១៨៖** ផែនការនេះត្រូវបានអនុម័តនៅឆ្នាំ២០១៣ និងដឹកនាំសម្របសម្រួលដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ ផែនការនេះផ្តោតសំខាន់ទៅលើការពង្រឹងសមត្ថភាព ការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបង្កើតឲ្យមានការបន្សុីគ្នារវាងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការធ្វើកំណែទម្រង់ស្ថាប័ន និងបង្ហាញពីតួនាទីនៃការស្រាវជ្រាវ និងអប់រំនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយជាតិ (ADPC & UNDRR, ២០១៩)។

**ប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយ៖** ដើម្បីស្វែងយល់កាន់តែច្បាស់អំពីផលប៉ះពាល់នៃគ្រោះមហន្តរាយនិងបង្កើនសមត្ថភាពឆ្លើយតប និងគាំទ្រដល់ការវាយតម្លៃហានិភ័យនៅថ្នាក់ខេត្ត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានបង្កើត CamDI ដែលជាមូលដ្ឋានទិន្នន័យស្តីពីការខាតបង់ និងខូចខាតដោយសារគ្រោះធម្មជាតិ (ADPC & UNDRR, ២០១៩)។ ស្រដៀងគ្នានេះក្រសួងធនធានទឹកបានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជាដើម្បីបង្កើត «បណ្តុំព័ត៌មានតាមដានគ្រោះរាំងស្ងួត» ដើម្បីបង្កើនសមត្ថភាពស្ថាប័នក្នុងការតាមដានអាកាសធាតុ និងប្រព័ន្ធប្រកាសអាសន្នជាមុន (ADPC & UNDRR, ២០១៩)។

**ម៉ូដែលស្តីពីការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ច (ម៉ូដែល CEGIM)៖** ម៉ូដែលនេះត្រូវបានសហការបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន។ វាត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ច និងកំណត់តំបន់អន្តរាគមន៍អាទិភាពដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ (MEF & GSSD, ២០១៩)។

លើសពីនេះប្រទេសកម្ពុជាក៏បានធ្វើការពិនិត្យវិភាគអំពីស្ថាប័ន និងការចំណាយជាសាធារណៈលើការងារអាកាសធាតុនិងក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុផងដែរ (CPEIR) ដោយបានធ្វើការវាយតម្លៃពីសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងបានពិនិត្យការងារអនុវត្តការចំណាយធៀបនឹងគោលនយោបាយដែលបានដាក់ចេញ (UNDP, ២០១២)។ ជាងនេះទៅទៀតក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុកម្ពុជាដែលមានគោលបំណងគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុរបស់រដ្ឋាភិបាល ព្រមទាំងក្របខ័ណ្ឌ និងការអនុវត្តហិរញ្ញប្បទានកម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិដែលមានគោលបំណងបង្កើនហិរញ្ញប្បទានសម្រាប់កម្ពុជាក៏បានអនុម័តឲ្យប្រើប្រាស់ផងដែរ (NCSD, ២០១៩b)។ ថវិកាសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើង ដើម្បីផ្តល់ហិរញ្ញប្បទានទៅគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសកម្មភាពកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយដើម្បីធានានិរន្តរភាពថវិកាសម្រាប់កិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងឆ្លើយតបជាបន្ទាន់ទៅនឹងគ្រោះមហន្តរាយ (ADPC & UNDRR, ២០១៩)។ ប្រទេសកម្ពុជាមានក្របខ័ណ្ឌសម្រាប់តាមដានត្រួតពិនិត្យការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដើម្បីពិនិត្យឡើងវិញពីផលប៉ះពាល់នៃគោលនយោបាយ ឯកសារគតិយុត្ត និងបទប្បញ្ញត្តិនានាស្តីពីការកាត់បន្ថយភាពងាយរងគ្រោះ ឬបន្ថយការបញ្ចេញកាបូនជាដើម (DCC/GSSD, ២០១៦)។

**នៅកម្រិតអន្តរជាតិ៖** ប្រទេសកម្ពុជាបានដាក់ជូននូវរបាយការណ៍ការចូលរួមចំណែករបស់ជាតិលើកទី១ (INDC) ទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ UNFCCC មុនពេលមានកិច្ចចរចាសកលនៅក្នុងសន្និសីទកំពូលបណ្តាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២១ នៅទីក្រុងប៉ារីស នាឆ្នាំ២០១៥។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពី ការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១៦ ដែលផ្តោតសំខាន់ទៅលើការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (NCSD, ២០១៩a)។ តាមរយៈយន្តការនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកាត់បន្ថយអត្រាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រហូតដល់ទៅ២៧% និងបង្កើនគម្របព្រៃឈើរហូតដល់ ៦០% នៅត្រឹមឆ្នាំ ២០៣០ (NCSD, ២០១៩a)។ ដើម្បីធានាថារបាយការណ៍ការចូលរួមចំណែករបស់ជាតិលើកទី១ (INDC) អាចសម្រេចបានរាជរដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយផែនការឯកសារផែនទីបង្ហាញផ្លូវ និងការចូលរួមរបស់ភាគីពាក់ព័ន្ធនឹងរបាយការណ៍ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុផងដែរ (NCSD, ២០១៩a)។ នៅក្នុងខែធ្នូ ឆ្នាំ២០២០ ប្រទេសកម្ពុជាបានដាក់ជូនរបាយការណ៍បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុទៅកាន់ទៅលេខាធិការដ្ឋាន(UNFCCC) ដោយក្នុងនោះរាជរដ្ឋាភិបាលបានប្តេជ្ញាក្នុងការកាត់បន្ថយអត្រាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៤១,៧% បើធៀបទៅនឹងការព្យាករណ៍តាមទម្លាប់ធម្មតាគិតត្រឹមឆ្នាំ២០៣០ (GSSD & MoE, ២០២០)។

## ១.៣ រចនាសម្ព័ន្ធស្ថាប័នពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

ទន្ទឹមនឹងការអភិវឌ្ឍគួរឲ្យកត់សម្គាល់ កម្ពុជាតែងតែគិតគូរលើការលើកកម្ពស់សមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដូចជា ការធ្វើទំនើបកម្មស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រចនាសម្ព័ន្ធពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុមានដូចជា៖

**គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ៖** គឺជាស្ថាប័នអន្តរក្រសួងដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដើម្បីសម្របសម្រួលការតាក់តែងគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ និងតាមដានការអនុវត្តគោលនយោបាយ បទប្បញ្ញត្តិ ឯកសារគតិយុត្ត និងកម្មវិធីនានានៅទូទាំងប្រទេស។

**ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព៖** គឺជាស្ថាប័នរៀបចំគោលនយោបាយដែលបង្កើតឡើងក្នុងឆ្នាំ២០១៥។ រដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងមានអគ្គលេខាធិការដ្ឋានជាចំណុះ ហើយមានសមាជិកភាពចូលរួមមកពីក្រសួង/ស្ថាប័នចំនួន ៣៦ និងអភិបាលរាជធានី/ខេត្តចំនួន ២៥ (NCSD, ២០១៩a)។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពមានតួនាទីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពពាក់ពន្ធ័នឹងការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព (GSSD, ២០១៧) ព្រមទាំងសម្របសម្រួល និងតាមដានវឌ្ឍនភាពការងារដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាស្តីពីសកម្មភាពអាកាសធាតុ (UNDP, ២០១៩)។

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ៖** គឺបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ក្នុងនាមជាអន្តរក្រសួងដែលមានភារកិច្ចដោះស្រាយការកើនឡើងហានិភ័យ នៃគ្រោះមហន្តរាយនៅទូទាំងប្រទេស (RGC, ២០១៣) និងមានអាណត្តិជាអ្នកសម្របសម្រួលក្នុងការការពារគ្រោះមហន្តរាយ សកម្មភាពបន្សាំ កាត់បន្ថយ និងឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយ (ADPC & UNDRR, ២០១៩)។ នាយកដ្ឋានឧតុនិយម និងនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេត្រូវបានតម្រូវឲ្យដឹកនាំការងារលើការព្យាករណ៍ព្យុះ និងទឹកជំនន់ និងផ្តល់ព័ត៌មានអំពីប្រព័ន្ធប្រកាសអាសន្នជាមុន ។

**គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖** គឺបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ដើម្បីធានាថាបញ្ហាយេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងគោលនយោបាយ និងកម្មវិធីអន្តរាគមន៍នានាស្តីពីការប្រែប្រួលអាកាសធាតុ។ ក្រុមការងារនេះរួមមានក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ (NCSD, ២០១៩b)។

## ១.៤ កម្មវិធីអន្តរាគមន៍ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ តាមរយៈការផលិត និងការផ្សព្វផ្សាយសម្ភារអប់រំលើកកម្ពស់ចំណេះដឹងស្តីពី ការប្រែប្រួលអាកាសធាតុ។ ជាឧទាហរណ៍ សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ អង់គ្លេស - ខ្មែរ ត្រូវបានប្រើប្រាស់ជាលក្ខណៈជាតិ ដើម្បីផ្តល់នូវការយល់ដឹង និងសង្គតិភាពការបកស្រាយវាក្យសព្ទបច្ចេកទេសស្តីពីការប្រែប្រួល

អាកាសធាតុដើម្បីជៀសវាងការភាន់ច្រឡំក្នុងការប្រើប្រាស់។ សៀវភៅសិក្សាគោលស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់វិទ្យាល័យ ដែលបានបង្ហាញពីទិដ្ឋភាពទូទៅនៃការប្រែប្រួលអាកាសធាតុផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ផ្តោតលើមូលហេតុ និងផលប៉ះពាល់ ភាពងាយរងគ្រោះ និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុត្រូវបានបោះពុម្ពផ្សាយជាផ្លូវការនៅឆ្នាំ២០១៨ (MoEYS, ២០១៨)។ លើសពីនេះទៀតវិទ្យាសាស្ត្រ ស្តីពីការប្រែប្រួលអាកាសធាតុក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងវគ្គសិក្សាផ្សេងៗផងដែរ (Deodato, Erdogmus, & Detten, ២០១៨)។

លេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ គឺជាស្ថាប័នរដ្ឋផ្សេងមួយទៀតនៅក្នុងប្រទេសកម្ពុជាដែលដើរតួនាទីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ វាមានសារៈសំខាន់ណាស់ដើម្បីបញ្ជាក់ថាលេខាធិការដ្ឋាននេះប្តេជ្ញាចិត្តក្នុងការដោះស្រាយ បញ្ហាការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។ ការប្តេជ្ញាចិត្តនេះមានដូចជា ការផ្តោតសំខាន់លើការបន្សាំខ្លួនតាមរយៈការជំរុញការចូលរួមពីអាជ្ញាធរថ្នាក់ក្រោមជាតិ តាមរយៈសកម្មភាពបន្សាំពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាពរស់នៅ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ទឹក (Green Climate Fund, n.d.)។

សាកលវិទ្យាល័យភូមិន្ទកសិកម្មគឺជាសាកលវិទ្យាល័យរដ្ឋឈានមុខគេលើជំនាញកសិកម្ម ហើយមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវកសិកម្ម និងបរិស្ថានដែលបានបង្កើតឡើងក្នុងឆ្នាំ២០១១ ដើម្បីអប់រំនិងស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (RUA, n.d)។ នៅឆ្នាំ២០១៥ សាកលវិទ្យាល័យ និងសាលាកសិកម្មចំនួនប្រាំពីរ[5] បានទទួលការគាំទ្រពីគម្រោងកែលម្អការអប់រំឧត្តមសិក្សាដែលផ្តល់មូលនិធិដោយធនាគារពិភពលោកបានបោះពុម្ពផ្សាយម៉ូលឌុលបង្រៀនចំនួន ៤ ស្តីពីការប្រែប្រួលអាកាសធាតុដោយផ្តោតសំខាន់ទៅលើវិស័យកសិកម្ម (MoEYS, ២០២០)។ លើសពីនេះទៀត នៅឆ្នាំ២០១៧ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតកម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់លើមុខជំនាញវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ ក្រោមកម្មវិធី LEAD ដែលទទួលបានការឧបត្ថម្ភថវិកាដោយទីភ្នាក់ងារ USAID (RUPP, ២០២០)។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន បានចេញផ្សាយគោលការណ៍ណែនាំស្តីពីបច្ចេកទេសបន្សាំដែលបានផ្តល់អនុសាសន៍លើបច្ចេកទេស និងជម្រើសចំនួន ៣៤ សម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម (MAFF, NCSD & MoE, ២០១៩)។ គោលការណ៍ណែនាំនេះមានគោលបំណងផ្តល់ជាគំនិតផ្តួចផ្តើមស្តីពីបច្ចេកទេស និងការអនុវត្តការបន្សាំនានា (MAFF, NCSD & MoE, ២០១៩)។

[5] សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យ ជា ស៊ីម កំចាយមា សាកលវិទ្យាល័យស្វាយរៀង សាលាជាតិកសិកម្មព្រែកលៀប សាលាជាតិកសិកម្មកំពង់ចាម សាកលវិទ្យាល័យបាត់ដំបង និងសាកលវិទ្យាល័យមានជ័យ

## ១.៥ គម្លាតរវាងគោលនយោបាយ និងកិច្ចអន្តរាគមន៍លើការងារប្រែប្រួលអាកាសធាតុ

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាបច្ចុប្បន្នរបស់ប្រទេសក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែគេសង្កេតឃើញថា នៅតែមានការខ្វះការយកចិត្តទុកដាក់លើកត្តាមួយចំនួនដែលទាក់ទងទៅនឹងស្ថានភាពប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គម និងនិន្នាការផ្សេងៗដូចជា នគរូបនីយកម្ម និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ទិន្នន័យភូមិសាស្ត្រ ការប្រែប្រួលយឺតតាមតំបន់ ហេដ្ឋារចនាសម្ព័ន្ធ និងយេនឌ័រ (NCSD, ២០១៩b)។ ឧទាហរណ៍ សកម្មភាព សូចនាករ និងធនធានចាំបាច់មួយចំនួន ដើម្បីសម្រេចគោលបំណងដែលផ្តោតលើយេនឌ័រនៅក្នុងCCCSP មិនត្រូវបានកំណត់បង្ហាញនៅក្នុងគោលនយោបាយជាតិនេះទេ (NCSD, ២០១៩b)។ លើសពីនេះទៅទៀតរបៀបនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុចូលទៅក្នុងផែនការ និងថវិកាថ្នាក់ក្រោមជាតិនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ការពង្រឹង ការត្រួតពិនិត្យតាមដានឲ្យកាន់តែប្រសើរឡើងនៅថ្នាក់ក្រោមជាតិ នឹងជួយគាំទ្រដល់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ព្រមទាំងជួយក្នុងការកសាងផែនការ បង្កើតផែនការថវិកា និងការអនុវត្តផងដែរ (NCSD, ២០១៩b)។

ឧបសគ្គមួយទៀតក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុរួមមាន កង្វះខាតការគាំទ្រផ្នែកហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស (MoE, ២០១៦)។ កង្វះខាតឧបករណ៍ និងគោលការណ៍ណែនាំក្នុងការវិភាជន៍ថវិកាសម្រាប់អន្តរាគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុទៅតាមវិស័យ និងទៅដល់ថ្នាក់ក្រោមជាតិនៅតែជាបញ្ហាប្រឈម ទោះបីការងារនេះជាកាតព្វកិច្ច និងអណត្តិរបស់ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុដើម្បីវិភាជន៍ថវិកាទៅដល់ក្រសួងពាក់ព័ន្ធក៏ដោយ។ ធនធានទាំងនេះចាំបាច់ត្រូវកៀរគរពីភាគីពាក់ព័ន្ធសំខាន់ៗដទៃទៀតដូចជា អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន (NCSD, ២០១៩b)។ របាយការណ៍មួយរបស់វិទ្យាស្ថានសភាកម្ពុជាបានបង្ហាញថាក្រសួងពាក់ព័ន្ធចំនួន ៣ គឺ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក៏បានជួបប្រទះបញ្ហាប្រឈមដូចគ្នានេះផងដែរ។ បញ្ហាទាំងនោះរួមមាន ឧបសគ្គផ្នែកហិរញ្ញវត្ថុ សមត្ថភាពធនធានមនុស្សនៅមានកម្រិត កង្វះទិន្នន័យ និងការស្រាវជ្រាវដែលអាចទុកចិត្តបាន និងទូលំទូលាយ ជាពិសេសកង្វះខាតការផ្ទេរបច្ចេកវិទ្យា និងការយល់ដឹងពីការអនុវត្តកម្មវិធីអន្តរាគមន៍ផ្តោតលើការប្រែប្រួលអាកាសធាតុ (Un, ២០១៨)។ លទ្ធផលនៃការសិក្សា KAP៣ នេះក៏បានបញ្ជាក់បន្ថែមថាបញ្ហានេះពិតជាកើតមានពិតមែន។

ការសិក្សានេះក៏បានពិនិត្យមើលនូវគោលនយោបាយរបស់រដ្ឋាភិបាលមួយចំនួន ក្នុងនោះវាបានបង្ហាញថាព័ត៌មានស្តីពី វិធីសាស្ត្រចាំបាច់ក៏ដូចជាយន្តការនៃការប្រាស្រ័យទាក់ទង ដែលមានប្រសិទ្ធភាពសម្រាប់ជួយគាំទ្រដល់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុគឺនៅមានកម្រិតនៅឡើយ។ លើសពីនេះទៀតប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍នានា ស្តីពីការលើកកម្ពស់ការយល់ដឹងដែលរួមមានការផលិតសៀវភៅសិក្សាគោលស្តីពីការប្រែប្រួលអាកាសធាតុ និងក្រុមគោលដៅជាកុមារក្នុងវ័យសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏មិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយទេ។

## ១.៦ ចំណេះដឹង ឥរិយាបថ និងការអនុវត្ត ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

ការសិក្សាស្រាវជ្រាវស្តីពីការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជាដែលផ្តោតសំខាន់លើចំណេះដឹង ឥរិយាបថ និងការអនុវត្ត ត្រូវបានធ្វើឡើងចំនួនពីរលើករួចមក ហើយគឺលើកទី១ ក្នុងឆ្នាំ២០១០ និងលើកទី២ ក្នុងឆ្នាំ២០១៥។ ការសិក្សាទាំងនេះមានគោលបំណងដើម្បីអង្កេតការចូលរួមរបស់ប្រជាជនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដើម្បីផ្តល់ជាព័ត៌មានសមស្របសម្រាប់កិច្ចអន្តរាគមន៍នានារបស់រដ្ឋាភិបាលនាពេលអនាគត។ ជាងនេះទៅទៀតការស្រាវជ្រាវផ្សេងទៀតដែលស្រដៀងនេះហៅថា អាកាសធាតុអាស៊ី ក៏បានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០១៨ ដោយអង្គការប៊ីប៊ីស៊ី មីឌាអាក់សិនផងដែរ ដើម្បីស្វែងយល់ថាតើប្រជាជនកម្ពុជាកំពុងរស់នៅយ៉ាងដូចម្តេចក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

### ចំណេះដឹង

របាយការណ៍ KAP១ ដែលជាការសិក្សាទូទាំងប្រទេសរៀបចំឡើងក្នុងឆ្នាំ២០១០ បានបង្ហាញថាប្រជាជនកម្ពុជាចំនួន ៨០% ធ្លាប់បានឮពាក្យថា «ការប្រែប្រួលអាកាសធាតុ» ហើយបានកត់សម្គាល់ពីការប្រែប្រួលធាតុអាកាស និងបរិយាកាស ជាពិសេសការប្រែប្រួលសីតុណ្ហភាព របបទឹកភ្លៀង និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដែលកើតឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន (MoE, ២០១១)។ សមាមាត្រនៃប្រជាជនដែលធ្លាប់បានឮពាក្យ «ការប្រែប្រួលអាកាសធាតុ» បានកើនឡើងដល់ ៩១% តាមរយៈការសិក្សា KAP២ ដែលបានធ្វើឡើងនៅឆ្នាំ២០១៥ (MoE, ២០១៦)។ ចំណែកការសិក្សាពីអាកាសធាតុអាស៊ីបានរកឃើញថាប្រជាជនកម្ពុជាចំនួន ៨៥% ធ្លាប់បានឮ/ស្គាល់ពាក្យ «ការប្រែប្រួលអាកាសធាតុ» (BBC Media Action, ២០១៩)។ ការសិក្សានោះដែរបាន បង្ហាញថាមានតែប្រជាជនចំនួន ៤២% ប៉ុណ្ណោះ ដែលបានយល់ច្បាស់ពីអត្ថន័យនៃពាក្យការប្រែប្រួលអាកាសធាតុ ហើយពួកគាត់ភាគច្រើនជាបុរស អ្នកមានកម្រិតនៃការអប់រំខ្ពស់ និងក្រុមយុវជន។ ចំណែកឯប្រជាជនចំនួន ៤៣% ទៀតគ្រាន់តែធ្លាប់បានឮពាក្យនេះ តែមិនយល់ពីអត្ថន័យរបស់វាឡើយ។

យោងតាមរបាយការនៃការស្រាវជ្រាវ KAP ទាំងពីរលើកកន្លងមកបានបង្ហាញថាអ្នកឆ្លើយតបសម្ភាសន៍ចំនួន ៧៨% នៅក្នុងឆ្នាំ២០១៥ បានចាត់ទុកថាការប្រែប្រួលអាកាសធាតុបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើ ខណៈអ្នកឆ្លើយតបសម្ភាសចំនួន ៦៧% ប៉ុណ្ណោះយល់ឃើញដូចនេះកាលពីឆ្នាំ២០១០។

### ឥរិយាបថ

ការយល់ឃើញពីសកម្មភាពចូលរួមជាលក្ខណៈសហគមន៍ (សំដៅទៅលើការខិតខំរួមគ្នានៅក្នុងសហគមន៍ ឬការធ្វើសកម្មភាពរួមប្រកបដោយសាមគ្គីភាព) ដើម្បីដោះស្រាយផលប៉ះពាល់នៃអាកាសធាតុបានកើនឡើងពី ៥២% ក្នុងឆ្នាំ២០១០ (KAP១) ដល់ ៥៦% ក្នុងឆ្នាំ២០១៥ (KAP២) (MoE, ២០១១; MoE, ២០១៦)។ ខណៈការសិក្សានៅឆ្នាំ២០១៩ បានរកឃើញថាប្រជាជនកម្ពុជារហូតដល់ ៩៣% ជឿជាក់ថាសហគមន៍អាចធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ហើយមានតែ ២៥% ប៉ុណ្ណោះដែលចង់ធ្វើការឆ្លើយតបរៀងៗខ្លួន ដើម្បីឆ្លើយតបនឹងការប្រែប្រួលទាំងនេះ (BBC Media Action, ២០១៩)។

ការសិក្សាអាកាសធាតុអាស៊ីក៏បានស្វែងយល់នូវកត្តានានាដែលបុគ្គលម្នាក់អាច ឬមិនអាចឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានផងដែរ។ ក្នុងនោះមានប្រជាជនកម្ពុជាចំនួន ៦៤% ជឿជាក់ថា ពួកគាត់មិនអាចធ្វើអ្វីបានច្រើនក្នុងការផ្លាស់ប្តូរអ្វីដែលកើតមានឡើងនៅក្នុងជីវិតរបស់ពួកគាត់ទេ។ ប្រជាជនចំនួន ៥៥% ទៀតបានរាយការណ៍ថាពួកគាត់មានអាទិភាពផ្សេងទៀតដែលត្រូវធ្វើដែលវាអាចរារាំងមិនឲ្យពួកគាត់ធ្វើសកម្មភាពឆ្លើយតបបាន។ ប្រជាជនចំនួន ៤៨% បានរាយការណ៍ថាពួកគាត់មានចំណេះដឹងតិចតួចក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចំណែក ៣៧% ទៀតជឿជាក់ថាសកម្មភាពរបស់ពួកគាត់ដើម្បីដោះស្រាយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនឹងមិនមានអ្វីខុសប្លែកទេ។

ឥរិយាបថក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលបានធ្វើក៏មានការផ្លាស់ប្តូរដែរនៅរយៈកាលកន្លងមក។ ក្នុងឆ្នាំ២០១០ មានតែប្រជាជនមួយភាគបីប៉ុណ្ណោះ (៣៣%) ដែលបានទទួលស្គាល់ថាការកាត់បន្ថយសកម្មភាពប្រចាំថ្ងៃដូចជា ការប្រើប្រាស់គ្រឿងម៉ាស៊ីន និងការប្រើប្រាស់ថាមពលអាចកាត់បន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ (MoE, ២០១១)។ ដោយឡែកនៅក្នុងឆ្នាំ២០១៦ មានប្រជាជនចំនួន៤៣% បានយល់ឃើញដូច្នោះ(MoE, ២០១៦)។ ចំណុចនេះបានបង្ហាញថាមនុស្សកាន់តែច្រើនកំពុងគិតអំពីការកាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់នៃអាកាសធាតុ។

## ការអនុវត្ត

ការសិក្សា KAP១ បានរកឃើញថាការដាំដើមឈើឲ្យបានច្រើន និងប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីៗគឺជាការអនុវត្តជាទូទៅក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (MoE, ២០១១)។ ដោយឡែកលទ្ធផលសិក្សាអាកាសធាតុអាស៊ីបានបង្ហាញថា ប្រជាជននៅតាមជនបទបានអនុវត្តការដាំដំណាំចម្រុះ ការផ្លាស់មុខដំណាំ និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលជាយុទ្ធសាស្ត្របន្សាំសំខាន់របស់ពួកគាត់ (BBC Media Action, ២០១៩)។

នៅក្នុងការសិក្សាអាកាសធាតុអាស៊ីនេះដដែលប្រជាជនកម្ពុជា ៦០% មិនទាន់បានត្រៀមខ្លួនសម្រាប់សកម្មភាពអាកាសធាតុធ្ងន់ធ្ងរនោះទេ ហើយប្រជាជនចំនួន ៤៣% បានរាយការណ៍ពីការផ្លាស់ប្តូរជីវភាពរស់នៅ ឬការងារដើម្បីទ្រទ្រង់ប្រាក់ចំណូលនៅក្រោមលក្ខខណ្ឌអាកាសធាតុផ្សេងៗគ្នា។ យុទ្ធសាស្ត្រដែលលេចធ្លោនោះគឺការស្វែងរកប្រាក់ចំណូលបន្ថែមរបស់ពួកគាត់តាមវិធីផ្សេងៗគ្នា (៥៩%) និងការធ្វើចំណាកស្រុកជាបណ្តោះអាសន្នដើម្បីស្វែងរកការងារធ្វើ (២១%) ជាដើម។ នៅពេលមានព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ប្រជាជនកម្ពុជាបានរាយការណ៍ថាពួកគាត់កាន់តែជំពាក់បំណុលគេច្រើន ហើយការធ្វើចំណាកស្រុកគឺជាជម្រើសដ៏សំខាន់សម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ ជាពិសេសគឺសហគមន៍ដែលមានប្រាក់ចំណូលពឹងផ្អែកខ្លាំងទៅលើធនធានធម្មជាតិ។ ស្របពេលដែលប្រជាជនជាច្រើនកំពុងធ្វើសកម្មភាពឆ្លើយតប ប្រជាជនកម្ពុជាមួយចំនួនជឿថាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមិនមែនជា

បញ្ហារបស់ពួកគាត់ទេ (៣៧%) ឬពួកគាត់មិនមែនជាអ្នកទទួលខុសត្រូវក្នុងការធ្វើសកម្មភាពឆ្លើយតបនឹងអាកាសធាតុនោះទេ (៣២%) (BBC Media Action, ២០១៩)។

## ១.៧ ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុក្នុងបរិបទយេនឌ័រ

សកម្មភាពដែលបុរស និងស្ត្រីនៅកម្ពុជាបានធ្វើដើម្បីត្រៀមបង្ការក្នុងគ្រាដែលមានអាកាសធាតុមិនប្រក្រតីកើតឡើងគឺមានលក្ខណៈខុសគ្នាគួរឲ្យកត់សម្គាល់។ យោងតាមការសិក្សាអាកាសធាតុអាស៊ី បុរសភាគច្រើន (៨២%) បានរៀនជំនាញដូចជា ហែលទឹក វិធីសាស្ត្រសង្គ្រោះបឋម និងការសង់ជម្រកជាដើម។ ដោយឡែកមានតែស្ត្រីចំនួន ៤២% ប៉ុណ្ណោះដែលបានរាយការណ៍ដូចគ្នានេះ ដែលប្រការនេះបានធ្វើឲ្យស្ត្រីងាយរងគ្រោះនឹងហានិភ័យនានាដូចជា ទឹកជំនន់ជាដើម។ ស្ត្រីភាគច្រើន ធ្វើការងារសម្រាប់គ្រួសារដូចជា ការរក្សាទុកអាហារ (ស្ត្រីចំនួន ៥៣% បើធៀបនឹងបុរសដែលមានចំនួន ៤៤%) ចំណែកឯបុរសវិញច្រើនធ្វើការងារទាក់ទងនឹងការជួសជុលកែលម្អផ្ទះសម្បែង (បុរស ៤១% ចំណែកស្ត្រី ៣៦%) សម្រាប់ការបន្សុាំ។

ទោះបីជាយ៉ាងនេះក្ដី ការសិក្សាដដែលនេះក៏បានបង្ហាញផងដែរថា ស្ត្រីទំនងជាអាចឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបានល្អប្រសើរជាងបុរស (ស្ត្រី ៧៦% និងបុរស ៦៨% រាយការណ៍ទំនងជាអាចដោះស្រាយនូវការប្រែប្រួលទាំងនេះ)។ ជាងនេះទៅទៀត ស្ត្រី៤៦% រាយការណ៍ថាទំនងជាត្រៀមខ្លួនបានល្អជាងមុនសម្រាប់ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ប្រៀបធៀបជាមួយបុរសត្រឹមតែ ៤០% ប៉ុណ្ណោះ (BBC Media Action, 2019)។ របាយការណ៍នេះក៏បានគូសបញ្ជាក់ផងដែរឬថាស្ត្រីទំនងជាធ្វើសកម្មភាពដើម្បីដោះស្រាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលជួបប្រទះឧបសគ្គច្រើនផ្នែករចនាសម្ព័ន្ធផ្នែកសង្គម និងផ្នែកធនធាន ហើយឧបសគ្គទាំងនេះទំនងជាចាក់ឫសយ៉ាងជ្រៅក្នុងផ្នត់គំនិត និងវិសមភាពយេនឌ័រនៅក្នុងសង្គមកម្ពុជា។

### ឧបសគ្គ និងកត្តាជំរុញទឹកចិត្តក្នុងការបន្សុាំទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ការសិក្សា KAP១ និង KAP២ បានបង្ហាញថាកង្វះខាតផ្នែកធនធានហិរញ្ញវត្ថុបានរាំងប្រជាជនកម្ពុជាភាគច្រើន (៦០%) ក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃអាកាសធាតុ។ ក្រៅពីនេះប្រជាជនមួយភាគបួន (២៥% នៅ KAP១ និង ៣០% នៅ KAP២) បានលើកឡើងអំពីកង្វះខាតចំណេះដឹងដែលជាឧបសគ្គសម្រាប់ពួកគាត់ក្នុងការឆ្លើយតប (MoE, ២០១១; MoE, ២០១៦)។ ការសិក្សាអាកាសធាតុអាស៊ីក៏បានរកឃើញលទ្ធផលប្រហាក់ប្រហែលគ្នាដែលក្នុងនោះប្រជាជនចំនួន ៦៤% បង្ហាញអំពីកង្វះធនធាន (ថវិកា និងឧបករណ៍ សម្ភារ) និងព័ត៌មានដែលជាឧបសគ្គដ៏សំខាន់សម្រាប់ពួកគាត់ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សាដដែលនេះក៏បានបង្ហាញផងដែរថាប្រជាជនកម្ពុជាភាគច្រើនបាននិយាយថាពួកគាត់ត្រូវការការគាំទ្រផ្នែកស្ថាប័ន ជាពិសេសពីសំណាក់រាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ប្រជាជនកម្ពុជាទាំងអស់ជឿជាក់ថាធនធាន និងចំណេះដឹងអំពីយុទ្ធសាស្ត្រ និងបច្ចេកទេសបន្សុាំគឺជាគន្លឹះក្នុងការធ្វើសកម្មភាព

ឆ្លើយតប (BBC Media Action, ២០១៩)។ បញ្ហាសុខភាព និងអនាគតកូនៗរបស់ពួកគាត់ គឺជាកត្តាជំរុញទឹកចិត្តចម្បងសម្រាប់ប្រជាជនកម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

បទដ្ឋានសង្គមដែលផ្អែកលើផ្នត់គំនិតយេនឌ័រ នៅក្នុងប្រទេសកម្ពុជាអាចរឹតត្បិតការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ និងការសម្រេចចិត្តនានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (Kem, ២០១៦)។ ដោយផ្អែកលើសន្ទស្សន៍ភាពធន់របស់ស្ត្រីកម្ពុជា (WRI) ស្ត្រីទទួលបានពិន្ទុទាបជាងបុរសទាក់ទងនឹងភាពធន់ដែលបានពិន្ទុត្រឹមតែ ០,៥៤ រីឯបុរស ០,៦១ (ActionAid Cambodia, ២០២០)។ លទ្ធផលនេះបង្ហាញថាស្ត្រីមានការចូលរួម និងការសម្រេចចិត្តតិចជាងបុរស ។

ការសិក្សារបស់អង្គការអាក់សិនអេដកម្ពុជា (២០២០) ដដែលនេះក៏បានបង្ហាញអំពីកង្វះការគាំទ្រពីអ្នកខាងក្រៅដល់ប្រជាជននៅតាមជនបទនៅក្នុងអំឡុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ និងកង្វះចំណេះដឹងស្តីពីការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ។ របាយការណ៍នេះបង្ហាញពីតួនាទីនៃការជួយគាំទ្រពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយនៅមានកម្រិតនៅឡើយក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសសម្រាប់ប្រជាជននៅតាមជនបទ។

# ២. វិធីសាស្ត្រនៃការស្រាវជ្រាវ

## ២.១ ការសិក្សាលើឯកសារដែលមានស្រាប់

មុនពេលចាប់ផ្ដើមគម្រោងនៃការសិក្សាស្រាវជ្រាវនេះ ឯកសារពាក់ព័ន្ធនានាដែលមានស្រាប់ត្រូវបានសិក្សាយ៉ាងលម្អិតដើម្បីបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ការរៀបចំគម្រោងស្រាវជ្រាវនេះ។ ការសិក្សាលើឯកសារពាក់ព័ន្ធបានបង្ហាញពីទិដ្ឋភាពរួមនៃការប្រែប្រួលអាកាសធាតុ និងគោលនយោបាយនានាក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ការពិនិត្យឯកសារដែលមានស្រាប់នេះបានកំណត់និងវិភាគ វិធីសាស្ត្រនានាក្នុងការសិក្សា KAP កន្លងមក និងវិធីសាស្ត្រមួយចំនួនដែលបានប្រើប្រាស់ក្នុងការអង្កេតរបស់ការស្រាវជ្រាវអាកាសធាតុអាស៊ីរបស់អង្គការប៊ីប៊ីស៊ី មីឌាអាក់សិន ផងដែរ។ ការពិនិត្យបែបនេះធ្វើឡើងក្នុងគោលបំណង ដើម្បីធ្វើការវាយតម្លៃពីចំណុចខ្លាំងនៃវិធីសាស្ត្រវាស់វែងផ្សេងៗគ្នា ដែលបានយកមកសិក្សាកន្លងមក ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយក្នុងការរៀបចំវិធីសាស្ត្រស្រាវជ្រាវសម្រាប់ការសិក្សា KAP៣ នេះ។

## ២.២ ការសិក្សាបែបបរិមាណវិស័យ

ការសិក្សា KAP៣ នេះបានសម្ភាសប្រជាជន[6] សរុបចំនួន១.៥៦០នាក់[7] ផ្ដោតលើតំបន់ភូមិសាស្ត្រទាំង៥ (ភ្នំពេញ តំបន់វាលទំនាប តំបន់ភ្នំ តំបន់ទន្លេសាប និងតំបន់ឆ្នេរ[8]) និងរាជធានី/ខេត្ត ទាំងឡាយនៅក្នុងប្រទេសកម្ពុជា។ ការជ្រើសរើសសំណាកដែលមានលក្ខណៈតំណាងឲ្យប្រជាសាស្ត្រនៃប្រទេសកម្ពុជាទាំងមូលត្រូវបានធ្វើឡើងដោយមានការបែងចែកប្រជាជនជាសំណុំផ្សេងៗគ្នា ដើម្បីឲ្យប្រាកដថាសំណាកដែលបានជ្រើសរើសអាចតំណាងឲ្យក្រុមប្រជាជននៅតំបន់ទីក្រុង និងជនបទ ក៏ដូចជាក្រុមបុរស និងស្ត្រី តំបន់ភូមិសាស្ត្រ និងចំនួនប្រជាជនទូទាំងប្រទេស។

---

[6] Sample size (n) = $\frac{\frac{z^2 \times p\,(1-p)}{e^2}}{1+(\frac{z^2 \times p\,(1-p)}{e^2 N})}$ ***N:*** *Population Size,* ***z:*** *Critical Value (or confidence level),* ***e:*** *Margin of Error,* ***p:*** *Sample Proportion*

[7] បន្ទាប់ពីថ្លឹងទិន្ន័យក្នុងស្ថិតិរួចហើយ ការវិភាគទិន្នន័យគឺប្រើចំនួនសរុប ១.៥៥៨

[8] យោងតាមឯកសារជំរឿនប្រជាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ នៅប្រទេសកម្ពុជាគេបែងចែកតំបន់ភូមិសាស្ត្រជាបួនធំៗគឺ តំបន់វាលទំនាប តំបន់ភ្នំ តំបន់ទន្លេសាប និងតំបន់ឆ្នេរ។ **តំបន់ទំនាបកណ្ដាល៖** ខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្ដាល ភ្នំពេញ ព្រៃវែង ស្វាយរៀង និងតាកែវ។ **តំបន់ទន្លេសាប៖** បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប ឧត្ដរមានជ័យ និងប៉ៃលិន។ **តំបន់ឆ្នេរ៖** កំពត កោះកុង ព្រះសីហនុ និងកែប។ **តំបន់ភ្នំ៖** កំពង់ស្ពឺ ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និងស្ទឹងត្រែង។ ដោយសារភ្នំពេញជារាជធានីរបស់ប្រទេសកម្ពុជាដែលមានចំនួនប្រជាជនច្រើនជាងគេ និងមានស្ថានភាពប្រជាសាស្ត្រប្លែកពីគេបើធៀបនឹងខេត្ត/ក្រុងនានា (មានចំនួនប្រជាជនដល់ទៅ២.១២៩.៣៧១នាក់ ឬស្មើនឹង ១៣,៩% នៃប្រជាជនសរុបក្នុងប្រទេស) វាមានសារៈសំខាន់ណាស់ដែលវិធីសាស្ត្រនៃការធ្វើសំណាកស្រាវជ្រាវគួរតែពិចារណាអំពីចំណុចនេះ។ ដូច្នេះរាជធានីភ្នំពេញត្រូវបានដកចេញពីតំបន់ទំនាបកណ្ដាលសម្រាប់ការសិក្សានេះដើម្បីដាក់វាជាតំបន់មួយដាច់ដោយឡែកពីតំបន់ទាំងបួន ក្នុងគោលបំណងដើម្បីធានាបានថាវិធីសាស្ត្រនៃការធ្វើ និងជ្រើសរើសសំណាកកាន់តែមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព។




**រូបភាពទី ១៖ ការបែងចែកសំណាកតាមខេត្តនានានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ**

វិធីសាស្ត្រប្រូបាបប៊ីលីតេសមាមាត្រទៅនឹងទំហំ (PPS) ត្រូវបានយកមកប្រើប្រាស់ក្នុងការជ្រើសរើសទីតាំងសិក្សាដោយចៃដន្យសម្រាប់ការចុះប្រមូលទិន្នន័យក្នុងតំបន់ភូមិសាស្ត្រនីមួយៗ ដើម្បីធានាបានថាសំណាកដែលត្រូវជ្រើសរើសសម្រាប់ការសិក្សានេះមានលក្ខណៈជាតំណាងប្រជាសាស្ត្រទាំងមូល។ ភូមិ និងប្លុកតូចៗនៅក្នុងភូមិដែលបានជ្រើសរើស គឺជាបំណែងចែកភូមិសាស្ត្រសម្រាប់តំបន់ជនបទ រីឯបំណែងចែកភូមិសាស្ត្រសំខាន់ៗនៅតាមសង្កាត់គឺជាបំណែងចែកតូចជាងគេសម្រាប់តំបន់ទីក្រុង/ប្រជុំជន។ គ្រួសារ (តាមខ្នងផ្ទះ) ត្រូវបានជ្រើសរើសដោយចៃដន្យដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសយកខាងស្តាំដៃ[9] តាមចលនារបស់ក្រុមការងារចុះប្រមូលទិន្នន័យ។ អ្នកឆ្លើយតបសម្ភាសន៍[10] ត្រូវបានជ្រើសរើសដោយប្រើប្រាស់វិធីសាស្ត្រចាប់យកដោយចៃដន្យ ឈ្មោះថាឃីសគ្រីត(Kish Grid)។

ការចុះប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះបានធ្វើឡើង តាមរយៈការសម្ភាសដោយផ្ទាល់ទល់មុខគ្នាតាមមូលដ្ឋាននៅអំឡុងចន្លោះខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០២០ បន្ទាប់ពីស្ថានភាពនៃការរឹតត្បិតទាក់ទងនឹងការរីករាលដាលនៃមេរោគកូវីដ១៩ ត្រូវបានបន្ធូរបន្ថយ និងមានភាពប្រសើរឡើង។ វិធានការសុវត្ថិភាពសម្រាប់ការការពារពីជំងឺកូវីដ១៩ បានរៀបចំយ៉ាងហ្មត់ចត់ និងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននៅ

[9] មានន័យថា ខ្នងផ្ទះដែលនៅលើផ្លូវខាងស្តាំដៃជាគោលដៅ ដែលត្រូវរាប់ដើម្បីជ្រើសរើសរហូតដល់ការសម្ភាសនីមួយៗបានជោគជ័យ

[10] នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះគេប្រើពាក្យថា «អ្នកឆ្លើយតបសម្ភាសន៍» និង «ប្រជាជនកម្ពុជា» ដើម្បីជំនួសគ្នាទៅវិញទៅមកដែលពាក្យទាំងនេះឆ្លុះបញ្ចាំងពីសំណាកជាតំណាងឲ្យប្រជាជនកម្ពុជាទាំងមូលដោយផ្អែកលើអាយុ ភេទ តំបន់ភូមិសាស្ត្រ និងក្រុមប្រជាជន។

អំឡុងពេលប្រមូលទិន្នន័យសម្រាប់ការសិក្សានេះ[11]។ ការអង្កេតនេះបានប្រើប្រាស់កម្មវិធីនៃការសម្ភាសដោយផ្ទាល់តាមរយៈការកត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិច (CAPI) នៅលើថេបប្លេតក្នុងការប្រមូល និងកត់ត្រាទិន្នន័យនៃកិច្ចសម្ភាសជាមួយអ្នកឆ្លើយតបសម្ភាសន៍ទាំងអស់ ដែលមានអាយុចាប់ពី ១៥ ដល់៥៥ ឆ្នាំ។

## ការជ្រើសរើសសំណាកសម្រាប់ការសិក្សា

តារាងទី១ បង្ហាញនូវទិដ្ឋភាពទូទៅនៃប្រជាសាស្ត្រសំខាន់ៗទៅតាមសំណាកដែលបានថ្លឹងឲ្យមានសមតុល្យទិន្នន័យ (in the weighted sample) សម្រាប់ការស្រាវជ្រាវនេះ។ ទិន្នន័យទាំងនេះត្រូវបានថ្លឹងទៅតាមអាយុ ភេទ និងទីតាំងនៃការសិក្សាដោយផ្អែកទៅលើទិន្នន័យគោលចុងក្រោយស្តីពីចំនួនប្រជាជនកម្ពុជា (ប្រើប្រាស់មូលដ្ឋានទិន្នន័យឃុំ/សង្កាត់ឆ្នាំ២០១៧[12] ដែលបានធ្វើបច្ចុប្បន្នភាពផ្អែកលើទិន្ន័យប្រជាសាស្ត្រឆ្នាំ២០១៤[13] របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃក្រសួងមហាផ្ទៃ) ដែលអាចរកបាន។

### តារាងទី១៖ សំណាកសម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ

| ប្រជាសាស្ត្រ | | សំណាកសរុប ១.៥៥៨ (ដែលបានថ្លឹងក្នុងស្ថិតិ) |
|---|---|---|
| ភេទ | បុរស | ៤៩% |
| | ស្ត្រី | ៥១% |
| អាយុ | ១៥-២៤ | ៣៥% |
| | ២៥-៣៤ | ២៥% |
| | ៣៥-៤៤ | ២៤% |
| | ៤៥-៥៥ | ១៦% |
| ទីតាំងសិក្សា | ទីក្រុង/ប្រជុំជន | ៣៣% |
| | ជនបទ | ៦៧% |
| តំបន់សិក្សា | ក្រុងភ្នំពេញ | ១០% |
| | តំបន់ទំនាប | ៣៩% |
| | តំបន់ភ្នំ | ១១% |

---

[11] ក្រុមការងារចុះប្រមូលទិន្នន័យនៅមូលដ្ឋានទាំងអស់គឺទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវអំពីវិធានការនានាដើម្បីបង្ការជំងឺកូវីដ១៩ ជាពិសេសសំណួរមួយចំនួនទាក់ទងនឹងការកំណត់អត្តសញ្ញាណនៃរោគសញ្ញាកូវីដ១៩ និងប្រវត្តិនៃការធ្វើដំណើរក៏បានដាក់បញ្ចូលទៅក្នុងបញ្ជីសំណួរក្នុងប្រព័ន្ធអេឡិចត្រូនិចផងដែរ។ បន្ថែមពីនេះក្រុមការងារបានគោរពនូវវិធានការនានាដែលបានដាក់ចេញដោយក្រសួងសុខាភិបាលដោយក្នុងនោះមានការអនុវត្តការរក្សាគម្លាត ពាក់ម៉ាស់ និងលាងដៃជាមួយអាល់កុល/ដែលជាប្រចាំនៅពេលធ្វើការសម្ភាស ហើយក៏បានប្រាប់នូវសេចក្តីណែនាំលម្អិតពីវិធានការទាំងនេះទៅកាន់អ្នកតបសម្ភាសន៍មុនពេលចាប់ផ្តើមផងដែរ។

[12] ទិន្នន័យប្រជាសាស្ត្រឆ្នាំ២០១៤ ត្រូវបានធ្វើបច្ចុប្បន្នភាពចេញពីជំរឿនប្រជាសាស្ត្រឆ្នាំ២០០៨។

[13] នៅពេលដែលការអង្កេត KAP៣ បានបញ្ចប់ លទ្ធផល/ទិន្នន័យផ្លូវការនៃជំរឿនប្រជាសាស្ត្រឆ្នាំ២០១៩ នៅប្រទេសកម្ពុជានៅមិនទាន់បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការសម្រាប់ការគណនាទម្ងន់នៃក្រុមសំណាកនីមួយៗនៅឡើយទេ។

| ប្រជាសាស្ត្រ | | សំណាកសរុប ១.៥៥៨ (ដែលបានថ្លឹងក្នុងស្ថិតិ) |
|---|---|---|
| | តំបន់ទន្លេសាប | ៣៣% |
| | តំបន់ឆ្នេរ | ៧% |
| ស្ថានភាពសេដ្ឋកិច្ច[14] | ក្រីក្របំផុត | ៤% |
| | ក្រីក្រ | ៥៧% |
| | មធ្យម | ៣៨% |
| | ធូរធារ | ១% |
| កម្រិតនៃការទទួលបានការអប់រំ | មិនបានចូលរៀននៅសាលា | ៦% |
| | បឋមសិក្សា | ៣៧% |
| | អនុវិទ្យាល័យ | ៣១% |
| | វិទ្យាល័យ | ២០% |
| | មហាវិទ្យាល័យ | ៥% |
| | ការបណ្តុះបណ្តាលវិជ្ជាជីវៈ | ០,៣% |
| មុខរបរ | អ្នកប្រកបការងារវិជ្ជាជីវៈ | ៧% |
| | អាជីវករ/ពាណិជ្ជករ | ២១% |
| | កសិករ និងអ្នកនេសាទ | ៣៤% |
| | កម្មករ (ជំនាញទាប និងគ្មានជំនាញ) | ៩% |
| | អ្នកមិនធ្វើការងារបានប្រាក់ចំណូល (ស្ត្រីមេផ្ទះ និស្សិត អ្នកចូលនិវត្តន៍ អ្នកគ្មានការងារធ្វើ) | ២៩% |

[14] ស្ថានភាពនៃសេដ្ឋកិច្ចត្រូវបានវាស់វែងតាមរយៈសំណួរមួយនៅក្នុងកម្រងសំណួរសម្រាប់អង្កេត។ ដើម្បីវាស់វែងពីស្ថានភាពនៃសេដ្ឋកិច្ចក្នុងគ្រួសារមួយឲ្យកាន់តែត្រឹមត្រូវ គួរតែប្រើបញ្ជីសំណួរជាស៊េរីមួយចំនួនដែលពិនិត្យមើលអំពីធាតុផ្សេងៗនៃភាពក្រីក្រដូចជា ការសួរសំណួរអំពីការទទួលបានសេវាថែទាំសុខភាព ការអប់រំ និងកម្រិតស្តង់ដារនៃជីវភាពរស់នៅរួមមាន ស្ថានភាពផ្ទះដែលមាន អនាម័យ លទ្ធភាពមានទឹក ឥន្ធនៈ អគ្គិសនីប្រើប្រាស់ ព្រមទាំងទ្រព្យសម្បត្តិផ្សេងៗទៀតផងដែរ។ ដោយឡែកដើម្បីឲ្យកម្រងសំណួនៃការអង្កេតសម្រាប់ការសិក្សានេះខ្លីតាមពេលវេលាដែលអាចធ្វើទៅបានក្នុងការស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចគ្រួសារជាមូលដ្ឋាន គេបានប្រើសំណួរតែមួយប៉ុណ្ណោះក្នុងការវាស់វែងដែលសំនួរនេះផ្អែកទៅតាមស្តង់ដារសំណួរនៃការអង្កេតរបស់ ប៊ីប៊ីស៊ី មីឌាអាក់សិន (សំណួរលម្អិតអាចចូលទៅកាន់ https://dataportal.bbcmediaaction.org/site/assets/uploads/2016/07/Common-Media-and-Demographic-Questions.pdf)។
សំណួរដែលសួរឲ្យអ្នកតបសម្ភាសន៍ឆ្លើយពីស្ថានភាពនៃសេដ្ឋកិច្ចដោយខ្លួនឯងដែលបានប្រើនៅក្នុងការសិក្សានេះមានគោលបំណងដាក់ក្រុមប្រជាជនឲ្យត្រូវតាមប្រភេទក្រុមដូចខាងក្រោម៖
*អ្នកដែលមិនមានប្រាក់គ្រប់គ្រាន់សូម្បីតែសម្រាប់ម្ហូបអាហារគឺស្ថិតក្នុងក្រុម «ក្រីក្របំផុត»។ អ្នកដែលអាចមានលទ្ធភាពទិញអាហារបាន ប៉ុន្តែការទិញសម្លៀកបំពាក់គឺជាបញ្ហាធ្ងន់ធ្ងរស្ថិតក្នុងក្រុម «ក្រីក្រ»។ អ្នកដែលអាចមានលទ្ធភាពទិញម្ហូប និងសម្លៀកបំពាក់បាន ប៉ុន្តែការទិញសម្ភារ/ឧបករណ៍ដូចជា ទូរទស្សន៍ ឬទូទឹកកក ពិបាកគឺស្ថិតក្នុងក្រុម «មធ្យម»។ ចំណែកឯអ្នកដែលអាចមានលទ្ធភាពទិញឧបករណ៍ប្រើប្រាស់ក្នុងផ្ទះសំខាន់ៗបាន ប៉ុន្តែការទិញឡានគឺហួសពីសមត្ថភាពរបស់ពួកគាត់ត្រូវស្ថិតក្នុងក្រុម «ធូរធារ»។* និយមន័យនេះអាចមានភាពខុសគ្នាជាមួយនិយមន័យស្តង់ដានៃភាពក្រីក្រដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

## ២.៣ ការសិក្សាស្រាវជ្រាវបែបគុណវិស័យ

**ការសម្ភាសបែបគុណវិស័យនៅដំណាក់កាលដំបូង៖** ការសម្ភាសស៊ីជម្រៅនានាត្រូវបានធ្វើឡើងជាមួយភាគីពាក់ព័ន្ធសំខាន់ៗដែលរួមមានអ្នកធ្វើការសម្រេចចិត្តនានានៅក្នុងក្រសួង/ស្ថាប័នរដ្ឋ សមាជិកព្រឹទ្ធសភាជាតិ សមាជិករដ្ឋសភា អ្នកធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ និងអ្នកតំណាងមកពីវិស័យឯកជន។ ការសម្ភាសនេះមានគោលបំណងស្វែងយល់ពីទស្សនៈ ការយល់ដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រទំនាក់ទំនងក៏ដូចជាកម្មវិធីអន្តរាគមន៍ចំបាច់នានា សម្រាប់ជួយគាំទ្រដល់ប្រជាជនដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនាពេលអនាគត។

**ការសម្ភាសបែបគុណវិស័យនៅដំណាក់កាលចុងក្រោយ៖** ការសម្ភាសស៊ីជម្រៅក្នុងដំណាក់កាលនេះត្រូវបានធ្វើឡើងជាមួយភាគីពាក់ព័ន្ធសំខាន់ៗនៅស្ថាប័នថ្នាក់ក្រោមជាតិរបស់រដ្ឋាភិបាល) ថ្នាក់ខេត្ត ស្រុក និងឃុំ (និងអ្នកអនុវត្តការងារអភិវឌ្ឍន៍) អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ (បន្ទាប់ពីការវិភាគទិន្នន័យនៃការអង្កេតបែបបរិមាណ ការសម្ភាសបែបគុណវិស័យនៅដំណាក់កាលដំបូង និងការត្រួតពិនិត្យលទ្ធផលសំខាន់ៗដែលមានស្រាប់របស់អង្គការប៊ីប៊ីស៊ី មីឌាអាក់សិន ត្រូវបានបញ្ចប់។ លើសពីនេះទៀត ការសម្ភាសស៊ីជម្រៅ និងការពិភាក្សាជាក្រុមក៏ត្រូវបានធ្វើឡើងជាមួយក្រុមមនុស្សដែលមានឥទ្ធិពលនៅមូលដ្ឋាន សមាជិក/ប្រជាជននៅសហគមន៍ ក្រុមងាយរងគ្រោះ[15] និងនិស្សិត។

ការសិក្សាបែបគុណវិស័យក្នុងដំណាក់កាលនេះក៏បានប្រើប្រាស់ការសង្កេតផងដែរ ដើម្បីធ្វើការផ្ទៀងផ្ទាត់លទ្ធផលពីប្រភពផ្សេងៗគ្នា។ វិធីសាស្ត្រនេះជួយបង្កើនសុក្រិតភាពនៅក្នុងការវិភាគទិន្នន័យ និងទាញយកករណីសិក្សាបង្ហាញអំពីភាពខុសគ្នានៃប្រជាជនកម្ពុជាក្នុងការធ្វើសកម្មភាពបន្សាំ និងឧបសគ្គនានាដែលពួកគាត់កំពុងជួបប្រទះក្នុងកិច្ចខិតខំប្រឹងប្រែងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ។

### តារាងទី២៖ ប្រភេទអ្នកចូលរួមការសិក្សាបែបគុណវិស័យ

| ក្រុមគោលដៅ | អ្នកចូលរួមសំខាន់ៗ |
|---|---|
| ស្ថាប័នរដ្ឋាភិបាល | ថ្នាក់ជាតិ (ក្រសួងពាក់ព័ន្ធនានា ស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា) |
| | ថ្នាក់ខេត្ត (អភិបាលខេត្ត) |
| | ថ្នាក់ស្រុក (អភិបាលស្រុក) |
| | ថ្នាក់ឃុំ (ក្រុមប្រឹក្សាឃុំ/មេឃុំ) |
| អ្នកមានឥទ្ធិពល | ប្រព័ន្ធផ្សព្វផ្សាយ (ស្ថាប័នសារព័ត៌មានឯកជន និងសាធារណៈ) |
| | វិស័យឯកជន |
| អង្គការសង្គមស៊ីវិល | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| | អង្គការអន្តរជាតិ |

[15] ក្រុមងាយរងគ្រោះក្នុងការសិក្សានេះសំដៅទៅលើក្រុម៖ ១) ប្រជាជនមានពិការភាព ២) ស្ត្រីដែលមានប្រវត្តិផ្សេងៗគ្នាដូចជា ស្ត្រីនៅទីជនបទដែលខ្វះការទទួលបានប្រព័ន្ធផ្សព្វផ្សាយ មេគ្រួសារជាស្ត្រី ឬស្ត្រីដែលមានប្តីបានធ្វើចំណាកស្រុក។

| ក្រុមគោលដៅ | អ្នកចូលរួមសំខាន់ៗ |
|---|---|
| ប្រជាជនទូទៅ | មេភូមិ |
| | គណៈកម្មាធិការឃុំដើម្បីស្ត្រី និងកុមារ និងគណៈកម្មាធិការឃុំសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ |
| | គ្រូបង្រៀន |
| | អ្នកដឹកនាំសាសនា/ចាស់ព្រឹទ្ធាចារ្យ |
| | ក្រុមងាយរងគ្រោះ (ជនពិការ ស្ត្រីជាមេគ្រួសារ ប្រជាជនក្រីក្រ ។ល។) |
| | អ្នកភូមិទូទៅ |
| | ស្ត្រី និងបុរស |
| | សិស្ស/និស្សិត |

## ២.៤ សិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ

បន្ទាប់ពីការវិភាគទិន្នន័យអង្កេតបែបបរិមាណ និងគុណវិស័យរួចមក លទ្ធផលនៃការសិក្សាបឋមត្រូវបានបង្ហាញទៅកាន់ភាគីពាក់ព័ន្ធមួយចំនួនដូចជា អ្នកតំណាងដែលអញ្ជើញមកពី ព្រឹទ្ធសភាជាតិ រដ្ឋសភា ស្ថាប័នរដ្ឋាភិបាល ភ្នាក់ងារសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នសិក្សានានានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០។ បទបង្ហាញនៃលទ្ធផលនេះមានគោលបំណងដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការសិក្សា និងស្វែងរកធាតុចូលនានាសម្រាប់ការកែលម្អ និងសរសេររបាយការណ៍ស្រាវជ្រាវចុងក្រោយ។

## ២.៥ កំណត់ចំណាំស្តីពីវិធីសាស្ត្រខុសគ្នារវាងការសិក្សានៃ KAP នាំងពីរ

ការសិក្សា KAP៣ បានប្រើប្រាស់បញ្ជីសំណួរដែលមានភាពខុសប្លែក[16]ពីការសិក្សា KAP កន្លងមក។ បញ្ជីសំណួរត្រូវបានរៀបចំឡើងដើម្បីសួរអ្នកតបសម្ភាសន៍ឲ្យធ្វើការឆ្លុះបញ្ចាំងអំពីការប្រែប្រួលនានា នៃធាតុអាកាស បរិស្ថាន និងធនធានផ្សេងៗដោយផ្អែកលើបទពិសោធន៍រស់នៅ និងការយល់ដឹងទាក់ទងនឹងការប្រែប្រួលធាតុអាកាស និងធនធាននានានៅជុំវិញខ្លួនពួកគាត់។[17]

[16] ការរៀបចំបញ្ជីសំណួរគឺផ្អែកតាមបទពិសោធន៍នៃការរៀនសូត្រតាមរយៈការស្រាវជ្រាវអាកាសធាតុអាស៊ីនៅកម្ពុជា។ សំណួរដែលប្រើក្នុងបញ្ជីសំណួរKAP៣ គឺប្រើពាក្យពេជន៍ស្រដៀងគ្នានឹងការអង្កេតនៃអាកាសធាតុអាស៊ី។

[17] ការសិក្សាបឋមដែលធ្វើឡើងដើម្បីជាចំណុចភ្ជាប់ឲ្យមានការសិក្សាជាបន្តបន្ទាប់របស់ការស្រាវជ្រាវអាកាសធាតុអាស៊ី បានរកឃើញថាអ្នកតបសម្ភាសន៍ជួបការលំបាកក្នុងការយល់ពីពាក្យថា «ការប្រែប្រួលអាកាសធាតុ»។ ដូច្នេះនៅពេលចាប់ផ្តើមសរសេរគម្រោងស្រាវជ្រាវសម្រាប់ KAP ៣ និងពេលបង្កើតឧបករណ៍ស្រាវជ្រាវយើងបានដឹងថាប្រជាជនពិតជាបានដឹងអំពីការប្រែប្រួលនានានៃធាតុអាកាស បរិស្ថាន និងធនធាន ប៉ុន្តែពួកគាត់មិនអាចផ្សារភ្ជាប់បទពិសោធន៍ទាំងនេះដោយផ្ទាល់ជាមួយពាក្យថា «ការប្រែប្រួលអាកាសធាតុ» នោះទេ។ ដើម្បីបង្កើនសុក្រិតភាពនៃការស្រាវជ្រាវ ការអង្កេតបានរៀបចំបញ្ជីសំណួរ និងភាសា ក៏ដូចជាពាក្យពេជន៍ដែលអាចផ្សារភ្ជាប់ជាមួយបទពិសោធន៍ប្រចាំថ្ងៃរបស់ប្រជាជនដូចជា អាហារ ទឹក ថាមពល អាកាសធាតុអាក្រក់នានា ជាជាងការប្រើពាក្យ ការប្រែប្រួលអាកាសធាតុដែលប្រជាជនមិនសូវស្គាល់/យល់។ ជាដំបូងអ្នកឆ្លើយតបសម្ភាសន៍ត្រូវបានសួរពីទស្សនៈជុំវិញការប្រែប្រួលសីតុណ្ហភាព របបទឹកភ្លៀង និងអាកាសធាតុអាក្រក់នានានៅក្នុងរយៈកាល ១០ឆ្នាំ ចុងក្រោយ។ បន្ទាប់មកពួកគេត្រូវបានសួរអំពីការប្រែប្រួលនៃធនធានដែលមានស្រាប់ដូចជា អាហារ ទឹក ថាមពល និងការប្រែប្រួលនៃបរិស្ថានជុំវិញរបស់ពួកគេ។ ការសាកសួរដោយប្រើពាក្យការប្រែប្រួលអាកាសធាតុគឺត្រូវបានគេសួរនៅចុងក្រោយគេបង្អស់។

ការសិក្សា KAP៣ ក៏បានដាក់បញ្ចូលនូវសំណួរមួយចំនួនដែលអាចបង្ហាញពីនិន្នាការរបស់សូចនាករសំខាន់ៗដើម្បីប្រៀបធៀបលទ្ធផលនៃការសិក្សា KAP១ និង KAP២។ សូចនាករដែលត្រូវដាក់បញ្ចូលនេះមានដូចខាងក្រោម៖

- ការយល់ដឹង/ស្គាល់ពាក្យ «ការប្រែប្រួលអាកាសធាតុ» និង «កម្តៅភពផែនដី»
- សកម្មភាពនានាដែលប្រជាជននៅតំបន់មួយចំនួនបានអនុវត្ត ដើម្បីឆ្លើយតបនឹងការប្រែប្រួល នៃបរិស្ថាន ធាតុអាកាស និងធនធាននានា។

នៅក្នុងការវិភាគបែបស្ថិតិវិទ្យានៃកម្រិតខុសគ្នាជាអត្ថន័យរវាងក្រុមសំណាកនីមួយៗ ក៏ត្រូវបានពន្យល់បកស្រាយបន្ថែមក្នុងរបាយការណ៍នេះផងដែរ។ ទន្ទឹមនឹងនេះការសិក្សានេះគឺបានគូសបញ្ជាក់បន្ថែមផងដែរ ប្រសិនបើលទ្ធផលវិភាគស្ថិតិវិទ្យាបង្ហាញភាពខុសគ្នាចំពោះបញ្ហាយេនឌ័រ។ ដោយឡែកប្រសិនបើមិនមានការបកស្រាយអំពីភាពខុសគ្នា ឬការបែងចែកតាមភេទនោះទេ មានន័យថាលទ្ធផលសិក្សា/ស្ថិតិវិទ្យា មិនបានបង្ហាញពីភាពខុសគ្នាជាអត្ថន័យសម្រាប់បកស្រាយរវាងភេទប្រុស និងភេទស្រីនោះទេ។

**តារាងទី ៣៖ សេចក្តីសង្ខេបអំពីវិធីសាស្ត្រខុសគ្នារវាងការសិក្សា KAP នីមួយៗ (រួមទាំងការពិនិត្យសូចនាករសំខាន់ៗផងដែរ)**

| | KAP១ | KAP២ | KAP៣ |
|---|---|---|---|
| ក្របខ័ណ្ឌនៃការតាក់តែងមូលដ្ឋានគំនិត | ការអង្កេត/បញ្ជីសំណួរបានរៀបចំឡើងក្នុងបរិបទនៃបទពិសោធន៍ប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាដែលទាក់ទងទៅនឹងការប្រែប្រួលនានានៃធាតុអាកាស ហើយការផ្សារភ្ជាប់ជាមួយការប្រែប្រួលផ្សេងទៀតក៏បានស្វែងយល់យ៉ាងលម្អិតផងដែរ។ | ពាក្យ «ការប្រែប្រួលអាកាសធាតុ» គឺបានបង្ហាញតាំងពីដំបូងនៅក្នុងការអង្កេត/បញ្ជីសំណួរ ហើយការផ្សារភ្ជាប់រវាងអ្នកឆ្លើយតបសម្ភាសន៍ជាមួយការប្រែប្រួលនានាគឺបានឆ្លុះបញ្ចាំងតាមរយៈពាក្យ «ការប្រែប្រួលអាកាសធាតុ» និង «វិសមរូបអាកាសធាតុ» ដោយមិនផ្តោតសំខាន់ថាអ្នកតបសម្ភាន៍យល់ពាក្យទាំងនេះឬអត់នោះទេ។ | ការអង្កេត/បញ្ជីសំណួរផ្តោតសំខាន់លើបទពិសោធន៍ប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាដែលទាក់ទងទៅនឹងការប្រែប្រួលនានានៃធាតុអាកាស បរិស្ថាន និងធនធាន។ ការផ្សារភ្ជាប់រវាងអ្នកឆ្លើយតបសម្ភាសន៍ជាមួយការប្រែប្រួលទាំងនេះគឺបានធ្វើការស្វែងយល់នៅគ្រប់សំណួរទាំងអស់ (ឧ. បញ្ហាសុខភាព ទឹក អាហារ ធាតុអាកាស)។ |
| សូចនាករសំខាន់ៗ — ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ | ពាក្យ «ការប្រែប្រួលអាកាសធាតុ» គឺបាននិយាយ/បង្ហើបជាលើកដំបូងនៅក្នុងការអង្កេត/បញ្ជីសំណួរនៅពេលដែលអ្នកឆ្លើយតបសម្ភាសន៍ត្រូវបានគេសួរថាតើពួកគេធ្លាប់បានឮពាក្យនេះដែរឬទេ។<br><br>សំណួរ៖<br>*KAP១៖ តើអ្នកធ្លាប់បានឮពាក្យ «ការប្រែប្រួលអាកាសធាតុ» ដែរឬទេ?* | ពាក្យ «ការប្រែប្រួលអាកាសធាតុ» គឺបាននិយាយ/បង្ហើបជាច្រើនដងតាំងពីដំបូងនៅក្នុងការអង្កេត/បញ្ជីសំណួរមុនពេលដែលអ្នកឆ្លើយតបសម្ភាសន៍ត្រូវបានគេសួរថាតើពួកគេធ្លាប់បានឮពាក្យនេះដែរឬទេ។<br><br>សំណួរ៖<br>*KAP២៖ ខ្ញុំនឹងសួរអ្នកនូវពាក្យមួយចំនួនដែលអ្នកប្រហែលជាធ្លាប់បានឮ។ សម្រាប់ពាក្យនីមួយៗ សូមប្រាប់ខ្ញុំថាអ្នកធ្លាប់ឮវាដែរឬទេ?* | ពាក្យ «ការប្រែប្រួលអាកាសធាតុ» ត្រូវបានគេសួរទៅកាន់អ្នកឆ្លើយតបសម្ភាសន៍នៅចុងក្រោយគេនៃការអង្កេត/បញ្ជីសំណួរ បន្ទាប់មកគេបានសួរដេញដោលបន្ថែមថាតើពួកគេដឹងពីអត្ថន័យនៃពាក្យនេះដែរឬទេដើម្បីបញ្ជាក់បន្ថែមសុក្រិតភាពនៃទិន្នន័យ។<br><br>សំណួរ៖<br>*KAP៣៖ តើអ្នកធ្លាប់បានឮពាក្យ «ការប្រែប្រួលអាកាសធាតុ» ដែរឬទេ?* |

| | | | | |
|---|---|---|---|---|
| | **សកម្មភាពឆ្លើយតបរបស់សហគមន៍** | បញ្ជីសកម្មភាពនៃការឆ្លើយតបដូចគ្នានឹងការសិក្សាពីមុនត្រូវបានប្រើក្នុងសំណួរទាក់ទងនឹងការឆ្លើយតបរបស់សហគមន៍ដោយការអានសកម្មភាពនីមួយៗ ហើយសួរបញ្ជាក់ពីការអនុវត្ត។ | | |
| | | សំណួរបានសួរអំពីការឆ្លើយតបទៅនឹង «ការប្រែប្រួលធាតុអាកាស»។<br>*KAP១៖ តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើសកម្មភាពអ្វីសម្រាប់ឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសដែរឬទេ?* | សំណួរបានសួរអំពីការឆ្លើយតបទៅនឹង «វិសមរូបអាកាសធាតុ»។<br>*KAP២៖ តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើសកម្មភាពអ្វីដើម្បីឆ្លើយតបនឹងវិសមរូបអាកាសធាតុដែរឬទេ?* | សំណួរបានសួរអំពី ការឆ្លើយតបទៅនឹង «ការប្រែប្រួលនៃការទទួលបានអាហារ ទឹក ថាមពល និងធាតុអាកាស»។<br>*KAP៣៖ តើប្រជាជននៅក្នុងភូមិ ឬតំបន់របស់អ្នកបានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃការទទួលបានអាហារ ថាមពល ទឹក និងការប្រែប្រួលធាតុអាកាស?* |
| | **សកម្មភាពឆ្លើយតបរបស់បុគ្គល** | ក្នុងសំណួរនេះបានសួរជារួមទាំងសកម្មភាពឆ្លើយតបរបស់បុគ្គល និងគ្រួសារ។<br>*KAP១៖ តើអ្នក ឬគ្រួសាររបស់អ្នកបានធ្វើសកម្មភាពអ្វីដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសដែរឬទេ?* | ក្នុងសំណួរនេះបានសួរអំពី «សកម្មភាពឆ្លើយតបទៅនឹងវិសមរូបអាកាសធាតុ»។ សកម្មភាពរបស់បុគ្គលត្រូវបានស្វែងយល់តាមរយៈបញ្ជីសកម្មភាពដូចគ្នានឹងបញ្ជីសកម្មភាពរួមគ្នារបស់សហគមន៍។<br>*KAP២៖ តើអ្នក ឬគ្រួសាររបស់អ្នកបានធ្វើសកម្មភាពអ្វីដើម្បីឆ្លើយតបនឹងវិសមរូបអាកាសធាតុដែរឬទេ?* | បញ្ជីសកម្មភាពឆ្លើយតបរបស់បុគ្គលគឺត្រូវបានស្វែងយល់តាមរយៈសំណួរទាំងអស់ដែលពាក់ព័ន្ធ (បញ្ហាសុខភាព ទឹក អាហារ និងធាតុអាកាស)<br>*KAP៣៖ តើអ្នកកំពុងធ្វើសកម្មភាពអ្វីខ្លះដើម្បីទប់ទល់/ឆ្លើយតបជាមួយនឹងការប្រែប្រួលនានានៃការទទួលបានអាហារ ទឹក ថាមពល និងឥន្ធនៈ ព្រមទាំងការប្រែប្រួលនៃធាតុអាកាស?* |

## ២.៦ ដែនកំណត់នៃការសិក្សា

តាមការពិភាក្សាខាងលើបានបង្ហាញថាការសិក្សា KAP៣ មានភាពខុសគ្នាជាមួយការសិក្សា KAP មុនៗ ទាក់ទងនឹងលំដាប់នៃសំណួរ ទម្រង់ និងមាតិកាសំណួរមួយចំនួន។ អាស្រ័យហេតុនេះក្រៅពីសំណួរដែលប្រើសម្រាប់កំណត់សូចនាករសំខាន់ៗ ការប្រៀបធៀបលទ្ធផលរវាងការសិក្សា KAP៣ និងការសិក្សានានារបស់ KAP កន្លងមកត្រូវបានបង្ហាញក្នុងករណីចាំបាច់ ដោយសារសំណួរសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងចំណេះដឹង និងឥរិយាបថ ត្រូវបានរៀបចំឡើងខុសគ្នា ហើយវាមិនអាចប្រៀបធៀបគ្នាបានទាំងស្រុងនោះទេ។ ក្នុងករណីដែលអាចធ្វើទៅបានរបាយការណ៍ KAP៣ ក៏បានព្យាយាមឆ្លុះបញ្ចាំងពីនិន្នាការនានាដែលពាក់ព័ន្ធនឹងចំណេះដឹង ឥរិយាបថ និងលទ្ធផលតាមតំបន់ភូមិសាស្ត្រសិក្សា ផងដែរ។

ការសិក្សាស្រាវជ្រាវ KAP៣ មានគោលបំណងបង្ហាញភស្តុតាង និងវាយតម្លៃអំពីការប្រែប្រួលចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនកម្ពុជាទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុដើម្បីទទួលបាន ព័ត៌មានសម្រាប់ជាមូលដ្ឋាននៃការតាក់តែងគោលនយោបាយក្នុងការលើកកម្ពស់ការយល់ដឹងនាពេលអនាគត។ ដូច្នេះការផ្តោតសំខាន់នៃទិន្នន័យដែលបានពីការសិក្សាបែបបរិមាណ និងគុណវិស័យសម្រាប់ការសិក្សានេះគឺដើម្បីការយល់ដឹងពីទស្សនៈវិស័យ ឥរិយាបថ និងសកម្មភាពនានាដែលប្រជាជនកម្ពុជាបាន និងកំពុងអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេជុំវិញបរិបទ នៃការប្រែប្រួលអាកាសធាតុ។ ចំណែកការសិក្សាស្រាវជ្រាវបែបគុណវិស័យ ដែលបានធ្វើឡើងជាមួយភាគីពាក់ព័ន្ធដទៃទៀតគឺធ្វើឡើងក្នុងគោលបំណងដើម្បីប្រើប្រាស់ជាព័ត៌មានសម្រាប់បំពេញបន្ថែម និងគាំទ្រដល់ទិន្នន័យដែលបានពីការអង្កេតបែបបរិមាណវិស័យជាមួយប្រជាជនតែប៉ុណ្ណោះ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះមិនមានគោលបំណងគូសបញ្ជាក់ ឬបង្ហាញពីការតាមដានការផ្លាស់ប្តូរចំណេះដឹង អាកប្បកិរិយា ឬការអនុវត្តនានាជុំវិញការប្រែប្រួលអាកាសធាតុនៅក្នុងកម្រិតស្ថាប័នណាមួយនោះទេ។ ជាងនេះទៅទៀតវាក៏មិនមែនជាដំណើរការនៃការវាយតម្លៃពីរបៀប ដែលកម្មវិធីអន្តរាគមន៍នានាបានធ្វើការក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការប្រែប្រួលអាកាសធាតុដែលត្រូវបានអនុវត្តដោយតួអង្គផ្សេងៗនោះដែរ។ ហេតុនេះការសិក្សាស្រាវជ្រាវដាច់ដោយឡែកមួយផ្សេងទៀត គួរតែត្រូវបានធ្វើការសិក្សាបន្ថែមទៀតក្នុងការវាយតម្លៃពីទិដ្ឋភាពនៃគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ និងការអនុវត្តរបស់ស្ថាប័ននានានៅក្នុងប្រទេសកម្ពុជាផងដែរ។

# ៣. លទ្ធផលនៃការស្រាវជ្រាវ

## ៣.១ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា

នៅក្នុងផ្នែកនេះការយល់ឃើញរបស់ប្រជាជនកម្ពុជាស្ដីពី ជីវភាពរស់នៅប្រចាំថ្ងៃក៏ដូចជាអាទិភាពផ្សេងៗ និងក្ដីកង្វល់របស់ពួកគាត់ត្រូវបានបង្ហាញ។

### ៣.១.១ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើនកាន់តែមានភាពប្រសើរឡើង

ប្រជាជនកម្ពុជាពីរភាគបី (៦៧%) ដែលបានឆ្លើយតបសម្ភាសន៍សម្រាប់ការសិក្សាបានយល់ថាជីវិតរបស់ពួកគាត់បានប្រសើរឡើងក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ[18]។ អ្នកឆ្លើយតបសម្ភាសន៍ជាបុរស (៧០%) ច្រើនជាងស្ត្រី (៦៥%) យល់ឃើញថាគុណភាពនៃជីវភាពរស់នៅរបស់ពួកគាត់ក្នុងរយៈពេល ៥ ឆ្នាំ កន្លងមកមានភាពប្រសើរឡើង។ ជាមួយគ្នានេះដែរក្រុមប្រជាជនដែលមានអាយុពី ១៥-២៤ ឆ្នាំ ចំនួន ៧៣% បានរាយការណ៍ថាគុណភាពនៃជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរឡើងក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះផងដែរ។ ប៉ុន្តែការសិក្សាក៏បង្ហាញផងដែរថាមិនមែនប្រជាជនគ្រប់រូបសុទ្ធតែមានអារម្មណ៍វិជ្ជមានចំពោះជីវភាពរស់នៅរបស់ពួកគាត់បែបនេះទេ។ ស្ថានភាពសេដ្ឋកិច្ច សង្គម (ដែលត្រូវបានវាស់វែងដោយប្រាក់ចំណូល កម្រិតនៃការអប់រំ ឬមុខរបរ) មានទំនាក់ទំនងជាវិជ្ជមានទៅនឹងភាពប្រសើរឡើងនៃជីវភាពរបស់ប្រជាជន។ ឧទាហរណ៍ អ្នកដែលមានសញ្ញាបត្រពីសាកលវិទ្យាល័យហាក់ដូចជាបានរៀបរាប់អំពីការកើនឡើងនូវគុណភាពជីវិតរបស់ពួកគាត់ (៨៦%) ច្រើនជាងអ្នកដែលមិនបានចូលរៀន (៥៣%)។ ស្របពេលដែលប្រទេសកម្ពុជានៅតែបន្តរីកចម្រើនផ្នែកសេដ្ឋកិច្ចដែលមានប្រមាណជា ៧% នៃផលិតផលជាតិសរុបជារៀងរាល់ឆ្នាំ (World Bank, ២០២០) ការសិក្សាបង្ហាញថាមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែទទួលបានផលប្រយោជន៍ស្មើគ្នាពីការរីកចម្រើននេះទេ។ អ្នកតបសម្ភាសន៍ចំនួនមួយភាគបី (៣៣%) បានរាយការណ៍ពីការធ្លាក់ចុះនៃប្រាក់ចំណូលគ្រួសាររបស់ពួកគាត់ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ[19]។

[18] QA2 «បើប្រៀបធៀបទៅ៥ឆ្នាំមុន តើអ្នកគិតថាជីវភាពរស់នៅរបស់អ្នកបានប្រសើរជាងមុន អាក្រក់ជាងមុន ឬនៅដដែល? »
[19] QDE11 «តើចំណូលគ្រួសាររបស់អ្នកមានការផ្លាស់ប្ដូរដូចម្ដេចនាពេល៥ឆ្នាំ កន្លងមកនេះ? »




រូបភាពទី២៖ ស្ថានភាពប្រាក់ចំណូលគ្រួសារ[20] តាមតំបន់ភូមិសាស្ត្រនៃការសិក្សានីមួយៗ[21]

## ៣.១.២ ប្រជាជនកម្ពុជាឲ្យតម្លៃទៅលើសុខភាព និងការអប់រំច្រើនជាងអ្វីៗទាំងអស់[22]

នៅពេលដែលសួរអំពីគុណតម្លៃសំខាន់បំផុតនៅក្នុងជីវិត ប្រជាជនកម្ពុជាបានសង្កត់ធ្ងន់លើបញ្ហាសុខភាព និងការអប់រំ។ ប្រជាជនស្ទើរតែទាំងអស់ (៩៤%) បានរាយការណ៍ថាការថែរក្សាសុខភាពរបស់ខ្លួន និងគ្រួសារឲ្យមានសុខភាពល្អមានសារៈសំខាន់ណាស់សម្រាប់ពួកគាត់ ហើយប្រជាជនចំនួន ៨២% បានលើកឡើងអំពីលទ្ធភាពទទួលបានការអប់រំសម្រាប់ខ្លួនឯង និងសម្រាប់គ្រួសាររបស់ពួកគាត់ជារឿងដែលសំខាន់។ ដោយឡែកប្រជាជនចំនួន ៧៤% បាននិយាយថាការរស់នៅចុះសម្រុងគ្នាជាមួយនឹងមនុស្សនៅជុំវិញខ្លួនគឺជាតម្លៃដ៏សំខាន់មួយផងដែរ។ ទោះជាគុណតម្លៃផ្សេងទៀតដូចជា សមត្ថភាពក្នុងការស្វែងរកប្រាក់ចំណូល (៦៨%) ការគោរពតាមទំនៀមទំលាប់ប្រពៃណី (៦៥%) និងការទទួលស្គាល់ និងការគោរពពីអ្នកដទៃ (៦២%) ហាក់ដូចជាមិនសូវត្រូវបានគេលើកឡើងច្រើនបើធៀបនឹងគុណតម្លៃពីរចំណុចខាងលើ ចំណុចទាំងនេះក៏នៅតែត្រូវបានប្រជាជនភាគច្រើនចាត់ទុកថាវាមានសារៈសំខាន់ផងដែរ។ ប្រជាជនកម្ពុជាតិចជាងពាក់កណ្ដាលគិតថា ការបញ្ចេញមតិទៅលើបញ្ហា ឬក្ដីកង្វល់ដែលពាក់ព័ន្ធនឹងពួកគាត់ (៤៥%) ក៏មានសារៈសំខាន់ប្រហាក់ប្រហែលនឹងការខ្វាយខ្វល់អំពីធម្មជាតិ (៤៣%) ដែរ។ កាលដែលមានទូរស័ព្ទស៊េរីទំនើបចុងក្រោយសម្រាប់ប្រើប្រាស់ គឺជាគុណតម្លៃទាបជាងគេសម្រាប់អ្នកតបសម្ភាសន៍ បើធៀបនឹងគុណតម្លៃដទៃដោយមានត្រឹមតែ ២៤% ប៉ុណ្ណោះដែលបានលើកឡើងពីចំណុចនេះ។

[20] និយមន័យនៃស្ថានភាពប្រាក់ចំណូលនៅក្នុងរបាយការណ៍នេះ៖ អ្នកក្រីក្រខ្លាំង៖ ជាប្រជាជនដែលពិបាកមានលទ្ធភាពទិញម្ហូបអាហារ។ អ្នកក្រីក្រ៖ ជាអ្នកដែលមានលទ្ធភាពទិញចំណីអាហារ និងសម្លៀកបំពាក់តែមិនមានលទ្ធភាពទិញសម្ភារ/ឧបករណ៍ប្រើប្រាស់ថ្លៃៗ។ អ្នកធូរធារ៖ ជាអ្នកដែលអាចមានលទ្ធភាពទិញសម្ភារ/ឧបករណ៍ប្រើប្រាស់ថ្លៃៗបានលើកលែងតែផ្ទះ។ អ្នកមាន៖ ជាអ្នកដែលអាចមានលទ្ធភាពទិញរបស់របរបានគ្រប់យ៉ាងរួមទាំងផ្ទះជាដើម។

[21] ទិន្នន័យដែលមានតម្លៃតូចជាង ៥% មិនអាចបង្ហាញឲ្យឃើញលើក្រាហ្វិកបានទេដោយសារតែការកំណត់ស្រាប់របស់ការរចនានៃក្រាហ្វិក

[22] QA1 «មនុស្សគ្រប់គ្នាមានគុណតម្លៃនិងជំនឿផ្សេងៗគ្នា។ ខាងក្រោមនេះជាបញ្ជីគុណតម្លៃដែលមនុស្សផ្សេងៗគ្នាបាននិយាយថាមានសារៈសំខាន់សម្រាប់ពួកគាត់។ ចំពោះគុណតម្លៃនីមួយៗ តើមានសារៈសំខាន់ ឬមិនសំខាន់ដូចម្ដេចសម្រាប់អ្នក? »




រូបភាពទី ៣៖ គុណតម្លៃដែលមានសារៈសំខាន់សម្រាប់ប្រជាជនកម្ពុជា

## ៣.១.៣ ការថែរក្សាសុខភាពឲ្យបានល្អគឺកត្តាជំរុញទឹកចិត្តចម្បងរបស់ប្រជាជន[23]

លទ្ធផលនៃការសិក្សាអំពីក្តីកង្វល់នេះមិនមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ហើយវាស្របគ្នាទៅនឹងគុណតម្លៃដែលបានពិភាក្សាក្នុងផ្នែកខាងលើផងដែរ។ សុខភាពមិនល្អ គឺជាក្តីកង្វល់ចម្បងដ៏ធំបំផុតរបស់ប្រជាជនកម្ពុជាប្រមាណ ២៤%។ ការសិក្សាអាកាសធាតុអាស៊ីក្នុងឆ្នាំ២០១៩ក៏បានបង្ហាញថា (២៥%) នៃអ្នកឆ្លើយតបសម្ភាសន៍យល់ថា ការរាតត្បាតបញ្ហាជំងឺ Covid-19 ហាក់ដូចជាមិនមានឥទ្ធិពលលើកម្រិតនៃការព្រួយបារម្ភអំពីសុខភាព។ បញ្ហាមិនមានការងារធ្វើគឺជាក្តីបារម្ភចម្បងរបស់ប្រជាជនកម្ពុជាដែលក្នុងនោះ ២០% នៃអ្នកតបសម្ភាសន៍បានលើកឡើងពីបញ្ហានេះ។ បន្ទាប់មកបញ្ហាមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការឲ្យកូនៗទទួលបានការអប់រំ ឬការសន្សំលុយឲ្យបានគ្រប់គ្រាន់សម្រាប់អនាគតជាក្តីកង្វល់ធំសម្រាប់អ្នកតបសម្ភាសន៍ចំនួន ១៩% ។

ការព្រួយបារម្ភរបស់ប្រជាជនកម្ពុជាឆ្លុះបញ្ចាំងពីផ្នត់គំនិតយេនឌ័របែបប្រពៃណីផងដែរ។ ស្ត្រីហាក់ដូចជាមានការព្រួយបារម្ភច្រើនអំពីសុខភាព សុខុមាលភាពគ្រួសារ និងការអប់រំរបស់កូនៗ រីឯបុរសវិញមានការព្រួយបារម្ភច្រើនចំពោះការទ្រទ្រង់ជីវភាពគ្រួសារ។ លទ្ធផលសិក្សានេះមានលក្ខណៈដូចគ្នានឹងការសិក្សាស្រាវជ្រាវពីមុនដែរ ដែលបុរស និងស្ត្រីបានបង្ហាញពីអាទិភាពខុសគ្នាបន្តិចបន្តួចរបស់ពួកគាត់ (Sao, Gowland, Kim, Hor & Ratan, ២០២០)។

---

[23] QA3a «បញ្ហាខាងក្រោមនេះ តើអ្វីជាក្តីកង្វល់ធំបំផុតរបស់អ្នកនាពេលបច្ចុប្បន្ន? »

## ៣.២ ការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ (ការយល់ដឹង)

នៅក្នុងផ្នែកនេះ ការពិនិត្យមើលអំពីការយល់ឃើញរបស់ប្រជាជនកម្ពុជាស្តីពីការប្រែប្រួលនានាក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយនេះពាក់ព័ន្ធនឹងលទ្ធភាពប្រើប្រាស់ធនធាន ការទាញយកធនធានធម្មជាតិ និងធាតុអាកាស រួមបញ្ចូលទាំងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរផងដែរត្រូវបានលើកយកពិភាក្សា។ ប្រជាជនកម្ពុជាភាគច្រើនជឿថា លទ្ធភាពទទួលបានធនធានសំខាន់ៗរបស់ពួកគាត់មានភាពប្រសើរឡើងនាពេល ១០ឆ្នាំ ចុងក្រោយនេះ ប៉ុន្តែបរិស្ថានធម្មជាតិកំពុងទទួលរងនូវការធ្លាក់ចុះ ហើយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរក៏តែងតែកើតមានឡើងក្លាយជារឿងធម្មតាដែរ។

### ៣.២.១ ការប្រែប្រួលនានានៃធនធានដែលមានស្រាប់

អ្នកតបសម្ភាសន៍ជិតពាក់កណ្តាល (៤៥%) យល់ថាលទ្ធភាពទទួលបានទឹកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងបរិភោគមានការកើនឡើងនៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។[24] ខណៈពេលដែលលទ្ធផលខាងដើមនេះបានឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា អ្នកតបសម្ភាសន៍ចំនួន ២៧% ផ្សេងទៀតជឿជាក់ថាលទ្ធភាពទទួលបានទឹកសម្រាប់ប្រើប្រាស់មានការថយចុះក្នុងរយៈពេលដូចគ្នានេះ ជាពិសេសអ្នកតបសម្ភាសន៍ចំនួន ១៣% យល់ថាលទ្ធភាពទទួលបានទឹកប្រើប្រាស់មានការធ្លាក់ចុះយ៉ាងខ្លាំងបំផុត។ ការយល់ឃើញអំពីការថយចុះនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ជាទូទៅត្រូវបានលើកឡើងដោយប្រជាជននៅតំបន់ជនបទ (៣០%) ច្រើនជាងប្រជាជននៅតំបន់ទីក្រុង/ប្រជុំជន (២៣%) ជាពិសេសក្នុងចំណោមកសិករ អ្នកនេសាទ និងក្រុមប្រជាជនដែលយល់ថារបបទឹកភ្លៀងបានថយចុះ។ ប្រជាជនរស់នៅតាមតំបន់ឆ្នេរ (២៦%) និងតំបន់ភ្នំ (៣៣%) ហាក់ដូចជាមិនសូវបានលើកឡើងពីភាពប្រសើរឡើងនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់នោះទេ។ លទ្ធផលនេះផ្ទុយស្រឡះពីប្រជាជនដែលរស់នៅតំបន់ទីក្រុង/ប្រជុំជនដែលមានប្រជាជនចំនួន ៥៨% បានរាយការណ៍អំពីលទ្ធភាពទទួលបានទឹកប្រើប្រាស់។

#### ករណីសិក្សាទី១៖ការស្វែងយល់ពីលទ្ធភាពទទួលបានទឹកប្រើប្រាស់នៅទីជនបទ

ដើម្បីដោះស្រាយបញ្ហាកង្វះខាតទឹកប្រើប្រាស់ ប្រជាជននៅតាមទីជនបទនៃប្រទេសកម្ពុជាបានលើកឡើងថា ជាធម្មតាពួកគាត់បានត្រងទឹកភ្លៀងដើម្បីស្តុកទឹកទុកក្នុងពាង ឬធុងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ប៉ុន្តែវានៅតែមិនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ពួកគាត់នោះទេ។ ហេតុនេះពួកគាត់បានរាយការណ៍ពីការលំបាកនានាក្នុងការទទួលបានទឹកស្អាត និងមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ ជាពិសេសក្នុងគ្រាមានទឹកជំនន់ និងគ្រោះរាំងស្ងួត។ ខាងក្រោមនេះជាឧទាហរណ៍មួយចំនួន ដែលប្រជាជនរស់នៅតំបន់ភូមិសាស្ត្រផ្សេងៗគ្នានៃប្រទេសកម្ពុជាបានលើកឡើងពីឧបសគ្គ និងកត្តាជំរុញទឹកចិត្តស្តីពីលទ្ធភាពទទួលបានទឹកប្រើប្រាស់។ ឧទាហរណ៍ទាំងនេះត្រូវបានលើកឡើងដោយអ្នកតបសម្ភាសន៍ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ។

---

[24] QB1. «ខ្ញុំចង់សួរអ្នកអំពីបញ្ហាសង្គម និងបរិស្ថានដែលបានប៉ះពាល់ជីវភាពរស់នៅរបស់អ្នក។ ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយ តើអ្នកយល់ថាបញ្ហាខាងក្រោមនេះមានការកើនឡើង នៅដដែល ឬថយចុះ?»

**តំបន់ភ្នំ - ខេត្តកំពង់ស្ពឺ**

- ទឹកសាបពីទំនប់ត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយអ្នកភូមិម្នាក់ដែលត្រូវបានចាត់តាំងជាអ្នកយាមទ្វារទឹក។ អ្នកភូមិជូនដំណឹងទៅមេភូមិ ឬប្រជាការពារភូមិនៅពេលដែលពួកគាត់ត្រូវការទឹកពីទំនប់សម្រាប់ប្រើប្រាស់ បន្ទាប់ពីអ្នកយាមទ្វារទឹកទទួលបានដំណឹងនេះគេនឹងចាត់វិធានការ។ ជាទូទៅប្រជាជននៅក្នុងតំបន់នេះសប្បាយចិត្តចំពោះការគ្រប់គ្រងទឹកសម្រាប់ការប្រើប្រាស់ជាសាធារណៈនៅក្នុងតំបន់របស់ពួកគាត់។ ទោះយ៉ាងណាក៏ដោយ ក៏មានករណីខ្លះត្រូវបានគេរាយការណ៍ថាកន្លែងមួយចំនួនដែលប្រជាជនអាចមានលទ្ធភាពទទួលបានទឹកស្អាតផ្គត់ផ្គង់ ឬអាចបូមទឹកអណ្តូងនៅក្នុងភូមិរបស់ពួកគាត់ជួនកាលក៏មានជម្លោះពីការប្រើប្រាស់ទឹកផងដែរ។ ជាក់ស្តែងមានករណីមួយបានកើតឡើង ដោយមានអណ្តូងទឹកមួយដែលត្រូវបានបរិច្ចាគដោយអង្គការមួយ ប៉ុន្តែត្រូវបានម្ចាស់ដីមិនអនុញ្ញាតឲ្យអ្នកភូមិផ្សេងទៀតប្រើប្រាស់ និងទុកអណ្តូងទឹកនោះសម្រាប់តែការប្រើប្រាស់ក្នុងគ្រួសារខ្លួនឯងប៉ុណ្ណោះ។
- ក្នុងករណីផ្សេងទៀត អ្នកភូមិខ្លះបានរាយការណ៍ថាទឹកអណ្តូងមិនស្អាត និងមានផ្ទុកសារជាតុពុលដែលពួកគាត់ជឿថាអាចប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ។ អ្នកភូមិយល់ថាគុណភាពទឹកក្រោមដីនៅក្នុងតំបន់របស់ពួកគាត់ត្រូវបានបំផ្លាញដោយចម្ការអំពៅក្បែរនោះដោយសារតែចម្ការមានការប្រើប្រាស់ជីគីមីច្រើន។

  *«មានទំនប់ចំនួនបី និងទន្លេធំពីរនៅក្នុងស្រុករបស់ខ្ញុំបូករួមទាំងអណ្តូងស្នប់ អណ្តូងលូ និងស្រះនៅក្នុងសហគមន៍ដែលអាចផ្តល់ទឹកគ្រប់គ្រាន់សម្រាប់ប្រជាជនអំឡុងពេលគ្រោះរាំងស្ងួត និងមានទឹកភ្លៀងតិច»*។ នេះជាការលើកឡើងដោយស្ត្រីជាអភិបាលរងស្រុកនៅក្នុងខេត្តកំពង់ស្ពឺ

**តំបន់ឆ្នេរ - ខេត្តកំពត**

- ប្រជាជនមួយចំនួននៅក្នុងតំបន់នេះមានលទ្ធភាពទទួលបានទឹកសាបប្រើប្រាស់ពីទំនប់ ដែលកំពុងសាងសង់ និងត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយក្រុមហ៊ុនឯកជនមួយ។ ប្រជាជនបង្ហាញពីក្តីកង្វល់អំពីការគ្រប់គ្រងទឹកពីទំនប់នេះនាពេលអនាគត ជាពិសេសនៅពេលដែលទឹកក្រោមដីលែងមាន ហើយពួកគាត់ជីកអណ្តូងសម្រាប់យកទឹកប្រើប្រាស់ ប៉ុន្តែទឹកមានជាតិប្រៃ ហើយមិនអាចបរិភោគបាន។
- តំបន់ទឹកប្រៃមួយចំនួនត្រូវបានគ្រប់គ្រងដោយអាជ្ញាធរ និងសហគមន៍ដើម្បីអភិរក្សធនធានជលផល។
- នៅក្នុងតំបន់នេះក៏មានការផ្តួចផ្តើមគំនិតប្រកបដោយប្រសិទ្ធភាពរវាងអាជីវករក្នុងស្រុក និងសមាជិកសហគមន៍ដើម្បីគ្រប់គ្រងលទ្ធភាពទទួលបានទឹកប្រើប្រាស់ដែរ។ ឧទាហរណ៍ អាជីវករក្នុងស្រុកបានជីកស្រះទឹកសម្រាប់សហគមន៍ ហើយជាថ្នូរពួកគាត់ទទួលបានអាចម៍ដីយកទៅលក់។

**តំបន់ទន្លេសាប - ខេត្តកំពង់ធំ**

- ការស្រាវជ្រាវបានរកឃើញអំពីទំនាស់ក្នុងការប្រើប្រាស់ទឹករបស់កសិកររស់នៅក្នុងតំបន់នេះពាក់ព័ន្ធនឹងការចែកចាយទឹកសម្រាប់ការងារកសិកម្ម។ ប្រជាជនដែលរស់នៅផ្នែកខ្សែទឹកខាងក្រោមក្នុងតំបន់នេះមិនបានទទួលទឹកគ្រប់គ្រាន់ដើម្បីស្រោចស្រពលើដីស្រែរបស់ពួកគាត់ទេបើធៀបទៅនឹងប្រជាជនដែលរស់នៅក្បែរផ្នែកខ្សែទឹកខាងលើ។ លើសពីនេះទៀតដីស្រែប្រមាណ ១.០០០ ហិកតា ដែលជាដីកម្មសិទ្ធឯកជន និងមានទីតាំងនៅក្បែរប្រឡាយមេបានប្រើប្រាស់ទឹកនោះភាគច្រើន។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានមិនអាចដោះស្រាយបញ្ហានេះបានទេ។ ដំណោះស្រាយមានតែការជីកអណ្តូងទេដែលអាចធ្វើឲ្យអ្នកភូមិទទួលបានទឹកសាបប្រើប្រាស់ផ្ទាល់ខ្លួន ប៉ុន្តែពួកគាត់ត្រូវចំណាយធនធាន ប្រើប្រាស់កម្លាំងពលកម្មផ្ទាល់ខ្លួន និងខ្ចីបុលគេដើម្បីបានទឹកប្រើប្រាស់។

- ដើម្បីដោះស្រាយបញ្ហាទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ សមាជិកសហគមន៍ពេលខ្លះត្រូវទិញទឹកសម្រាប់ប្រើប្រាស់ ដែលកត្តានេះបានជះឥទ្ធិពលអវិជ្ជមានដល់ចំណូលគ្រួសាររបស់ពួកគាត់។

**តំបន់វាលទំនាប - ខេត្តព្រៃវែង**

- ប្រជាជននៅក្នុងតំបន់នេះត្រងទឹកភ្លៀងទុក និងបូមទឹកពីអណ្តូងស្នប់របស់ពួកគាត់សម្រាប់ប្រើប្រាស់។ ទោះបីមានអណ្តូងជាច្រើននៅទីនេះក៏ដោយក៏ប្រជាជនបានរាយការណ៍ថា ពួកគាត់មានការលំបាកក្នុងការទទួលបានទឹកសម្រាប់ប្រើប្រាស់ដោយសារកង្វះការផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីគ្រោះរាំងស្ងួត និងទឹកភ្លៀងមិនមានគ្រប់គ្រាន់។
- ប្រជាជននៅតំបន់នេះក៏បានកោតសរសើរដល់រដ្ឋាភិបាលដែលបានសាងសង់ប្រព័ន្ធធារាសាស្ត្រ (បន្ថែមពីលើទន្លេក្នុងតំបន់ដែលពួកគាត់អាចប្រើប្រាស់បាន) ព្រោះវាបានជួយពួកគាត់ក្នុងការធ្វើការងារកសិកម្មដាំដុះបាន។ មេឃុំ និងមេភូមិមានតួនាទីចែកចាយទឹកពីប្រព័ន្ធធារាសាស្ត្រទាំងនេះ ជាពិសេសគឺនៅរដូវប្រាំង។ លទ្ធភាពទទួលបានទឹកសម្រាប់ប្រើប្រាស់នៅក្នុងតំបន់នេះគឺប្រសើរជាងកាលពីមុន។ ទោះយ៉ាងណាក៏ដោយគ្រួសារក្រីក្រនៅតែពិបាកក្នុងការទទួលបានទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់។

អ្នកឆ្លើយតបសម្ភាសន៍លើសពាក់កណ្តាល (៥១%) យល់ថាមានការកើនឡើងនូវលទ្ធភាពទទួលបានចំណីអាហារដែលមានតម្លៃសមរម្យក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ។ អ្នកឆ្លើយតបសម្ភាសន៍ ៥០% យល់ថាមានការកើនឡើងនូវប្រភេទអាហារ និងប្រភេទបន្លែជាច្រើនក្នុងរយៈពេលដូចគ្នានេះ។ អ្នករស់នៅទីក្រុងភ្នំពេញ (៦៤%) និងតំបន់ខ្ពង់រាប (៥៨%) និងអ្នកមានជីវភាពសមរម្យ (៦១%) ហាក់ដូចជាជឿជាក់ថាមានការកើនឡើងនូវលទ្ធភាពទទួលបានអាហារដែលមានតម្លៃ សមរម្យច្រើនជាងអ្នកដែលរស់នៅនៅតំបន់ឆ្នេរ (៣៣%) និងតំបន់ភ្នំ (៣៩%)។ បើទោះជាប្រជាជនជាច្រើនយល់ថាមានការកើនឡើងនូវលទ្ធភាពទទួលបានចំណីអាហារ ប៉ុន្តែលទ្ធផលសិក្សាក៏បានបង្ហាញថាមានការថយចុះនៃលទ្ធភាពដែលអាចរកត្រីបាន។ ប្រជាជនបួននាក់ក្នុងចំណោមប្រាំនាក់ (៧៩%) គិតថាលទ្ធភាពទទួលបានត្រីធម្មជាតិបរិភោគមានការថយចុះក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ ហើយអ្នកតបសម្ភាសន៍បីនាក់ក្នុងចំណោមប្រាំនាក់ (៥៩%) យល់ថាមានការថយចុះយ៉ាងខ្លាំងនៃធនធាននេះ។ នេះគឺជាក្តីកង្វល់ដ៏ធំមួយនៅក្នុងសង្គមដែលត្រីគឺជាប្រភពអាហារប្រូតេអ៊ីនដ៏សំខាន់បំផុតសម្រាប់មនុស្សភាគច្រើន។

លទ្ធផលសិក្សាដែលប្រើប្រាស់ការស្រាវជ្រាវបែបគុណវិស័យបានរកឃើញថា ត្រីគឺជាប្រភពចំណូល និងអាហារសំខាន់មួយសម្រាប់អ្នកនេសាទនៅតំបន់ឆ្នេរ។ ទាំងបុរស និងស្ត្រីបានបង្ហាញពីការព្រួយបារម្ភអំពីការថយចុះនូវទិន្នផលត្រីធម្មជាតិដោយសារតែសីតុណ្ហភាពកាន់តែក្តៅជាងមុន (ពួកគាត់បាននិយាយថាត្រីបានរត់ចូលទៅក្នុងទឹកជ្រៅដើម្បីរកទឹកត្រជាក់)។ ពួកគាត់ក៏មានការព្រួយបារម្ភអំពីខ្យល់ព្យុះដែលកើតឡើងកាន់តែធ្ងន់ធ្ងរជាងមុន និងពេលខ្លះបានរារាំងពួកគាត់មិនឲ្យចេញទៅនេសាទបានទៀតផង។

*«ទឹកជំនន់បានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ទំនប់ ប្រឡាយ និងផ្លូវថ្នល់ និងបំផ្លាញដំណាំស្រូវ។ ម្យ៉ាងទៀតភាពរាំងស្ងួត និងការកើនឡើងសីតុណ្ហភាពជំរុញឲ្យមានការថយចុះនៃផលត្រី»*។ លើកឡើងដោយបុរសជាមេភូមិ ខេត្តព្រៃវែង

នៅតាមតំបន់ជនបទការស្រាវជ្រាវបែបគុណវិស័យបានរកឃើញថា ប្រជាជនបានរាយការណ៍ពីលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានអាហារនិងបន្លែសម្រាប់បរិភោគនារដូវវស្សា ដែលអាចជួយពួកគាត់ក្នុងការសន្សំប្រាក់ដោយមិនចាំបាច់ទិញអាហារពីផ្សារបានខ្លះដែរ។ ផ្ទុយទៅវិញប្រជាជនក៏យល់ថាពួកគាត់ពឹងផ្អែកកាន់តែខ្លាំងឡើងលើការទិញចំណីអាហារពីផ្សារក្នុងរដូវប្រាំង។ ពេលខ្លះពួកគាត់មានការព្រួយបារម្ភអំពីការបរិភោគម្ហូបអាហារទាំងនេះព្រោះពួកគាត់ជឿថាបន្លែដែលនាំចូលពីប្រទេសក្រៅ ជាពិសេសពីប្រទេសវៀតណាមបានប្រើប្រាស់គីមីក្នុងកម្រិតខ្ពស់។

*«នៅរដូវប្រាំងពួកយើងមួយចំនួនបានទិញទឹកសម្រាប់ប្រើប្រាស់ និងបរិភោគនៅក្នុងគ្រួសារក៏ដូចជាទិញម្ហូបអាហារផងដែរពីព្រោះយើងមិនអាចរកត្រី និងដាំបន្លែដោយខ្លួនឯងបានដោយសារទឹកមិនគ្រប់គ្រាន់។ ដូច្នេះយើងត្រូវតែមានការចំណាយបន្ថែមស្របពេលដែលពួកយើងមានការខ្វះខាតប្រាក់ និងមានប្រាក់ចំណូលមិនទៀងទាត់។» លើកឡើងដោយអ្នកចូលរួមក្នុងក្រុមពិភាក្សាជាបុរសនៅក្នុងខេត្តកំពង់ស្ពឺ*

ទាក់ទងនឹងការប្រើប្រាស់ថាមពល អ្នកតបសម្ភាសន៍បីភាគបួន (៧៧%) បានរាយការណ៍អំពីការកើនឡើងនៃការប្រើប្រាស់អគ្គិសនី (សាធារណៈ ឬឯកជន) នៅក្នុងសហគមន៍របស់ពួកគាត់ក្នុងរយៈពេល ១០ ឆ្នាំ កន្លងមក។ ជាពិសេសលទ្ធផលនេះក៏ត្រូវបានគេរកឃើញនៅតំបន់ទីក្រុង/ប្រជុំជន (៧៨%) និងជនបទ (៧៧%) បើទោះបីជាលទ្ធផលនេះត្រូវបានគេរាយការណ៍ភាគច្រើនដោយអ្នកដែលមានជីវភាពមធ្យម (៨៣%) ច្រើនជាងប្រជាជនក្រីក្រ (៧៤%) ក៏ដោយ។ អ្នកតបសម្ភាសន៍ច្រើនជាងពាក់កណ្តាល (៥៩%) ក៏បានរាយការណ៍ផងដែរថាមានការកើនឡើងនូវការប្រើប្រាស់ប្រេងឥន្ធនៈ ដែលមានតម្លៃសមរម្យសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ លទ្ធផលនេះក៏បានរាយការណ៍ដោយអ្នកដែលមានជីវភាពប្រសើរ (៦៨%) ច្រើនជាងអ្នកមានជីវភាពក្រីក្រ (៥៣%) ដែរ ហើយលទ្ធផលនេះត្រូវបានរាយការណ៍ស្រដៀងគ្នារវាងប្រជាជននៅតំបន់ទីក្រុង/ប្រជុំជន (៥៨%) និងជនបទ (៦០%) ផងដែរ។

ទោះបីជាលទ្ធភាពជារួមស្តីពីការប្រើប្រាស់អគ្គិសនី និងប្រេងឥន្ធនៈត្រូវបានគេរាយការណ៍ថា មានការកើនឡើងក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះក៏ដោយ ក៏ប្រជាជនដែលរស់នៅឆ្ងាយពីផ្លូវធំៗនៅតាមតំបន់ជនបទបានលើកឡើងក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យថា ពួកគាត់នៅតែប្រឈមនឹងបញ្ហាខ្វះលទ្ធភាពប្រើប្រាស់/ទទួលបានធនធានទាំងនេះដែរ។ ពួកគាត់ជួបនឹងការលំបាកក្នុងការតភ្ជាប់បណ្តាញ ឬមិនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ចំណាយលើសេវាកម្មនៃការដំឡើងដំបូង។ ឧទាហរណ៍៖ អ្នកតបសម្ភាសន៍នៅតាមជនបទមួយចំនួនបាននិយាយថាពួកគាត់ចំណាយទឹកប្រាក់ប្រមាណ ១៥-២០ ដុល្លារអាមេរិក រីឯអ្នកផ្សេងទៀតចំណាយត្រឹមតែ ៥-៩ ដុល្លារអាមេរិក ក្នុងមួយខែលើថ្លៃអគ្គិសនីនេះ។ បើទោះបីជាមានការកើនឡើងនូវលទ្ធភាពប្រើប្រាស់អគ្គិសនី ដែលធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបាននូវតម្រូវការជាមូលដ្ឋានយ៉ាងណាក៏ដោយ ក៏វាអាចបង្កើតសម្ពាធផ្នែកហិរញ្ញវត្ថុបន្ថែមទៀតសម្រាប់គ្រួសារមួយចំនួនផងដែរ។




រូបភាពទី ៤៖ ការយល់ឃើញពីការប្រែប្រួលលទ្ធភាពទទួលបានធនធាននានា

## ៣.២.២ ការប្រែប្រួលនានានៃបរិស្ថានធម្មជាតិ

ជីវភាពរស់នៅ និងលទ្ធភាពទទួលបានធនធានសំខាន់ៗរបស់ប្រជាជនកម្ពុជាមានភាពប្រសើរឡើងនៅក្នុងទសវត្សរ៍កន្លងមកនេះ បើផ្អែកតាមការយល់ឃើញរបស់ប្រជាជនកម្ពុជា។ ប៉ុន្តែការយល់ឃើញរបស់ពួកគាត់ចំពោះការប្រែប្រួលបរិស្ថានធម្មជាតិមានភាពផ្ទុយគ្នាពីការយល់ឃើញខាងលើ។ អ្នកឆ្លើយតបសម្ភាសន៍ប្រមាណជិតបីភាគបួន (៧៣%) បានយល់ថាមានការថយចុះនូវចំនួនដើមឈើ[25] និងអ្នកឆ្លើយតបសម្ភាសន៍ប្រមាណ ៧១% យល់ថាមានការថយចុះនូវភាពចម្រុះនៃពូជសត្វព្រៃ និងបក្សីក្នុងអំឡុងមួយទសវត្សរ៍កន្លងមក។ ការធ្លាក់ចុះធនធានទាំងពីរនេះត្រូវបានរាយការណ៍កាន់តែច្រើនឡើងដោយប្រជាជនដែលរស់នៅតំបន់ជនបទ ហើយជិតពីរភាគបី (៦៤%) នៃអ្នកឆ្លើយតបសម្ភាសន៍ យល់ថាមានការថយចុះនៃពូជត្រីក្នុងអំឡុងពេលដូចគ្នានេះដែរ។ ពួកគាត់ភាគច្រើន (៦៩%) ក៏បានគិតថាសត្វល្អិតចង្រៃដូចជា រុយ និងមូសបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ។

[25] QC1. «បន្ទាប់មកទៀត ខ្ញុំនឹងសួរអំពីការយល់ឃើញពីការប្រែប្រួលផ្នែកសង្គម និងបរិស្ថាន។ ក្នុងសហគមន៍របស់អ្នកតើសកម្មភាពខាងក្រោមនេះមានការកើនឡើង ថយចុះ ឬនៅដដែល ក្នុងអំឡុងពេល១០ឆ្នាំ ចុងក្រោយនេះ។



បុរសម្នាក់កំពុងតែរែកត្រី ស្ថិតនៅតំបន់ឆ្នេរសមុទ្រ។ ការនេសាទត្រីសមុទ្រជាមុខរបរមួយយ៉ាងសំខាន់សម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាជននៅក្នុងតំបន់នោះ។

អ្នកឆ្លើយតបសម្ភាសន៍ប្រមាណ ៦១% គិតថាបរិមាណសំរាម និងប្លាស្ទិកបានកើនឡើងនាពេល ១០ ឆ្នាំ ចុងក្រោយនេះដែលភាគច្រើនគឺជាអ្នកដែលរស់នៅក្នុងតំបន់ទីក្រុង/ប្រជុំជន (៦៧%) និងអ្នករស់នៅរាជធានីភ្នំពេញ (៧៩%)។ ការបំពុលខ្យល់ក៏បានកើនឡើងផងដែរ បើយោងទៅតាមអ្នកឆ្លើយតបសម្ភាសន៍ប្រមាណ ៤២% ជាពិសេសប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញ (អ្នកឆ្លើយតប ៦១% ដែលបានលើកឡើងពីបញ្ហានេះ)។ ក្នុងអំឡុងពេលសម្ភាសន៍ជាមួយអ្នកធ្វើការក្នុងវិស័យឯកជន អ្នកសារព័ត៌មាន និងតំណាងភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាល ពួកគេជាច្រើនបានសង្កេតឃើញថាបរិមាណប្លាស្ទិកនិងសំរាមត្រូវបានសាយភាយចូលទៅក្នុងទន្លេមេគង្គ ដែលធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកនិងត្រីដែលចំណុចនេះបណ្តាលមកពីកង្វះការយល់ដឹង និង បច្ចេកទេសក្នុងការគ្រប់គ្រងកាកសំណល់។




រូបភាពទី ៥៖ ការយល់ឃើញពីការប្រែប្រួលបរិស្ថាន[26]

## ៣.២.៣ ការប្រែប្រួលនៃរបបធាតុអាកាស

ប្រទេសកម្ពុជាបានជួបប្រទះនូវការប្រែប្រួលនៃរបបធាតុអាកាសធ្ងន់ធ្ងររួចមកហើយដែលវាបានកើតឡើងនៅមុនការចេញផ្សាយនៃរបាយការណ៍នេះទៅទៀត។ ការសិក្សាក្នុង KAP៣ នេះបានរកឃើញថាប្រជាជនកម្ពុជា រហូតដល់ ៦៩% យល់ឃើញថាមានការថយចុះនៃបរិមាណទឹកភ្លៀងនៅក្នុងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ[27]។ អ្នកនេសាទ និងកសិករ (៧៤%) និងប្រជាជនដែលរស់នៅតាមតំបន់ទន្លេសាប (៧៥%) និងតំបន់ភ្នំ (៧៤%) ហាក់ដូចជាមានការយល់ឃើញថាមានការថយចុះនៃរបបទឹកភ្លៀងច្រើនជាងអ្នកដែលរស់នៅតាមតំបន់ឆ្នេរ (មានត្រឹមតែ៤៧%)។

ប្រជាជនដែលបានរាយការណ៍អំពីការថយចុះនូវរបបទឹកភ្លៀងនេះមានចំនួនប្រហាក់ប្រហែលនឹងចំនួនប្រជាជន (៧៤%) ដែលបានរាយការណ៍អំពីការកើនឡើងនៃសីតុណ្ហភាពក្នុងរយៈពេលទសវត្សរ៍កន្លងមក។ ប្រជាជននៅរាជធានីភ្នំពេញ (៨៥%) និងតំបន់ទន្លេសាប (៨០%) សង្កេតឃើញថាមានការកើនឡើងនៃសីតុណ្ហភាពច្រើនជាងប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរ (មានតែ៥៦%)។

---

[26] នៅពេលដែលទិន្នន័យបូកទៅមិនគ្រប់១០០% ទិន្នន័យដែលបាត់នោះគឺសំដៅលើ «មិនដឹង» ឬ «បដិសេធមិនឆ្លើយ»។

[27] QC2 «នៅក្នុងតំបន់ដែលអ្នករស់នៅក្នុងរយៈពេល១០ឆ្នាំ ចុងក្រោយ តើសកម្មភាពខាងក្រោមនេះមានការកើនឡើង នៅដដែល ឬថយចុះ? »



ស្ត្រីជាកសិករម្នាក់កំពុងដើរក្នុងវាលស្រែស្ងួតហែង ស្ថិតក្នុងតំបន់ទន្លេសាប។ ដំណាំស្រូវបានជួបនូវការគំរាមកំហែងនៅពេលដែលទឹកភ្លៀងធ្លាក់មិនគ្រប់គ្រាន់។

ការប្រែប្រួលជាក់ស្តែងនៃរបបទឹកភ្លៀង និងសីតុណ្ហភាពក៏ជំរុញឲ្យមានការយល់ឃើញអំពីការកើនឡើងនៃគ្រោះរាំងស្ងួត និងទឹកជំនន់ផងដែរ។ ជាងមួយភាគបីនៃប្រជាជន (៣៦%) បានគិតថាភាពរាំងស្ងួត និងកង្វះខាតទឹកមានការកើនឡើងក្នុងមួយទសវត្សរ៍ចុងក្រោយ ជាពិសេសអ្នកដែលរស់នៅតាមតំបន់ទន្លេសាប (៤៥%) និងតំបន់ភ្នំ (៤១%)។ ប្រជាជនក្រីក្រ (៤០%) និងអ្នកនេសាទ និងកសិករ (៤៣%) បានរាយការណ៍អំពីបញ្ហានៃការកើនឡើងនូវគ្រោះរាំងស្ងួតច្រើនជាងអ្នកឆ្លើយតបសម្ភាសន៍ផ្សេងៗទៀត។ លើសពីនេះទៀតប្រជាជនកម្ពុជាប្រមាណ ៥៤% យល់ថាទឹកជំនន់បានថយចុះដោយក្នុងនោះប្រជាជនរស់នៅតំបន់បឹងទន្លេសាបភាគច្រើន (៧១%) បានរាយការណ៍អំពីរឿងនេះ។ ក្រៅពីនេះប្រជាជនប្រហែលពាក់កណ្តាលយល់ថាមានការកើនឡើងនៃខ្យល់កន្ត្រាក់ និងព្យុះ (៤៥%) និងផ្គររន្ទះ (៥០%) ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ។

ការយល់ឃើញនានាអំពីការប្រែប្រួលនៃរបបធាតុអាកាស គឺមានភាពស្របគ្នាទៅនឹងការព្យាករណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែរដោយក្នុងនោះ សីតុណ្ហភាពទំនងជានឹងបន្តកើនឡើង ហើយភាពមិនទៀងទាត់នៃរបបទឹកភ្លៀងនឹងកាន់តែធ្ងន់ធ្ងរ និងខុសប្រក្រតី។ គេរំពឹងថាប្រជាជនកម្ពុជានឹងប្រឈមមុខរដូវប្រាំងកាន់ដែលកាន់តែក្តៅ និងគ្រោះរាំងស្ងួតខ្លាំងកាន់តែយូរ ចំណែកឯរដូវវស្សានឹងកាន់តែខ្លី និងកាន់តែមានបាតុភូតធម្មជាតិធ្ងន់ធ្ងរ (NCDDS, ២០១៧)។




រូបភាពទី ៦៖ ការយល់ឃើញពីការប្រែប្រួលធាតុអាកាសតាមតំបន់ភូមិសាស្ត្រនីមួយៗ (% នៃការកើនឡើង)

## ៣.៣ ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ

នៅពេលដែលសួរអ្នកឆ្លើយតបសម្ភាសន៍ថាតើពួកគាត់ធ្លាប់បានឮវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ»[28] ដែរឬទេ អ្នកឆ្លើយតបសម្ភាសន៍ជិតបីភាគបួន (៧២%)[29] បាននិយាយថាពួកគាត់ធ្លាប់ឮវាក្យសព្ទនេះ ដោយក្នុងនោះបុរសមានចំនួន ៧៣% និងស្ត្រី ៧១%។ ពេលស្វែងយល់បន្ថែមអំពីកម្រិតនៃការយល់ដឹងរបស់ពួកគាត់អំពីវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ» នេះ លទ្ធផលបានបង្ហាញថា មានតែប្រជាជនមួយភាគបី (៣៣%) ប៉ុណ្ណោះបាននិយាយថាពួកគាត់បានដឹងពីអត្ថន័យ/យល់វាក្យសព្ទនេះ ដោយឡែកប្រជាជនចំនួន ៣៩% ទៀតដែលធ្លាប់បានឮវាក្យសព្ទនេះមិនបានដឹងពីអត្ថន័យ/យល់របស់វានោះទេ។ ប្រជាជនដែលមានកម្រិតអប់រំខ្ពស់អាចយល់ដឹងអំពីអត្ថន័យនៃវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ» នេះ

[28] QK1a ‘តើអ្នកធ្លាប់ឮឃ្លា «ការប្រែប្រួលអាកាសធាតុ» ដែរឬទេ ?’

[29] បើទោះជាមានតែអ្នកសម្ភាចំនួន ៧២% ធ្លាប់ឮពាក្យ «ការប្រែប្រួលអាកាសធាតុ» ហើយបើមើលមួយភ្លែត វាអាចមើលទៅដូចជាការធ្លាក់ចុះពីការយល់ដឹងនៃពាក្យនេះបើធៀបនឹងការសិក្សា KAP១ (៨០%) និង KAP២ (៩១%) ការសិក្សាទាំង៣ នេះមិនអាចប្រៀបធៀបគ្នាបាននោះទេ ដោយសារតែការប្រើប្រាស់ទម្រង់កម្រងសំណួរអង្កេតផ្សេងគ្នា។ KAP៣ មិនបានប្រើប្រាស់ពាក្យ «ការប្រែប្រួលអាកាសធាតុ» ជាមួយអ្នកតបសម្ភាសន៍នៅមុនពេលយើងចាប់ផ្តើមសួរសំណួរទៅពួកគាត់ថាធ្លាប់បានឮពាក្យនេះទេ។ វិធីសាស្ត្រនេះអាចធ្វើលទ្ធផលមានសុក្រឹតភាពច្រើនបំផុត។ ទម្រង់កម្រងសំណួរអង្កេតនេះគួរតែត្រូវប្រើប្រាស់សម្រាប់ការសិក្សា KAP នាពេលអនាគតដែលអាចតាមដានមិនត្រឹមតែកម្រិតនៃការស្គាល់ពាក្យនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំណេះដឹងជាក់ស្តែងនៃអត្ថន័យនៃពាក្យនេះផងដែរ។

ដោយក្នុងនោះអ្នកដែលមានកម្រិតអប់រំថ្នាក់សាកលវិទ្យាល័យ (៩៨%) វិទ្យាល័យ (៨៨%) អនុវិទ្យាល័យ (៧០%) និងបឋមសិក្សា (៦៤%) បានបញ្ជាក់ថាយល់/ដឹងពីវាក្យសព្ទនេះ។ ប្រជាជនកម្ពុជាម្នាក់ក្នុងចំណោមបួននាក់ (២៨%) មិនដែលបានដឹងអំពីវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ»នេះទាល់តែសោះ។ អ្នកដែលខ្វះចំណេះដឹងអំពីពាក្យនេះច្រើនតែជាកម្មករដែលមានជំនាញទាប ឬគ្មានជំនាញ (៣៥%) អ្នកដែលមិនធ្លាប់បានចូលរៀននៅសាលា (៤៩%) ឬប្រជាជនក្រីក្រខ្លាំង (៥១%)។ ការសិក្សាស្រាវជ្រាវបែបគុណវិស័យដែលជាផ្នែកមួយនៃការសិក្សានេះក៏បានបញ្ជាក់ផងដែរថា ពាក្យនេះអាចមិនសូវស្គាល់/យល់ក្នុងចំណោមប្រជាជនកម្ពុជាពិតមែន។ លទ្ធផលនៃការសម្ភាសបែបគុណវិស័យជាមួយមន្ត្រីតំណាងពីក្រសួងនិងស្ថាប័ននានាបង្ហាញថាវាជាការចាំបាច់ណាស់ដែលត្រូវប្រើប្រាស់ពាក្យ «ការប្រែប្រួលអាកាសធាតុ» ដោយមានការពន្យល់រៀបរាប់បន្ថែមទៀតឲ្យកាន់តែងាយយល់ រួមជាមួយនឹងការបង្ហាញពីមូលហេតុដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុផងដែរ ដើម្បីជួយគាំទ្រប្រជាជនកម្ពុជាឲ្យមានការយល់ដឹងបន្ថែមទៀតអំពីបញ្ហានេះ។

បន្ទាប់ពីបានសាកសួរអ្នកតបសម្ភាសន៍អំពីពាក្យការប្រែប្រួលអាកាសធាតុ អ្នកស្រាវជ្រាវក៏បានសួរអំពីពាក្យ «**កម្តៅភពផែនដី**» [30] ដោយប្រើប្រាស់វិធីសាស្ត្រដូចគ្នាដែរ។ លទ្ធផលទទួលបានគឺប្រហាក់ប្រហែលគ្នាទៅនឹងការស្គាល់ពាក្យ «**ការប្រែប្រួលអាកាសធាតុ**» ដែរគឺមានអ្នកធ្លាប់ឮពាក្យនេះចំនួន ៧១% ដោយក្នុងនោះប្រជាជនចំនួន ៣១% ធ្លាប់ឮ និងស្គាល់/យល់អត្ថន័យនៃពាក្យ «**កម្តៅភពផែនដី**» ហើយ ៤០% ផ្សេងទៀតមិនបានដឹងអំពីពាក្យនេះទេ។




**រូបភាពទី ៧៖ ការស្គាល់ពាក្យ ការប្រែប្រួលអាកាសធាតុ និងកម្តៅភពផែនដី**

[30] QK1b តើអ្នកធ្លាប់ឮឃ្លា «កម្តៅភពផែនដី» ដែរឬទេ ?

## ៣.៤ ឥរិយាបថស្តីពីការប្រែប្រួលអាកាសធាតុ

### ៣.៤.១ ប្រជាជនកម្ពុជាគិតថាការប្រែប្រួលអាកាសធាតុកំពុងតែកើតមានឡើងនៅក្នុងប្រទេសកម្ពុជា

បន្ទាប់ពីការសួរសំណួរដោយមិនបង្ហើបចម្លើយអំពីចំណេះដឹងនៃពាក្យការប្រែប្រួលអាកាសធាតុរួចមក អ្នកសម្ភាសបានអាននិយមន័យនៃពាក្យនេះទៅកាន់អ្នកឆ្លើយតបសម្ភាសន៍ ដើម្បីឲ្យពួកគាត់យល់ពីបរិបទមុនពេលចាប់ផ្តើមសួរពួកគាត់ថា តើការប្រែប្រួលអាកាសធាតុកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជាដែរឬទេ។[31] ប្រជាជនភាគច្រើន (៨៤%) គិតថាការប្រែប្រួលអាកាសធាតុកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ហើយ ៨១% គិតថាការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់ដល់ប្រទេសកម្ពុជានាពេលអនាគតផងដែរ។ ប្រជាជនដែលជួបប្រទះបញ្ហានៃការថយចុះនូវរបបទឹកភ្លៀង (៩១%) និងទឹកជំនន់ (៩០%) ភាគច្រើនយល់ស្របថាការប្រែប្រួលអាកាសធាតុកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា។

លទ្ធផលទាំងនេះមានភាពស្របគ្នាទៅនឹងលទ្ធផល ដែលទទួលបានពីការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យដែលបានរកឃើញថាទាំងបុរស និងស្ត្រីបានយល់ថា មានការប្រែប្រួលធាតុអាកាស ធនធានដែលមានស្រាប់ និងបរិស្ថានដែលពួកគាត់បានជួបប្រទះគឺកាន់តែធ្ងន់ធ្ងរខ្លាំងនៅក្នុងឆ្នាំ២០២០ ហើយពួកគាត់ក៏យល់ថាបញ្ហានេះនឹងកាន់តែធ្ងន់ធ្ងរឡើងនាពេលអនាគតផងដែរ។ ពួកគាត់ក៏បានលើកឡើងជាឧទាហរណ៍ខ្លះៗអំពីការប្រែប្រួលដូចជា របបទឹកភ្លៀងមិនទៀងទាត់ ភាពធ្ងន់ធ្ងរនៃខ្យល់ព្យុះ ការកើនឡើងកាន់តែធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់ និងការកើនឡើងនូវសីតុណ្ហភាពនៅក្នុងតំបន់របស់ពួកគាត់រស់នៅ ព្រមទាំងផលប៉ះពាល់នានាចំពោះ ជីវភាពរស់នៅរបស់ពួកគាត់ ជាពិសេសអ្នករស់នៅតាមតំបន់ជនបទ។ ការសិក្សាស្រាវជ្រាវពីមុនបានរកឃើញថា ទោះបីជាបុរស និងស្ត្រីបានជួបប្រទះនូវការប្រែប្រួលទាំងនេះដូចគ្នាក៏ដោយ ប៉ុន្តែផលប៉ះពាល់ទាំងឡាយទៅលើបុរស និងស្ត្រីមានលក្ខណៈខុសគ្នា។ ស្ត្រីមានក្តីកង្វល់ច្រើនអំពីការប្រែប្រួលទាំងនេះ (លទ្ធភាពប្រើប្រាស់ទឹកក្នុងគ្រួសារ) ជះឥទ្ធិពលដល់សមត្ថភាពរបស់ពួកគាត់ក្នុងការមើលថែទាំកូនៗ និងសត្វចិញ្ចឹម។ ដោយឡែកបុរសតែងតែព្រួយបារម្ភអំពីផលប៉ះពាល់ទាំងនេះដែលនឹងជះឥទ្ធិពលដល់អនាគត និងជីវភាពរស់នៅរបស់ពួកគាត់ (Sao, et al., ២០២០)។

ក្នុងចំណោមប្រជាជនកម្ពុជា អ្នកដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមល្អប្រសើរ (កម្រិតអប់រំ ឬទ្រព្យសម្បត្តិ) គឺមានកម្រិតនៃការយល់ដឹងខ្ពស់អំពីការប្រែប្រួលអាកាសធាតុ និងកម្តៅភពផែនដី។ នេះមានន័យថាអ្នកដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមល្អប្រសើរ ពួកគាត់រមែងមានចំណេះដឹងខ្ពស់អំពីបញ្ហានៃការប្រែប្រួលអាកាសធាតុនេះផងដែរ ជាពិសេសពួកគាត់ក៏មានជំនឿថាការប្រែប្រួលអាកាសធាតុកំពុងតែកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ហើយនឹងបន្តកើតមានឡើងនាពេលអនាគត។

---

[31] QK2 «ការប្រែប្រួលអាកាសធាតុសំដៅទៅលើ «ការផ្លាស់ប្តូរអាកាសធាតុ និងធាតុអាកាសដែលនៅតែបន្តកើតមានឡើងជាច្រើនទសវត្សរ៍ ឬរយៈពេលយូរ»។»

## ៣.៤.២ ការបាត់បង់ព្រៃឈើគឺជាកត្តាចម្បង ដែលប្រជាជនយល់ឃើញថាជាកត្តាជំរុញឲ្យមានការប្រែប្រួលអាកាសធាតុ[32]

ការសិក្សានេះបានសាកសួរប្រជាជនកម្ពុជាអំពីបុព្វហេតុនានា ដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ[33] ដោយប្រើបញ្ជីចម្លើយដែលមានស្រាប់។ លទ្ធផលបានរកឃើញថាប្រជាជនចំនួន៧៦% បានលើកឡើងពីបញ្ហានៃការបាត់បង់ព្រៃឈើបង្កឲ្យមានការប្រែប្រួលអាកាសធាតុ។ លទ្ធផលនេះត្រូវបានលើកឡើងច្រើនក្នុងចំណោមប្រជាជនដែលមានចំណេះដឹងអំពីអត្ថន័យនៃវាក្យសព្ទ «ការប្រែប្រួលអាកាសធាតុ» និង «កម្តៅភពផែនដី»។ ប្រជាជនច្រើនជាងពាក់កណ្តាល (៥៣%) បានសន្និដ្ឋានថាការប្រែប្រួលអាកាសធាតុបង្កឡើងដោយសកម្មភាពរបស់មនុស្សដែលនាំឲ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ លទ្ធផលនេះត្រូវបានលើកឡើងច្រើនដោយក្រុមបុរស (៦០%) បើធៀបទៅនឹងស្ត្រី (៤៧%) និងក្រុមអ្នកប្រកបការងារអាជីព (៦៧%) បើធៀបទៅនឹងក្រុមកម្មករមានជំនាញទាប ឬគ្មានជំនាញ (៤០%)។ មូលហេតុចម្បងៗដែលបានលើកឡើងអំពីបញ្ហាដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុរួមមាន កត្តាធម្មជាតិ (៥២%) ការធ្លាយស្រទាប់អូហ្សូន (៥០%) និងកំណើនប្រជាជន (៤៩%)។ ប្រជាជនមិនសូវបានផ្សារភ្ជាប់ការចំណាកស្រុកមកកាន់ទីក្រុងជាមូលហេតុនៃការប្រែប្រួលអាកាសធាតុនោះទេ ដោយសារមានតែប្រជាជនចំនួន ៣៤% បានលើកឡើងពីបញ្ហានេះ។ ក្រៅពីនេះប្រជាជនចំនួន ២២% បានលើកឡើងអំពីជំនឿដែលថាឥទ្ធិពលរបស់ព្រះបានធ្វើឲ្យមានការប្រែប្រួលអាកាសធាតុនេះ។




រូបភាពទី ៨៖ ការយល់ឃើញពីកត្តាបង្កឲ្យមានការប្រែប្រួលអាកាសធាតុ

[32] QK3 «តើកត្តាអ្វីខ្លះខាងក្រោមនេះដែលអ្នកគិតថាជាកត្តាបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ? »

[33] អ្នកស្រាវជ្រាវបានអានអំពីកត្តាជំរុញដ៏មានសក្តានុពលទាំង៧៖ ១. សកម្មភាពមនុស្សដែលនាំឲ្យមានការបញ្ចេញឧស្ម័នដែលគេហៅថាឧស្ម័នផ្ទះកញ្ចក់ ២. ការធ្លាយស្រទាប់ការពារឧស្ម័នដែលគ្របបណ្តប់ភពផែនដីហៅថា ស្រទាប់អូហ្សូន ៣. កម្លាំងនៃធម្មជាតិ ៤. ហេតុផលជំនឿ ៥. បាត់បង់ព្រៃឈើ ៦.កំណើនប្រជាជន និង ៧.ការចំណាកស្រុកមកទីក្រុង។

នៅពេលសួរសំណួរបន្ថែម[34] ថាតើពួកគាត់គិតថាសកម្មភាពរបស់មនុស្សគឺជាបុព្វហេតុចម្បងដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុដែរឬទេ ប្រជាជនចំនួនបីភាគបួន (៧៦%) បានយល់ស្របនឹងការលើកឡើងនេះស្របពេលដែលអ្នកឆ្លើយតបសម្ភាសន៍ចំនួនន ៣៥% (ក្នុងចំណោម៧៦%) បានយល់ស្របខ្លាំងបំផុត។ ប្រជាជននៅតំបន់ឆ្នេរចំនួន ៨៧% ដែលមានអាយុពី ១៥ ទៅ ២៤ ឆ្នាំ ចំនួន ៩១% បានយល់ស្របថាការប្រែប្រួលអាកាសធាតុពិតជាបណ្តាលមកពីសកម្មភាពមនុស្សប្រាកដមែន។

ប្រជាជនច្រើនជាងមួយភាគបី (៣៨%) ជឿជាក់ថាសកម្មភាពរបស់ពួកគាត់បានរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ[35] ចំណែកឯ ៥៨% មិនយល់ស្របនឹងបញ្ហានេះទេ។ សកម្មភាពមនុស្សដែលជាកត្តាជំរុញឲ្យមានការប្រែប្រួលអាកាសធាតុដែលបានលើកឡើងច្រើនបំផុតរួមមាន ការដុតសំរាម ឬកាកសំណល់ដែលបានលើកឡើងដោយប្រជាជនចំនួន ៣៣%។[36] អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺមានតែប្រជាជនចំនួន ២២% ប៉ុណ្ណោះដែលជឿថាការកាប់អុសសម្រាប់ចម្អិនអាហារបានរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។ ដោយឡែកលទ្ធផលនេះមានលក្ខណៈផ្ទុយគ្នាពីអ្នកឆ្លើយតបសម្ភាសន៍ដ៏ច្រើនលើសលុបដែលបានលើកឡើងថា ការបាត់បង់ព្រៃឈើគឺជាកត្តាជំរុញដ៏សំខាន់បំផុតដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ។

## ៣.៥ ផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

### ៣.៥.១ ផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់មានកម្រិតមធ្យម ប៉ុន្តែវាត្រូវបានគេរំពឹងថានឹងមានការកើនឡើង

នៅពេលសួរថា[37] តើការប្រែប្រួលបរិស្ថានធម្មជាតិបានប៉ះពាល់កម្រិតណាដល់ជីវភាពរស់នៅរបស់ពួកគាត់នៅក្នុងឆ្នាំ២០២០ ប្រជាជនកម្ពុជាប្រមាណ ២៥% បានរាយការណ៍ថាវាមានផលប៉ះពាល់ក្នុងកម្រិតទាបប៉ុណ្ណោះ។ ក្រៅពីនេះប្រជាជនចំនួន ៥៣% យល់ថាមានផលប៉ះពាល់ក្នុងកម្រិតមធ្យម ចំណែកឯ ២២% ទៀតយល់ថាមានផលប៉ះពាល់ក្នុងកម្រិតខ្ពស់។ នៅពេលសួរអំពីពេលអនាគត[38] ប្រជាជនជាងមួយភាគបី (៣៨%) បានបង្ហាញពីក្តីកង្វល់ថាការប្រែប្រួលទាំងនេះនឹងប៉ះពាល់ដល់ជីវភាពរបស់ពួកគាត់ក្នុងកម្រិតខ្ពស់នៅថ្ងៃមុខៗ។ ដោយឡែកប្រជាជនចំនួន ៣៥% បានរំពឹងថានឹងទទួលផលប៉ះពាល់ក្នុងកម្រិតមធ្យម ហើយ ១៤% ទៀតយល់ថាវានឹងមានផលប៉ះពាល់ក្នុងកម្រិតទាបចំពោះជីវភាពរស់នៅនាពេលអនាគត។ អ្នកឆ្លើយតបសម្ភាសន៍ចំនួន ១២% ផ្សេងទៀតនិយាយថាពួកគាត់មិនបានដឹង ឬមិនអាចព្យាករណ៍ពីកម្រិតនៃផលប៉ះពាល់ដែលពួកគាត់នឹងជួបប្រទះនាពេលអនាគតបាននោះទេ។

---

[34] QK3X «អ្នកខ្លះនិយាយថាសកម្មភាពមនុស្សគឺជាបុព្វហេតុចម្បងនៃការប្រែប្រួលអាកាសធាតុ។ តើអ្នកយល់ព្រម ឬមិនយល់ស្របនឹងការលើកឡើងបែបនេះ? »

[35] QK3Y «តើអ្នកយល់ថាសកម្មភាពរបស់អ្នកចូលរួមចំណែកដល់ការប្រែប្រួលអកាសធាតុដែរឬទេ? »

[36] QK3Z «ប្រសិនបើមាន តើអ្នកគិតថាសកម្មភាពរបស់អ្នកដូចម្តេចដែលបានចូលរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ? »

[37] QX1a «តើអ្នកយល់ថាផលប៉ះពាល់ដែលបង្កដោយការប្រែប្រួលបរិស្ថានធម្មជាតិជុំវិញខ្លួនអ្នក (លទ្ធភាពប្រើប្រាស់ទឹក និងការប្រែប្រួលនៃធាតុអាកាស) បានជះឥទ្ធិពលដល់ការរស់នៅរបស់អ្នកកម្រិតណាក្នុងពេលបច្ចុប្បន្ន? »

[38] QX1b «តើអ្នកយល់ថាផលប៉ះពាល់ដែលបង្កដោយការប្រែប្រួលបរិស្ថានធម្មជាតិជុំវិញខ្លួនអ្នក (លទ្ធភាពប្រើប្រាស់ទឹក និងការប្រែប្រួលនៃធាតុអាកាស) នឹងជះឥទ្ធិពលដល់ការរស់នៅរបស់អ្នកកម្រិតណានាពេលអនាគត? »




រូបភាពទី ៩៖ ការយល់ឃើញពីផលប៉ះពាល់ក្នុងពេលបច្ចុប្បន្ន និងអនាគត

ការសិក្សានេះបានរកឃើញអំពីទំនាក់ទំនងរវាងប្រជាជន ដែលយល់ឃើញពីផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាស និងលទ្ធភាពទទួលបានទឹកនាពេលបច្ចុប្បន្នជាមួយនឹងកម្រិតនៃការអប់រំរបស់ពួកគាត់។ មានភស្តុតាងបង្ហាញឲ្យឃើញថាប្រជាជន ដែលមានកម្រិតនៃការអប់រំក្នុងប្រព័ន្ធទាបរមែងគិតថាផលប៉ះពាល់នៃការប្រែប្រួលនានានៃបរិស្ថានធម្មជាតិមានកម្រិតទាបប៉ុណ្ណោះមកលើជីវភាពរស់នៅរបស់ពួកគាត់ក្នុងឆ្នាំ២០២០។ ប្រជាជនកម្ពុជា ដែលមានកម្រិតនៃការអប់រំទាបភាគច្រើនជាប្រជាជនដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។ ការយល់ឃើញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលមានកម្រិតទាបនេះជាឧបសគ្គរាំងដល់សមត្ថភាពរបស់ប្រជាជនក្នុងការត្រៀមខ្លួនឆ្លើយតបនឹងការប្រែប្រួលទាំងនេះ។




រូបភាពទី ១០៖ ផលប៉ះពាល់បច្ចុប្បន្នដែលបង្កឡើងដោយការប្រែប្រួលធាតុអាកាស បរិស្ថាន និងលទ្ធភាពប្រើប្រាស់ទឹក បែងចែកតាមកម្រិតនៃការទទួលបានអប់រំ

បើក្រឡេកមើលឲ្យកាន់តែច្បាស់ ថាតើការប្រែប្រួលនៃរបបធាតុអាកាស និងលទ្ធភាពទទួលបានធនធានដូចជា ទឹក ចំណីអាហារ និងប្រេងឥន្ធនៈបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាយ៉ាងដូចម្តេច[39] វាច្បាស់ណាស់ថាសមត្ថភាពរបស់ប្រជាជនក្នុងការរកប្រាក់ចំណូល និងការថែទាំសុខភាពឲ្យបានល្អត្រូវបានរងផលប៉ះពាល់ខ្លាំងជាងគេបំផុត ដែលលទ្ធផលនេះដូចគ្នាទៅនឹងការសិក្សាអាកាសធាតុអាស៊ីដែរ។ ប្រជាជនបួននាក់ក្នុងចំណោមប្រាំនាក់ (៧៩%) នៃការសិក្សាKAP៣ នេះបាននិយាយថាការប្រែប្រួលធនធានដែលមានស្រាប់ និងរបបធាតុអាកាសបានប៉ះពាល់ដល់សមត្ថភាពរបស់ពួកគាត់ក្នុងការរកប្រាក់ចំណូលចិញ្ចឹមជីវិត ជាពិសេសស្ត្រី (៨២%) បានរាយការណ៍ពីការលំបាកបញ្ហានេះច្រើនជាងបុរស (៧៥%)។ អ្នកតបសម្ភាសន៍បួននាក់ក្នុងចំណោម៥នាក់ (៧៨%) ជឿជាក់ផងដែរថាការរក្សាសុខភាពឲ្យបានល្អគឺកាន់តែជួបការលំបាកខ្លាំងឡើង ដោយសារការប្រែប្រួលបរិស្ថាននេះ។ ស្ត្រីរស់នៅតំបន់ជនបទចំនួន ៨១% និងប្រជាជនដែលប្រឈមនឹងហានិភ័យខ្ពស់នៃធាតុអាកាសធ្ងន់ធ្ងរចំនួន ៨៣% បានជួបប្រទះនឹងបញ្ហានេះច្រើនជាងគេ។

ប្រជាជនកម្ពុជាចំនួនតិចតួចបំផុត បានអះអាងថាការប្រែប្រួលធនធាន និងធាតុអាកាសបានប៉ះពាល់ដល់សមត្ថភាពរបស់ពួកគាត់ក្នុងការបរិភោគចំណីអាហារដែលពួកគាត់ចង់បាន បើទោះជាមានប្រជាជនច្រើនជាងពាក់កណ្តាល (៥៨%) បានរងផលប៉ះពាល់ពីបញ្ហានេះក៏ដោយ។ បញ្ហានេះត្រូវបានរាយការណ៍ភាគច្រើនពីសំណាក់ប្រជាជន ដែលបានទទួលរងផលប៉ះពាល់ពីការប្រែប្រួលទាំងនេះដែលស្ថិតក្នុងកម្រិតខ្ពស់ (៧៤%) និងប្រជាជនដែលបានយល់ឃើញថាមានការកើនឡើងនៃគ្រោះទឹកជំនន់នានា (៧៧%)។ ប្រជាជនជាងពាក់កណ្តាល (៦៣%) ដែលបានរាយការណ៍ពីការប្រែប្រួលនានាចំពោះការទទួលបានចំណីអាហារ[40]។ បញ្ហានេះច្រើនឃើញបានលើកឡើងក្នុងចំណោមប្រជាជនដែលមានអាយុពី២៥-៣៤ឆ្នាំ ដែលមានចំនួន ៧២% និងប្រជាជនដែលរស់នៅតំបន់បឹងទន្លេសាបដែលមានចំនួន ៨៦% ។

ប្រជាជនកម្ពុជាចំនួន ៤៤% បាននិយាយថាលទ្ធភាពមានទឹកប្រើប្រាស់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់បានទទួលរងផលប៉ះពាល់ពីការប្រែប្រួលនានានៃធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់។ ប្រជាជនរស់នៅតាមតំបន់ជនបទ (៤៥%) ច្រើនជាងអ្នករស់នៅទីក្រុង (៤២%) បានរាយការណ៍ពីផលប៉ះពាល់នេះ។ បញ្ហានៃការទទួលបានទឹកប្រើប្រាស់[41] ដែលកើតឡើងជាទូទៅរួមមានកង្វះទឹកស្អាតប្រើប្រាស់ (៧១%) ហើយបញ្ហានេះភាគច្រើនបានលើកឡើងក្នុងចំណោមប្រជាជនដែលរស់នៅតំបន់ជនបទ (៧៤%) តំបន់ភ្នំ (៨០%) និងតំបន់ឆ្នេរ (៨៤%)។ កង្វះទឹកដែលអាចប្រើប្រាស់បានក៏ត្រូវបានលើកឡើងដោយប្រជាជនចំនួន ៦២% ដែរ ដែលពួកគាត់ជាអ្នកបានជួបបញ្ហាខ្វះខាតទឹក។

[39] QX2 «តាមការយល់ឃើញរបស់អ្នក តើការប្រែប្រួលទាំងនេះ (លទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងការប្រែប្រួលនៃធាតុអាកាស) បានប៉ះពាល់សមត្ថភាពរបស់ក្នុងការធ្វើ...........? »

[40] QX4 តើរបបអាហាររបស់អ្នក/គ្រួសារអ្នកបានប៉ះពាល់យ៉ាងដូចម្តេច?

[41] QX5a «ជាចុងក្រោយតើការប្រើប្រាស់ទឹក (សម្រាប់បរិភោគ ចម្អិនអាហារ បោកគក់ ងូតទឹកធ្វើឲ្យត្រជាក់ខ្លួនក្នុងពេលមានសីតុណ្ហភាពក្តៅ) ប្រចាំថ្ងៃរបស់អ្នកបានប៉ះពាល់បែបណាខ្លះ? »

ការលើកឡើងនេះភាគច្រើនគឺក្នុងចំណោមប្រជាជនដែលរស់នៅតំបន់ជនបទ និងតំបន់ទន្លេសាបដែលប្រជាជនចំនួន ៧៣% នៃប្រជាជនដែលរស់នៅតំបន់ទន្លេសាបជួបបញ្ហាខ្វះទឹក។

**ប្រអប់ទី ១៖ ការយល់ឃើញពីហានិភ័យដែលប៉ះពាល់ដល់បុរស និងស្ត្រី**

ការសិក្សាបែបគុណវិស័យរបស់ KAP៣ នេះបានបង្ហាញពីការយល់ឃើញខុសៗគ្នាអំពីហានិភ័យទាក់ទងនឹងការប្រែប្រួលនៃធាតុអាកាស បរិស្ថាន ធនធានដែលមានស្រាប់ទៅតាមប្រភេទក្រុមផ្សេងៗគ្នា។

អ្នកចូលរួមក្នុងការសិក្សាជាតំណាងស្ថាប័នរដ្ឋាភិបាលនានាយល់ឃើញថាស្ត្រីមានហានិភ័យ និងងាយទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ពួកគាត់យល់ឃើញទៀតថាស្ត្រីមានភាពកម្លាំងទន់ខ្សោយជាងបុរស ដូច្នេះហើយស្ត្រីមិនសូវមានភាពធន់ទ្រាំច្រើនទេ។ ឧទាហរណ៍ ពួកគាត់មានអារម្មណ៍ថាបុរសអាចទ្រាំទ្រនឹងសីតុណ្ហភាពខ្ពស់ជាងស្ត្រីដែលងាយនឹងឈឺថ្កាត់ភ្លាមៗ។ ការលើកឡើងបែបនេះត្រូវបានគាំទ្រដោយអ្នកចូលរួមក្នុងកាសិក្សានេះនៅកម្រិតសហគមន៍ផងដែរ ដោយពួកគាត់យល់ថាពេលខ្លះស្ត្រីងាយរងគ្រោះជាងបុរសដោយសារតែស្ត្រីត្រូវទទួលខុសត្រូវក្នុងការថែទាំកូន និងមនុស្សចាស់ជរាក្នុងគ្រួសារ។ ស្ត្រីដែលមានពិការភាព ស្ត្រីជាមេគ្រួសារ កុមារ និងមនុស្សចាស់ក៏ត្រូវបានគេមើលឃើញថាជាក្រុមដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុដែរ ដោយសារពួកគាត់យល់ថាក្រុមទាំងនេះមានសុខភាព និងរាងកាយខ្សោយ ខ្វះថវិកា និងមធ្យោបាយធ្វើដំណើរ។

អ្នកចូលរួមមកពីស្ថាប័នរដ្ឋាភិបាលក៏បានទទួលស្គាល់ផងដែរថា ពេលខ្លះស្ត្រីប្រឈមនឹងហានិភ័យខ្ពស់ពីផលប៉ះពាល់នៃកាប្រែប្រួលធនធាន និងធាតុអាកាស ដោយសារតែការងារប្រចាំថ្ងៃក្នុងគ្រួសាររបស់ពួកគាត់មានជាច្រើនដូចជា ការចម្អិនអាហារ និងការបោសសម្អាត (ដែលស្ត្រីភាគច្រើននៅប្រទេសកម្ពុជាជាអ្នកទទួលខុសត្រូវ) និងត្រូវការធនធានជាមូលដ្ឋានដូចជាទឹកជាដើម។ ប្រការនេះវាអាចជួយបង្កើនភាពងាយរងគ្រោះដល់ស្ត្រីជាពិសេសស្ត្រីនៅតំបន់ជនបទដែលមានលទ្ធភាពទទួលបានព័ត៌មាន ជំនាញ និងឱកាសតិចតួច ដោយសារស្ត្រីត្រូវចំណាយពេលជាច្រើនជាមួយនឹងការងារក្នុងគ្រួសារ។

ទោះបីជាយ៉ាងណាអ្នកចូលរួមខ្លះមកពីស្ថាប័នរដ្ឋាភិបាល និងសមាជិកសហគមន៍មួយចំនួនក៏យល់ថាបុរសមួយចំនួនក៏ប្រឈមនឹងហានិភ័យពីការប្រែប្រួលអាកាសធាតុច្រើនជាងស្ត្រីក្នុងជីវិតប្រចាំថ្ងៃដែរ។ ឧទាហរណ៍ ពួកគាត់បានលើកឡើងពីគ្រោះថ្នាក់ដល់អាយុជីវិតភ្លាមៗ ដែលបុរសត្រូវប្រឈមមុខនៅពេលដែលបុរសត្រូវទៅចេញទៅនេសាទក្នុងពេលមានខ្យល់ព្យុះជាដើម។

*«ខ្យល់ព្យុះបណ្តាលឲ្យរបើងដំបូលផ្ទះខូចខាត ហើយផ្ទះត្រូវដួលរលំក៏ដូចជាបំផ្លិចបំផ្លាញចំការទុរេន និងស្វាយផងដែរ។ ការកើនឡើងសីតុណ្ហភាពធ្វើឲ្យសត្វចិញ្ចឹមឈឺ និងបំផ្លាញផលដំណាំ»* លើកឡើងដោយ បុរសជាមេឃុំ ក្នុងខេត្តកំពត

*«មុខសញ្ញាគ្រោះថ្នាក់ដូចជាទឹកជំនន់ប៉ះពាល់យ៉ាងខ្លាំងចំពោះស្ត្រីក្នុងកំឡុងពេលមានផ្ទៃពោះ និងកុមារ ឬមនុស្សចាស់ដែលមិនចេះហែលទឹក។ ជាពិសេសក្មេងៗមិនដឹងអីច្រើនទេ ហើយមនុស្សចាស់មានរាងកាយ និងសុខភាពទន់ខ្សោយ។»* លើកឡើងដោយបុរសជនពិការ នៅរាជធានីភ្នំពេញ

ក្រុមសំខាន់ៗផ្សេងទៀតដែលត្រូវបានរកឃើញថាងាយរងគ្រោះជាងគេចំពោះការប្រែប្រួលបរិស្ថាន និងធាតុអាកាសនោះគឺកសិករ និងប្រជាជនរស់នៅតំបន់ជនបទ។ អ្នកចូលរួមនានាមកពីស្ថាប័នរដ្ឋាភិបាល និងសមាជិកសហគមន៍បានទទួលស្គាល់ថាប្រជាជនដែលពឹងផ្អែកលើដីធ្លី និងធនធានធម្មជាតិដើម្បីជីវភាពរស់នៅ

គឺជាអ្នកដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលទាំងនេះច្រើនជាងគេ។ ផ្ទុយទៅវិញប្រជាជនដែលរស់នៅតំបន់ទីក្រុងមានលទ្ធភាពទទួលបានសេវាសាធារណៈកាន់តែច្រើន និងមានការងារធ្វើ និងប្រភពព័ត៌មានជាច្រើនប្រភេទ ដូច្នេះពួកគាត់អាចមានភាពងាយស្រួលក្នុងការដោះស្រាយបញ្ហាមូលដ្ឋាននានាដូចជា កង្វះទឹកជាដើម។

*«ជាឧទាហរណ៍នៃការប្រើប្រាស់ទឹក ប្រជាជននៅទីក្រុងប្រើប្រាស់ទឹកម៉ាស៊ីនខណៈដែលប្រជាជននៅតាមជនបទត្រូវទៅដងទឹក។»* លើកឡើងដោយបុរសជាតំណាងមកពីស្ថាប័នក្រសួងមួយ

## ៣.៦ ការអនុវត្តក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

### ៣.៦.១ ប្រជាជនកម្ពុជាបានបង្ហាញពីការត្រៀមបង្ការក្នុងកម្រិតមធ្យមនៅពេលមានព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ[42]

ប្រជាជនកម្ពុជាជាងពាក់កណ្តាល (៥៦%) បានអះអាងថាពួកគាត់បានត្រៀមបង្ការរួចរាល់សម្រាប់អាកាសធាតុធ្ងន់ធ្ងរដូចជា ការកើនឡើងកម្ដៅ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ឬទឹកជំនន់ ដោយក្នុងនោះប្រជាជនដែលគិតថាពួកគាត់មានការត្រៀមបង្ការក្នុងកម្រិតខ្ពស់មានចំនួន ១៤% ហើយអ្នកបានត្រៀមបង្ការក្នុងកម្រិតមធ្យមមានចំនួន ៤២%។ ដោយឡែក ៧៤% នៃប្រជាជនដែលប្រកបការងារអាជីពយល់ថាពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទប់ទល់ទៅនឹងធាតុអាកាសធ្ងន់ធ្ងរ រីឯកសិករ និងអ្នកនេសាទមានចំនួន ៥៥% និងកម្មករជំនាញទាប ឬគ្មានជំនាញមានចំនួន ៥៤% បង្ហាញថាអាចត្រៀមបង្ការខ្លួនផងដែរ។ លទ្ធផលដែលគេវិភាគបែងចែកតាមតំបន់ភូមិសាស្ត្រនីមួយៗបង្ហាញថា ប្រជាជននៅតំបន់ឆ្នេរមានការត្រៀមបង្ការតិចតួចជាងគេបំផុតចំពោះព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ (មានតែ ៤៥% ប៉ុណ្ណោះដែលយល់ថាអាចត្រៀមបង្ការ) ខណៈពេលដែលប្រជាជននៅតំបន់ភ្នំហាក់ដូចជាបានត្រៀមបង្ការខ្លួនច្រើនជាងគេ (មានចំនួន ៦២%)។ លទ្ធផលក៏បង្ហាញផងដែរថាវាមិនមានទំនាក់ទំនងរវាងប្រជាជនដែលយល់ថាមានហានិភ័យចំពោះធាតុអាកាសធ្ងន់ធ្ងរនិងការរាយការណ៍អំពីការត្រៀមបង្ការចំពោះបញ្ហានេះទេ។ នេះជាការបង្ហាញអំពីតម្រូវការនានាក្នុងការត្រៀមបង្ការចំពោះព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ជាពិសេសក្នុងចំណោមប្រជាជនដែលប្រឈមនឹងហានិភ័យខ្ពស់។

ការស្រាវជ្រាវបែបគុណវិស័យបានរកឃើញថា ការគាំទ្រឲ្យមានការត្រៀមបង្ការសម្រាប់រយៈពេលវែងចំពោះធាតុអាកាសធ្ងន់ធ្ងរនៅក្នុងកម្រិតសហគមន៍នៅមានកម្រិតនៅឡើយ ហើយការគាំទ្រដែលបានផ្តល់ឲ្យគឺផ្តោតសំខាន់ទៅលើតែការឆ្លើយតបនឹងគ្រោះមហន្តរាយប៉ុណ្ណោះ។ អ្នកតំណាងមកពីឃុំជាច្រើនបានអះអាងថា ពួកគាត់កំពុងធ្វើសមាហរណកម្មបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំរបស់ពួកគាត់ និងធ្វើការដើម្បីជួយប្រជាជនឲ្យឆ្លើយតបនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ។ ទោះជាយ៉ាងនេះក្តី ផែនការឃុំ/សង្កាត់ត្រូវដោះស្រាយបញ្ហាជាច្រើន ដែលកើតឡើងដោយក្នុងនោះបញ្ហាប្រែប្រួលអាកាសធាតុ

---

[42] QD5 «ប្រសិនបើព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ (ក្តៅពេក ត្រជាក់ ខ្យល់ព្យុះ/ខ្យល់បក់ខ្លាំង ផ្លេកបន្ទោរ/រន្ទះ) កើតឡើងនៅតំបន់អ្នករស់នៅ តើអ្នកគិតថាអ្នកមានការត្រៀមបង្ការកម្រិតណា? អាចត្រៀមបង្ការ ឬមិនបានត្រៀមបង្ការ?

គឺគ្រាន់តែជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនទៀតប៉ុណ្ណោះ។ សមិទ្ធិផលសំខាន់ៗជាច្រើនរបស់តំណាងឃុំដែលបានលើកឡើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុមានដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ប្រព័ន្ធធារាសាស្ត្រ) ឬផែនការថវិកាសម្រាប់ជួយគាំទ្រក្រោយពេលមានគ្រោះមហន្តរាយ (ជំនួយស្បៀងអាហារ និងការជីកជញ្ជូនជាដើម)។

លទ្ធផលសិក្សាបង្ហាញថាប្រជាជនកម្ពុជាមានចំណេះដឹងខ្លះដែរ ស្តីពីការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតសហគមន៍។ ប្រជាជននៅតំបន់ជនបទបាននិយាយថា ពួកគាត់មិនបានចូលរួមក្នុងកិច្ចប្រជុំនានាពាក់ព័ន្ធនឹងបញ្ហានេះនៅក្នុងតំបន់ដែលគាត់រស់នៅនោះទេដោយសារពួកគាត់ខ្វះខាតបណ្តាញគាំទ្រនានា ហើយក៏ត្រូវឲ្យអាទិភាពខ្ពស់ចំពោះការរកប្រាក់ចំណូល និងទំនួលខុសត្រូវការងារក្នុងគ្រួសាររបស់ពួកគាត់ច្រើនជាងដែរ។ ប្រជាជននៅតំបន់ជនបទក៏បានរាយការណ៍ពីការចែករំលែកព័ត៌មានមិនគ្រប់គ្រាន់ពីអាជ្ញាធរឃុំផងដែរ។ ផ្ទុយទៅវិញ អ្នកតំណាងពីរដ្ឋបាលស្រុក និងខេត្តយល់ថាប្រជាជននៅមូលដ្ឋានមិនសូវស្តាប់តាមការណែនាំរបស់ពួកគាត់ពោលគឺប្រជាជននៅតែបន្តកាប់បំផ្លាញព្រៃឈើ បោះចោលកាកសំណល់នៅក្បែរផ្លូវទឹក និងចោលសំរាមពេញដីជាដើម។

### ៣.៦.២ ប្រជាជនកម្ពុជាកំពុងចាត់វិធានការដើម្បីឆ្លើយតបនឹងធាតុអាកាសធ្ងន់ធ្ងរ

ក្រុមអ្នកស្រាវជ្រាវបានសាកសួរប្រជាជនដោយមិនបង្ហើបចម្លើយ[43] ចំពោះការយល់ឃើញរបស់ពួកគាត់ថា តើប្រជាជនកម្ពុជាអាចឆ្លើយតបនឹងធាតុអាកាសធ្ងន់ធ្ងរយ៉ាងដូចម្តេច។ ចម្លើយដែលច្រើនជាងគេបំផុតគឺការបង្កើតផែនការត្រៀមបង្ការចំពោះគ្រោះមហន្តរាយ ដែលលើកឡើងដោយអ្នកតបសម្ភាសន៍ចំនួន ២៤%។ បន្ទាប់មកប្រជាជនចំនួន២២% បានលើកឡើងអំពីការកែលម្អផ្ទះជាបណ្តោះអាសន្នដើម្បីទប់ទល់ ហើយ ១៩% ទៀតគិតថាប្រជាជនគួរតែស្តុកទុកម្ហូបអាហារផងដែរ។ ប្រជាជនដែលយល់ថាគ្រោះទឹកជំនន់មានការកើនឡើងក្នុងតំបន់រស់នៅរបស់ពួកគាត់ (២៦%) បានលើកឡើងពីតម្រូវការក្នុងការស្តុកទុកស្បៀងអាហារច្រើនជាងគេ។ ទោះជាយ៉ាងណាក៏ដោយអ្នកឆ្លើយតបសម្ភាសន៍ច្រើនជាងមួយភាគបី (៣៥%) មិនអាចគិតឃើញពីវិធានការណាមួយដែលអាចជួយឲ្យពួកគាត់ត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរទេ។ អ្នកតបសម្ភាសន៍ដែលមានជីវភាពក្រីក្រ (៥៣%) ហាក់បីដូចជានៅខ្វះខាតចំណេះដឹងនេះច្រើនជាងគេក្នុងការប្រាប់ពីវិធានការនានាដែលគួរធ្វើ។

នៅពេលក្រុមការងារស្រាវជ្រាវបានសួរសំណួរផ្ទៀតផ្ទាត់ដោយបង្ហើបចម្លើយ[44] ស្តីពីសកម្មភាពនានាដែលពួកគាត់បានធ្វើដើម្បីដោះស្រាយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ការតាមដានព័ត៌មាននៃការព្យាករអាកាសធាតុគឺជាសកម្មភាព ដែលពួកគាត់បានធ្វើជាទូទៅច្រើនជាងគេបំផុតដែលមានរហូតដល់ ៦៤% បន្ទាប់មកគឺការសន្សំប្រាក់ (៥៨%) និងការស្តុកទុកស្បៀងអាហារ (៤៧%)។ អ្នកតបសម្ភាសន៍ដែល

[43] QG2 «តើប្រជាជនគួរត្រៀមបង្ការ/ត្រៀមខ្លួនជាស្រេចដូចម្តេចចំពោះធាតុអកាសធ្ងន់ធ្ងរ? »

[44] QG3 «នេះគឺជាសកម្មភាពជាច្រើនដែលប្រជាជនអាចធ្វើដើម្បីជួយពួកគាត់ក្នុងការដោះស្រាយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដូចជា ខ្យល់ព្យុះ/ខ្យល់បក់បោកខ្លាំង ផ្តេកបន្ទោរ/រន្ទះ គ្រោះទឹកជំនន់/ភ្លៀងធ្លាក់ជោកជាំ សីតុណ្ហភាពមិនប្រក្រតី។ សូមប្រាប់ថាសកម្មភាពណាខ្លះដែលអ្នកបានធ្វើ។»

មានជីវភាពក្រីក្រជាក្រុមដែលបានរាយការណ៍តិចតួចបំផុតអំពីការសន្សំប្រាក់ (៤០% នៃប្រជាជនក្រីក្រធៀបនឹង ៩៦% នៃប្រជាជនដែលមានជីវភាពធូរធារ) ឬការស្តុកទុកស្បៀងអាហារ (៣១% នៃប្រជាជនក្រីក្រធៀបនឹង ៨១% នៃប្រជាជនដែលមានជីវភាពធូរធារ)។

### ៣.៦.៣ ប្រជាជនកម្ពុជាកំពុងផ្លាស់ប្តូរជីវភាពរស់នៅ និងរបៀបរបបរស់នៅដើម្បីសម្របខ្លួនទៅនឹងធាតុអាកាសធ្ងន់ធ្ងរ ការប្រែប្រួលបរិស្ថាន និងធនធានដែលមានស្រាប់

ថ្វីបើជួបប្រទះនឹងបញ្ហាប្រឈមនានាក៏ដោយប្រជាជនជាងមួយភាគបី (៣៧%) បានលើកឡើងថាពួកគាត់បានចាប់ផ្តើមធ្វើការផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគាត់ ដើម្បីសម្របខ្លួនឲ្យបានល្អប្រសើរទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានធនធាន និងរបបធាតុអាកាស[45]។ ក្នុងចំណោមអ្នកឆ្លើយតបសម្ភាសន៍ទាំងអស់មានប្រជាជនចំនួនតែ ៦% ប៉ុណ្ណោះដែលបាននិយាយថាពួកគាត់បានធ្វើការផ្លាស់ប្តូរជាច្រើនចំពោះជីវភាពរស់នៅរបស់ពួកគាត់ ខណៈដែល៣១% ទៀតបានរាយការណ៍ថាបានធ្វើការផ្លាស់ប្តូរខ្លះៗដែរ។ ដោយឡែកអ្នកតបសម្ភាសន៍ចំនួន ៦២% បានរាយការណ៍ថាមិនបានធ្វើការផ្លាស់ប្តូរជីវភាពរបស់ពួកគាត់ទេដែលក្នុងនោះចំនួនស្ត្រីដែលបានរាយការណ៍អំពីបញ្ហានេះ (៦៦%) មានច្រើនជាងបុរស (៥៩%)។ ប្រជាជននៅតំបន់ទន្លេសាបហាក់ដូចជាមិនសូវបានធ្វើការផ្លាស់ប្តូរជីវភាពរស់នៅប៉ុន្មានទេ ដោយគេឃើញមានតែប្រជាជនចំនួន ២៦% នៃក្រុមនេះប៉ុណ្ណោះដែលបានរាយការណ៍ថាបានផ្លាស់ប្តូរ។ លទ្ធផលនេះក៏បានបង្ហាញអំពីទំនាក់ទំនងអវិជ្ជមានរវាងការធ្វើសកម្មភាពឆ្លើយតបជាមួយនឹងអាយុ ដែលមានន័យថាមនុស្សដែលមានវ័យកាន់តែចាស់កាន់តែមិនសូវធ្វើការផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគាត់។

នៅពេលគេសួរដោយមិនបង្ហើបចម្លើយ[46] ទៅកាន់អ្នកដែលបានធ្វើការផ្លាស់ប្តូរជីវភាពរស់នៅ គេបានរកឃើញថាប្រជាជនចំនួន៦២% បាននិយាយថាពួកគាត់បានផ្លាស់ប្តូរជីវភាពរស់នៅតាមរយៈការផ្លាស់ប្តូរការងារ/មុខរបរ។ ការផ្លាស់ប្តូរការងារ/មុខរបរនេះត្រូវបានលើកឡើងច្រើននៅក្នុងចំណោមប្រជាជនដែលកំពុងស្ថិតក្នុងអាយុធ្វើការងារ[47] (៧០% ក្នុងចំណោមអ្នកដែលបានធ្វើការផ្លាស់ប្តូរជីវភាពបានរាយការណ៍ថាបានប្តូរការងារ/មុខរបរ)។ ការផ្លាស់ប្តូរការងារ/មុខរបរនេះក៏ត្រូវបានគេរកឃើញក្នុងចំណោមក្រុមបុរស (៦៦%) ច្រើនជាងក្រុមស្ត្រី (៥៨%) ។ ចំពោះតំបន់ទីតាំងភូមិសាស្ត្រនីមួយៗវិញ អ្នករស់នៅតំបន់ទន្លេសាប (៧៥%) បានរាយការណ៍ច្រើនអំពីការផ្លាស់ប្តូរការងារ/មុខរបរដោយសារតែមានការប្រែប្រួលនៃលទ្ធភាពទទួលបានធនធាន និងធាតុអាកាស។ ដោយឡែកអ្នករស់នៅរាជធានីភ្នំពេញមានតិចតួចប៉ុណ្ណោះ (៤៩%) ដែលបានធ្វើការផ្លាស់ប្តូរការងារ/មុខរបរ។ ចំពោះអ្នកដែលបានរាយការណ៍ថាគុណភាពជីវិតរបស់ពួកគាត់មានការថយចុះ ឬយ៉ាប់យ៉ឺនជាងមុននៅក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនេះ (៧០%) ក៏បានលើកឡើងអំពីការផ្លាស់ប្តូរការងារ/មុខរបរ ដែលជាយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហារបស់ពួកគាត់

---

[45] QD1 តើអ្នក ឬគ្រួសារអ្នកបានធ្វើការផ្លាស់ប្តូរជីវភាពរស់នៅ/ការងារដើម្បីទប់ទល់/ដោះស្រាយបញ្ហាការប្រែប្រួលលទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនី និងប្រេងឥន្ធនៈប្រើប្រាស់ និងការប្រែប្រួលនៃធាតុអាកាសដែលអ្នកជួបប្រទះ ដែរឬទេ?

[46] QD2 «អ្នកបាននិយាយថាអ្នក ឬគ្រួសារអ្នកបានធ្វើការផ្លាស់ប្តូរជីវភាពរស់នៅដើម្បីដោះស្រាយនឹងការប្រែប្រួលទៅនឹងការប្រែប្រួលលទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនី និងប្រេងឥន្ធនៈប្រើប្រាស់។ តើអ្នកបានធ្វើការផ្លាស់ប្តូរអ្វីខ្លះ?» (សួរភ្លាមៗឥតព្រៀងទុក)។

[47] អាយុ ២៥-៣៤

ដែរ។ បញ្ហាទាំងនេះបង្ហាញពីភាពផុយស្រួយនៃជីវភាពរស់នៅរបស់ពួកគេ។ យុទ្ធសាស្ត្រដោះស្រាយដែលត្រូវបានលើកឡើងច្រើនជាងគេទីពីរគឺការស្វែងរកប្រាក់ចំណូលបន្ថែម ដែលមានប្រជាជនជាងមួយភាគបី (៣៦%) បានលើកឡើងផងដែរ។

## ករណីសិក្សាទី២៖ ប្រជាជនកំពុងជួបប្រទះការថយចុះនូវប្រាក់ចំណូល

បុរសជាអ្នកភូមិម្នាក់នៅខេត្តកំពតបានចែករំលែកបទពិសោធន៍ក្នុងការជួបប្រទះបញ្ហាជាច្រើនដូចជា គ្រោះរាំងស្ងួត ការកើនឡើងសីតុណ្ហភាព ទឹកជំនន់ ការហូរចូលទឹកសមុទ្រ ខ្យល់បក់បោកខ្លាំង កង្វះទឹក និងព្យុះរន្ទះជាដើម។

គ្រោះរាំងស្ងួត និងបញ្ហាទឹកមិនគ្រប់គ្រាន់សម្រាប់ដំណាំកសិកម្មគឺជាបញ្ហាសំខាន់សម្រាប់កសិករ និងអ្នកនេសាទដោយសារតែពួកគាត់ត្រូវពន្យារពេលដាំដុះស្រូវតាំងពីខែឧសភារហូតដល់ខែកញ្ញា។ ពួកគាត់ក៏បាននិយាយផងដែរថា ការកើនឡើងសីតុណ្ហភាពកំពុងធ្វើឲ្យប៉ះពាល់ដល់ទិន្នផលត្រីដោយសារតែត្រីទៅរស់នៅក្នុងទឹកត្រជាក់ដែលធ្វើឲ្យពួកគាត់កាន់តែពិបាកនេសាទ។ ប្រការនេះបានកាត់បន្ថយប្រាក់ចំណូលរបស់ពួកគាត់ដែលបានពីការប្រកបនេសាទ និងការងារកសិកម្មដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណូលទាំងមូលរបស់គ្រួសារពួកគាត់។ ទឹកជំនន់ក្នុងឆ្នាំ២០១៩-២០២០ ក៏បានធ្វើឲ្យខូចខាតដល់ផលដំណាំ បន្លែ និងដំណាំស្រូវ និងបង្កឲ្យសត្វចិញ្ចឹមមានជំងឺផងដែរ។

ខុសគ្នាពីតំបន់ផ្សេងៗ តំបន់ឆ្នេរតែងជួបប្រទះការហូរចូលនៃទឹកប្រៃដែលបានធ្វើឲ្យខូចខាតផលស្រូវ ហើយវាកាន់តែធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរកប្រាក់ចំណូលរបស់កសិករកាន់តែខ្លាំងឡើង។ ដោយសារតែជីវភាពរស់នៅរបស់ពួកគាត់ភាគច្រើនពឹងផ្អែកទៅលើធាតុអាកាស ធនធានដែលមានស្រាប់ និងការអនុវត្តតាមបែបប្រពៃណី ជីវភាពរស់នៅរបស់អ្នកភូមិបានរងផលប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលនៃរបបធាតុអាកាស និងធនធានដែលមានស្រាប់។ លើសពីនេះគេមានឱកាសការងារតិចតួចជាងមុន ដូច្នេះអ្នកភូមិមានការលំបាកក្នុងការស្វែងរកប្រាក់ចំណូលបន្ថែមតាមមធ្យោបាយផ្សេងទៀត។

បន្ទាប់មកអ្នកស្រាវជ្រាវបានសួរអ្នកឆ្លើយតបសម្ភាសន៍ទាំងអស់អំពីសកម្មភាពនានាដែលពួកគាត់កំពុងធ្វើក្នុងការឆ្លើយតបនឹងការប្រែប្រួលនៃធនធាន និងធាតុអាកាស[48]។ ការផ្លាស់ប្តូរក្នុងការប្រើប្រាស់ថាមពល (រួមមានការប្រើប្រាស់អគ្គិសនីកាន់តែមានប្រសិទ្ធភាព ការប្រើប្រាស់ឧបករណ៍សន្សំសំចៃភ្លើង និងការប្រើប្រាស់ថាមពលជំនួសដើម្បីចម្អិនអាហារ) គឺជាយុទ្ធសាស្ត្រដែលត្រូវបានលើកឡើងដោយប្រជាជនកម្ពុជាចំនួន ៧៤%។ ដោយឡែកមានតែប្រជាជន ចំនួនតិចតួច (១៤%) ដែលបានរាយការណ៍អំពីការប្រើប្រាស់ថាមពលកកើតឡើងវិញដូចជា ថាមពលសូឡា ឬអំពូលភ្លើងសូឡាជាដើម។

សកម្មភាពដែលបានលើកឡើងជាច្រើនបំផុតទីពីរនោះគឺការស្វែងរកចំណូលបន្ថែមតាមមធ្យោបាយផ្សេងៗដែលមានប្រជាជនចំនួនតិចជាងពាក់កណ្តាល (៤៧%) បានធ្វើសកម្មភាពនេះ។ ក្នុងនោះចំនួនបុរស (៥៣%) ច្រើនជាងស្ត្រី (៤១%) ចំនួនប្រជាជនរស់នៅតំបន់ភ្នំ (៧០%) និងប្រជាជនប្រកប

[48] QD4a «តើអ្នកកំពុងធ្វើអ្វីសកម្មភាពខ្លះដើម្បីទប់ទល់/ដោះស្រាយបញ្ហានៃការប្រែប្រួលនៃលទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនី និងប្រេងឥន្ធនៈប្រើប្រាស់ និងការប្រែប្រួលនៃធាតុអាកាស? » (សូមអានចម្លើយដើម្បីជ្រើសរើស)

ការងារអាជីព កសិករនិងអ្នកនេសាទ (ទាំងពីរប្រភេទមានចំនួន៥៥% ដូចគ្នា) បានបង្ហាញថាពួកគាត់ស្វែងរកប្រាក់ចំណូលបន្ថែមក្នុងការដោះស្រាយបញ្ហា។ ប្រជាជនប្រមាណ ៣០% បានលើកឡើងថាពួកគាត់បានផ្លាស់ប្តូរទីតាំងប្រកបការងារ ឬអាជីវកម្ម (ដូចជាប្តូរតំបន់នេសាទ ឬទីតាំងកន្លែងលក់គ្រឿងទេស) ដើម្បីទប់ទល់នឹងការផ្លាស់ប្តូរនៃធាតុអាកាស ឬធនធានដែលមានស្រាប់។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺកម្មករដែលមានជំនាញទាប ឬគ្មានជំនាញចំនួន ៣៩% បានរាយការណ៍អំពីការផ្លាស់ប្តូរទីតាំងការងាររបស់ពួកគាត់ដែលនេះជាចំនួនច្រើនជាងក្រុមដែលមានមុខរបរផ្សេងទៀត។ បន្ទាប់មកអ្នកនេសាទនិងកសិករដែលផ្លាស់ប្តូរទីកន្លែងប្រកបរបរមានចំនួន ៣៥%។

ក្រៅពីសកម្មភាពដែលបានរៀបរាប់ខាងលើ ប្រជាជនម្នាក់ក្នុងចំណោមប្រាំនាក់ (២១%) បានលើកឡើងថាពួកគាត់បានរៀនជំនាញថ្មី ឬបច្ចេកទេសកសិកម្មដើម្បីរក្សាប្រាក់ចំណូលរបស់ពួកគាត់។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ផងដែរនោះគឺអ្នកដែលមានលទ្ធភាពប្រើប្រាស់វិទ្យុ ប្រព័ន្ធបណ្តាញសង្គម ឬកម្មវិធីផ្ញើសារតាមអ៊ីនធើណែតហាក់ដូចជាបានរៀនសូត្រជំនាញថ្មីៗនេះច្រើនជាងគេ។

នៅពេលដែលពិនិត្យមើលភាគរយជារួមទាក់ទងនឹងការធ្វើសកម្មភាពឆ្លើយតប ដោយប្រើប្រាស់បញ្ជីសកម្មភាពដូចមានបង្ហាញក្នុងរូបភាពខាងក្រោម ប្រជាជនចំនួន ៩១% ក្នុងការសិក្សា KAP៣ នេះបានធ្វើសកម្មភាពយ៉ាងហោចណាស់មួយដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃធាតុអាកាស និងធនធានដែលមានស្រាប់។ ចំពោះលទ្ធផលនេះគេឃើញមានភាពខុសគ្នាគួរឲ្យកត់សម្គាល់តាមបែបស្ថិតិវិទ្យាផងដែរ រវាងបុរស (៩៣%) និងស្ត្រី (៨៩%) បើទោះបីជាវាស្ថិតក្នុងសមាមាត្រតិចតួចក៏ដោយ។ បើប្រៀបធៀបទៅនឹងការសិក្សា KAP១ មានតែប្រជាជនចំនួន ៧៣% និងសិក្សាKAP២ មានប្រជាជនចំនួន ៩៤% ដែលបានធ្វើសកម្មភាពឆ្លើយតប។[49] នេះបង្ហាញឲ្យឃើញថាយ៉ាងហោចណាស់ប្រជាជនកម្ពុជាកំពុងចាត់វិធានការណាមួយដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស ធនធាន និងបរិស្ថាន ហើយសកម្មភាពទាំងនេះកាន់តែមានសន្ទុះខ្លាំងឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ។

[49] សំណួរដែលត្រូវបានប្រើដើម្បីបង្កើតតួលេខទាំងនេះមានភាពខុសគ្នាទៅតាមការសិក្សានៃ KAPs ទាំងបី។ KAP១៖ «តើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកបានធ្វើអ្វីមួយដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសដែរឬទេ?» KAP២៖ «តើអ្នក ឬសមាជិកគ្រួសារអ្នកបានឆ្លើយតបអ្វីខ្លះទៅនឹងការប្រែប្រួលអាកាសធាតុ? » KAP៣៖ «តើអ្នកកំពុងធ្វើសកម្មភាពអ្វីខ្លះដើម្បីទប់ទល់/ដោះស្រាយបញ្ហាការប្រែប្រួលនៃលទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនី និងប្រេងឥន្ធនៈប្រើប្រាស់ និងការប្រែប្រួលនៃធាតុអាកាស? »




រូបភាពទី ១១៖ ចំនួនអ្នកតបសម្ភាសន៍ដែលបានរាយការណ៍ថាបានធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស

### ៣.៦.៤ ប្រជាជនកម្ពុជាមានឆន្ទៈក្នុងការធ្វើការផ្លាស់ប្តូរបន្ថែមទៀតដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់

នៅពេលដែលសួរអំពីឆន្ទៈរបស់ពួកគាត់ក្នុងការធ្វើការផ្លាស់ប្តូរបន្ថែមទៀត ដើម្បីជីវភាពរបស់ពួកគាត់ឆ្លើយតបនឹងការប្រែប្រួលធនធានដែលមានស្រាប់ និងរបបធាតុអាកាស អ្នកឆ្លើយតបសម្ភាសន៍ចំនួន ៧៩% បាននិយាយថាពួកគាត់មានឆន្ទៈខ្ពស់ ឬមធ្យមក្នុងការធ្វើការផ្លាស់ប្តូរនាពេលអនាគត។[50]

ពេលសួរអំពីសកម្មភាពដែលពួកគាត់នឹងធ្វើនាពេលអនាគត[51] ប្រជាជនចំនួន ៨៦% ដែលជាអ្នកបានធ្វើការផ្លាស់ប្តូររួចមកហើយ គឺមានបំណងស្វែងរកប្រាក់ចំណូលបន្ថែមតាមមធ្យោបាយផ្សេងៗទៀត ហើយភាគច្រើននៃអ្នករាយការណ៍បែបនេះគឺជាក្រុមមនុស្សវ័យក្មេងជាង [52] (៩៣% នៃពួកគាត់បាននិយាយថាពួកគាត់មានឆន្ទៈធ្វើការផ្លាស់ប្តូរបន្ថែម) និងអ្នកដែលមានកម្រិតនៃការអប់រំខ្ពស់បំផុត (៩០% នៃអ្នកមានការអប់រំនៅថ្នាក់វិទ្យាល័យ និង ៩៣% នៃអ្នកមានការអប់រំនៅកម្រិតសាកលវិទ្យាល័យ)។

ភាគច្រើននៃអ្នកដែលបានធ្វើការផ្លាស់ប្តូររួចហើយ (៨៦%) ក៏បាននិយាយផងដែរថាពួកគាត់បានផ្លាស់ប្តូរការងារ/មុខរបរ ឬទីតាំងអាជីវកម្ម ហើយ ៧៤% នៃពួកគាត់បានអះអាងថាបានត្រៀមខ្លួនរួចជាស្រេចក្នុងប្រើប្រាស់ឥន្ធនៈឲ្យកាន់តែមានប្រសិទ្ធភាព។ អ្នកតបសម្ភាសន៍ចំនួន ៧០% ក៏បានបង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនជំនាញថ្មីៗ និងបច្ចេកទេសកសិកម្មនាពេលអនាគតផងដែរ។ ប្រជាជននៅតាមតំបន់ជនបទ (៧២%) កសិករ និងអ្នកនេសាទ (៧៣%) និងបុរសចំនួន ៧៤% បើធៀបទៅនឹងស្ត្រី (៦៦%) មានទំនោរចង់ធ្វើសកម្មភាពទាំងនេះជាងគេ។ ប្រជាជនចំនួនច្រើន (៦៦%) បានលើកឡើងអំពីការត្រៀមខ្លួនរួចរាល់ដើម្បីធ្វើការជាមួយប្រជាជនផ្សេងទៀតនៅក្នុងសហគមន៍របស់ពួកគាត់ក្នុងការដោះស្រាយ

---

[50] QD3 «តើអ្នកមានបំណងធ្វើការផ្លាស់ប្តូរការងារ/ជីវភាពរស់នៅបែបណាខ្លះដើម្បីទប់ទល់/ដោះស្រាយបញ្ហាការប្រែប្រួលនៃលទ្ធភាពមានទឹកប្រើប្រាស់ ចំណីអាហារបរិភោគ អគ្គិសនី និងប្រេងឥន្ធនៈប្រើប្រាស់ និងការប្រែប្រួលធាតុអាកាសដែលអ្នកជួបប្រទះ ? »

[51] QD4b «តើអ្នកនឹងធ្វើសកម្មភាពទាំងនេះដែរឬទេ ? »

[52] អាយុ ១៥-២៤ឆ្នាំ

បញ្ហាដែលបង្កឡើងដោយធាតុអាកាសធ្ងន់ធ្ងរ។ យន្តការនៃការឆ្លើយតបនាពេលអនាគតចំនួនពីរដែលប្រជាជនកម្ពុជាមិនសូវបានលើកឡើងគឺការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ (៣៨%) និងការធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ (២៨%)។ ក្នុងនោះក្រុមប្រជាជនដែលមានអាយុពី១៥–២៤ឆ្នាំ រស់នៅតាមតំបន់ជនបទភាគច្រើន (៤៤%) រាយការណ៍ថាពួកគាត់នឹងធ្វើចំណាកស្រុកនាពេលអនាគត។

ជារួមលទ្ធផលបង្ហាញថាវាមានភាពផ្ទុយស្រឡះរវាងសកម្មភាពដែលប្រជាជនកម្ពុជាបាននិយាយថាពួកគាត់បានអនុវត្តរួចហើយ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាសជាមួយនឹងសកម្មភាពដែលពួកគាត់គ្រោងនឹងធ្វើសម្រាប់ពេលអនាគត។ ចំណុចនេះក៏អាចជារឿងធម្មតាដែរសម្រាប់ប្រជាជនក្នុងការគិតអំពីផែនការនាពេលអនាគត ដែលមើលទៅដូចជាធំធេងជាងអ្វីដែលបានអនុវត្តរួច ប៉ុន្តែករណីខ្លះទៀតវាក៏អាចបណ្តាលមកពីពួកគាត់ធ្លាប់បានឆ្លងកាត់ឧបសគ្គច្រើន នៅពេលកន្លងមកក្នុងការព្យាយាមធ្វើការផ្លាស់ប្តូរផងដែរ។




**រូបភាពទី១២៖ ការផ្លាស់ប្តូរដែលប្រជាជនបានកំពុងធ្វើនាពេលបច្ចុប្បន្ន និងមានបំណងធ្វើនាពេលអនាគត**

**ករណីសិក្សាទី ៣៖ ការអនុវត្តសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ**

**ខេត្តកំពត**

ការស្រាវជ្រាវបែបគុណវិស័យបង្ហាញអំពីរបៀបដែលប្រជាជនកម្ពុជាកំពុងធ្វើសកម្មភាព ដើម្បីដោះស្រាយជាមួយនឹងការប្រែប្រួលធនធាន និងរបបធាតុអាកាស។ នៅខេត្តកំពតប្រជាជនបានលើកឡើងថានៅពេលដែលពួកគាត់ប្រឈមនឹងគ្រោះរាំងស្ងួត ឬខ្វះទឹក អ្នកភូមិបានជីកស្រះ និងប្រើម៉ាស៊ីនដើម្បីបូមទឹក ស្រោចស្រពស្រែក៏ដូចជាបានត្រងទឹកភ្លៀងទុកសម្រាប់ប្រើប្រាស់ផងដែរ។ អ្នកភូមិខ្លះក៏បានផ្លាស់ប្តូរមុខដំណាំរបស់ពួកគាត់ដូចជាដាំឪឡឹក ត្រសក់ និងសណ្តែកដីដែលពួកគាត់យល់ថាវាមានភាពធន់នឹងការប្រែប្រួលអាកាសធាតុជាង។ ដោយឡែកក៏មានអ្នកដទៃទៀតបានបោះបង់ចោលការធ្វើស្រែទាំងស្រុង ហើយបានសម្រេចចិត្តធ្វើការជាកម្មករជំនួសវិញដែរ។

**ខេត្តកំពង់ធំ**

នៅក្នុងខេត្តនេះកង្វះខាតទឹកគឺជាបញ្ហាដ៏ធំសម្រាប់អ្នកភូមិច្រើនជាងបញ្ហានៃការកើនឡើងនៃសីតុណ្ហភាព និងខ្យល់ព្យុះទៅទៀត។ ពួកគាត់យល់ថាប្រភពទឹករបស់ពួកគាត់ដូចជា ប្រឡាយមេ និងប្រឡាយទឹកតូចៗមិនគ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការរបស់សហគមន៍នោះទេ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះក្រៅតែពីការធ្វើស្រែក្នុងរដូវវស្សា អ្នកភូមិក្នុងឃុំមួយក៏បានចាប់ផ្តើមធ្វើស្រូវប្រាំងពីរទៅបីដងក្នុងមួយឆ្នាំ ហើយចាប់ផ្តើមពង្រីកការធ្វើស្រែលើដីផ្សេងបន្ថែមទៀត។ អ្នកភូមិជាច្រើនក៏បានព្យាយាមជីកអណ្តូង និងស្រះដើម្បីទទួលបានទឹកប្រើប្រាស់ ប៉ុន្តែវាមិនទទួលបានជោគជ័យនោះទេដោយសារគ្មានប្រភពទឹកក្រោមដីនៅក្បែរនោះ។ អ្នកភូមិមួយចំនួនបានធ្វើចំណាកស្រុកទៅធ្វើការងារសំណង់ជាជាងព្យាយាមដោះស្រាយបញ្ហាកង្វះទឹក ឬផ្លាស់ប្តូរការអនុវត្តកសិកម្មរបស់ពួកគាត់ ។

## ៣.៦.៥ ការឆ្លើយតបនឹងកង្វះទឹក និងចំណីអាហារ

កង្វះទឹក និងគ្រោះរាំងស្ងួតនៅប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយស្ថានភាពនៃរដូវវស្សាដែលចាប់ផ្តើមយឺតយ៉ាវ និងបញ្ចប់លឿនជាងមុន។ បញ្ហានេះបានធ្វើឲ្យប៉ះពាល់ដល់កសិករដែលធ្វើស្រែចម្ការ និងពឹងអាស្រ័យយ៉ាងខ្លាំងលើទឹកភ្លៀង (MoE & FAO, ២០២០)។

ដោយសារបញ្ហានេះបានគំរាមកំហែងដល់លទ្ធភាពមានទឹកស្អាតប្រើប្រាស់ និងអាហារបរិភោគដែលមានតម្លៃសមរម្យ ប្រជាជនបានខិតខំស្វែងរកយន្តការដោះស្រាយ។ នៅពេលសួរប្រជាជនអំពីរបៀបដែលពួកគាត់បានដោះស្រាយបញ្ហាអសន្តិសុខទឹក [53] អ្នកស្រាវជ្រាវបានរកឃើញថាការស្តុកទុក ឬសន្សំសំចៃទឹក និងបន្សុទ្ធទឹកឲ្យបានស្អាតដើម្បីបរិភោគ (ចម្លើយទាំងពីរត្រូវបានលើកឡើងដោយអ្នកតបសម្ភាសន៍ចំនួន ៧៧%) គឺជាវិធីសាស្ត្រទូទៅបំផុតដែលពួកគាត់បានអនុវត្ត។ ប្រជាជននៅតំបន់ជនបទ (៨១%) បាននិយាយថាពួកគាត់បានស្តុកទុកទឹកច្រើនជាងប្រជាជនដែលរស់នៅទីក្រុង/តំបន់ប្រជុំជន

[53] QE2a និង QF2a «សូមប្រាប់ខ្ញុំថាតើសកម្មភាពអ្វីខ្លះដែលអ្នកកំពុងអនុវត្ត? » (អានចម្លើយសម្រាប់ជ្រើសរើស)

(៧០%)។ លើសពីនេះទៀតការស្វែងរកប្រភពផ្គត់ផ្គង់ទឹកថ្មីដូចជា ការជីកស្រះ ឬអណ្តូងទឹក ត្រូវបានលើកឡើងដោយប្រជាជនកម្ពុជាចំនួន ៤១%។ ការលើកឡើងបែបនេះត្រូវបានគេរកឃើញជាពិសេសក្នុងចំណោមប្រជាជននៅតាមតំបន់ជនបទ (៥០%) និងកសិករ/អ្នកនេសាទ (៥៣%) បើប្រៀបធៀបនឹងប្រជាជននៅតំបន់ទីក្រុងដែលមានចំនួនត្រឹមតែ ២២% ប៉ុណ្ណោះ។

អ្នកឆ្លើយតបសម្ភាសន៍ក៏បានរាយការណ៍អំពីសកម្មភាពនៅតាមសហគមន៍ក្នុងការឆ្លើយតបទៅនឹងកង្វះខាតទឹក (សូមមើលរូបភាពទី១៦)។ ដើម្បីកែលម្អប្រព័ន្ធធារាសាស្ត្រ អ្នកតបសម្ភាសន៍ចំនួន ៤៦% បានរាយការណ៍ថាសហគមន៍របស់ពួកគាត់បានសាងសង់ប្រឡាយធារាសាស្ត្រ ហើយ ៤០% បានរាយការណ៍ថាសហគមន៍របស់ពួកគាត់បានសាងសង់ប្រឡាយទប់ទឹក ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះទឹក។ ប្រភេទសកម្មភាពឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងទឹកមានការកើនឡើង បើប្រៀបធៀបទៅនឹងការសិក្សា KAP២។

## ប្រអប់ទី ២៖ ការដោះស្រាយបញ្ហាកង្វះទឹករបស់រដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិខិតខំផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតទៅឲ្យប្រជាជន និងបានទទួលស្គាល់ថាប្រជាជនរស់នៅតំបន់ជនបទងាយប្រឈមនឹងបញ្ហាកង្វះទឹក។

អ្នកពាក់ព័ន្ធជាច្រើនរួមទាំងអ្នកចូលរួមដែលមកពីស្ថាប័នរដ្ឋាភិបាលផ្សេងៗគ្នាបានរាយការណ៍ថា ការផ្តល់ព័ត៌មានការលើកកម្ពស់ការយល់ដឹង និងការគាំទ្ររបស់រដ្ឋាភិបាលនៅមានកម្រិតនៅឡើយ ជាពិសេសពាក់ព័ន្ធនឹងប្រធានបទនៃការប្រែប្រួលអាកាសធាតុ។ បញ្ហានេះកើតឡើងដោយសារតែរដ្ឋាភិបាលក៏មានបញ្ហាអាទិភាពជាច្រើននៅថ្នាក់ក្រោមជាតិ។ សេចក្តីរាយការណ៍បានបង្ហាញថារដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់ស្រុកកំពុងធ្វើការជាមួយថ្នាក់ឃុំ ដើម្បីជួយប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនចំណេះដឹង និងការជួយគាំទ្រ និងផ្តល់សម្ភារនានា បើទោះបីជាកិច្ចអន្តរាគមន៍ទាំងនេះនៅមានទំហំតិចតួច និងអាចឆ្លើយតបនឹងតម្រូវការរយៈពេលខ្លីយ៉ាងណាក៏ដោយ។

អ្នកចូលរួមក្នុងការសិក្សាបែបគុណវិស័យបង្ហាញអំពី បំណងរបស់រដ្ឋាភិបាលក្នុងការជួយគាំទ្រសមាជិកសហគមន៍ឲ្យមានលទ្ធភាពទទួលបានទឹកប្រើប្រាស់កាន់តែប្រសើរឡើងជាឧទាហរណ៍៖

- នៅខេត្តកំពង់ធំ(តំបន់ទន្លេសាប)៖ អាជ្ញាធរថ្នាក់ខេត្ត និងស្រុកបានផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋ និងផ្តល់ព័ត៌មានអំពីការស្តុកទឹកដល់ឃុំដើម្បីផ្សព្វផ្សាយព័ត៌មាននេះបន្តទៅដល់ប្រជាជននៅមូលដ្ឋាន។
- នៅខេត្តកំពង់ស្ពឺ(តំបន់ភ្នំ)៖ អាជ្ញាធរខេត្ត និងស្រុកបានសហការគ្នាដើម្បីកែលម្អប្រព័ន្ធធារាសាស្ត្រដូចជាទំនប់ប្រឡាយ និងអាងស្តុកទឹកដើម្បីបង្កើនលទ្ធភាពទទួលបានទឹកសម្រាប់ប្រើប្រាស់។
- នៅខេត្តកំពត(តំបន់ឆ្នេរ)៖ អាជ្ញាធរខេត្ត និងស្រុកបានគាំទ្រដល់ឃុំជាប្រចាំដោយផ្តល់អណ្តូងទឹក និងសម្ភារថែរក្សាអនាម័យផ្សេងៗ។
- នៅខេត្តព្រៃវែង(តំបន់វាលទំនាប)៖ អាជ្ញាធរខេត្ត និងស្រុកបានផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់ឃុំអំពីបច្ចេកទេសកសិកម្ម និងគាំទ្រដល់ការកសាងប្រព័ន្ធធារាសាស្ត្របន្ថែមដូចជា ស្រះ និងប្រឡាយជាដើម។




## រូបភាពទី១៣៖ ការឆ្លើយតបនឹងកង្វះទឹកប្រើប្រាស់នាពេលបច្ចុប្បន្ន



បុរសម្នាក់កំពុងតែរក្សាទឹកភ្លៀងទុកក្នុងពាង ស្ថិតក្នុងតំបន់ឆ្នេរសមុទ្រ។ ការរក្សាទុកទឹកភ្លៀងត្រូវបានអនុវត្តជារឿយៗដោយប្រជាជនកម្ពុជាដើម្បីប្រមូលទឹកទុកប្រើប្រាស់។

ដើម្បីដោះស្រាយការប្រែប្រួលលទ្ធភាពទទួលបានចំណីអាហារ ប្រជាជនចំនួន ៧៩% បាននិយាយថាពួកគាត់កំពុងកាត់បន្ថយការខ្ជះខ្ជាយ/បោះចោលអាហារ ហើយអ្នកឆ្លើយតបសម្ភាស៍ចំនួនប្រហាក់ប្រហែលនេះក៏បានរាយការណ៍ដែរថាពួកគាត់ ដាំដំណាំចម្រុះ (៧៦%) និងផ្លាស់ប្តូររបបអាហារ (៧០%)។ អ្វីដែលមិនគួរឲ្យភ្ញាក់ផ្អើលនោះគឺប្រជាជននៅតាមជនបទបានផ្លាស់ប្តូរមុខដំណាំ ដែលសកម្មភាពនេះធ្វើឡើងច្រើនក្នុងចំណោមប្រជាជននៅតំបន់ជនបទ (៨៦%) បើប្រៀបធៀបនឹងប្រជាជននៅតំបន់ទីក្រុង/ទីប្រជុំជន (៥៧%)។




**រូបភាពទី១៤៖ ការឆ្លើយតបនឹងកង្វះម្ហូបអាហារ**



ស្ត្រីម្នាក់កំពុងដើរក្នុងសួនបន្លែដែលអនុវត្តបច្ចេកទេសកសិកម្មវៃឆ្លាតខាងអាកាសធាតុ

## ៣.៦.៦ សកម្មភាពឆ្លើយតបនៅកម្រិតសហគមន៍

ការស្រាវជ្រាវបែបគុណវិស័យបានរកឃើញថាបញ្ហានៃការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាពឃុំស្ទើរតែទាំងអស់។ អាទិភាពចម្បង ដើម្បីដោះស្រាយបញ្ហានេះគឺផ្តោតលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដើម្បីដោះស្រាយតម្រូវការសំខាន់ៗដូចជា ការទទួលបានទឹកតាមរយៈប្រព័ន្ធធារាសាស្ត្រ។ ប៉ុន្តែសម្រាប់ឃុំមួយចំនួនក៏នៅមានការលំបាកខ្លះដែរក្នុងការដាក់បញ្ចូលការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនេះដោយសារនៅថ្នាក់ឃុំរបស់ពួកគាត់ នៅមានអាទិភាពជាច្រើនដែលត្រូវដោះស្រាយដូចជា ការពង្រឹងជីវភាពរស់នៅរបស់ប្រជាជន បញ្ហាសុខភាព អំពើហិង្សាក្នុងគ្រួសារ សន្តិសុខ និងការអប់រំជាដើម។ ក្រៅពីនៅកម្រិតឃុំក៏មានឧទាហរណ៍ពីថ្នាក់ស្រុកមួយបានរាយការណ៍ថាពួកគាត់មានធនធាននៅមានកំណត់នៅឡើយ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដោយក្នុងនោះពួកគាត់អាចមានថវិកាត្រឹមតែ ៥% នៃថវិកាសរុបសម្រាប់ឆ្នាំ២០២១ សម្រាប់ធ្វើការងារនេះ។ ទោះជាយ៉ាងណាក៏ដោយការសិក្សានេះក៏បានរកឃើញថា ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុគឺជាការងារអាទិភាពដែលត្រូវបានចូលរួមដោះស្រាយកាន់តែច្រើនឡើងដោយភាគីពាក់ព័ន្ធជាច្រើនមិនត្រឹមតែរាជរដ្ឋាភិបាលប៉ុណ្ណោះទេ។ ភាគីពាក់ព័ន្ធជាច្រើនទៀតមានដូចជា អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក៏កំពុងធ្វើការជាមួយអាជ្ញាធរ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍កម្ពុជាដែរ។

ការសិក្សា KAP នានាបានព្យាយាមវាស់វែងសកម្មភាពដែលប្រជាជនកម្ពុជាយល់ថាពួកគាត់បានធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលធនធានដែលមានស្រាប់ បរិស្ថាន និងរបបធាតុអាកាសនៅក្នុងសហគមន៍របស់ពួកគាត់[54]។ ជារួមលទ្ធផលនៃការសិក្សាបានបង្ហាញថាប្រជាជនក្នុងសហគន៍បានធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលនានាដែលបានលើកឡើង ហើយចំនួនអ្នកធ្វើសកម្មភាពនេះក៏ មានការកើនឡើងពី ៨៣% នៅក្នុង KAP២ ឆ្នាំ២០១៥ រហូតដល់ ៩១% នៅក្នុង KAP៣ ឆ្នាំ២០២០។[55] នៅក្នុងការសិក្សា KAP២ ប្រជាជនជាស្ត្រីចំនួនត្រឹមតែ ៨៣% បានរាយការណ៍ថាប្រជាជននៅក្នុងសហគមន៍របស់ពួកគាត់កំពុងធ្វើសកម្មភាពឆ្លើយតប ដែលចំនួននេះតិចជាងបើប្រៀបធៀបនឹងចំនួនដែលបានរកឃើញនៅក្នុងការសិក្សា KAP៣ នេះគឺ ៨៩%។ លទ្ធផលនេះចង្អុលបង្ហាញពីនិន្នាការកើនឡើង ដែលប្រជាជនកាន់តែច្រើនបានរាយការណ៍អំពីការធ្វើសកម្មភាពឆ្លើយតបជាលក្ខណៈបុគ្គល (ដូចបានលើកឡើងខាងលើ)។

---

[54] QY5 តើប្រជាជននៅក្នុងភូមិឬតំបន់របស់អ្នកបានធ្វើអ្វីខ្លះដើម្បីឆ្លើយតបនឹងការប្រែប្រួលលទ្ធភាពទទួលបានទឹក ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាស?

[55] ខណៈពេលដែលអ្នកតបសម្ភាសន៍បានឆ្លើយសំណួរដោយប្រើប្រាស់បញ្ជីសកម្មភាពដូចគ្នាក្នុងការសិក្សានីមួយៗ វាមានភាពខុសគ្នាបន្តិចបន្តួចរវាង KAP៣ នៅក្នុងការប្រើប្រាស់ពាក្យ។ KAP១៖ «តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើអ្វីខ្លះក្នុងការឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស?» KAP២៖ «តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងវិសមរូបអាកាសធាតុ? » KAP៣៖ «តើប្រជាជននៅក្នុងភូមិ ឬតំបន់របស់អ្នករស់នៅបានធ្វើអ្វីខ្លះដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាស? »




រូបភាពទី ១៥៖ ចំនួនអ្នកតបសម្ភាសន៍ដែលបានរាយការណ៍ថាប្រជាជនក្នុងសហគន៍កំពុងធ្វើសកម្មភាពឆ្លើយតប

អ្នកតបសម្ភាសន៍នៅក្នុងការសិក្សា KAP៣ នេះបានកត់សម្គាល់ឃើញថាប្រជាជននៅក្នុងសហគមន៍របស់ពួកគាត់កំពុងប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬកង្ហារ (៧៩%) ដាំដំណាំដូចធម្មតា (៧៣%) និងដាំដុះបន្លែបន្ថែមទៀត (៥៨%)។ ពួកគាត់បានរាយការណ៍អំពីការផ្លាស់ប្តូរសំខាន់ៗដើម្បីដោះស្រាយបញ្ហាខ្វះខាតទឹកដូចជា ការសាងសង់ទំនប់ទឹក និងប្រឡាយ និងធារាសាស្ត្រនានាកាន់តែច្រើនជាងមុនបើប្រៀបធៀបនឹងការសិក្សា KAP១ និង KAP២។

ការស្រាវជ្រាវបែបគុណវិស័យនៃការសិក្សា KAP៣ បានរកឃើញឧទាហរណ៍នានាដែលសមាជិកសហគមន៍កំពុងធ្វើសកម្មភាពឆ្លើយតបដែលចំណុចនេះមានភាពស្រដៀងគ្នាទៅនឹងលទ្ធផលនៃការអង្កេតបែបបរិមាណវិស័យស្តីពីសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស និងបរិស្ថានផងដែរ។ សមាជិកសហគមន៍បានរាយការណ៍ថាពួកគាត់បានជីកអណ្តូង និងស្រះដើម្បីឆ្លើយតបនឹងគ្រោះរាំងស្ងួត និងបានផ្លាស់ទីលំនៅសត្វចិញ្ចឹមទៅតំបន់ដែលមានសុវត្ថិភាពនៅពេលមានទឹកជំនន់ ព្រមទាំងបានបិទឧបករណ៍អេឡិចត្រូនិកក្នុងអំឡុងពេលមានព្យុះភ្លៀងជាដើម (ដើម្បីជៀសវាងការឆ្លងចរន្តអគ្គិសនីដោយសាររន្ទះ)។

*«នៅពេលមានខ្យល់ព្យុះអ្នកភូមិបញ្ជូនកូនៗទៅកាន់កន្លែងដែលមានសុវត្ថិភាពដូចជា ផ្ទះអ្នកជិតខាងដែលជាផ្ទះថ្មជាដើម។ ក្នុងអំឡុងពេលមានផ្គររន្ទះពួកគាត់មិនជ្រកក្រោមដើមឈើទេ ហើយនាំគ្នាបិទទូរស័ព្ទ ទូរទស្សន៍ និងវិទ្យុក៏ដូចជាទុកសម្ភារដែលមានជាតិដែកនៅឆ្ងាយពីខ្លួននៅពេលពួកគាត់ចេញទៅខាងក្រៅ។» លើកឡើងដោយបុរសជាមេភូមិ នៅខេត្តព្រៃវែង*

*«ដើម្បីទប់ទល់នឹងកម្តៅពួកយើងងូតទឹកឲ្យបានញឹកញាប់ ប្រើប្រាស់កង្ហារ និងដាំដើមឈើឲ្យបានច្រើន។ យើងក៏បានជីកអណ្តូង និងស្រះនៅក្នុងសហគមន៍ដើម្បីផ្គត់ផ្គង់ទឹកក្នុងអំឡុងពេលគ្រោះរាំងស្ងួតផងដែរ» លើកឡើងដោយក្រុមបុរសដែលចូលរួមក្នុងការពិភាក្សាជាក្រុមនៅខេត្តកំពង់ស្ពឺ*




រូបភាពទី១៦៖ ការយល់ឃើញរបស់សហគមន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលធនធាន បរិស្ថាន និងធាតុអាកាស[56]

## ៣.៦.៧ ឥរិយាបថចំពោះសកម្មភាពឆ្លើយតបរបស់សហគមន៍

ការធ្វើការរួមគ្នាអាចជាវិធីសាស្ត្រដ៏សំខាន់សម្រាប់សហគមន៍ក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ លទ្ធផលអង្កេតនៃការសិក្សា KAP៣ បង្ហាញថាប្រជាជនចំនួន ២៥% បាននិយាយថាពួកគាត់បានធ្វើការជាមួយអ្នកដទៃទៀត ឬចែករំលែកធនធានដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ (សូមមើលរូបភាពទី ១២ នៅផ្នែកខាងលើ)។ ក្នុងនោះដែរប្រជាជនដែលមានការយល់ដឹងច្រើនអំពីពាក្យ «ការប្រែប្រួលអាកាសធាតុ» និង «កម្តៅភពផែនដី» បានខិតខំប្រឹងប្រែងច្រើនក្នុងសកម្មភាពរួមគ្នា ឬចែករំលែកធនធាននៅក្នុងតំបន់។

ទោះបីជាយ៉ាងណាក៏កម្រិតនៃការធ្វើសកម្មភាពរួមគ្នារបស់ប្រជាជន ដើម្បីដោះស្រាយបញ្ហាមិនទាន់មានភាពស្របគ្នានឹងឥរិយាបថជារួមរបស់ប្រជាជនក្នុងការធ្វើការងាររួមគ្នានោះទេ។ នេះបង្ហាញឲ្យឃើញថាប្រជាជនចង់ធ្វើការជាមួយគ្នាច្រើនជាងអ្វីដែលពួកគាត់កំពុងធ្វើ។ អ្នកសម្ភាសន៍ភាគច្រើន (៨៧%) បានគិតថាសហគមន៍របស់ពួកគាត់អាចនឹងធ្វើការជាមួយគ្នាបាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ ហើយពួកគាត់ក៏ពេញចិត្តក្នុងការធ្វើសកម្មភាពរួមគ្នាជាជាងការធ្វើសកម្មភាពឆ្លើយតបជាលក្ខណៈបុគ្គលរៀងៗខ្លួន។[57]

[56] នៅក្នុងការសិក្សា KAP១ ចម្លើយ «សង់ផ្ទះដែលធន់នឹងខ្យល់ព្យុះ» មិនបានបង្ហាញនៅក្នុងរបាយការណ៍នោះទេ ដូចនេះចម្លើយនេះមិនមានទិន្នន័យដែលអាចប្រៀបធៀបបាននៅក្នុងរូបភាពនេះទេ។

[57] QD6 «ចំពោះប្រយោគដែលខ្ញុំអាននីមួយៗ សូមអ្នកបង្ហាញថាតើអ្នកយល់ស្រប ឬមិនយល់ស្របនឹងប្រយោគខាងក្រោម។ សូមអ្នកជ្រើសរើសថាអ្នកយល់ស្របខ្លាំង យល់ស្រប មិនយល់ទាល់តែសោះ ឬមិនយល់ស្រប។»

ទោះបីជាប្រជាជនភាគច្រើនចង់ធ្វើការងាររួមគ្នាក៏ពិតមែន តែការសិក្សាក៏បានបង្ហាញផងដែរថា ប្រជាជនម្នាក់ក្នុងចំណោមប្រាំនាក់ប៉ុណ្ណោះ (២០%) បានបញ្ជាក់ថាពួកគាត់ចូលចិត្តធ្វើការងារឆ្លើយតបតែម្នាក់ឯងដើម្បីដោះស្រាយបញ្ហាទាំងនេះ។ បើទោះជាប្រជាជនប្រមាណពីរភាគបី (៦៥%) គិតថាពួកគាត់មិនសូវជាអាចធ្វើអ្វីបានច្រើនក្នុងការផ្លាស់ប្តូរអ្វី ដែលកើតមានឡើងនៅក្នុងជីវិតរបស់ពួកគាត់ក៏ដោយ ក៏ពួកគាត់នៅតែមានការយល់ឃើញអំពី ភាពចាំបាច់ក្នុងការពង្រឹងបន្ថែមនូវសមត្ថភាពក្នុងការដោះស្រាយបញ្ហារបស់បុគ្គលម្នាក់ៗដែរតាមរយៈការមើលឃើញពីផលប្រយោជន៍រួម។ ក្នុងនោះដែរមានប្រជាជនចំនួន ៨៣% គិតថាពួកគាត់អាចជួយសហគមន៍របស់គាត់ក្នុងការត្រៀមបង្ការទៅនឹងគ្រោះមហន្តរាយ និងធាតុអាកាសធ្ងន់ធ្ងរឲ្យកាន់តែប្រសើរជាងមុន។ លទ្ធផលនេះបង្ហាញយ៉ាងច្បាស់ថារាល់កម្មវិធី/កិច្ចអន្តរាគមន៍នានាដែលមានគោលបំណងបង្កើនការត្រៀមបង្ការចំពោះមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ គួរតែផ្តោតសំខាន់លើអនុភាពនៃការធ្វើសកម្មភាពរួមគ្នាក្នុងសហគមន៍។ លទ្ធផលនេះក៏ត្រូវបានរកឃើញដូចគ្នាក្នុងការសិក្សាបែបគុណវិស័យ ដែលបង្ហាញថាមានឧទាហរណ៍តិចតួចបំផុតរបស់សហគមន៍ក្នុងការធ្វើការរួមគ្នាដើម្បីធ្វើសកម្មភាពឆ្លើយតប។ ឧទាហរណ៍នៃសកម្មភាពទាំងនេះរួមមានសមាជិកសហគមន៍នៅក្នុងខេត្តព្រៃវែងនៃតំបន់វាលទំនាបកណ្តាលបានធ្វើការរួមគ្នាក្នុងការជីកប្រឡាយ ដើម្បីទទួលបានទឹកប្រើប្រាស់ក្រោមការផ្តួចផ្តើមរបស់ថ្នាក់ឃុំ។ សមាជិកសហគមន៍នៅខេត្តកំពង់ធំក៏បានរាយការណ៍ថាបានធ្វើការរួមគ្នាដើម្បីស្វែងរកការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើឲ្យការផ្គត់ផ្គង់ទឹកសម្រាប់ស្រោចស្រពស្រូវកាន់តែប្រសើរឡើង បើទោះបីជាពួកគាត់មិនបានទទួលជោគជ័យក្នុងការដោះស្រាយបញ្ហានេះក៏ដោយ។




**រូបភាពទី១៧៖ ឥរិយាបថចំពោះការធ្វើសកម្មភាពឆ្លើយតបលក្ខណៈបុគ្គល និងរួមគ្នា (% នៃការយល់ស្រប)**

### ៣.៦.៨ ការពិភាក្សារបស់សហគមន៍ស្ដីពីបញ្ហាបរិស្ថាន និងធាតុអាកាសនានា

ស្ទើរតែពាក់កណ្ដាល (៤២%) នៃប្រជាជនកម្ពុជាបាននិយាយថា ពួកគាត់មិនបាននិយាយជាមួយនរណាម្នាក់អំពីសកម្មភាពដែលពួកគាត់បានធ្វើ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលនៃលទ្ធភាពទទួលបានធនធាន និងការប្រែប្រួលធាតុអាកាសនោះទេ[58] ចំណែកអ្នកឆ្លើយតបសម្ភាសន៍ម្នាក់ក្នុងចំណោមបួននាក់ (២៩%) បានពិភាក្សាគ្នាជាមួយគ្រួសារ សាច់ញាតិ (២៤%) ឬអ្នកជិតខាងក្នុងសហគមន៍រស់នៅរបស់ពួកគាត់ (២២%)។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ១៨% នៃអ្នកឆ្លើយតបសម្ភាសន៍ក៏បានរាយការណ៍ថាបានពិភាក្សាអំពីការបបន្សុំនឹងការប្រែប្រួលអាកាសធាតុជាមួយអាជ្ញាធរភូមិ ឬឃុំផងដែរ។ ទោះបីជាលទ្ធផលបង្ហាញថាមានការពិភាក្សាក្នុងគ្រួសារ ឬជាមួយប្ដី/ប្រពន្ធនៅតិចតួចក៏ដោយតែវាបង្ហាញថាជាជោគជ័យមួយព្រោះការចូលរួមជាមួយអាជ្ញាធរអាចជះឥទ្ធិពលកាន់តែច្រើនទៅលើការបន្សុំខ្លួនរបស់បុគ្គលម្នាក់ៗក៏ដូចជាសហគមន៍ទូទៅផងដែរ។

ក្នុងចំណោមអ្នកដែលបានរាយការណ៍ថាបានពិភាក្សាជាមួយអ្នកជិតខាងស្ដីពីសកម្មភាពឆ្លើយតបដែលមានសក្ដានុពលនានាច្រើនជាងពាក់កណ្ដាល (៥៧%) បាននិយាយថាពួកគាត់មិនបាននិយាយញឹកញាប់[59]ជាមួយអ្នកជិតខាងអំពីសកម្មភាពទាំងនេះនោះទេ ដោយឡែកមានតែ ៨% នៃពួកគាត់ប៉ុណ្ណោះ ដែលបានពិភាក្សាអំពីបញ្ហានេះជាញឹកញាប់បង្គួរ។

## ៣.៧ ការស្វែងយល់អំពីឧបសគ្គ និងកត្តាជំរុញទឹកចិត្តក្នុងការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះនឹងពិភាក្សាអំពីកត្តានានាដែលប្រជាជនកម្ពុជាយល់ថាបានរារាំង និងជួយឲ្យពួកគាត់អាចឆ្លើយតបចំពោះការប្រែប្រួលនៃលទ្ធភាពទទួលបានធនធាន បរិស្ថាន និងរបបធាតុអាកាស។

វាជាការសំខាន់ណាស់ដែលត្រូវស្វែងយល់អំពីឧបសគ្គនានា ដែលរារាំងប្រជាជនកម្ពុជាពីការធ្វើសកម្មភាពសម្របខ្លួនទៅនឹងការគំរាមកំហែងដែលបង្កឡើងដោយអាកាសធាតុ ដើម្បីស្វែងរកមធ្យោបាយក្នុងការជំនះឧបសគ្គទាំងនោះ។ ការខ្វះខាតការគាំទ្រផ្នែកស្ថាប័ន និងធនធានសម្រាប់ឆ្លើយតបគឺជាកត្តាចម្បងដែលប្រជាជនកម្ពុជាបានលើកឡើងថា ជាឧបសគ្គក្នុងការធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលទាំងនេះ។ ដោយឡែកអ្វីដែលគួរឲ្យកត់សម្គាល់នោះគឺជាងពាក់កណ្ដាលនៃប្រជាជនកម្ពុជា (៥៧%) បានរៀបរាប់ពីអារម្មណ៍ហាក់អស់សង្ឃឹមក្នុងការធ្វើសកម្មភាពឆ្លើយតបដោយសារតែពួកគាត់យល់ឃើញថាការធ្វើសកម្មភាពប្រហែលជានឹងមិនធ្វើឲ្យមានអ្វីប្រែប្រួលនោះទេ។

[58] QY0 «តើអ្នកបានជជែក/ពិភាក្សានៅក្នុងសហគមន៍ ឬតំបន់អ្នករស់នៅអំពីការធ្វើសកម្មភាពក្នុងការឆ្លើយតប/ដោះស្រាយការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាសដែរឬទេ? »

[59] QY1 «តើអ្នកបានជជែក/ពិភាក្សានៅក្នុងសហគមន៍ ឬតំបន់អ្នករស់នៅអំពីការធ្វើសកម្មភាពក្នុងការឆ្លើយតប/ដោះស្រាយការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាសញឹកញាប់កម្រិតណា? »

## ៣.៧.១ ឧបសគ្គរាំងចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

នៅពេលសួរអំពីឧបសគ្គចម្បងៗបំផុត ដែលរាំងមិនឲ្យពួកគាត់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងការប្រែប្រួលធនធានដែលមានស្រាប់[60] ប្រជាជនកម្ពុជាបញ្ជាក់ថាពួកគាត់ត្រូវការការជួយគាំទ្រពីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។




**រូបភាពទី ១៨៖ ឧបសគ្គនានាក្នុងការឆ្លើយតប/ធ្វើសកម្មភាពឆ្លើយតប[61]**

### *៣.៧.១.១ ឧបសគ្គផ្នែកស្ថាប័ន*

អ្នកឆ្លើយតបសម្ភាសន៍បួននាក់ក្នុងចំណោមប្រាំនាក់ (៨០%) បាននិយាយថាពួកគាត់មិនទាន់បានធ្វើសកម្មភាពឆ្លើយតបបានច្រើនជាលក្ខណៈបុគ្គលចំពោះការប្រែប្រួលនានានៃអាកាសធាតុនោះទេ

---

[60] QS1 «យើងបានឃើញនូវវិធីមួយចំនួនដែលមនុស្សអាចឆ្លើយតប/ធ្វើសកម្មភាពដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃលទ្ធភាពប្រើប្រាស់ទឹក ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងការប្រែប្រួលនៃអាកាសធាតុ។ ឥឡូវនេះខ្ញុំនឹងអានប្រយោគមួយចំនួនដែលជាមូលហេតុធ្វើឲ្យមនុស្សខ្លះមិនឆ្លើយតប/ធ្វើសកម្មភាព។ ចំពោះប្រយោគនីមួយៗដែលខ្ញុំអានសូមនិយាយថាតើអ្នកយល់ស្រប ឬមិនយល់ស្រប និងហេតុផលដែលធ្វើឲ្យអ្នកមិនឆ្លើយតប/ធ្វើសកម្មភាព។»

[61] ចម្លើយទីមួយ «ការធ្វើសកម្មភាព/ឆ្លើយតបនឹងមិនធ្វើឲ្យមានអ្វីខុសប្លែកគ្នានោះទេ» មានចំនួន៥៧% គឺមិនស្ថិតក្នុងឧបសគ្គទាំងបីទេ។

ដោយសារតែពួកគាត់ត្រូវការការជួយគាំទ្រពីសំណាក់រដ្ឋាភិបាល។ ភាគច្រើននៃប្រជាជន (៨៣%) ជឿជាក់ថាអាជ្ញាធរមូលដ្ឋាន/ក្រុមប្រឹក្សាឃុំរបស់ពួកគាត់កំពុងធ្វើសកម្មភាពនានា ដើម្បីជួយឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលដែលបានរារាំងសមត្ថភាពបន្សាំខ្លួនរបស់ពួកគេ។ អ្នកមានកម្រិតនៃការអប់រំទាបហាក់ដូចជាទាមទារការជួយគាំទ្រដើម្បីធ្វើសកម្មភាពពីសំណាក់រាជរដ្ឋាភិបាលច្រើនជាងគេ។ លទ្ធផលអង្កេតបានបង្ហាញយ៉ាងច្បាស់ពីភាពខុសគ្នាទៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ក្នុងនោះផងដែរប្រជាជននៅតំបន់ឆ្នេរ (៤៨%) និងទន្លេសាប (៤៣%) បានយល់ស្របខ្លាំងបំផុតអំពីតម្រូវការនៃការជួយគាំទ្រពីរដ្ឋាភិបាលក្នុងការឆ្លើយតបបើធៀបនឹងតំបន់ភូមិសាស្ត្រផ្សេងៗទៀត។ ចំពោះប្រជាជនដែលរស់នៅតំបន់ឆ្នេរ (២៩%) និងទន្លេសាប (៣១%) ក៏ជាអ្នកដែលមានទំនុកចិត្តខ្លាំងទៅលើស្ថាប័នជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកថាពួកគាត់កំពុងធ្វើសកម្មភាពចាំបាច់នានាដើម្បីដោះស្រាយបញ្ហាទាំងនេះ។




**រូបភាពទី១៩៖ ទំនុកចិត្តទៅលើស្ថាប័ននានាក្នុងការធ្វើសកម្មភាពឆ្លើយតប**

ទោះបីជាប្រជាជនភាគច្រើនបានរាយការណ៍ថាមានទំនុកចិត្តខ្ពស់[62] ទៅលើស្ថាប័នរដ្ឋាភិបាលក្នុងការចាត់វិធានការចាំបាច់នានាដើម្បីឆ្លើយតបនឹងការប្រែប្រួលធនធាន បរិស្ថាន និងធាតុអាកាសយ៉ាងណាក៏ដោយក៏លទ្ធផលនៃការសិក្សានេះបង្ហាញថាប្រជាជនចំនួនពីរភាគបី (៦៦%)[63] បានលើកឡើងថាពួកគាត់មិនបានដឹង/ស្គាល់អំពីក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងមូលដ្ឋានរបស់ពួកគាត់ឡើយ ហើយប្រជាជនចំនួន ៦១% ក៏មិនដែលធ្លាប់ឮ/ដឹងអំពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំនោះដែរ។ កង្វះការយល់ដឹងទាំងនេះធ្វើឲ្យមានការចូលរួមតិចតួចពីប្រជាជនដែលបញ្ហាទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញអំពីអត្រានៃការចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងការប្រជុំនានាទាក់ទងនឹងការគ្រប់គ្រង និងត្រៀមបង្ការគ្រោះមហន្តរាយនៅមានកម្រិតទាបនៅឡើយ។ ក្នុងនោះផងដែរប្រជាជនត្រឹមតែ ១៧%[64]

[62] QY2 «តើអ្នកមានទំនុកចិត្តបែបបណាទៅលើស្ថាប័នខាងក្រោមនេះក្នុងការធ្វើសកម្មភាពចំបាច់នានាដើម្បីជួយឆ្លើយតបនឹងការប្រែប្រួលការផ្គត់ផ្គង់ទឹក ចំណីអាហារ ថាមពល និងធាតុអាកាស?តើមានទំនុកចិត្ត ឬគ្មានទំនុកចិត្ត? »

[63] QY3a «តើអ្នកធ្លាប់ឮ ឬស្គាល់ស្ថាប័នខាងក្រោមនេះដែរឬទេ? »

[64] QY3b «តើអ្នកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល/ការប្រជុំពាក់ព័ន្ធនឹងការគ្រប់គ្រង និងត្រៀមបង្ការគ្រោះមហន្តរាយដែរឬទេ? »

ប៉ុណ្ណោះបាននិយាយថាពួកគាត់ធ្លាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំទាក់ទងទៅនឹងប្រធានបទនេះ។

ប្រជាជនកម្ពុជាចំនួនបីភាគបួន (៧៥%) គិតថាពួកគាត់អាចនឹងមិនធ្វើសកម្មភាពឆ្លើយតបនោះទេ ដោយសារពួកគាត់ត្រូវការការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមប្រជាជនដែលងាយរងគ្រោះបំផុតត្រូវការការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលច្រើនជាងគេ។ ក្រុមដែលងាយរងគ្រោះនេះ មានដូចជា កម្មករគ្មានជំនាញ (៨៣%) និងប្រជាជនដែលបានយល់ថាមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ (៨០%)។

ការស្រាវជ្រាវបែបគុណវិស័យដែលជាផ្នែកមួយនៃការសិក្សានេះបានរកឃើញថា អ្នកដែលមានកម្រិតនៃការអប់រំទាប អ្នកមានលទ្ធភាពទទួលបានព័ត៌មានតិចតួច និងអ្នកដែលត្រូវការឲ្យអាទិភាពខ្ពស់ទៅលើការរកចំណូល និងការប្រកបរបរចិញ្ចឹមជីវិត ជាទូទៅពួកគាត់មិនសូវបានដឹងអំពីវិធីសាស្ត្របន្សាំខ្លួនទៅនឹងអាកាសធាតុដែលអាចជួយឲ្យជីវិតរបស់ពួកគាត់ប្រសើរឡើងនោះទេ។ ការសម្ភាសជាមួយភាគីពាក់ព័ន្ធនានាក៏បានទទួលស្គាល់អំពីឧបសគ្គរាំងនានានៅកម្រិតមូលដ្ឋាន ដែលរំខានដល់ការជួយគាំទ្រដល់សមាជិកសហគមន៍ឲ្យយល់ដឹងពីបញ្ហាប្រឈមនានាដែលបង្កឡើងដោយការប្រែប្រួលធាតុអាកាស និងធ្វើសកម្មភាពឆ្លើយតបនឹងបញ្ហាទាំងនោះដែរ។ ពួកគាត់បានសង្កេតឃើញថាអាជ្ញាធរមូលដ្ឋានអាចដើរតួនាទីកាន់តែប្រសើរក្នុងការផ្សព្វផ្សាយព័ត៌មាននៅក្នុងសហគមន៍តាមវិធីងាយៗដូចជា ការចូលរួមវេទិកា ឬកម្មវិធីនានា ឬការធ្វើសេចក្តីប្រកាសព័ត៌មានដោយប្រើប្រាស់ឧបករណ៍បំពងសំឡេង និងមីក្រូហ្វូនជាដើម។

### ៣.៧.១.២. ឧបសគ្គផ្នែកធនធាន

ការសិក្សាបានបង្ហាញយ៉ាងច្បាស់ថាកង្វះធនធាន និងព័ត៌មាននានាគឺជាឧបសគ្គចម្បងផ្សេងទៀតដែលរារាំងការធ្វើសកម្មភាពឆ្លើយតបជាលក្ខណៈបុគ្គលរបស់ប្រជាជន ក្រៅពីជំនួយគាំទ្រពីសំណាក់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ភាគីពាក់ព័ន្ធពិសេសរាជរដ្ឋាភិបាលដែលបានចូលរួមក្នុងការសិក្សានេះក៏បានទទួលស្គាល់ផងដែរថាសមាជិកសហគមន៍ជាពិសេសអ្នកនៅតាមតំបន់ជនបទ តែងតែខ្វះខាតធនធាននានា ដើម្បីធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលនៃធាតុអាកាស បរិស្ថាន និងធនធាន។ ឧទាហរណ៍ ពួកគាត់បានសង្កេតឃើញថាធនធានទឹកកាន់តែមានតិចទៅៗ ហើយគ្រោះមហន្តរាយដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួតបានធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់កសិករក្នុងការរកប្រាក់ចំណូលហើយជារឿយៗវាបានជំរុញឲ្យពួកគាត់ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ។

តាមរយៈការអង្កេតប្រជាជនកម្ពុជាភាគច្រើន (៧០%) បាននិយាយថាពួកគាត់អាចនឹងមិនធ្វើសកម្មភាពឆ្លើយតបបាននោះទេ បើសិនពួកគាត់ខ្វះខាតធនធានចាំបាច់នានាដូចជា លុយកាក់ និងសម្ភារ/ឧបករណ៍ដើម្បីធ្វើសកម្មភាព។ ប្រជាជនដែលបានរាយការណ៍ថាជីវភាពរស់របស់ពួកគាត់បានធ្លាក់ចុះក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ បានលើកឡើងច្រើនពីបញ្ហាកង្វះខាតធនធានចាំបាច់ដែលមានរហូតដល់ ៧៩% បើប្រៀបធៀបនឹងប្រជាជនដែលមានជីវភាពប្រសើរឡើង (មានត្រឹមតែ ៦៩%)។ បើមើលទៅតាមតំបន់ភូមិសាស្ត្រសិក្សានីមួយៗលទ្ធផលនៃការសិក្សាបង្ហាញថា ប្រជាជនរស់នៅតំបន់ទន្លេសាប

(៧៥%) និងតំបន់ឆ្នេរ (៧៩%) មានចំនួនច្រើនជាងគេដែលនិយាយថាពួកគាត់ខ្វះធនធានសម្រាប់ធ្វើសកម្មភាពឆ្លើយតប។

ការទទួលបានព័ត៌មានគឺមានសារៈសំខាន់ណាស់សម្រាប់ដោះស្រាយបញ្ហានេះ។ ក្នុងនោះផងដែរ ប្រជាជនជិតពីរភាគបី (៦៣%) បានលើកឡើងថាពួកគាត់នឹងមិនធ្វើសកម្មភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនោះទេបើសិនជាពួកគាត់ខ្វះលទ្ធភាពទទួលបានព័ត៌មាន។ លទ្ធផលនេះគឺប្រហាក់ប្រហែលគ្នានឹងចំនួនប្រជាជនកម្ពុជា (៦៣%) ដែលបាននិយាយថាពួកគាត់មិនយល់ដឹងអំពីវិធីសាស្ត្រក្នុងការឆ្លើយតបនោះទេ។ ប្រជាជនរស់នៅតំបន់ឆ្នេរភាគច្រើន (៧០%) និយាយថាពួកគាត់មិនដឹងពីរបៀបធ្វើសកម្មភាពនេះទេ។ ស្ថានភាពសេដ្ឋកិច្ចសង្គមក៏ជាកត្តារារាំងមួយក្នុងការធ្វើសកម្មភាពឆ្លើយតបផងដែរ ដោយក្នុងនេះប្រជាជនដែលមានកម្រិតនៃការអប់រំ និងប្រាក់ចំណូលទាបហាក់ដូចជាបានរាយការណ៍ច្រើនជាងគេក្នុងការដែលមិនបានធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលទាំងនោះ ដោយសារតែកង្វះលទ្ធភាពទទួលយកព័ត៌មាន និងមិនដឹងពីរបៀបនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ទោះបីជាមានអ្នកឆ្លើយតបសម្ភាសន៍មួយចំនួនបានយល់ថាការធ្វើសកម្មភាពរបស់ពួកគាត់ ហាក់មិនទាន់ប្រសិទ្ធភាពគ្រប់គ្រាន់ក៏ដោយក៏ប្រជាជនភាគច្រើន (៥៤%) មិនយល់ស្របនឹងគំនិតដែលថាការធ្វើសកម្មភាពឆ្លើយតបមិនមែនជាទំនួលខុសត្រូវរបស់ពួកគាត់។ ប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមខ្ពស់កាន់តែមិនយល់ស្របនឹងការលើកឡើងថា ការធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមិនមែនជាទំនួលខុសត្រូវរបស់ខ្លួន (ដែលក្នុងនោះមានអ្នកប្រកបការងារអាជីពចំនួន ៧១% រីឯកសិករ និងអ្នកនេសាទមានត្រឹមតែ ៥០%)។ ការសិក្សាបង្ហាញយ៉ាងច្បាស់ថាក្រុមប្រជាជនដែលងាយរងគ្រោះ ឬមានជីវភាពខ្វះខាតត្រូវការពឹងផ្អែកខ្លាំងទៅលើជំនួយពីខាងក្រៅ។ វាក៏បង្ហាញផងដែរថាមនុស្សជាច្រើនមិនបោះបង់ការទទួលខុសត្រូវទាំងស្រុងរបស់ពួកគាត់ ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិស្ថានដគាត់មានចំណេះដឹង ការជួយគាំទ្រ និងមានធនធានគ្រប់គ្រាន់។

*«យើងមិនធ្វើសកម្មភាពឆ្លើយតបដោយសារតែខ្វះបទពិសោធន៍ ចំណេះដឹង ធនធាន និងដើមទុននៅមានកម្រិតដើម្បីធ្វើសកម្មភាពមួយចំនួន»*។ លើកឡើងដោយការពិភាក្សាជាក្រុមដែលមានទាំងបុរស និងស្ត្រីនៅខេត្តកំពង់ធំ

### ៣.៧.១.៣ ឧបសគ្គផ្នែកសង្គម

លទ្ធផលនៃការសិក្សា KAP៣ បង្ហាញថាឧបសគ្គសំខាន់ទីបីរបស់ប្រជាជនកម្ពុជាដែលរារាំងដល់ការធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុគឺឧបសគ្គផ្នែកសង្គម។ ឧបសគ្គទាំងនេះរួមមាន កង្វះការគាំទ្រពីមិត្តភក្ត្រ/អ្នកនៅជុំវិញខ្លួន ព្រមទាំងការដែលមិនសូវមើលឃើញថាវាមានភាពបន្ទាន់ក្នុងការដោះស្រាយដែលចំណុចទាំងនេះមានទំនាក់ទំនងទៅនឹងបទដ្ឋាននៅក្នុងសហគមន៍ និងអាទិភាពរបស់បុគ្គលម្នាក់ៗ។

ឧបសគ្គផ្នែកសង្គមដែលត្រូវបានលើកឡើងច្រើនបំផុតនោគឺ ប្រជាជនមានអាទិភាពផ្សេងៗទៀតដែលត្រូវដោះស្រាយសិន (៦១%)។ ក្នុងនោះប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរភាគច្រើន (៧១%)

បានលើកឡើងពីឧបសគ្គបែបនេះច្រើនជាងគេ។ ស្ថានភាពសេដ្ឋកិច្ចសង្គមគឺជាកត្តាជំរុញឲ្យមានឧបសគ្គនេះផងដែរ ខណៈប្រជាជនក្រីក្របានលើកឡើងច្រើនជាងគេថាពួកគាត់មានអាទិភាពផ្សេងទៀតដែលរារាំងក្នុងការធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិស្ថាន របបធាតុអាកាស និងធនធានដែលមានស្រាប់។ ឧបសគ្គផ្នែកសង្គមទីពីរគឺ ពួកគាត់មិនស្គាល់នរណា ដែលបានធ្វើសកម្មភាពឆ្លើយតបនោះទេ ដែលបញ្ហានេះត្រូវបានលើកឡើងដោយប្រជាជនប្រមាណ ៥៩%។

ឧបសគ្គផ្នែកសង្គមដែលគួរឲ្យកត់សម្គាល់ផ្សេងទៀតនោះគឺប្រជាជនប្រមាណ ៤២% ជឿថាគ្រួសាររបស់ពួកគាត់នឹងមិនយល់ព្រមឲ្យពួកគាត់ធ្វើសកម្មភាពឆ្លើយតបនោះទេ។ ការឆ្លើយតបចំពោះសំណួរនេះមានការប្រែប្រួលទៅតាមប្រភេទនៃក្រុមអាយុ ដោយក្រុមប្រជាជនដែលមានអាយុចាប់ពី៤៥-៥៥ឆ្នាំ (៤៩%) មានចំនួនច្រើនជាងក្រុមប្រជាជនអាយុ២៥-៣៤ឆ្នាំ (៣៧%) ដែលពួកគេហាក់មិនសូវជាគិតថាមានការលើកទឹកចិត្តពីក្រុមគ្រួសាររបស់ពួកគេ ក្នុងការធ្វើសកម្មភាពឆ្លើយតបនោះទេ។

សាសនា និងជំនឿមិនមែនជាឧបសគ្គចំបងដែលរារាំងដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនោះទេដោយសារមានប្រជាជនភាគច្រើន (៥៦%) មិនបានយល់ស្របថាសាសនា ឬជំនឿរបស់ពួកគាត់គឺជាហេតុផលដែលរារាំងពួកគាត់ក្នុងការធ្វើសកម្មភាពឆ្លើយតបនោះឡើយ។

ក្រៅពីនេះបញ្ហាទាក់ទងនឹងការមិនធ្វើសកម្មភាពឆ្លើយតប ដោយសារតែកត្តាខ្លាចមានហានិភ័យដែលកត្តានេះមានតួលេខទាបជាងគេបំផុតពីព្រោះមានតែប្រជាជនកម្ពុជាចំនួន ៣៨% ប៉ុណ្ណោះដែលនិយាយថាការព្យាយាមសាកល្បងធ្វើអ្វីដែលថ្មីគឺមានភាពប្រថុយប្រថានច្រើន និងបានរារាំងពួកគាត់មិនឲ្យធ្វើសកម្មភាពឆ្លើយតប។ ប្រជាជនដែលមានឆន្ទៈធ្វើការផ្លាស់ប្ដូរជីវភាពរស់នៅរបស់ពួកគាត់ (៦៨%) ជាអ្នកដែលយល់ស្របច្រើនជាងអ្នកដែលមិនមានឆន្ទៈក្នុងការផ្លាស់ប្ដូរ (៤៩%) ថាវាមានភាពប្រថុយប្រថានខ្លាំងក្នុងការសាកល្បងធ្វើអ្វីថ្មីដើម្បីឆ្លើយតប។

## ៣.៧.២ កត្តាជំរុញក្នុងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ

កត្តាដែលជំរុញទឹកចិត្តឲ្យប្រជាជនកម្ពុជាធ្វើសកម្មភាព ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃធនធានដែលមានស្រាប់ និងរបបធាតុអាកាស ត្រូវបានបកស្រាយបន្ថែមនៅក្នុងផ្នែកនេះ[65]។ ការថែរក្សាសុខភាពឲ្យបានល្អ និងបញ្ហាអនាគតកូនៗរបស់ពួកគាត់គឺជាកត្តាជំរុញទឹកចិត្តធំជាងគេរបស់ពួកគាត់ក្នុងការធ្វើសកម្មភាឆ្លើយតប។

ប្រជាជនកម្ពុជាភាគច្រើនបានយល់ស្របថាពួកគាត់នឹងធ្វើសកម្មភាពឆ្លើយតប ដោយសារតែពួកគាត់ចង់បានអនាគតល្អប្រសើរសម្រាប់កូនៗ (៩៨%) ចង់មានសុខភាពល្អ (៩៨%) ចង់ធ្វើអ្វីមួយដើម្បីថែរក្សារបៀបរបបរស់នៅរបស់ពួកគាត់ (៩៦%) ឬយកចិត្តទុកដាក់ចំពោះបរិស្ថាន (៩៥%)។ អ្នកឆ្លើយតបសម្ភាសន៍តិចតួចប៉ុណ្ណោះដែលបានលើកឡើងថា ពួកគាត់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួល

[65] QS2 "ប្រជាជនមួយចំនួនបានលើកពីហេតុផលមួយចំនួនដែលពួកគាត់បានឆ្លើយតបនឹងផលប៉ះពាល់នានាដែលគាត់បានជួបប្រទះ។ ចំពោះឃ្លា/ប្រយោគ ដែលខ្ញុំបានអានខាងក្រោមនេះ សូមអ្នកប្រាប់ថាតើអ្នកយល់ស្រប ឬមិនយល់ស្របទៅនឹងហេតុផលដែលជំរុញទឹកចិត្តឲ្យអ្នកឆ្លើយតប/ធ្វើសកម្មភាព" ។

អាកាសធាតុដើម្បីផ្សារភ្ជាប់ជាមួយការរកប្រាក់ចំណូល ឬសន្សំប្រាក់បន្ថែម និងដើម្បីធ្វើឲ្យមានអារម្មណ៍ល្អប្រសើរ ខណៈអ្នកឆ្លើយតបសម្ភាសន៍រហូតដល់៩១% បានចាត់ទុកកត្តាជំរុញទាំងពីរនេះជាចំណុចសំខាន់សម្រាប់ការធ្វើសកម្មភាពឆ្លើយតប។ ការធ្វើសកម្មភាពឆ្លើយតបដោយសារតែមានបុគ្គលដទៃទៀតកំពុងធ្វើសម្មភាពដែរ (៨៨%) និងដោយសារតែមានព័ត៌មានគ្រប់គ្រាន់ដើម្បីឆ្លើយតប (៨២%) គឺជាកត្តាជំរុញលើកទឹកចិត្តតិចជាងគេសម្រាប់ប្រជាជនក្នុងការធ្វើសកម្មភាពឆ្លើយតប បើធៀបនឹងកត្តាផ្សេងទៀត។




**រូបភាពទី២០៖ កត្តាជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប**

ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងការយល់ស្របទៅនឹងកត្តាជំរុញទឹកចិត្តនានាដែលបានពិភាក្សានៅផ្នែកខាងលើ។ ចំណុចនេះមានន័យថាប្រជាជនដែលមានចំណេះដឹង/ព័ត៌មានកាន់តែច្រើននោះពួកគាត់ក៏មានការជំរុញលើកទឹកចិត្តកាន់តែខ្ពស់ក្នុងការធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែរ។ ប្រជាជនរស់នៅតំបន់ជនបទហាក់ដូចជាបានរាយការណ៍ច្រើនជាងគេថាបើមានការជំរុញទឹកចិត្តផ្សេងៗនោះអាចជួយឲ្យពួកគាត់ ធ្វើសកម្មភាពឆ្លើយតបបានច្រើនដែរ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺអ្នកឆ្លើយតបសម្ភាសន៍ដែលស្ថិតក្រុមដែលមានអាយុច្រើនជាងគេ (ចាប់ពី៤៥-៥៥ឆ្នាំ) យល់ស្របច្រើនជាងគេថា កត្តាជំរុញទឹកចិត្តដែលបានលើកឡើងទាំងនេះគឺអាចជួយពួកគាត់ឲ្យធ្វើសកម្មភាពឆ្លើយតប។ កត្តាទាំងនេះអាចបង្ហាញថាប្រជាជននៅតំបន់ជនបទ និងអ្នកដែលមានវ័យចំណាស់ងាយទទួលយកកត្តាជំរុញនានា ដើម្បីធ្វើសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលនានានៃរបបធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់។

ការស្រាវជ្រាវបែបគុណវិស័យបានរកឃើញថាមានកត្តាផ្សេងៗទៀត ដែលបានជួយប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតប។ កត្តាជំរុញទាំងនេះរួមមាន ការជួយគាំទ្រ និងការលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋាន

និងការចែករំលែកព័ត៌មាន (ជាពិសេសសម្រាប់អ្នកដែលមិនសូវមានបណ្តាញទំនាក់ទំនង ឬអ្នកដែលមិនសូវមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល) ពីបុគ្គលគម្រូនានាដូចជា មេភូមិ និងអ្នកដឹកនាំសាសនា ការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស ឬកម្លាំងពលកម្មដើម្បីអនុវត្តសកម្មភាពនានា។ អ្នកតបសម្ភាសន៍ ដែលបានចូលរួមក្នុងការសិក្សាមកពីស្ថាប័នរដ្ឋាភិបាលក៏បានទទួលស្គាល់ផងដែរថាសកម្មភាពនៃការជំរុញទឹកចិត្តគឺផ្សារភ្ជាប់ទៅនឹងសមត្ថភាពក្នុងការបន្សាំជារួមរបស់ប្រជាជនផងដែរ។ ពួកគាត់បានឆ្លុះបញ្ចាំងថា ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើភាពធន់របស់ប្រជាជន។ ឧទាហរណ៍ ប្រជាជនរស់នៅតំបន់ទីក្រុងមានហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងសេវាសុខភាពប្រសើរជាង ដូច្នេះសមត្ថភាពបន្សាំរបស់ពួកគាត់ក៏ខ្ពស់ជាងប្រជាជនដែលរស់នៅតំបន់ជនបទដែរ។

### ៣.៧.៣ ឥទ្ធិពលនៃតួនាទី និងផ្នត់គំនិតយេនឌ័រពាក់ព័ន្ធនឹងការធ្វើសកម្មភាពឆ្លើយតប

បុរសភាគច្រើនដែលរស់នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា ប្រកបរបបកសិកម្ម និងនេសាទដែលងាយរងគ្រោះខ្លាំងដោយសារឥទ្ធិពលនៃអាកាសធាតុ ចំណែកឯស្ត្រីវិញជាទូទៅ ត្រូវបានគេរំពឹងថាជាអ្នកមើលថែទាំគ្រួសារនិងកូនៗ (បូករួមទាំងការផ្គត់ផ្គង់ទឹកស្អាត និងចំណីអាហារក្នុងគ្រួសារ) បន្ថែមលើការងារកសិកម្ម ឬសកម្មភាពបង្កើតប្រាក់ចំណូលផ្សេងទៀត។ បន្ទុកការងារដ៏ធ្ងន់នេះបានកើនឡើងទ្វេដងចំពោះស្ត្រី ជាពិសេសក្នុងចំណោមគ្រួសារដែលមានប្តីធ្វើចំណាកស្រុកដោយទុកឲ្យស្ត្រីជាអ្នកមើលការខុសត្រូវក្នុងគ្រួសារតែម្នាក់ឯងក្នុងរយៈពេលវែង និងបានធ្វើឲ្យស្ត្រីកាន់តែងាយរងគ្រោះ ជាពិសេសក្នុងអំឡុងពេលមានព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរកើតឡើង។

***«បុរសអាចទៅរកការងារសំណង់នៅកន្លែងផ្សេងៗដើម្បីរកប្រាក់ចំណូលបន្ថែម ប៉ុន្តែស្ត្រីមានការងារផ្ទះ និងត្រូវមើលថែកូនៗ ឪពុកម្តាយចាស់ជរា និងសត្វចិញ្ចឹម។»*** *លើកឡើងដោយក្រុមពិភាក្សាជាស្ត្រីនៅខេត្តកំពត*

ការអង្កេតបែបបរិមាណវិស័យបានរកឃើញភស្តុតាងស្តីពី ការចាក់ឫសគល់នៃតួនាទីយេនឌ័រដែលបានដាក់បន្ទុកយ៉ាងខ្លាំងមកលើស្ត្រី ដែលមិនសូវទទួលបានអំណាចក្នុងការធ្វើការសម្រេចចិត្តចាំបាច់នានា។ ប្រជាជនចំនួនប្រាំបួននាក់ក្នុងចំណោមដប់នាក់ (៨៩%) បានយល់ស្របថា «ស្ត្រីមានតួនាទីមើលថែទាំផ្ទះ និងគ្រួសារ»[66] ហើយអ្នកឆ្លើយតបសម្ភាសន៍ទាំងបុរស និងស្ត្រីក៏បានយល់ស្របនឹងការលើកឡើងបែបនេះផងដែរ។ ដោយឡែកប្រជាជនរស់នៅតំបន់ជនបទ (៦៣%) មានច្រើនជាងប្រជាជននៅតំបន់ទីក្រុង/ប្រជុំជន (៥៥%) ដែលបានយល់ស្របយ៉ាងខ្លាំងទៅលើចំណុចនេះ។ វាមិនមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ នៅពេលដែលមានប្រជាជនវ័យចំណាស់ច្រើនជាងប្រជាជនក្នុងវ័យផ្សេងៗទៀតបានយល់ស្របពីតួនាទីរបស់ស្ត្រីក្នុងការមើលថែទាំផ្ទះ និងគ្រួសារ។ ការសិក្សាកន្លងមកក៏បានបង្ហាញផងដែរថា

---

[66] QS3 ខ្ញុំនឹងអានឃ្លាខាងក្រោមនេះដែលទាក់ទងនឹងលទ្ធភាពរបស់ស្ត្រីក្នុងការបន្សាំទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងការប្រែប្រួលធាតុអាកាស។ ខ្ញុំនឹងអានឃ្លានីមួយៗសូមអ្នកបង្ហាញថាអ្នកយល់ស្រប ឬមិនយល់ស្រប។

ប្រជាជនកម្ពុជាកំពុងជួបប្រទះការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់ដូចគ្នា ប៉ុន្តែផលប៉ះពាល់នៃការប្រែប្រួលនេះអាចជះឥទ្ធិពលទៅលើបុរស និងស្ត្រីខុសៗគ្នាដោយសារតែការបែងចែកការងាររវាងភេទទាំងពីរផ្អែកទៅលើបទដ្ឋានយេនឌ័រនៅក្នុងសង្គមកម្ពុជា (Sao, et al., ២០២០)។




**រូបភាពទី២១៖ ការយល់ស្របនឹងប្រយោគនានាពាក់ព័ន្ធនឹងតួនាទីយេនឌ័រ**

ប្រជាជនកម្ពុជាជិតបីភាគបួន (៧២%) បានយល់ស្របនឹងការលើកឡើងដែលថា «បុរសគឺជាអ្នកសម្រេចចិត្តចុងក្រោយនៅក្នុងគ្រួសារទាក់ទងនឹងសកម្មភាពបន្សាំ»។ ក្នុងនោះដែរចំនួនបុរស (៧៦%) ច្រើនជាងស្ត្រី (៦៩%) ដែលបានយល់ស្របនឹងការលើកឡើងបែបនេះ ហើយក្រុមប្រជាជនដែលមានអាយុច្រើនជាងគេ (ចាប់ពី៤៥-៥៥ឆ្នាំ) កាន់តែមានភាគរយច្រើនជាងគេ (៨៤%) ក្នុងការបង្ហាញពីការយល់ស្របចំពោះចំណុចនេះ។ ការសិក្សាក៏បង្ហាញផងដែរថាមិនមានភាពខុសប្លែកគ្នាច្រើនរវាងអ្នករស់នៅតំបន់ទីក្រុង/ប្រជុំជន (៧៤%) និងជនបទ (៦៩%) ពាក់ព័ន្ធនឹងការយល់ស្របទៅនឹងការលើកឡើងខាងលើនេះដែរ។ ដោយឡែកប្រជាជនដែលរស់នៅតំបន់ភ្នំ (៧៩%) មានការយល់ស្របច្រើនជាងគេចំពោះការលើកឡើងថាបុរសគួរជាអ្នកសម្រេចចិត្ត បើធៀបនឹងប្រជាជនដែលរស់នៅតំបន់ផ្សេងៗទៀត។ ទិន្នន័យបែបគុណវិស័យ ដែលបានប្រមូលនៅក្នុងខេត្តមួយនៃតំបន់ភ្នំនេះក៏បានគាំទ្រទៅនឹងលទ្ធផលនៃការសិក្សានេះផងដែរ ដោយប្រជាជនជាច្រើនមានអារម្មណ៍ថាបុរសគួរតែធ្វើការសម្រេចចិត្តចុងក្រោយ ដោយសារតែបុរសជាអ្នករកប្រាក់ចំណូលចំបងចិញ្ចឹមគ្រួសារ មានបទពិសោធន៍ច្រើន និងកម្លាំងខ្លាំងក្លាជាងស្ត្រី។ សរុបមកស្ត្រីនៅកម្ពុជាជាទូទៅទុកចិត្តទៅលើបុរសក្នុងការធ្វើការសម្រេចចិត្តធំៗក្នុងគ្រួសារ ហើយជាធម្មតាស្ត្រីធ្វើការសម្រេចចិត្តតែលើការងារណាដែលជាការចំណាយតិចតួចប៉ុណ្ណោះ លើកលែងតែករណីដែលប្តីរបស់ពួកគាត់អវត្តមាន ដោយសារតែការធ្វើចំណាកស្រុកដែលស្ត្រីត្រូវធ្វើការសម្រេចចិត្តចុងក្រោយ (Sao, et al., ២០២០)។

*«បុរស និងស្ត្រីបានពិភាក្សាគ្នាមុនពេលធ្វើការសម្រេចចិត្ត ប៉ុន្តែបុរសជាអ្នកសម្រេចចុងក្រោយព្រោះគាត់ជាអ្នករកប្រាក់ចំណូលក្នុងគ្រួសារ។ លើសពីនេះទៀតស្ត្រីមិនអាចធ្វើការងារប្រើកម្លាំងធ្ងន់ៗដូចបុរសទេដូចជា ទៅកាប់អុស លីសែងស្រូវទាំងបាវៗ និងបូមទឹកជាដើម។»* *លើកឡើងដោយការពិភាក្សាជាក្រុមដែលមានទាំងបុរស និងស្ត្រីនៅខេត្តកំពង់ស្ពឺ*



ស្ត្រីមេផ្ទះមួយរូបកំពុងចំអិនម្ហូបអាហារសម្រាប់ក្រុមគ្រួសាររបស់គាត់

បញ្ហាបិតាធិបតេយ្យ និងឋានានុក្រមនៅតែកើតមានឡើងក្នុងសង្គមកម្ពុជា ហើយស្ត្រីនៅតែបន្តប្រឈមនឹងការរើសអើងផ្នែកនយោបាយ និងសេដ្ឋកិច្ច (MoWAs, ២០១៤)។ ការលើកឡើងបែបនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងការសិក្សាបែបគុណវិស័យរបស់ KAP៣ ដែលរកឃើញថាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងស្ត្រីដែលមានសមាជិកគ្រួសារមានពិការភាពជួបប្រទះការលំបាកច្រើនជាងអ្នកដទៃក្នុងការស្វែងរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ។

ទោះជាយ៉ាងណា នៅពេលដែលគេសួរអំពីការចូលរួមក្នុងវិស័យនយោបាយរបស់ស្ត្រីប្រជាជនកម្ពុជាភាគច្រើន (៩៣%) បានយល់ស្របថា «ស្ត្រីគួរតែបញ្ចេញមតិរបស់ពួកគាត់ឲ្យកាន់តែច្រើននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងសហគមន៍ និងការប្រជុំសាធារណៈនានា»។ បើទោះបីជាបញ្ហាយេនឌ័រមិនមានឥទ្ធិពលលើការយល់ស្របទៅនឹងការលើកឡើងនេះក៏ដោយក៏លទ្ធផលសិក្សាបង្ហាញថា កម្រិតនៃការអប់រំ និងអាយុរបស់អ្នកឆ្លើយតបសម្ភាសន៍មានឥទ្ធិពលទៅលើការគិតបែបនេះ។ ជាក់ស្តែងក្រុមមនុស្សចាស់ និងអ្នកដែលមានកម្រិតនៃការអប់រំខ្ពស់មានការយល់ស្របថាស្ត្រីគួរចូលរួមបញ្ចេញមតិ និងសម្រេចចិត្ត។ ចំនុចនេះបង្ហាញថាជាទ្រឹស្តីមនុស្សឲ្យតម្លៃទៅលើមតិយោបល់របស់ស្ត្រី ដែលត្រូវបានបង្ហាញជាសាធារណៈ ប៉ុន្តែនៅក្នុងស្ថានភាពជាក់ស្តែងស្ត្រីកម្រនឹងចូលរួមក្នុងវេទិកា ឬការប្រជុំនានា ជាពិសេសពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងអាកាសធាតុ ហើយបញ្ហាទាំងនេះធ្វើឲ្យឱកាសរបស់ពួកគាត់ក្នុងការរៀនសូត្រ និងចែករំលែកព័ត៌មានកាន់តែមានតិចតួចដែរ (Sao, et al., ២០២០)។

**ករណីសិក្សាទី ៤៖ស្ត្រីមេម៉ាយជាម្ដាយម្នាក់និយាយអំពីការដោះស្រាយបញ្ហាកង្វះទឹក**[67]

ស៊ីណាជាស្ត្រីមេម៉ាយម្នាក់រស់នៅតំបន់ភ្នំនៃខេត្តកំពង់ស្ពឺ និងរស់នៅជាមួយកូនប្រុសរបស់គាត់ដែលមានពិការភាពម្នាក់។ គាត់ជាមេគ្រួសារ និងជាអ្នករកប្រាក់ចំណូលតែម្នាក់ឯងក្នុងគ្រួសារ ហើយទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារបញ្ហាកង្វះទឹក។

ស៊ីណាជាកសិករធ្វើស្រែតាមបែបប្រពៃណី និងពឹងផ្អែកទាំងស្រុងលើប្រភពទឹកពីធម្មជាតិ សម្រាប់ការងារកសិកម្មរបស់គាត់។ ប៉ុន្តែគ្រោះរាំងស្ងួតជាទូទៅធ្វើឲ្យគាត់គ្មានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពផលដំណាំរបស់គាត់នោះទេ។ របបទឹកភ្លៀងតិចតួចនេះបានបង្កឲ្យមានការលំបាកយ៉ាងខ្លាំងដល់ស៊ីណាក្នុងការស្វែងរកទឹក និងរក្សាទុកទឹកភ្លៀងសម្រាប់ការប្រើប្រាស់ក្នុងគ្រួសាររបស់គាត់។ ដើម្បីស្វែងរកចំណូលបន្ថែមក្នុងការផ្គត់ផ្គង់គ្រួសារ ស៊ីណាបានទៅស៊ីឈ្នួលគេនៅក្នុងចម្ការអំពៅដែលនៅក្បែរតំបន់គាត់រស់នៅនាពេលដែលរដូវធ្វើស្រែត្រូវបានបញ្ចប់។

លទ្ធភាពទទួលបានទឹកប្រើប្រាស់កាន់តែពិបាកខ្លាំងសម្រាប់ស៊ីណា ដោយសារតែស្ថានភាពផ្ទាល់ខ្លួនរបស់គាត់។ គាត់ត្រូវបានសហគមន៍/អ្នកភូមិរើសអើងគាត់ដោយសារតែកូនរបស់គាត់មានពិការភាព និងជួបបញ្ហាពិបាកក្នុងការធ្វើអនាម័យខ្លួនឯង។ ដូចនេះហើយគាត់ត្រូវបានគេរើសអើងដោយមិនឲ្យទៅប្រើប្រាស់ទឹកអណ្ដូងរួមនៅក្នុងសហគមន៍/ភូមិរបស់គាត់ទេ។ ជាលទ្ធផលគាត់គ្មានជម្រើសអ្វីក្រៅពីជីកកាយធ្វើអណ្ដូងដោយដៃខ្លួនឯងផ្ទាល់ដោយមិនបានជួលកម្លាំងពលកម្មពីប្រភពខាងក្រៅទេព្រោះគាត់មិនមានលទ្ធភាពក្នុងការចំណាយលុយជួលគេធ្វើនោះទេ ។

## ៣.៨ ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទង

### ៣.៨.១ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ

ផ្នែកនេះគេពិនិត្យមើលការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ដើម្បីប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយប្រជាជនវាមានសារៈសំខាន់ណាស់ដែលគេត្រូវស្វែងយល់ថា តើអ្វីខ្លះដែលពួកគាត់ចង់ដឹង ប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះដែលពួកគាត់ប្រើប្រាស់ តើនរណាខ្លះដែលពួកគាត់ពិភាក្សាជាមួយ និងទុកចិត្តជាងគេ ជាពិសេសតើពួកគាត់ចង់ទទួលបានព័ត៌មានតាមវិធីណាខ្លះ។

[67] ករណីសិក្សានេះត្រូវបានរកឃើញនៅពេលធ្វើការពិភាក្សាជាក្រុមជាមួយស្ត្រីងាយរងគ្រោះ




រូបភាពទី ២២៖ ប្រព័ន្ធផ្សព្វផ្សាយដែលបានប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំចុងក្រោយ

### *៣.៨.១.១ ការប្រើប្រាស់ទូរស័ព្ទដៃ*

ទូរស័ព្ទដៃគឺជាឧបករណ៍ទំនាក់ទំនងដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងចំណោមប្រជាជនកម្ពុជា។ ក្នុងនោះ ប្រជាជនចំនួន ៩០% បានរាយការណ៍ថាពួកគាត់បានប្រើប្រាស់វាមិនថានៅផ្ទះ ឬក៏កន្លែងផ្សេងៗនោះទេក្នុងអំឡុងពេលមួយខែចុងក្រោយ។[68] បើទោះជាអត្រាអ្នកប្រើប្រាស់ទូរស័ព្ទខ្ពស់ក៏ពិតមែនតែលទ្ធផលបង្ហាញថា កម្រិតនៃការប្រើប្រាស់ទូរស័ព្ទដៃរបស់ក្រុមប្រជាជនទាំងអស់មិនសុទ្ធតែស្មើៗគ្នានោះទេ ដោយបុរស (៩៤%) និងអ្នករស់នៅទីក្រុង/ប្រជុំជន (៩៥%) មានទូរស័ព្ទដៃសម្រាប់ប្រើប្រាស់ច្រើនជាងស្ត្រី (៨៦%) និងប្រជាជនរស់នៅតំបន់ជនបទ (៨៨%)។ អ្នកឆ្លើយតបសម្ភាសន៍ដែលមានអាយុតិចជាងគេក្នុងចន្លោះពី ១៤-២៤ឆ្នាំ មាន (៩៣%) ប្រើប្រាស់ទូរស័ព្ទដៃច្រើនជាងក្រុមមនុស្សចាស់ដែលមានអាយុចន្លោះពី ៤៥-៥៥ឆ្នាំ (៨១%)។ អ្នកដែលមានទូរស័ព្ទប្រើស្ទើរតែទាំងអស់គ្នា (៩៥%)[68]បានប្រើប្រាស់ទូរស័ព្ទប្រភេទស្មាតហ្វូន។ ដោយឡែកប្រជាជននៅតាមជនបទដែលប្រើទូរស័ព្ទមិនសូវជាមានលទ្ធភាពប្រើប្រាស់ទូរស័ព្ទប្រភេទទូរស័ព្ទដៃទំនើបច្រើនដូចអ្នករស់នៅតំបន់ទីក្រុង/ប្រជុំជន

---

[68] QMC8 «តើអ្នកមានទូរស័ព្ទដៃទំនើប ដែរឬទេ? »

នោះទេ។ នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចសង្គមមានទំនាក់ទំនងនឹងលទ្ធភាពមានទូរស័ព្ទដៃទំនើបប្រើប្រាស់សម្រាប់អ្នកមានជីវភាពធូរធារអាចនឹងមានលទ្ធភាពច្រើនជាងក្នុងការប្រើប្រាស់ទូរស័ព្ទប្រភេទនេះ។




រូបភាពទី ២៣៖ រយៈពេលចំណាយក្នុងការប្រើប្រាស់ទូរស័ព្ទដៃតាមក្រុមអាយុ

ការហៅទូរស័ព្ទចេញ ឬចូលគឺជាហេតុផលដែលត្រូវបានប្រជាជនលើកឡើងច្រើនជាងគេបំផុត (៨៦%) សម្រាប់តម្រូវការក្នុងការប្រើប្រាស់ទូរស័ព្ទ។ ហេតុផលនេះត្រូវបានលើកឡើងដោយក្រុមមនុស្សចាស់ដែលមានអាយុចាប់ពី ៤៥-៥៥ឆ្នាំ ប្រមាណ ៩៤%[69] ដែលមានចំនួនច្រើនជាងក្រុមមនុស្សអាយុចាប់ពី ១៥-២៤ឆ្នាំ ដែលមានត្រឹមតែ ៧៥%។ បើប្រៀបធៀបតាមក្រុមអាយុនីមួយៗការប្រើប្រាស់បណ្តាញសង្គមតាមទូរស័ព្ទដៃ (ដែលមានប្រជាជនប្រមាណ៥៧% បានប្រើប្រាស់វា) ត្រូវបានប្រើប្រាស់ច្រើនជាងគេក្នុងចំណោមប្រជាជនជាយុវវ័យដែលមានអាយុ ១៥-២៥ឆ្នាំ (៦៩%) រីឯក្រុមមនុស្សចាស់ដែលមានអាយុ ៤៥-៥៥ឆ្នាំ មានត្រឹមតែ ៣៨% ប៉ុណ្ណោះ។ ស្ទើរតែមួយភាគបី (៣២%) នៃអ្នកប្រើប្រាស់ទូរស័ព្ទដៃដែលភាគច្រើនជាក្រុមមនុស្សវ័យក្មេងបាននិយាយថា ពួកគាត់បានប្រើប្រាស់សេវាកម្មព័ត៌មានសំឡេងនៅលើទូរស័ព្ទ (ឧ.ស្តាប់ព័ត៌មាន និងទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីកីឡា)។

ភាគច្រើននៃអ្នកប្រើប្រាស់ទូរស័ព្ទដៃ (៧៩%) រាយការណ៍ថាពួកគាត់បានចំណាយពេលជាងមួយម៉ោងលើទូរស័ព្ទដៃរបស់ពួកគាត់ជារៀងរាល់ថ្ងៃ ដោយឡែកស្ទើរតែពាក់កណ្តាលនៃអ្នកប្រើប្រាស់ទូរស័ព្ទដៃ (៤៧%) បាននិយាយថាពួកគាត់បានចំណាយពេលច្រើនជាង៣ម៉ោង ក្នុងការប្រើប្រាស់ទូរស័ព្ទដៃជាពិសេសគឺការប្រើអ៊ីនធើណេត។[70] លទ្ធផលនេះបានបង្ហាញថានៅកម្ពុជាអ្នកដែលប្រើប្រាស់អ៊ីនធើណេត

[69] MC10 «តើមូលហេតុចំបងអ្វីខ្លះដែលអ្នកប្រើប្រាស់ទូរស័ព្ទដៃ? »

[70] QMC9 «តើអ្នកចំណាយពេលប៉ុន្មានក្នុងការប្រើប្រាស់ទូរស័ព្ទដៃ (រួមទាំងផ្ញើសារ ហៅទូរស័ព្ទចេញចូល ប្រើប្រាស់បណ្តាញសង្គម និងស្វែងរកព័ត៌មានតាមគេហទំព័រ? »

អាចប្រើប្រាស់បានតាមរយៈទូរស័ព្ទដៃមួយរយភាគរយ ដោយឡែកមានតែប្រជាជនប្រមាណ ៧% អាចប្រើអ៊ីនធើណេតដោយប្រើប្រាស់កុំព្យូទ័រ និង ២% ប្រើប្រាស់អ៊ីនធើណេតនៅលើថេបប្លេត។

ប្រជាជនកម្ពុជាប្រមាណបីភាគបួន (៧៦%) ដែលប្រើប្រាស់ទូរស័ព្ទដៃបានលើកឡើងពីការប្រើប្រាស់បណ្តាញសង្គមនៅក្នុងអំឡុងមួយឆ្នាំចុងក្រោយនេះផងដែរ។ អ្នកដែលបាន និងកំពុងប្រើប្រាស់បណ្តាញសង្គមនាពេលថ្មីៗនេះគឺបុរស (៨២%) ច្រើនជាងស្ត្រី (៧១%) អ្នករស់នៅទីក្រុង/ប្រជុំជន (៨៥%) ច្រើនជាងអ្នករស់នៅជនបទ (៧២%) និងក្រុមប្រជាជនអាយុ១៥-២៤ឆ្នាំ (៨៩%) ច្រើនជាងក្រុមមនុស្សចាស់អាយុ ៤៥-៥៥ឆ្នាំ (៥១%)។ ហ្វេសប៊ុក (Facebook) គឺជាបណ្តាញសង្គមដែលត្រូវបានគេប្រើប្រាស់ជាទូទៅច្រើនជាងគេបំផុត (៩៧%)[71] បន្ទាប់មកគឺយូធ្យូប (YouTube) ដែលមានអ្នកប្រើប្រាស់ចំនួន ៩៣% (ដែលក្នុងនោះ ៨២% ប្រើប្រាស់វារាល់ថ្ងៃ)។ ប្រជាជនចំនួន ១៦% ប្រើប្រាស់អ៊ីនស្តាក្រាម (Instagram) ដែលក្នុងនោះភាគច្រើននៃពួកគេជាអ្នករស់នៅទីក្រុង/ប្រជុំជន និងជាក្រុមមនុស្សយុវវ័យ ចំណែកឯកម្មវិធីវដអាប់វិញ (WhatsApp) មានអ្នកប្រើប្រាស់ចំនួនតែ ៦% ប៉ុណ្ណោះ ហើយជាទូទៅពួកគេជាអ្នករស់នៅក្នុងតំបន់ទីក្រុង។

### ៣.៨.១.២ ការប្រើប្រាស់អ៊ីនធើណេត

ប្រជាជនកម្ពុជាប្រមាណ ៧២% បានប្រើប្រាស់អ៊ិនធើណេត ហើយវាត្រូវបានគេប្រើប្រាស់យ៉ាងច្រើនក្នុងចំណោមក្រុមយុវវ័យ/មនុស្សវ័យក្មេង។ ភាគច្រើននៃប្រជាជនដែលមានអាយុ ១៥-២៤ឆ្នាំ (៨៨%) បានរាយការណ៍ថាមានការប្រើប្រាស់អ៊ីនធើណេតច្រើនជាងគេ បើធៀបទៅនឹងក្រុមប្រជាជនអាយុចន្លោះពី៤៥-៥៥ឆ្នាំ ដែលមានត្រឹមតែ ៤៥% ប៉ុណ្ណោះ។ លទ្ធភាពប្រើប្រាស់/ទទួលបានសេវាប្រព័ន្ធអ៊ីនធើណេតសម្រាប់ប្រជាជនដែលរស់នៅតំបន់ទីក្រុង/ប្រជុំជន (៨០%) មានច្រើនជាងអ្នករស់នៅតំបន់ជនបទ (៦៨%)។ បុរស (៧៨%) ត្រូវបានគេរាយការណ៍ថាមានការប្រើប្រាស់អ៊ិនធើណេតច្រើនជាងស្ត្រី (៦៦%) ហើយអ្នកដែលមានកម្រិតនៃការអប់រំខ្ពស់ក៏មានការប្រើប្រាស់វាច្រើនជាងក្រុមដទៃផ្សេងទៀតដែរ។ អ្នកប្រើប្រាស់អ៊ីនធើណេតស្ទើតែទាំងអស់ (៩២%) បាននិយាយថាពួកគាត់បានប្រើវាជារៀងរាល់ថ្ងៃ។[72] បើនិយាយពី

---

[71] QMC7b «តើអ្នកប្រើប្រាស់វាញឹកញាប់កម្រិតណា? តើអ្នកប្រើប្រាស់វា ២ ឬ៣ដងក្នុងមួយថ្ងៃ ម្តងក្នុងមួយថ្ងៃ ២ ឬ៣ដងក្នុងមួយសប្តាហ៍ម្តងក្នុងមួយសប្តាហ៍ ២ ឬ៣ដងក្នុងមួយខែ ម្តងក្នុងមួយខែ ឬតិចជាងម្តងក្នុងមួយខែ?»

[72] QMC1c «តើអ្នកប្រើប្រាស់សេវា ឬឧបករណ៍ខាងក្រោមញឹកញាប់កម្រិតណា? »

ការចំណាយពេលវេលាប្រចាំថ្ងៃលើការប្រើប្រាស់អ៊ីនធើណេតវិញ ប្រជាជនកម្ពុជាចំនួន ២៨% ចំណាយពេលតិចជាងមួយម៉ោង ហើយ ៣៦% ចំណាយពេលច្រើនជាង៣ម៉ោងក្នុងមួយថ្ងៃ។




រូបភាពទី ២៤៖ លទ្ធភាពទទួលបានអ៊ីនធើណេតប្រើប្រាស់តាមក្រុមអាយុ

## ៣.៨.១.៣ ការប្រើប្រាស់ទូរទស្សន៍ និងវិទ្យុ

បន្ទាប់ពីការប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធើណេត ទូរទស្សន៍ក៏ត្រូវបានប្រជាជនចំនួន ៦៨% ប្រើប្រាស់ផងដែរ។ ចំនួនបុរស (តាមការរាយការណ៍បុរស ៧១% បានមើលទូរទស្សន៍ បើធៀបទៅនឹងស្ត្រីមានត្រឹមតែ ៦៥% ប៉ុណ្ណោះ) និងក្រុមប្រជាជនដែលមានអាយុច្រើន (៧៥% នៃក្រុមមនុស្សដែលមានអាយុពី៤៥-៥៥ឆ្នាំ ផ្ទុយពីក្រុមមនុស្សដែលមានអាយុចន្លោះពី១៥-២៤ឆ្នាំ មានត្រឹមតែ ៦៨%) ហាក់ដូចជាមើលទូរទស្សន៍បានច្រើន។ បីភាគបួននៃអ្នកដែលបានមើលទូរទស្សន៍ (៧៣%) បាននិយាយថាពួកគាត់បានមើលទូរទស្សន៍រៀងរាល់ថ្ងៃ។ ប៉ុស្តិ៍ទូរទស្សន៍ដែលពួកគាត់មើលញឹកញាប់ជាងគេបំផុតគឺ ប៉ុស្តិ៍ទូរទស្សន៍ហង្សមាស (៤៩%) បន្ទាប់មកគឺប៉ុស្តិ៍ទូរទស្សន៍ម៉ាយធីវី (៣៧%) ប៉ុស្តិ៍ទូរទស្សន៍បាយ័ន (៣៣%) ទូរទស្សន៍ប៉ុស្តិ៍លេខ៥ (២៥%) ប៉ុស្តិ៍ស៊ីអិនស៊ី (២១%) និងប៉ុស្តិ៍ភីអិនអិន(២១%)។[73] ប្រជាជនកម្ពុជាមានចំនួនច្រើនបានរាយការណ៍ថា បានមើលកម្មវិធីទូរទស្សន៍មួយចំនួនដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។ ក្នុងនោះផងដែរប្រជាជនជាងពាក់កណ្ដាល (៥៣%) នៃចំនួនអ្នកដែលបានមើលទូរទស្សន៍គឺបានមើលកម្មវិធីទូរទស្សន៍ស្តីពីការព្យាករណ៍ជាតុអាកាស ហើយប្រជាជនប្រមាណជា ៣៣% បានមើលកម្មវិធីកសិកម្មរបស់ទូរទស្សន៍បាយ័ន ២៧% បានមើលកម្មវិធីជជែកពិភាក្សាពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា និង ១០% ទៀតបានមើលកម្មវិធីកុំចាំទឹកភ្លៀង។[74]

---

[73] MC2a សូមប្រាប់អំពីប៉ុស្តិ៍ទូរទស្សន៍ដែលអ្នកបានមើលចាប់ពេលចូលឆ្នាំខ្មែរ (មួយឆ្នាំចុងក្រោយ)
[74] MC3a «តើកម្មវិធីទូរទស្សន៍អ្វីខ្លះដែលអ្នកធ្លាប់មើល (តាមទូរទស្សន៍ ឬអនឡាញ)? »

វិទ្យុគឺជាប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានប្រើប្រាស់តិចតួចបំផុត ក្នុងចំណោមអ្នកដែលបានផ្តល់កិច្ចសម្ភាសន៍ដែលមានត្រឹមតែ ២៨% ប៉ុណ្ណោះដែលបានរាយការណ៍ថាបានស្តាប់វិទ្យុក្នុងរយៈពេលមួយឆ្នាំចុងក្រោយ។ ចំនួនបុរសស្តាប់វិទ្យុច្រើនជាងស្ត្រី (បុរស ៣១% និងស្ត្រី ២៤%)។ ប្រជាជនដែលមានអាយុច្រើនគឺជាក្រុមដែលមានការស្តាប់វិទ្យុច្រើនជាងគេ ដោយឡែកការស្តាប់វិទ្យុរវាងអ្នករស់នៅតំបន់ទីក្រុង/ប្រជុំជនជាមួយអ្នករស់នៅតំបន់ជនបទមិនមានភាពខុសគ្នាទេ។ អ្នកដែលបានស្តាប់វិទ្យុស្ទើរតែពីរភាគបី (៦៤%) បានរាយការណ៍ថាបានស្តាប់វិទ្យុជារៀងរាល់ថ្ងៃ។ កម្មវិធីប៉ុស្តិ៍វិទ្យុដែលបានស្តាប់ច្រើនជាងគេគឺវិទ្យុអេប៊ីស៊ីដែលមានកម្មវិធីចរាចរណ៍នៅកម្ពុជា (FM១០៧.៥) (១៥%) វិទ្យុបាយ័ន (៧%) វិទ្យុអាស៊ីសេរី (៦%) វិទ្យុសម្លេងអាស៊ីអាគ្នេយ៍ (៣%) និងសាជីវកម្មផ្សព្វផ្សាយអូស្ត្រាលីដែលហៅថាអេប៊ីស៊ីអូស្ត្រាលី (៣%)[75]។

## ៣.៨.២ ប្រភពព័ត៌មានទាក់ទងនឹងការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធាន

នៅក្នុងផ្នែកនេះត្រូវបានវិភាគអំពីប្រភពនៃព័ត៌មាន ដែលប្រជាជនកម្ពុជាបានទទួលស្គាល់អំពីការប្រែប្រួលនៃធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់។ ក្នុងផ្នែកនេះក៏បានបង្ហាញនូវប្រភពព័ត៌មានដែលប្រជាជនជឿទុកចិត្តបំផុត និងវិធីដែលពួកគាត់ចង់ទទួលបានព័ត៌មានផងដែរ។


ទូទស្សន៍ខ្សែភាពយន្តក្នុងភូមិបណ្តែតទឹកនៃបឹងទន្លេសាប

[75] MC4a «សូមប្រាប់ខ្ញុំថាតើប៉ុស្តិ៍វិទ្យុអ្វីខ្លះដែលអ្នកបានស្តាប់ចាប់តាំងពីបុណ្យចូលឆ្នាំខ្មែរ (មួយឆ្នាំចុងក្រោយ)»

### ៣.៨.២.១ ការទទួលបានព័ត៌មានគ្រប់គ្រាន់អំពីការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធាន[76]

ប្រជាជនកម្ពុជាជាងពាក់កណ្តាល (៥៧%) គិតថាពួកគាត់បានទទួលព័ត៌មានគ្រប់គ្រាន់ស្តីពីការឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ ថាមពល ឬធាតុអាកាស នៅពេលគេសួរអំពីចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគាត់។ ក្នុងចំណោមអ្នកដែលនិយាយថាបានទទួលព័ត៌មានគ្រប់គ្រាន់ មានតែប្រជាជនចំនួន ៩% ប៉ុណ្ណោះដែលយល់ថាពួកគាត់ទទួលបានព័ត៌មានគ្រប់គ្រាន់ខ្លាំង ហើយ ៤៨% ទៀតគិតថាទទួលបានព័ត៌មានគ្រប់គ្រាន់ក្នុងកម្រិតមធ្យម។ ប្រជាជននៅតំបន់ឆ្នេរគឺជាក្រុមដែលមិនសូវទទួលបានព័ត៌មានគ្រប់គ្រាន់ច្រើនជាងគេ ធៀបនឹងតំបន់ផ្សេងទៀត (ដោយមានត្រឹមតែ ៤០% ប៉ុណ្ណោះ) ចំណែកឯប្រជាជននៅតំបន់ទន្លេសាប (៥១% ) ក៏ជាក្រុមដែលទទួលបានព័ត៌មានក្នុងកម្រិតទាបជាងកម្រិតមធ្យមថ្នាក់ជាតិផងដែរ។ ប្រជាជននៅក្នុងតំបន់ទាំងនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ដូច្នេះពួកគាត់ប្រឈមនឹងហានិភ័យអាកាសធាតុខ្ពស់ដែលរារាំងដល់ការស្វែងរកប្រាក់ចំណូល។ នៅពេលដែលពួកគាត់ទទួលបានព័ត៌មានបានតិចជាងក្រុមមនុស្សដទៃដែលរស់នៅតាមបណ្តាខេត្តផ្សេងទៀតនេះបញ្ជាក់ថាពីភាពងាយរងគ្រោះរបស់ពួកគាត់ និងតម្រូវការព័ត៌មានបន្ថែមទៀតដើម្បីឆ្លើយតបនឹងការប្រែប្រួលទាំងនេះ។

### *៣.៨.២.២ ប្រភពព័ត៌មានទូទៅ*

ប្រព័ន្ធផ្សព្វផ្សាយគឺជាប្រភពព័ត៌មានដ៏លេចធ្លោជាងគេ ក្នុងចំណោមប្រភពព័ត៌មានដែលប្រជាជននិយមប្រើប្រាស់ដើម្បីជួយពួកគាត់ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិស្ថាន និងធនធាន[77]។ ប្រជាជនម្នាក់ក្នុងចំណោមបួននាក់បាននិយាយថាពួកគាត់បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (២៥%) (ឧ.ទូរទស្សន៍ និងវិទ្យុ) ឬបណ្តាញផ្សព្វផ្សាយសង្គម (២៤%) ដើម្បីទទួលបានព័ត៌មានទាំងនេះ។ ចំនួនប្រជាជនប្រហាក់ប្រហែលគ្នានេះ (២៣%) បាននិយាយថា ពួកគាត់បានស្វែងរកព័ត៌មានពីអាជ្ញាធរមូលដ្ឋានរបស់ពួកគាត់ ដោយក្នុងនោះប្រជាជននៅតាមជនបទ (២៥%) មានច្រើនជាងអ្នករស់នៅតំបន់ទីក្រុង/ប្រជុំជន (១៩%)។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនស្ទើរតែមួយភាគបី (៣០%) បាននិយាយថា ពួកគាត់មិនបានពិភាក្សាជាមួយនរណាម្នាក់ ឬទទួលបានព័ត៌មានណាមួយអំពីបញ្ហាទាំងនេះទេ ហើយអ្នកដែលបានលើកឡើងបែបនេះភាគច្រើនគឺប្រជាជនដែលរស់នៅតាមតំបន់ជនបទ (៣២%) និងតំបន់ឆ្នេរ(៤៧%)។

---

[76] QJ3 «តើអ្នកយល់ថាអ្នកមានការយល់ដឹងកម្រិតណាពាក់ព័ន្ធនឹងអ្វីដែលអ្នកអាចដោះស្រាយបញ្ហាប្រែប្រួលការផ្គត់ផ្គង់ទឹក ចំណីអាហារ ថាមពល និងធាតុអាកាសដែលអ្នកជួបប្រទះ ? »

[77] QJ1 «តើអ្នកទទួលបានព័ត៌មានទាំងនេះមកពីណា ? »




រូបភាពទី២៥៖ ប្រភពព័ត៌មានស្ដីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

### ៣.៨.២.៣ ប្រភពព័ត៌មានដែលគួរឲ្យទុកចិត្តបំផុត[78]

ទោះបីជាប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេរាយការណ៍ថា ជាប្រភពព័ត៌មានដ៏ពេញនិយមបំផុតរបស់ប្រជាជនក៏ដោយការសិក្សា KAP៣ បានបង្ហាញថាប្រជាជនជឿជាក់លើអាជ្ញាធរមូលដ្ឋានរបស់ពួកគាត់ចំពោះព័ត៌មានទាក់ទងនឹងការប្រែប្រួលធាតុអាកាសនិងធនធាន។ ប្រជាជនប្រមាណ ៨០% បានជឿជាក់ទៅលើអាជ្ញាធរមូលដ្ឋាន បន្ទាប់មកគឺប្រភពព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយដូចជា ទូរទស្សន៍ និងវិទ្យុ (៧៣%)។ ប្រភពព័ត៌មានដែលលេចធ្លោទីបីគឺបណ្ដាញសង្គម ដែលមានប្រជាជនប្រមាណ ៤៦% មានភាពជឿជាក់ផងដែរ។ ប្រជាជននៅតាមតំបន់ជនបទមិនត្រឹមតែស្វែងរកព័ត៌មានពីអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះទេ ពួកគាត់ថែមទាំងយល់ថាអាជ្ញាធរមូលដ្ឋានជាប្រភពព័ត៌មានដែលអាចជឿទុកចិត្តបានទៀតផង។ ចំណុចនេះត្រូវបានលើកឡើងដោយប្រជាជនរស់នៅតំបន់ជនបទ (៨៣%) ច្រើនជាងប្រជាជនដែលរស់នៅតំបន់ទីក្រុង (៧២%)។

ការស្រាវជ្រាវបែបគុណវិស័យក៏បានរកឃើញថា បើទោះបីអាជ្ញាធរមូលដ្ឋានជាប្រភពព័ត៌មានដែលអាចជឿទុកចិត្តបានពីសំណាក់ប្រជាជនកម្ពុជាក៏ដោយ វាមិនមែនមានន័យថាអាជ្ញាធរបានធ្វើសកម្មភាពឆ្លើយតបទៅនឹងបញ្ហាទាក់ទងនឹងអាកាសធាតុរបស់ពួកគាត់ទេ។ ឧទាហរណ៍ សមាជិកសហគមន៍បានរាយការណ៍ថា ប្រសិនបើពួកគាត់មានបញ្ហាពួកគាត់ច្រើនតែទៅនិយាយពិភាក្សាជាមួយមេភូមិរបស់ពួកគាត់ជាមុនសិន (ជាក់ស្ដែងដូចជា ការស្នើសុំជីកស្រះ ឬខួងអណ្ដូងដើម្បីទទួលបានទឹកបន្ថែម)។ ពេលខ្លះការធ្វើបែបនេះមានប្រសិទ្ធភាព ប៉ុន្តែនៅពេលខ្លះទៀតត្រូវចំណាយពេលយូរណាស់ដើម្បីដោះស្រាយបញ្ហា

[78] QJ2 «ចំពោះប្រភពព័ត៌មានទូទៅ តើអ្នកទុកចិត្តប្រភពនេះដែរឬទេ? »

នេះពីព្រោះមេភូមិត្រូវទំនាក់ទំនងជាមួយមេឃុំ ដើម្បីអនុវត្តស្របតាមនីតិវិធីរដ្ឋបាលរបស់រដ្ឋាភិបាលដើម្បីដំណើរការស្នើសុំ។

ប្រជាជនក៏មានទំនុកចិត្តខ្ពស់ទៅលើគ្រូបង្រៀនផងដែរដែលមានរហូតដល់ចំនួន ៧៦% បន្ទាប់មកគឺសមាជិកគ្រួសារ និងមិត្តភក្តិ (៧៤%) អង្គការមិនមែនរដ្ឋាភិបាល (៥៥%) និងអ្នកដឹកនាំសាសនានានា (៥៤%)។ មូលហេតុដែលមិនទាន់មានក្រុមណាមួយក្នុងចំណោមក្រុមខាងលើត្រូវបានគេចាត់ទុកថាជាប្រភពព័ត៌មានសំខាន់ជាងគេបំផុតពាក់ព័ន្ធនឹងបញ្ហាការប្រែប្រួលនៃធាតុអាកាស និងធនធាននោះអាចដោយសារតែមានការយល់ឃើញថា ក្រុមទាំងនេះមិនសូវមានសិទ្ធិអំណាចទៅលើបញ្ហាទាំងនេះ។ ប៉ុន្តែក្រុមទាំងនេះក៏ត្រូវបានមើលឃើញថា ជាក្រុមដែលអាចផ្តល់ឱកាសល្អសម្រាប់ការប្រាស្រ័យទាក់ទងពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ។ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀតអាចទទួលបានអត្ថប្រយោជន៍ពីការកំណត់ស្វែងរកភាពជាដៃគូ ដែលមានសក្តានុពលជាមួយនឹងអ្នកដឹកនាំដែលអាចទុកចិត្តបានដើម្បីផ្សព្វផ្សាយព័ត៌មាន និងបង្កើតសកម្មភាពនៅក្នុងសហគមន៍។

### *៣.៨.២.៤.ការយល់ឃើញអំពីការផ្សាយព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុតាមប្រព័ន្ធផ្សព្វផ្សាយ*

ការជឿទុកចិត្តខ្ពស់របស់ប្រជាជនកម្ពុជាទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ត្រូវបានគេរកឃើញបន្ថែមទៀតចេញពីកម្រងសំណួរផងដែរ។[79] ប្រជាជនកម្ពុជាជាងពាក់កណ្តាល (៥៩%) គិតថាប្រព័ន្ធផ្សព្វផ្សាយគ្របដណ្តប់លើការផ្សាយព័ត៌មានអំពីការប្រែប្រួលនៃធាតុអាកាស និងធនធានដែលមានស្រាប់។ ប្រជាជននៅតាមតំបន់ទីក្រុង/ប្រជុំជន (៦៣%) មានការជឿជាក់ទៅលើរឿងនេះច្រើនជាងអ្នករស់នៅតាមតំបន់ជនបទ (៥៧%)។ ជាថ្មីម្តងទៀតប្រជាជនដែលរស់នៅតំបន់ឆ្នេរបានបង្ហាញពីលទ្ធផលខុសគ្នាពីក្រុមដទៃទៀត ដោយមានប្រជាជនត្រឹមតែ ៤៣% ប៉ុណ្ណោះដែលបានយល់ថាប្រព័ន្ធផ្សព្វផ្សាយគ្របដណ្តប់ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។

## ៣.៩ ការវិភាគបំបែកប្រភេទប្រជាជននៅតាមក្រុម

របាយការណ៍នេះមានគោលបំណងផ្តល់នូវទិដ្ឋភាពលម្អិតអំពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុចំពោះប្រជាជនកម្ពុជា ដែលក្នុងនោះរួមមាន ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ដល់ការរស់នៅ និងសកម្មភាពនានាដែលពួកគាត់កំពុង ឬគ្រោងនឹងធ្វើដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលទាំងនេះ។ តាមរយៈការវិភាគទាំងអស់នេះ ក្រុមអ្នកស្រាវជ្រាវបានពិនិត្យមើលទៅលើក្រុមមនុស្សខុសៗគ្នា និងចង្អុលបង្ហាញពីភាពខុសគ្នានៅពេលដែលកម្រិតចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ពួកគាត់មានកម្រិតខុសគ្នាពីអត្រាមធ្យមថ្នាក់ជាតិផងដែរ។

ផ្នែកនេះបង្ហាញអំពីការវិភាគទៅតាមក្រុមមនុស្សនីមួយៗ នៅក្នុងប្រទេសកម្ពុជាដែលត្រូវបានបែងចែកទៅតាមកម្រិតនៃការចូលរួមពាក់ព័ន្ធនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ ការវិភាគនេះក៏ពិនិត្យមើល

[79] QJ4 «តើអ្នកយល់ថាប្រព័ន្ធផ្សព្វផ្សាយបានផ្សាយព័ត៌មានស្តីពីការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងការប្រែប្រួលធាតុអាកាសក្នុងកម្រិតណាដែរ? »

ផងដែរនូវវិធីសាស្ត្រប្រាស្រ័យទាក់ទងដែលគួរត្រូវបានប្រើដើម្បីជួយគាំទ្រក្រុមនីមួយៗ។ ក្រុមអ្នកស្រាវជ្រាវបានប្រើបច្ចេកទេសស្ថិតិហៅថាការវិភាគបំបែកតាមក្រុម ដើម្បីកំណត់ស្វែងរកក្រុមមនុស្សស្រដៀងគ្នាដោយផ្អែកលើ៖

- កម្រិតចំណេះដឹងរបស់ពួកគាត់ស្ដីពីការប្រែប្រួលអាកាសធាតុ
- ផលប៉ះពាល់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែលពួកគាត់ជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ
- កត្តាជំរុញទឹកចិត្ត និងឆន្ទៈក្នុងការឆ្លើយតបនឹងការប្រែប្រួលទាំងនេះ
- សកម្មភាពនានាដែលពួកគាត់កំពុងអនុវត្ត ដើម្បីឆ្លើយតបនឹងការប្រែប្រួលទាំងនេះ
- ឧបសគ្គដែលពួកគាត់ជួបប្រទះ ប្រសិនបើពួកគាត់ចង់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលទាំងនេះ
- ការជឿទុកចិត្តរបស់ពួកគាត់ចំពោះការឆ្លើយតបរបស់ស្ថាប័នទៅលើការប្រែប្រួលអាកាសធាតុ

អ្នកតបសម្ភាសន៍ត្រូវបានចែកចេញជាបួនក្រុមផ្សេងគ្នា ដោយផ្អែកទៅលើបទពិសោធន៍របស់ពួកគាត់ទាក់ទងទៅនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ ក្រុមទាំងបួនរួមមាន៖ ក្រុមមានឆន្ទៈ ក្រុមមិនខ្វល់ខ្វាយ ក្រុមព្យាយាមធ្វើសកម្មភាព និងក្រុមខ្វះការជំរុញទឹកចិត្ត។ តារាងទី៤ ផ្ដល់នូវទិដ្ឋភាពទូទៅនៃក្រុមទាំងនេះ។

**តារាងទី ៤៖ ក្រុមនីមួយៗតាមប្រជាសាស្ត្រ[80]**

| ប្រជាសាស្ត្រ | | សរុប | ក្រុមមានឆន្ទៈ | ក្រុមមិនខ្វល់ខ្វាយ | ក្រុមព្យាយាមធ្វើសកម្មភាព | ក្រុមខ្វះការជំរុញទឹកចិត្ត |
|---|---|---|---|---|---|---|
| | បំណែងចែកប្រជាជន | 100% | 25% | 21% | 38% | 16% |
| ភេទ | បុរស | 51% | 54% | 61% | 49% | 39% |
| | ស្ត្រី | 49% | 46% | 39% | 51% | 61% |
| អាយុ | ១៥-២៤ | 39% | 39% | 52% | 36% | 32% |
| | ២៥-៣៤ | 25% | 25% | 25% | 26% | 21% |
| | ៣៥-៤៤ | 22% | 21% | 15% | 25% | 28% |
| | ៤៥-៥៥ | 14% | 15% | 9% | 13% | 19% |
| តំបន់ភូមិសាស្ត្រ | ភ្នំពេញ | 10% | 11% | 10% | 8% | 11% |
| | តំបន់ទំនាប | 38% | 39% | 38% | 40% | 33% |
| | តំបន់ភ្នំ | 10% | 14% | 11% | 9% | 8% |
| | តំបន់បឹងទន្លេសាប | 36% | 32% | 35% | 37% | 43% |
| | តំបន់ឆ្នេរ | 5% | 5% | 5% | 6% | 4% |
| កម្រិតវប្បធម៌ | បឋមសិក្សា | 41% | 25% | 28% | 53% | 52% |
| | អនុវិទ្យាល័យ | 31% | 30% | 33% | 31% | 27% |
| | វិទ្យាល័យ | 22% | 33% | 28% | 13% | 17% |
| | ឧត្តមសិក្សា | 7% | 11% | 10% | 2% | 4% |

[80] ភាគរយមិនស្មើ១០០ភាគរយ ដោយសារការបង្គត់លេខនៅក្រោយក្បៀស

| | | | | | | |
|---|---|---|---|---|---|---|
| តំបន់ | ទីក្រុង/ទីប្រជុំជន | 33% | 38% | 37% | 25% | 37% |
| | ជនបទ | 67% | 62% | 63% | 75% | 63% |
| មុខរបរ | អ្នកប្រកបការងារវិជ្ជាជីវៈ | 7% | 7% | 13% | 3% | 9% |
| | អាជីវករ/ពាណិជ្ជករ | 20% | 22% | 15% | 19% | 23% |
| | កសិករ និងអ្នកនេសាទ | 35% | 32% | 29% | 41% | 32% |
| | កម្មករ(មានជំនាញទាប និងគ្មានជំនាញ) | 9% | 9% | 5% | 12% | 7% |
| | អ្នកមិនធ្វើការងារបានប្រាក់ចំណូល (ស្ត្រីមេផ្ទះ សិស្ស/និស្សិត អ្នកចូលនិវត្តន៍ អ្នកគ្មានការងារធ្វើ) | 30% | 30% | 40% | 26% | 29% |

**តារាងទី៥៖ លក្ខណៈវិនិច្ឆ័យសំខាន់ៗរបស់ក្រុមទាំងបួន**

| | ក្រុមមានឆន្ទៈ | ក្រុមមិនខ្វល់ខ្វាយ | ក្រុមព្យាយាមធ្វើសកម្មភាព | ក្រុមខ្វះការជំរុញទឹកចិត្ត |
|---|---|---|---|---|
| ឧបសគ្គផ្នែកសង្គម | មធ្យម | ទាប | ខ្ពស់ | មធ្យម |
| ឧបសគ្គផ្នែកស្ថាប័ន | ខ្ពស់ | ទាប | ខ្ពស់ | មធ្យម |
| ការធ្វើសកម្មភាពឆ្លើយតប | ខ្ពស់ | ខ្ពស់ | ខ្ពស់ | ទាប |
| កត្តាជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប | ខ្ពស់ | ទាប | ខ្ពស់ | ទាប |
| ការយល់ឃើញចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | ខ្ពស់ | មធ្យម | មធ្យម | ទាប |
| ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ | ខ្ពស់ | មធ្យម | ទាប | ទាប |
| ទំនុកចិត្តទៅលើការឆ្លើយតបរបស់ស្ថាប័នចំពោះការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | ខ្ពស់ | ទាប |

## ក្រុមមានឆន្ទៈ (២៥% នៃសំណាកសរុប)

បុគ្គលិកលក្ខណៈសំខាន់ៗរបស់ក្រុមមានឆន្ទៈគឺ៖ ពួកគាត់ជាក្រុមដែលបាន និងកំពុងធ្វើសកម្មភាពឆ្លើយតប ហើយក៏មានចំណេះដឹង និងការជំរុញទឹកចិត្តដើម្បីធ្វើសកម្មភាពឆ្លើយតបបន្ថែមទៀតដែរ។ ប្រជាជនដែលស្ថិតក្នុងក្រុមនេះភាគច្រើនជាអ្នក៖

- មានការអប់រំខ្ពស់
- មានវ័យក្មេង
- នៅតំបន់ទីក្រុង/ប្រជុំជន

ប្រជាជននៅក្នុងក្រុមមាន «ឆន្ទៈ» មានកម្រិតនៃការអប់រំខ្ពស់ជាងគេ ហើយភាគច្រើនជាបុរស និងជាអ្នករស់នៅក្នុងតំបន់ទីក្រុង/ប្រជុំជន ហើយក្រុមនេះក៏ជាក្រុមមនុស្សធំជាងគេតំណាងឲ្យសង្គមកម្ពុជា

ផងដែរ។ ប្រជាជនពីរភាគបីនៃក្រុមនេះមានអាយុក្រោម៣៥ឆ្នាំ ហើយប្រជាជនពីរនាក់ក្នុងចំណោមប្រាំនាក់ មានអាយុក្រោម ២៥ឆ្នាំ។ ប្រជាជនមួយភាគបីនៃក្រុមនេះគឺជាកសិករ ឬអ្នកនេសាទ រីឯមួយភាគបីផ្សេងទៀតគឺជាក្រុមដែលមិនមានប្រកបការងាររកប្រាក់ចំណូលនោះទេ។

ប្រជាជននៅក្នុងក្រុមមានឆន្ទៈមានចំណេះដឹងខ្ពស់បំផុតស្តីពីការប្រែប្រួលអាកាសធាតុក្នុងចំណោមប្រជាជនកម្ពុជាដោយសារក្រុមនេះមានកម្រិតនៃការអប់រំខ្ពស់។ ពួកគាត់ជាក្រុមដែលយល់ថាការប្រែប្រួលបរិស្ថានធម្មជាតិបានជះឥទ្ធិពលទៅលើជីវិតរបស់ពួកគាត់ខ្លាំងជាងគេ ហើយពួកគាត់ក៏ជាក្រុមដែលមានការលើកទឹកចិត្តខ្ពស់ជាងគេដែរក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នានាដូចជា តាមរយៈការផ្លាស់ប្តូរជីវភាពរស់នៅចំបាច់នានារបស់ពួកគាត់។ ប្រជាជននៅក្នុងក្រុមមានឆន្ទៈបាននឹងកំពុងធ្វើសកម្មភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹក ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ ក៏ដូចជាការប្រែប្រួលនៃធាតុអាកាសផងដែរ។ ជាពិសេសក្រុមនេះមិនងាយជួបប្រទះឧបសគ្គផ្នែកសង្គមក្នុងការធ្វើសកម្មភាពឆ្លើយតបនោះទេ។ បើទោះបីជាពួកគាត់មានជំនឿយ៉ាងមុតមាំទៅលើប្រសិទ្ធភាពនៃការធ្វើសកម្មភាពរួមគ្នាជាសហគមន៍ ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងអាកាសធាតុយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនសូវជាមានជំនឿខ្លាំងទៅលើអាជ្ញាធរក្នុងការធ្វើសកម្មភាពឆ្លើយតបចាំបាច់នានា ដើម្បីគាំទ្រដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនោះទេ។ ប្រជាជននៅក្នុងក្រុមនេះភាគច្រើនគិតថាការគាំទ្រពីសំណាក់រដ្ឋាភិបាលមិនគ្រប់គ្រាន់គឺជាឧបសគ្គក្នុងការធ្វើសកម្មភាពឆ្លើយតប។

ប្រជាជនក្នុងក្រុមមានឆន្ទៈបានកត់សម្គាល់ច្រើនអំពីការថយចុះនៃចំនួនដើមឈើ និងសត្វព្រៃ និងសត្វល្អិតជាច្រើនប្រភេទ ក៏ដូចជាការកើនឡើងនៃសំណល់ប្លាស្ទិក និងការបំពុលបរិយាកាស។ ពួកគាត់ភាគច្រើនមានការយល់ឃើញពីផលប៉ះពាល់ នៃការប្រែប្រួលបរិស្ថានទៅលើជីវិតរស់នៅរបស់ពួកគាត់ (ដូចជាប៉ះពាល់ដល់សមត្ថភាពរកប្រាក់ចំណូល ការថែរក្សាសុខភាពឲ្យបានល្អ និងលទ្ធភាពមានទឹកប្រើប្រាស់ជាដើម)។ ពួកគាត់ក៏បានគិតទុកផងដែរថាជីវិតរបស់ពួកគាត់នឹងទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុនាពេលអនាគត។

ទោះជាយ៉ាងណាក៏ដោយប្រជាជននៅក្នុងក្រុមនេះមិនរាថយចំពោះផលប៉ះពាល់ ដែលពួកគាត់បានជួបប្រទះនោះទេ។ ពួកគាត់ជាក្រុមដែលព្យាយាមស្វែងរកចំណូលបន្ថែមតាមមធ្យោបាយផ្សេងៗ តាមដានព័ត៌មានស្តីពីការព្យាករណ៍អាកាសធាតុ និងរៀបចំត្រៀមបង្ការ និងធ្វើសកម្មភាពឆ្លើយតបចំពោះព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដូចជា មានផែនការត្រៀមបង្ការចំពោះគ្រោះមហន្តរាយ ធ្វើការកែលម្អផ្ទះដើម្បីទប់ទល់បញ្ហានានា ស្តុកទឹកទុកប្រើប្រាស់ និងពិភាក្សាជាមួយអ្នកដទៃអំពីវិធីដោះស្រាយដែលពួកគាត់អាចអនុវត្តបាន។ ប្រជាជនដែលស្ថិតក្នុងក្រុមមានឆន្ទៈ ភាគច្រើនប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម អ៊ីនធើណេត និងមើលទូរទស្សន៍ ហើយពួកគាត់ក៏ស្តាប់វិទ្យុច្រើនជាងប្រជាជនកម្ពុជានៅក្នុងក្រុមផ្សេងទៀតផងដែរ។

**គោលបំណងសម្រាប់ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជន «មានធន្ទះ»**

- ប្រជាជនទាំងនេះមានការជំរុញទឹកចិត្តខ្ពស់រួចទៅហើយក្នុងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ពួកគាត់បានធ្វើសកម្មភាពឆ្លើយតបដោយឯករាជ្យ និងបានផ្សារភ្ជាប់ខ្លួនជាមួយបញ្ហាការប្រែប្រួលអាកាសធាតុថែមទៀតផង។ ក្រុមនេះគួរតែត្រូវចាត់ទុកជាក្រុមគំរូ ដើម្បីជួយលើកទឹកចិត្តអ្នកដទៃទៀតឲ្យធ្វើសកម្មភាពឆ្លើយតប បើទោះជាពួកគេនៅមិនទាន់មានការគាំទ្រពីស្ថាប័ននានាក៏ដោយ។
- ក្រុមនេះគួរត្រូវបានបង្ហាញពីរបៀបនៃការអន្តរាគមន៍នានាដែលអង្គការមិនមែនរដ្ឋាភិបាល និង/ឬរដ្ឋាភិបាលអាចផ្ដល់សេវាគាំទ្រដល់ក្រុមប្រជាជន ដើម្បីអាចជួយពួកគាត់ឲ្យធ្វើសកម្មភាពបានកាន់តែច្រើន ឬបង្កើនចំណេះដឹងបន្ថែមទៀត សម្រាប់ជួយកសាងទំនុកចិត្តក្នុងការជួយគាំទ្រ។

## ក្រុមមិនខ្វល់ខ្វាយ (២១% នៃសំណាកសរុប)

បុគ្គលិកលក្ខណៈសំខាន់ៗរបស់ក្រុមមិនខ្វល់ខ្វាយគឺ៖ ពួកគាត់ជាក្រុមដែលមិនសូវមានការជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតបអ្វីនោះទេ ប្រសិនបើបញ្ហាជីវភាពរស់នៅរបស់ពួកគាត់មិនទទួលរងផលប៉ះពាល់។ ប្រជាជនដែលស្ថិតក្នុងក្រុមនេះភាគច្រើនជា៖

- បុរស
- អ្នកមានស្ថានភាពសេដ្ឋកិច្ចសង្គមខ្ពស់
- មនុស្សវ័យក្មេង

ប្រជាជននៅក្នុងក្រុម «មិនខ្វល់ខ្វាយ» ភាគច្រើនជាក្រុមប្រជាជនដែលមានវ័យក្មេងជាងគេនៅក្នុងសង្គមកម្ពុជា (ជាងពាក់កណ្ដាលនៃក្រុមនេះមានអាយុក្រោម ២៥ឆ្នាំ) ហើយពួកគាត់ភាគច្រើនជាបុរសផងដែរ។ ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគាត់ក៏ខ្ពស់ជាងកម្រិតមធ្យមប្រាក់ចំណូលរបស់ជាតិដែរ នេះមានន័យថា ប្រជាជនក្នុងក្រុមនេះមានប្រាក់ចំណូល ខ្ពស់ជាងពីរដង នៃប្រាក់ចំណូលមធ្យមរបស់ប្រជាជនកម្ពុជាទូទៅ និងភាគច្រើនជាក្រុមមនុស្សដែលប្រកបការងារជំនាញ។ ប្រជាជននៅក្នុងក្រុមនេះភាគច្រើន (៨៧%) ក៏បានគិតថាជីវិតរបស់ពួកគាត់មានភាពល្អប្រសើរឡើងក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះដែរ។

ប្រជាជនក្នុងក្រុមនេះមានចំណេះដឹងជាមធ្យមស្ដីពីការប្រែប្រួលអាកាសធាតុ ដោយសារតែស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគាត់មានកម្រិតខ្ពស់។ ពួកគាត់បានដឹងអំពីផលប៉ះពាល់មួយចំនួន ហើយថែមទាំងបានធ្វើសកម្មភាពខ្លះៗដើម្បីឆ្លើយតប (ភាគច្រើនដាំដុះដំណាំ ឬចិញ្ចឹមសត្វផ្សេងៗ) ព្រមទាំងមិនមានឧបសគ្គរាំងណាមួយដែលកើតមានឡើងដោយសារកង្វះការជួយគាំទ្រពីអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល ឬអ្នកនៅជុំវិញខ្លួនរបស់ពួកគាត់នោះឡើយ។ ប៉ុន្តែក្រុមមិនខ្វល់ខ្វាយនេះមិនសូវជាមានការជំរុញទឹកចិត្តជាពិសេសណាមួយទៅលើសកម្មភាពឆ្លើយតបនាពេលអនាគត ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនោះឡើយ។ កត្តានេះអាចបណ្ដាលមកពីពួកគាត់ យល់ថាបានរៀបចំត្រៀមបង្ការបានល្អក្នុងការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ពីព្រោះពួកគាត់មិនសូវមានបន្ទុកផ្នែកសេដ្ឋកិច្ចក្នុងការធ្វើសកម្មភាព

ឆ្លើយតបទាំងនោះទេ បើធៀបជាមួយក្រុមប្រជាជនផ្សេងៗទៀត ឬដោយសារពួកគាត់មានប្រាក់ចំណូលបន្ថែមច្រើនជាងប្រជាជនកម្ពុជាដទៃទៀត។

ប្រជាជននៅក្នុងក្រុម «មិនខ្វល់ខ្វាយ» ហាក់ដូចជាមានការអប់រំខ្ពស់ ហើយមានប្រាក់ចំណូលខ្ពស់ជាងប្រជាជនទូទៅនៅក្នុងសង្គមកម្ពុជា។ ស្ទើរតែពាក់កណ្តាលនៃក្រុមមិនខ្វល់ខ្វាយគឺស្ថិតនៅក្នុងក្រុមដែលធ្វើការងារមិនមានប្រាក់ចំណូល (ភាគច្រើនជានិស្សិត) ហើយ ២០% ទៀតគឺអ្នកប្រកបការងារអាជីព។ លទ្ធភាពទទួលបានធនធាន ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងក្រុមនេះមានកម្រិតខ្ពស់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ប្រជាជននៅក្នុងក្រុមនេះយល់ថាពួកគាត់ទទួលរងផលប៉ះពាល់តិចតួចពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ពួកគាត់មិនមានជួបការលំបាកអ្វីក្នុងការបន្សាំខ្លួនជាមួយនឹងការប្រែប្រួលទាំងឡាយ ហើយក៏មិនសូវជាពិភាក្សាអំពីការធ្វើសកម្មភាពចំបងៗជាមួយអ្នកដទៃដែរ។

**គោលបំណងសម្រាប់ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជន «មិនខ្វល់ខ្វាយ»**

- ដោយសារតែជាប្រជាជនក្នុងក្រុមនេះមានអាយុតិចជាងគេបំផុតក្នុងចំណោមក្រុមទាំងបួន និងទំនងជាត្រូវប្រឈមនឹងផលប៉ះពាល់ច្រើនពីការប្រែប្រួលអាកាសធាតុទៅលើជីវិតរស់នៅរបស់គាត់នាពេលអនាគត។ គំនិតផ្តួចផ្តើមនានាក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនក្នុងក្រុមនេះគួរតែធ្វើយ៉ាងណាឲ្យពួកគាត់យល់ដឹងពីហានិភ័យ ដែលបង្កឡើងដោយអាកាសធាតុដែលបង្កផលប៉ះពាល់កើតមានឡើងនានាទៅលើជីវិតរបស់ពួកគាត់ ក្នុងរយៈពេលខ្លី និងរយៈពេលវែង។
- ទោះបីជាប្រជាជននៅក្នុងក្រុមនេះមិនទាន់ទទួលរងផលប៉ះពាល់ច្រើន និងមានកម្រិតនៃការលើកទឹកចិត្តទាបក៏ដោយ ក៏ពួកគាត់មិនប្រឈមនឹងឧបសគ្គក្នុងការធ្វើសកម្មភាពឆ្លើយតបនោះទេ។ ពួកគាត់មានធនធាន និងឥទ្ធិពលច្រើនក្នុងការលើកទឹកចិត្តសហគមន៍របស់ពួកគាត់ដែលជាញឹកញាប់តែងពឹងផ្អែកលើជំនួយគាំទ្រពីស្ថាប័ននានាដើម្បីធ្វើសកម្មភាពឆ្លើយតប។

## ក្រុមព្យាយាមធ្វើសកម្មភាព (៣៨% នៃសំណាកសរុប)

បុគ្គលិកលក្ខណៈសំខាន់ៗរបស់ក្រុមព្យាយាមធ្វើសកម្មភាពគឺ ពួកគាត់ជាក្រុមដែលមានការជំរុញទឹកចិត្តខ្ពស់ក្នុងការធ្វើសកម្មភាពឆ្លើយតប ប៉ុន្តែពួកគាត់ប្រឈមនឹងឧសគ្គជាច្រើន។ ប្រជាជនដែលស្ថិតក្នុងក្រុមនេះភាគច្រើនជាអ្នកៈ

- មានកម្រិតនៃការអប់រំទាប
- មានស្ថានភាពសេដ្ឋកិច្ចសង្គមទន់ខ្សោយ និងស្ថានភាពការងារកម្រិតទាប
- រស់នៅតំបន់ជនបទ

ក្រុម «ព្យាយាមធ្វើសកម្មភាព» ក្នុងការឆ្លើយតបគឺជាក្រុមធំជាងគេបង្អស់ដែលមានចំនួនប្រជាជនដែលបានសម្ភាសន៍ ប្រហែលពីរនាក់ក្នុងចំណោមប្រាំនាក់នៃប្រជាជនកម្ពុជា។ ប្រជាជននៅក្នុងក្រុមនេះមានកម្រិតនៃការអប់រំទាបបំផុត (ជាងពាក់កណ្តាលនៃពួកគាត់ទទួលបានការសិក្សាត្រឹមតែកម្រិតបឋមសិក្សាប៉ុណ្ណោះ) ភាគច្រើនជាប្រជាជនក្រីក្រ ឬក្រីក្រខ្លាំង និងមកពីតំបន់ជនបទ។ ប្រជាជនច្រើនប្រមាណ

បួននាក់ក្នុងចំណោមដប់នាក់នៃក្រុមនេះគឺជាកសិករ ឬអ្នកនេសាទ។ បុរស និងស្ត្រីមានចំនួនស្មើគ្នានៅក្នុងក្រុមនេះ ហើយអាយុពួកគាត់ស្របគ្នាជាមួយស្ថានភាពប្រជាជនកម្ពុជាដែលក្នុងនោះ មួយភាគបីនៃពួកគាត់មានអាយុក្រោម ២៥ឆ្នាំ និងច្រើនជាង ៦០% មានអាយុតិចជាង ៣៥ឆ្នាំ។

ប្រជាជននៅក្នុងក្រុមនេះមានចំនួនច្រើនជាងគេ ដែលយល់ថាជីវភាពរបស់ពួកគាត់កាន់តែពិបាកខ្លាំងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ពួកគាត់គឺជាក្រុមដែលទទួលរងផលប៉ះពាល់ច្រើនជាងគេចំពោះលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់។ ប្រជាជនក្នុងក្រុមនេះបានព្យាយាមយ៉ាងខ្លាំងបំផុតតាមដែលអាចធ្វើទៅបានដើម្បីត្រៀមបង្ការចំពោះព្រឹត្តិការណ៍ជាតុអាកាសធ្ងន់ធ្ងរ។ ភាគច្រើនពួកគាត់បានលើកឡើងអំពីការសន្សំប្រាក់សម្រាប់ដោះស្រាយបញ្ហានេះ និងបានស្វែងរកប្រភពចំណូលផ្សេងទៀតផងដែរ។ ខណៈពេលដែលប្រជាជននៅក្នុងក្រុមនេះបានធ្វើសកម្មភាពឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុច្រើនជាងក្រុមប្រជាជនផ្សេងៗទៀត ពួកគាត់ភាគច្រើនក៏គិតថាការធ្វើសកម្មភាពឆ្លើយតបមិនមែនជាទំនួលខុសត្រូវរបស់ពួកគាត់នោះទេ។

ក្រុម «ព្យាយាមធ្វើសកម្មភាព» មានចំណេះដឹងទាបបំផុតអំពីការប្រែប្រួលអាកាសធាតុ ហើយហាក់ដូចជាមិនសូវបានយល់ដឹងអំពីផលប៉ះពាល់របស់វាមកលើជីវិតរបស់ពួកគាត់នោះទេ។ ទោះបីយ៉ាងនេះក្តី ប្រជាជនក្នុងក្រុមនេះ ហាក់ដូចជាបានធ្វើសកម្មភាពឆ្លើយតបច្រើនជាងក្រុមដទៃទៀតដើម្បីបន្សាំខ្លួនទៅនឹងការប្រែប្រួលទាំងនេះ។ មិនតែប៉ុណ្ណោះពួកគាត់មានការជំរុញទឹកចិត្តខ្ពស់ក្នុងការធ្វើសកម្មភាពបន្ថែមទៀត ជាពិសេសគឺធ្វើការផ្លាស់ប្តូរការងារ/ប្រកបមុខរបរចិញ្ចឹមជីវិត និងលើកកម្ពស់កម្រិតជីវភាពរបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង។

ឧបសគ្គសំខាន់ៗក្នុងការធ្វើសកម្មភាពបន្ថែមទៀតរបស់ប្រជាជននៅក្នុងក្រុមនេះ គឺពួកគាត់មានអារម្មណ៍ថាវាមានការចំបាច់ក្នុងការទទួលបានការឯកភាពពីអ្នកនៅជុំវិញពួកគាត់ និងការជួយគាំទ្របន្ថែមពីស្ថាប័ននានា។ ពួកគាត់បង្ហាញពីទំនុកចិត្តខ្ពស់ទៅលើស្ថាប័ននានាដែលអាចជួយពួកគាត់បាន ប្រសិនបើស្ថាប័នទាំងនេះអាចផ្តល់នូវការគាំទ្របន្ថែមទៀត ដើម្បីឲ្យក្រុមនេះអាចធ្វើសកម្មភាពដោយឯករាជ្យបន្ថែមទៀតក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងការពឹងផ្អែកជំនួយពីអ្នកខាងក្រៅ។ ឥរិយាបថរបស់ប្រជាជននៅក្នុងក្រុមនេះចំពោះបទដ្ឋានយេនឌ័រគឺមានលក្ខណៈអភិរក្សខ្លាំងបំផុត។ ក្រុម «ព្យាយាមធ្វើសកម្មភាព» មានលទ្ធភាពអនធើណេតតិចតួចជាងក្រុមប្រជាជនដទៃទៀតដែរ។

### គោលបំណងសម្រាប់ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជន «ព្យាយាមធ្វើសកម្មភាព»

- ការជួយជំរុញទឹកចិត្តឲ្យមានការចូលរួមរបស់ក្រុមដ៏ធំបំផុតនេះគឺជាអាទិភាពសម្រាប់ការប្រាស្រ័យទាក់ទង និងអន្តរាគមន៍ផ្សេងៗនាពេលអនាគត។ ប្រជាជននៅក្នុងក្រុមនេះមានការជំរុញទឹកចិត្តខ្ពស់ ហើយក៏ជាក្រុមដែលបានធ្វើសកម្មភាពឆ្លើយតបរួចហើយដែរ។ កិច្ចអន្តរាគមន៍ និងការប្រាស្រ័យទាក់ទងនានាដែលគួរបង្កើនការយល់ដឹងសម្រាប់ក្រុមនេះអំពីការជួយគាំទ្រ ដែលមានស្រាប់សម្រាប់ពួកគាត់គឺជារឿងសំខាន់ ជាពិសេសការបង្កើនទំនុកចិត្ត និងភាពជឿជាក់របស់ពួកគាត់ចំពោះស្ថាប័ននានា។

- ការជួយក្រុមនេះឲ្យមានភាពជឿជាក់លើការធ្វើការរួមគ្នាក្នុងសហគមន៍អាចជួយជំរុញឲ្យប្រជាជននៅក្នុងក្រុមនេះធ្វើសកម្មភាពឆ្លើយតបបន្ថែមទៀតបានទាំងលក្ខណៈបុគ្គល និងរួមគ្នាផងដែរ។ ប្រជាជនទាំងនេះនឹងទទួលបានអត្ថប្រយោជន៍ ជាពិសេសពីវេទិកាចែករំលែកចំណេះដឹងឲ្យកាន់តែប្រសើរឡើងក្នុងសហគមន៍របស់ពួកគាត់។
- ការយល់ដឹងរបស់ប្រជាជនក្នុងក្រុមនេះអំពីទំនាក់ទំនងរវាងការប្រែប្រួលនៃបរិស្ថាន និងអាកាសធាតុជាមួយបញ្ហានានាដែលពួកគាត់ប្រឈមមុខនៅក្នុងជីវិតប្រចាំថ្ងៃ គឺនៅមានកម្រិតទាបនៅឡើយ។ ប្រជាជនក្រុមនេះ គួរតែជាក្រុមគោលដៅដ៏សំខាន់សម្រាប់ការប្រាស្រ័យទាក់ទងរបស់រដ្ឋាភិបាល ដោយពួកគាត់ត្រូវការការពន្យល់ណែនាំឲ្យបានក្បោះក្បាយអំពីការប្រែប្រួលអាកាសធាតុ និងបញ្ហាពាក់ព័ន្ធនានា។

## ក្រុមខ្វះការជំរុញទឹកចិត្ត (១៦% នៃសំណាកសរុប)

បុគ្គលិកលក្ខណៈសំខាន់ៗរបស់ក្រុមខ្វះការជំរុញទឹកចិត្តគឺ ពួកគាត់ជាក្រុមដែលមានការប្រឈមនឹងឧបសគ្គច្រើន និងខ្វះការជំរុញទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប។ ប្រជាជនដែលស្ថិតក្នុងក្រុមនេះភាគច្រើនជា៖

- ស្ត្រី
- មនុស្សចាស់
- អ្នកមានស្ថានភាពសេដ្ឋកិច្ចសង្គមទន់ខ្សោយ

ក្រុមនេះគឺជាក្រុមតូចជាងគេ និងមានអំណាចតិចតួចជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ប្រជាជននៅក្នុងក្រុមនេះភាគច្រើនជាស្ត្រី មនុស្សចាស់ដែលមានអាយុច្រើនជាងមធ្យម និងមកពីក្រុមប្រជាជនដែលមានសេដ្ឋកិច្ចសង្គមទាប។ ពួកគាត់ទទួលបានការអប់រំទាបជាងកម្រិតនៃការអប់រំមធ្យមថ្នាក់ជាតិ ហើយភាគច្រើនមកពីតំបន់ជនបទ។

ប្រជាជននៅក្នុង «ក្រុមខ្វះការជំរុញទឹកចិត្ត» នេះមិនមានសិទ្ធិអំណាច និងទទួលបានពិន្ទុទាបជាងគេចំពោះសូចនាករស្ទើរតែទាំងអស់ដែលត្រូវបានវាស់វែងនៅក្នុងការសិក្សានេះ។ ពួកគាត់មានចំណេះដឹងទាបស្តីពីការប្រែប្រួលអាកាសធាតុ ហើយពួកគាត់យល់ដឹងតិចតួចពីផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាសមកលើជីវិតរស់នៅរបស់ពួកគាត់។ ជាលទ្ធផលការជំរុញទឹកចិត្តរបស់ពួកគាត់គឺមានទាបជាងគេបំផុតក្នុងការធ្វើសកម្មភាពឆ្លើយតប និងបន្សាំខ្លួនទៅនឹងការប្រែប្រួលនៃធាតុអាកាស និងលទ្ធភាពទទួលបានធនធានសំខាន់ៗ។

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺហេតុផល ដែលធ្វើឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើងមិនមែនជាការជំរុញលើកទឹកចិត្តប្រជាជននៅក្នុងក្រុមនេះឲ្យធ្វើសកម្មភាពឆ្លើយតបនេះទេ។ ពួកគាត់មានការជឿជាក់តិចតួចបំផុតទៅលើប្រសិទ្ធភាព នៃសកម្មភាពសហគមន៍ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងមានការជឿជាក់ទាបបំផុតចំពោះសកម្មភាពរបស់អាជ្ញាធរក្នុងការដោះស្រាយបញ្ហានេះ។

ក្រុម «ក្រុមខ្វះការជំរុញទឹកចិត្ត» នេះយល់ថាពួកគាត់បានផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគាត់ដើម្បីបន្សាំខ្លួនទៅនឹងការផ្លាស់ប្តូរទាំងឡាយ ប៉ុន្តែពួកគាត់បានទទួលស្គាល់ថាពួកគាត់មានការត្រៀមបង្ការតិចបំផុតក្នុងការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ។ ឧទាហរណ៍ ពួកគាត់មិនសូវបានត្រៀមស្តុកទុកអាហារ ទឹក ឬមិនសូវមានលុយត្រៀមសម្រាប់អនាគតទេ។ បញ្ហានេះកើតឡើងដោយសារតែស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គាត់មានកម្រិតទាប ហើយពួកគាត់មានឥរិយាបថខុសប្លែកពីប្រជាជននៅក្នុងក្រុម «ព្យាយាមធ្វើសកម្មភាព» បើទោះបីជាពួកគាត់មានកម្រិតប្រាក់ចំណូល និងការអប់រំទាបស្រដៀងគ្នាក៏ដោយ។

ទន្ទឹមនឹងនេះប្រជាជននៅក្នុងក្រុម «ក្រុមខ្វះការជំរុញទឹកចិត្ត» មិនសូវមានការពិភាក្សាអំពីសកម្មភាពឆ្លើយតបសំខាន់ៗជាមួយអ្នកដទៃទេ ហើយពួកគាត់ក៏មានលទ្ធភាពទាបបំផុតក្នុងការទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយផងដែរ។ ដោយសារតែពួកគាត់ភាគច្រើនជាស្ត្រី ព្រមទាំងទទួលបានការជួយគាំទ្រតិចតួចក្នុងការបញ្ចេញមតិយោបល់នៅក្នុងសហគមន៍ ចំណុចនេះបានជំរុញឲ្យប្រជាជននៅក្នុងក្រុមនេះប្រឈមមុខយ៉ាងធ្ងន់ធ្ងរទៅនឹងបទដ្ឋានយេនឌ័របែបអវិជ្ជមាន។ ជាលទ្ធផលពួកគាត់មានអារម្មណ៍ថាមិនសូវមានឥទ្ធិពលលើការចាត់ចែងជីវភាពរស់នៅរបស់ពួកគាត់ឡើយ។

**គោលបំណងសម្រាប់ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជន «ក្រុមខ្វះការជំរុញទឹកចិត្ត»**

- ប្រជាជននៅក្នុងក្រុមនេះគឺងាយរងគ្រោះខ្លាំងពីការប្រែប្រួលអាកាសធាតុ ដូច្នេះហើយពួកគាត់គួរតែជាក្រុមអាទិភាពមួយផ្សេងទៀតសម្រាប់កិច្ចអន្តរាគមន៍ ឬគំនិតផ្តួចផ្តើមនានាក្នុងការប្រាស្រ័យទាក់ទងសម្រាប់ពេលអនាគត។ ប្រជាជននៅក្នុងក្រុមនេះប្រឈមនឹងហានិភ័យដោយសារពួកគាត់ខ្វះព័ត៌មាន និងមិនអាចកំណត់រកភាពងាយរងគ្រោះរបស់ខ្លួនឯងបានឡើយ។ ពួកគាត់ត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតបងាយៗដែលពួកគាត់អាចធ្វើខ្លួនឯងបាន និងត្រូវការមានគំរូដែលអាចជឿជាក់បានក្នុងការជំរុញទឹកចិត្តពួកគាត់ដើម្បីធ្វើសកម្មភាពឆ្លើយតប។
- កិច្ចអន្តរាគមន៍តាមរយៈការប្រាស្រ័យទាក់ទង ដែលមានបំណងជំរុញឲ្យមានការពិភាក្សាបន្ថែមទៀតក្នុងចំណោមប្រជាជនក្នុងក្រុមនេះ អាចជួយឲ្យពួកគាត់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងជំរុញពួកគាត់ឲ្យធ្វើសកម្មភាពតាមដែលអាចធ្វើទៅបាន។ សកម្មភាពគឺអាចធ្វើបានតាមរយៈវិធីសាស្ត្រក្នុងការផ្សព្វផ្សាយការប្រាស្រ័យទាក់ទងក្នុងមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានៃការខ្វះខាតលទ្ធភាពទទួលបានប្រព័ន្ធផ្សព្វផ្សាយរបស់ប្រជាជននៅក្នុងក្រុមនេះ។

# ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៤.១ សេចក្តីសន្និដ្ឋាន

ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលចំពោះប្រព័ន្ធធាតុអាកាសនៅកម្ពុជា ហើយប្រជាជនកម្ពុជាក៏បានកត់សម្គាល់ពីការផ្លាស់ប្តូរទាំងនេះផងដែរ។ ពួកគាត់ យល់ថាសីតុណ្ហភាពកាន់តែក្តៅឡើង របបទឹកភ្លៀងកាន់តែថយចុះ ហើយភាពធ្ងន់ធ្ងរនៃគ្រោះរាំងស្ងួតក៏កើតមានកាន់តែច្រើនឡើងផងដែរ។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃរបបទឹកភ្លៀងនៅរយៈពេលច្រើនឆ្នាំចុងក្រោយនេះបង្ហាញថា ប្រជាជនបានជួបប្រទះនូវរដូវប្រាំងដែលស្ងួតហួតហែងខ្លាំង ហើយបញ្ហានេះវាបានកើតឡើងជាច្រើនឆ្នាំកន្លងទៅ មុនការស្រាវជ្រាវ KAP៣ នេះទៅទៀត។

ទោះបីជាប្រជាជនកម្ពុជាភាគច្រើនបានលើកឡើងពីភាពប្រសើរឡើងនូវលទ្ធភាពទទួលបានទឹក ចំណីអាហារ និងថាមពលក្តី ក៏ពួកគាត់បានសង្កេតឃើញពីផលប៉ះពាល់អវិជ្ជមាននានានៃការប្រែប្រួលបរិស្ថាន និងធាតុអាកាស មកលើជីវិតរស់នៅរបស់ពួកគាត់ផងដែរ។ ដោយសារតែប្រជាជនកម្ពុជាបានផ្តល់នូវតម្លៃខ្ពស់ទៅលើសុខភាព ដូច្នេះពួកគាត់ហាក់ដូចជាយល់ឃើញថាផលប៉ះពាល់ពីការប្រែប្រួលទាំងនេះបានជះឥទ្ធិពលមកលើបញ្ហាសុខភាពរបស់ពួកគាត់។ ប្រជាជនជាច្រើនយល់ថាការប្រែប្រួលអាកាសធាតុបណ្តាលឲ្យមានជំងឺតិចតួច និងអាចមានស្ថានភាពធ្ងន់ធ្ងរដែរតែបញ្ហានេះបានក្លាយជារឿងធម្មតាទៅហើយសម្រាប់ពួកគាត់។ ជារួមប្រជាជនកម្ពុជាមានការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីអនាគតព្រោះពួកគាត់មានយល់ថាការប្រែប្រួលនានានៃធាតុអាកាស និងបរិស្ថាន នឹងជះឥទ្ធិពលកាន់តែខ្លាំងដល់ជីវិតរស់នៅរបស់ពួកគាត់នាពេលខាងមុខ។

បើទោះបីជាប្រជាជនកម្ពុជាជាច្រើនបានកត់សម្គាល់ពីការប្រែប្រួលធាតុអាកាស និងបរិស្ថានក៏ពិតមែនប៉ុន្តែមិនមែនមានន័យថាប្រជាជនកម្ពុជាទាំងអស់ សុទ្ធតែអាចផ្សារភ្ជាប់ការប្រែប្រួលទាំងនេះទៅនឹងការលំបាកក្នុងជីវភាពរស់នៅដែលពួកគាត់កំពុងតែជួបប្រទះនោះដែរ។ ប្រជាជនដែលមិនសូវមានចំណេះដឹង (ហើយមានភាពក្រីក្រខ្លាំង) គឺជាអ្នកដែលមានអារម្មណ៍ថាជីវភាពរស់នៅរបស់ពួកគាត់កាន់តែយ៉ាប់យ៉ឺនក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ហើយពួកគាត់ក៏មិនសូវបានយល់ដឹងអំពីការប្រែប្រួលនានានៃបរិស្ថានដែលបាន និងកំពុងជះឥទ្ធិពលដល់ជីវិតរស់នៅរបស់ពួកគាត់នោះដែរ។

ប្រជាជនកម្ពុជាជាច្រើន ជាពិសេសអ្នកដែលមានស្ថានភាពប្រាក់ចំណូលទាប ឬអ្នកដែលទទួលបានការអប់រំទាបមានបំណងចង់ធ្វើការផ្លាស់មុខរបររបស់ពួកគាត់ ដើម្បីបន្សាំខ្លួនទៅនឹងស្ថានភាពប្រែប្រួលទាំងនេះ។ ពួកគាត់មានការត្រៀមខ្លួនក្នុងការស្វែងរកវិធីសាស្ត្រថ្មីៗដើម្បីរកប្រាក់ចំណូលបន្ថែម និងឬ/ផ្លាស់ប្តូរការងារ/មុខរបរ រៀនជំនាញថ្មីៗ និងការធ្វើការរួមគ្នាបន្ថែមទៀត។ ប្រជាជនភាគច្រើនក៏កំពុងធ្វើសកម្មភាពជាច្រើនដើម្បីដោះស្រាយបញ្ហាកង្វះទឹក និងអាហារផងដែរ។ បំណងប្រាថ្នាចង់ឲ្យមានសុខភាពល្អអនាគតល្អសម្រាប់កូនៗ និងអាចថែរក្សាបាននូវរបៀបរបបរស់នៅបច្ចុប្បន្នរបស់ពួកគាត់គឺជាកត្តាជំរុញទឹកចិត្តដ៏ធំបំផុតសម្រាប់ប្រជាជនកម្ពុជាក្នុងការធ្វើសកម្មភាពត្រៀមបង្ការ និងឆ្លើយតបនឹងការប្រែប្រួលនានានៃធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់។

ទោះជាយ៉ាងណា មានកត្តាផ្សេងៗជាច្រើនទៀតបានរារាំងដល់កិច្ចប្រឹងប្រែងនៃការបន្សាំខ្លួនរបស់ប្រជាជនកម្ពុជាទៅនឹងការប្រែប្រួលអាកាសធាតុ។ ប្រជាជនជាច្រើនយល់ថាពួកគាត់ត្រូវការការគាំទ្របន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើសកម្មភាពឆ្លើយតប។ ទន្ទឹមនឹងនេះពួកគាត់ក៏បង្ហាញនូវការជឿជាក់ខ្ពស់ទៅលើសមត្ថភាពរបស់ស្ថាប័នថ្នាក់ជាតិ ខេត្ត/ក្រុង ស្រុក អាជ្ញាធរមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលកំពុងផ្តល់ផលប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាផងដែរ។

ឧបសគ្គសំខាន់ៗផ្សេងទៀតសម្រាប់ប្រជាជនកម្ពុជារួមមាន កង្វះខាតធនធាន និងព័ត៌មាន កង្វះខាតការគាំទ្រផ្នែកបរិស្ថានសង្គម និងតម្រូវការអាទិភាពចាំបាច់ផ្សេងទៀតដែលត្រូវដោះស្រាយសម្រាប់បញ្ហាជីវភាព។

## ៤.២ អនុសាសន៍

### ជំរុញនិងផ្សារភ្ជាប់ប្រជាជនគោលដៅឲ្យចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖

- ប្រជាជនកម្ពុជាកំពុងធ្វើសកម្មភាពកាន់តែច្រើនឡើង ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលពួកគាត់បានជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ។ ទោះជាយ៉ាងនេះក្តី កម្មវិធីអន្តរាគមន៍ ឬយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនានាពាក់ព័ន្ធនឹងអាកាសធាតុជាកត្តាចាំបាច់ ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតបបន្ថែមទៀតនាពេលអនាគត៖
    - **ប្រើប្រាស់ចំណុចគន្លឹះសំខាន់ៗដែលជាមូលដ្ឋានក្នុងការជំរុញលើកទឹកចិត្តដល់ប្រជាជនកម្ពុជាបន្ថែមក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដូចជា បញ្ហាសុខភាព ការអប់រំ មុខរបរចិញ្ចឹមជីវិត។** ការប្រើប្រាស់កម្លាំងជំរុញទាំងនេះ និងការបង្ហាញពីរបៀបធ្វើសកម្មភាពឆ្លើយតបដែលអាចជួយពួកគាត់បានអាចជួយលើកទឹកចិត្តដល់ប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតប និងបង្កើនភាពធន់របស់ខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។[81] លើសពីនេះទៀត ការកសាងចំណេះដឹងអំពីវិធីត្រៀមបង្ការ ឬបន្សាំខ្លួននឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពដោយរួមបញ្ចូលទាំងវិធី ដែលអាចទទួលបានព័ត៌មានកាន់តែច្រើនឡើងនឹងជួយពួកគាត់ឲ្យបង្កើនការត្រៀមបង្ការ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុកាន់តែប្រសើរឡើង។
    - ជំរុញឲ្យការពិភាក្សាទាក់ទងនឹងផលប៉ះពាល់ដែលបង្កដោយការប្រែប្រួលធាតុអាកាស បរិស្ថាន និងធនធាននានាដែលអាចជួយប្រជាជនក្នុងការបង្កើតគំនិតថ្មីៗ និងចែករំលែកការរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនដូចគ្នា និងក្នុងចំណោមអ្នកធ្វើការសម្រេចចិត្ត ឬអ្នក

[81] ឧទាហរណ៍ យើងអាចសង្កត់ធ្ងន់ទៅលើអត្ថប្រយោជន៍នៃការធ្វើសកម្មភាពឆ្លើយតបឲ្យទាក់ទងទៅនឹងប្រាក់ចំណូលបច្ចុប្បន្ន សុខភាព និងអនាគតកូនៗរបស់ពួកគាត់នៅថ្ងៃមុខ។

ដែលមានឥទ្ធិពលនៅមូលដ្ឋាន។ ចំណុចទាំងនេះអាចជួយប្រជាជនក្នុងការដោះស្រាយបញ្ហាឲ្យបានកាន់តែប្រសើរ។ **ការធ្វើបែបនេះគឺដោយសារតែការជជែកពិភាក្សាគឺជាកត្តាជំរុញធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថ ប៉ុន្តែប្រជាជនកម្ពុជាមិនសូវបានជជែកពិភាក្សា ឬចែករំលែកគ្នាអំពីសកម្មភាពនានា ដែលពួកគាត់បានអនុវត្តក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនោះទេ។**

- **ដោះស្រាយបញ្ហាសំខាន់ៗដែលជះឥទ្ធិពលដល់ប្រជាជនកម្ពុជា រយៈពេលវែង (ដូចជាបញ្ហាគ្រោះរាំងស្ងួត និងកង្វះទឹក) នឹងជួយជំរុញទឹកចិត្តឲ្យប្រជាជនធ្វើសកម្មភាព។ ប្រជាជនកម្ពុជាកាន់តែច្រើនបានកត់សម្គាល់ពីការកើនឡើងកម្តៅ និងការថយចុះនៃរបបទឹកភ្លៀង។** ការយកចិត្តទុកដាក់លើបញ្ហានេះនឹងជួយបំពេញសេចក្តីត្រូវការ ដែលមានស្រាប់របស់ប្រជាជន ព្រមទាំងអាចជានាបាននូវការចូលរួមរបស់សហគមន៍ជាមួយអ្នកធ្វើការសម្រេចចិត្ត និងអាជ្ញាធរបានកាន់តែច្រើនឡើង។ បញ្ហាទាំងនេះមានភាពខុសគ្នាទៅតាមតំបន់ និងក្រុមប្រជាជនផ្សេងៗគ្នាដូច្នេះយុទ្ធសាស្ត្រសម្រាប់ការដោះស្រាយបញ្ហាទាំងនេះទាមទារឲ្យមានការកំណត់គោលដៅដោយប្រុងប្រយ័ត្ន។[82]
- **ជួយប្រជាជនកម្ពុជាក្នុងការផ្សារភ្ជាប់ការប្រែប្រួលនានា ដែលពួកគាត់ជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃទៅនឹងពាក្យ «ការប្រែប្រួលអាកាសធាតុ» តាមរយៈការពិភាក្សា និងការប្រាស្រ័យទាក់ទងនានា។** ការសិក្សាបានបង្ហាញថាមានប្រជាជនច្រើនដែលមិនទាន់បានយល់ពីអត្ថន័យនៃពាក្យបច្ចេកទេសសំខាន់ៗដូចជា ការប្រែប្រួលអាកាសធាតុ និងកម្តៅភពផែនដី បើទោះបីជាពួកគាត់កំពុងទទួលរងផលប៉ះពាល់ទៅលើជីវិតប្រចាំថ្ងៃក៏ដោយ។ ការប្រាស្រ័យទាក់ទងដែលអាចផ្សារភ្ជាប់ការយល់ដឹងនៃពាក្យទាំងនេះជាមួយសកម្មភាពប្រចាំថ្ងៃក្នុងជីវិតរបស់ប្រជាជនកម្ពុជាអាចមានប្រយោជន៍ច្រើនក្នុងការបង្កើនចំណេះដឹង ។
- **ព្យាយាមបន្សីគ្នារវាងតម្រូវការអាទិភាពរបស់ប្រជាជនកម្ពុជា ដែលពួកគាត់យល់ថាការសម្របខ្លួនជាមួយអ្នកដទៃក្នុងសហគមន៍ក៏ជារឿងសំខាន់ ដើម្បីលើកទឹកចិត្តប្រជាជនក្នុងការធ្វើសកម្មភាពភាពឆ្លើយតប។** ការបង្កើតបទដ្ឋានអ្វីមួយថ្មីអាចជាមានការលំបាក ប៉ុន្តែការប្រើប្រាស់បុគ្គល/ជនគំរូក្នុងមូលដ្ឋានជារឿងដែលអាចធ្វើទៅបាន តាមរយៈការធ្វើឲ្យគេមើលឃើញពីផលចំណេញផ្នែកសេដ្ឋកិច្ចនៃការផ្លាស់ប្តូរតាមវិធីសាមញ្ញៗ ចំណាយថវិកាតិចតួច និងអាចអនុវត្តតាមបានក្នុងការត្រៀមបង្ការ និងទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ចំណុចនេះអាចជួយដល់សហគមន៍/ប្រជាជនឲ្យមើលឃើញពីគុណតម្លៃ នៃការធ្វើសកម្មភាពឆ្លើយតប ព្រមទាំងអាចបណ្តុះគំនិតពួកគាត់ឲ្យគិតថាការធ្វើសកម្មភាពទាំងនេះមានភាពវិជ្ជមាន និងអាចធ្វើទៅបានទាំងអស់គ្នា។ ប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងទូលំទូលាយអាចជាវិធីដ៏មានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ដើម្បីដោះស្រាយបញ្ហា

[82] ឧទាហរណ៍ កង្វះទឹកគឺជាក្តីកង្វល់ជាក់ស្តែងមួយសម្រាប់ប្រជាជននៅតំបន់ជនបទ ជាពិសេសអ្នកនៅតំបន់ឆ្នេរ និងតំបន់ភ្នំ។

ប្រែប្រួលអាកាសធាតុ តាមរយៈការឆ្លុះបញ្ចាំងពីតថភាពជីវិត និងបុគ្គលគំរូ ដែលអាចជួយជំរុញទឹកចិត្តដល់អ្នកផ្សេងទៀត។

- ក្រុមប្រជាជនកម្ពុជាសំខាន់ៗមួយចំនួនអាចនឹងទទួលបានអត្ថប្រយោជន៍ពីការទទួលបានអាទិភាពនៅក្នុងកម្មវិធីអន្តរាគមន៍ ឬយុទ្ធសាស្ត្រទំនាក់ទំនងស្តីពីការប្រែប្រួលអាកាសធាតុផ្សេងៗនាពេលអនាគត។[83] ក្រុមប្រជាជនជាក់លាក់ ដែលធ្លាប់បានជួបប្រទះផលប៉ះពាល់ចំពោះជីវិតប្រចាំថ្ងៃរបស់ពួកគាត់ដោយសារតែការប្រែប្រួលធាតុអាកាស និងបរិស្ថាន ប៉ុន្តែពួកគាត់មិនបានកត់សម្គាល់ឃើញពីការប្រែប្រួលទាំងនោះ ឬមិនបានភ្ជាប់បញ្ហាទៅនឹងការប្រែប្រួលអាកាសធាតុនោះទេ។ ចំពោះក្រុមប្រជាជនក្នុងស្ថានភាពនេះ ពួកគាត់គួរទទួលបានការផ្តល់អាទិភាពពីការប្រាស្រ័យទាក់ទង និងការជួយគាំទ្រផ្សេងៗ។ **ប្រជាជនកម្ពុជាដែលងាយរងគ្រោះបំផុតមួយចំនួន** (ដូចជាប្រជាជនក្រីក្រខ្លាំង និងមានការអប់រំទាបបំផុត ព្រមទាំងអ្នកប្រឈមខ្លាំងនឹងធាតុអាកាសធ្ងន់ធ្ងរ) មិនសូវបានកត់សម្គាល់ពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវិតរបស់ពួកគាត់នោះឡើយ ហើយពួកគាត់ក៏យល់ថាមិនសូវបានត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនោះដែរ។ ក្រុមអាទិភាពសំខាន់ៗមានដូចខាងក្រោមនេះ៖
    - **កសិករ និងអ្នកនេសាទ ដែលមានជីវភាព** ពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិ និងធាតុអាកាស ហើយពួកគាត់បានទទួលរងផលប៉ះពាល់ពីការផ្លាស់ប្តូរទាំងនេះ។[84] **កសិករ និងអ្នកនេសាទត្រូវបានរកឃើញថាភាគច្រើនស្ថិតក្នុងក្រុម «ព្យាយាមធ្វើសកម្មភាព» ឆ្លើយតប។ ពួកគាត់មានឆន្ទៈក្នុងការធ្វើសកម្មភាព ប៉ុន្តែពួកគាត់គួរទទួលបានផលប្រយោជន៍បន្ថែមពីការបង្កើនបណ្តាញទំនាក់ទំនង ការចែករំលែកសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការធ្វើការងាររួមគ្នា។**
    - **ប្រជាជនដែលរស់នៅតំបន់ឆ្នេរ** ងាយនឹងរងគ្រោះពីការប្រែប្រួលអាកាសធាតុ។[85] ប្រជាជននៅតំបន់ឆ្នេរត្រូវការការគាំទ្រ និងព័ត៌មានដើម្បីជួយពួកគាត់ក្នុងការដោះស្រាយនូវតម្រូវការជាមូលដ្ឋានសំខាន់បំផុតរបស់ពួកគាត់ដូចជា កង្វះទឹកដែលបានអូសបន្លាយរយៈពេលវែង និង

---

[83] ជាទូទៅប្រជាជនកម្ពុជាគិតថាជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរឡើងក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ដោយក្នុងនោះមានមួយភាគបី (៦៧%) បានលើកឡើងដូច្នេះ។ ប៉ុន្តែចំណុចវិជ្ជមានផ្នែកជីវភាពគឺជាបញ្ហាប្រឈមសម្រាប់ប្រជាជនដែលងាយរងគ្រោះ ពីព្រោះអ្នកដែលគិតថាជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរឡើងភាគច្រើនគឺជាអ្នកដែលមានកម្រិតនៃការអប់រំខ្ពស់ និងមានស្ថានភាពសេដ្ឋកិច្ចល្អប្រសើរ។ ផ្ទុយទៅវិញប្រជាជនមួយភាគបី (៣៣%) ដែលបានរាយការណ៍ពីការថយចុះនៃប្រាក់ចំណូលក្នុងគ្រួសារក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។

[84] ឧទាហរណ៍ អ្នកនេសាទបានទទួលរងផលប៉ះពាល់ជាពិសេសពីការធ្លាក់ចុះនៃធនធានត្រីធម្មជាតិដោយសារតែសីតុណ្ហភាពឡើងក្តៅ។ កសិករបានរាយការណ៍ថាបានជួបប្រទះនូវគ្រោះរាំងស្ងួត និងការថយចុះនៃរបបទឹកភ្លៀងដែលធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណូលរបស់ពួកគាត់។ ទោះបីជាបែបនេះក្តី កសិករ និងអ្នកនេសាទមានចំនួនត្រឹមច្រើនជាងពាក់កណ្តាល ៥៥ប៉ុណ្ណោះ ដែលបានត្រៀមបង្ការចំពោះព្រឹត្តិការណ៍ធាតុអាកាស%) ធ្ងន់ធ្ងរ។ទោះបីជាយ៉ាងណាក៏ប្រជាជនកម្ពុជាជិតមួយភាគបី ចង់រៀនជំនាញថ្មីៗដើម្បីដោះស្រាយបញ្ហាទាំងនេះ (%៧៣)

[85] ពួកគាត់ចំនួនមួយភាគបួនមានអារម្មណ៍ថាមិនសូវមានលទ្ធភាពទទួលបានទឹកប្រើប្រាស់នោះឡើយ ហើយពួកគាត់បានលើកឡើងជាញឹកញាប់ពីការហូរចូលទឹកសមុទ្រដែលបានប៉ះពាល់ដល់លទ្ធភាពនៃក្នុងការដាំដុះដំណាំ និងលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគឲ្យបានគ្រប់គ្រាន់។ អ្នករស់នៅតាមតំបន់ឆ្នេរមានចំនួនតិចតួចជាងគេបំផុតត្រឹមតែមួយភាគបីប៉ុណ្ណោះដែលមានអារម្មណ៍ថាលទ្ធភាពទទួលបានអាហាររបស់ពួកគាត់មានភាពប្រសើរឡើង ហើយប្រជាជននៅតំបន់នេះក្នុងចំនួនតិចជាងពាក់កណ្តាលយល់ថាបានត្រៀមបង្ការសម្រាប់ធាតុអាកាសធ្ងន់ធ្ងរ។ ពួកគាត់ភាគច្រើនត្រូវការការជួយគាំទ្រពីរដ្ឋាភិបាលដើម្បីធ្វើសកម្មភាពឆ្លើយតប ហើយពួកគាត់មិនមានចំណេះដឹងពីការធ្វើសកម្មភាពឆ្លើយតបនោះទេ។ លទ្ធផលនេះបញ្ជាក់ពីការពិតដែលថាមានតែប្រជាជនចំនួនពីរនាក់ក្នុងចំណោមប្រាំនាក់ប៉ុណ្ណោះដែលបានយល់ថាទទួលបានការជូនដំណឹងអំពីការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

លទ្ធភាពទទួលបានអាហារនៅមានកម្រិត។ **ពួកគាត់ក៏នៅខ្វះខាតទំនុកចិត្ត ហើយត្រូវការការគាំទ្រច្រើនបំផុតពីអ្នកដទៃ ជាពិសេសគឺការបង្ហាញពួកគាត់នូវវិធីដើម្បីឲ្យគាត់អាចជួយខ្លួនឯងបានកាន់តែមានប្រសិទ្ធភាព ព្រមទាំងរបៀបទទួលបានការគាំទ្រ និងព័ត៌មាននានាពីសំណាក់រដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល។**

- **ក្រុមប្រជាជនដែលមានភាពក្រីក្រខ្លាំង** គឺជាក្រុមសំខាន់មួយទៀតដែលប្រឈមនឹងឧបសគ្គច្រើនក្នុងការចាត់វិធានការដើម្បីការពារខ្លួនពីការប្រែប្រួលនានានៃធាតុអាកាស បរិស្ថាន និងធនធានដែលមានស្រាប់។[86] **ក្រុមដែលងាយរងគ្រោះបំផុតនេះតស៊ូឆ្លើយតបនឹងតម្រូវការមូលដ្ឋាន ហើយពួកគាត់ត្រូវការការជួយគាំទ្រ និងព័ត៌មានច្រើនបំផុតដើម្បីជួយពួកគាត់ឲ្យត្រៀមខ្លួនសម្រាប់អាកាសធាតុធ្ងន់ធ្ងរ និងទប់ទល់នឹងភាពតានតឹងក្នុងរយៈពេលវែង។**

## សកម្មភាពឆ្លើយតបរបស់សហគមន៍គឺទាមទារឲ្យមានការពង្រឹងសមត្ថភាពពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីជួយដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ៖

វិធីជាច្រើនដែលភាគីពាក់ព័ន្ធផ្សេងៗអាចជួយគាំទ្រដល់សហគមន៍ក្នុងការធ្វើសកម្មភាពត្រៀមបង្ការ និងបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគាត់បាន។

## អ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយ

- ការធ្វើសេចក្តីសម្រេចចិត្តនានាលើគោលនយោបាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ គួរមានការពិចារណាក្នុងការប្រើវិធីសាស្ត្រដែលមានការចូលរួមពីថ្នាក់ក្រោម (bottom-up approach) លើកកម្ពស់ការចូលរួម និងតាមដានឲ្យមានការចូលរួមពេញលេញរបស់ស្ត្រីនៅគ្រប់កម្រិតទាំងអស់ ព្រមទាំងផ្តោតសំខាន់លើការដោះស្រាយបញ្ហាប្រឈមបន្ទាន់ៗដែលសហគមន៍កំពុងជួបប្រទះ។ នៅពេលធ្វើផែនការសម្រាប់យុទ្ធសាស្ត្រ ឬគោលនយោបាយនានាក្នុងប្រធានបទការប្រែប្រួលអាកាសធាតុនេះ វាមានសារៈសំខាន់ក្នុងការស្គាល់/ដឹងពីក្រុមគោលដៅឲ្យបានច្បាស់ជាមុនដូចជា ស្គាល់ពីតម្រូវការរបស់ពួកគាត់ ដឹងពីកត្តាជំរុញទឹកចិត្ត ដឹងពីវិធីដែលពួកគាត់ចង់ទទួលបានព័ត៌មាន និងដឹងពីតម្រូវការផ្សេងៗគ្នារបស់ក្រុមប្រជាជនខុសៗគ្នា (ឧទាហរណ៍ តម្រូវការខុសគ្នាតាមភេទ ទីតាំងភូមិសាស្ត្រ កម្រិតនៃប្រាក់ចំណូលជាដើម)។ ការធ្វើបែបនេះនឹងជួយឲ្យកិច្ចអន្តរាគមន៍នានាមានភាពកាន់តែសមស្រប និងផ្សារភ្ជាប់កាន់តែប្រសើរក្នុងការចូលរួមចំណែក ក្នុងការអនុវត្តគោលនយោបាយប្រកបដោយភាពវិជ្ជមាន។ ដូច្នេះអ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយអាចពិចារណាអំពីការដាក់គោលបំណង

[86] នៅពេលដែលសួរថាតើគេគួរធ្វើអ្វីខ្លះដើម្បីត្រៀមបង្ការសម្រាប់អាកាសធាតុធ្ងន់ធ្ងរ ប្រជាជនជាងពាក់កណ្តាល (៥៣%) នៅក្នុងក្រុមនេះមិនអាចរៀបរាប់ពីសកម្មភាពណាមួយដែលពួកគាត់បានធ្វើនោះទេ។ ទោះបីជាមានការសួរដេញបន្ថែមទៀតក៏សមាជិកនៃក្រុមនេះមិនអាចរៀបរាប់ពីសកម្មភាពឆ្លើយតបសំខាន់ៗនោះបានដែរ។ ប្រជាជនក្រីក្រមិនសូវបានធ្វើការសន្សំប្រាក់ ឬមានអាហារស្តុកទុកនោះទេ។ ចំណុចនេះបង្ហាញថាបើទោះជាវាជាសកម្មភាពសាមញ្ញក៏ដោយ ក៏វាជាការលំបាកសម្រាប់ក្រុមនេះផងដែរ។ នៅពេលសួរអំពីការផ្លាស់ប្តូរដែលពួកគាត់បានធ្វើចំពោះជីវភាពរស់នៅ ប្រជាជនចំនួន ៧១% នៅក្នុងក្រុមនេះបានធ្វើការផ្លាស់ប្តូរការងារដែលជាយុទ្ធសាស្ត្រដោះស្រាយមួយដែលបង្ហាញពីភាពផុយស្រួយនៃជីវភាពរបស់ពួកគាត់។ ប្រជាជននៅក្នុងក្រុមនេះតិចតួចណាស់ដែលនិយាយថាពួកគាត់យល់ពីពាក្យ «ការប្រែប្រួលអាកាសធាតុ»។

រួមក្នុងការជួយក្រុមគោលដៅ ដើម្បីឲ្យពួកគាត់មានការផ្លាស់ប្តូរអាកប្បកិរិយាដូចបានលើកឡើងខាងដើម ដែលជាចំណុចស្នូលនៃការតាក់តែងគោលនយោបាយនានានាពេលអនាគត។

- តាមរយៈការសិក្សានេះបានរកឃើញចំណុចសំខាន់ៗសម្រាប់គោលនយោបាយដែលមានដូចជា បញ្ហាប្រព័ន្ធធារាសាស្រ្ត និងទឹកប្រើប្រាស់ ជាពិសេសសម្រាប់ប្រជាកសិករ និងអ្នកនេសាទ។ ដូច្នេះគោលនយោបាយដែលផ្តោតសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹក និងមានប្រព័ន្ធធារាសាស្រ្តប្រើប្រាស់ អាចនឹងផ្តល់នូវផលប្រយោជន៍សម្រាប់លទ្ធភាពរបស់បុរស និងស្ត្រីក្នុងការឆ្លើយតបជាមួយការប្រែប្រួលអាកាសធាតុ ព្រមទាំងជួយបង្កើននូវជីវភាព ក៏ដូចជាចូលរួមកាត់បន្ថយភាពក្រីក្រផងដែរ។ ការសិក្សានេះបានរកឃើញផងដែរថាស្ត្រីមានការប្រឈមនឹងភាពងាយរងគ្រោះទាក់ទងនឹងបញ្ហាទឹកប្រើប្រាស់ ដូចនេះស្ត្រីអាចនឹងទទួលបាននូវផលប្រយោជន៍ពីអភិក្រមផ្លាស់ប្តូរយេនឌ័រ (gender transformative approaches) ដែលធ្វើការពិចារណាអំពីតម្រូវការ និងបទពិសោធន៍ផ្សេងៗរបស់ស្ត្រី និងកុមារីជាដើម។
- ការកាត់តែង អនុវត្ត និងអភិវឌ្ឍគោលនយោបាយនានាក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុគួរសាកល្បងពិចារណាអំពីការផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយ ដោយគិតគូរអំពីសមត្ថភាពក្នុងការយល់ដឹងពីគោលនយោបាយទាំងនោះរបស់ភាគី/ក្រុមមនុស្សផ្សេងៗគ្នា ក៏ដូចជាការចូលរួមរបស់ពួកគេក្នុងដំណើរការរៀបចំគោលនយោបាយទាំងនោះ។
- ការវិភាគយ៉ាងពេញលេញអំពីប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុមិនបានគ្របដណ្តប់នៅក្នុងការសិក្សានេះទេ។ ដូច្នេះការវិភាគពេញលេញបែបនេះគួរតែពិចារណាសម្រាប់ការសិក្សាលើកក្រោយ ឬការសិក្សាផ្សេងទៀតនាពេលអនាគតដោយសារការវិភាគស៊ីជម្រៅអំពីប្រសិទ្ធភាពនៃគោលនយោបាយគឺមានសារៈសំខាន់ក្នុងការប្រើប្រាស់ប្រាស់ ដើម្បីផ្សារភ្ជាប់ជាមួយលទ្ធផលនៃការសិក្សាស្រាវជ្រាវដូចមានក្នុងការសិក្សានេះដើម្បីអាចផ្តល់ជាគំនិត អនុសាសន៍ពេញលេញសម្រាប់ការតាក់តែងគោលនយោបាយនាពេលអនាគត។

## ថ្នាក់ជាតិ

- តំបន់ភូមិសាស្ត្រមួយចំនួន ជាពិសេសតំបន់ឆ្នេរងាយទទួលរងគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុជាងគេ។ **ការបង្កើនវិមជ្ឈការដល់ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន** ស្តីពីកិច្ចអន្តរាគមន៍ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុអាចជួយគាំទ្រឲ្យការអនុវត្តកម្មវិធីអន្តរាគមន៍ទាំងនេះ កាន់តែមានប្រសិទ្ធភាពចំគោលដៅ និងឃើញលទ្ធផលភ្លាមៗនៅក្នុងកម្រិតសហគមន៍តាមមូលដ្ឋាន។ ឧទាហរណ៍ ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ ២០១៤-២០២៣ បានប្តេជ្ញាគាំទ្រភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ និងអនុវត្តការងារប្រែប្រួលអាកាសធាតុ។ គោលបំណងជាយុទ្ធសាស្រ្តទី៥ ស្តីពី «ការបង្កើនសមត្ថភាពចំណេះដឹង និងការយល់ដឹងអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ» គួរតែបន្តជាអាទិភាពរបស់ស្ថាប័នរាជរដ្ឋាភិបាលទាំងអស់ក្នុងការធ្វើសកម្មភាព និងកិច្ចអន្តរាគមន៍ ឆ្លើយតបនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ **ដូច្នេះ ផែនការដាក់លាក់ក្នុងការកសាងចំណេះដឹង និងការ**

**ប្រាស្រ័យទាក់ទងគួរតែត្រូវបង្កើតឡើង ដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់នានាទៅតាមតំបន់ងាយរងគ្រោះផ្សេងៗ។**

- ជួយគាំទ្រដល់រាជរដ្ឋាភិបាលនៅគ្រប់កម្រិត **ដើម្បីស្វែងយល់ និងជួយឲ្យការប្រាស្រ័យទាក់ទងកាន់តែមានប្រសិទ្ធភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលគួរត្រូវបានដាក់បញ្ចូលទៅក្នុងផែនការការងារ។** ការរៀបចំផែនការការងារ និងគោលបំណងដែលមានភាពងាយស្រួលយល់នៅគ្រប់កម្រិតនឹងជួយដល់ប្រជាជននៅក្នុងសហគមន៍ដោយបង្កើនការយល់ដឹង អំពីសកម្មភាពដែលពួកគាត់អាចឆ្លើយតបបាន។ ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ជាតិដែលទទួលបន្ទុកផ្នែកគោលនយោបាយការប្រែប្រួលអាកាសធាតុគួរពិចារណាវាយតម្លៃឡើងវិញចំពោះ៖ ១) ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការនានា ២) សមត្ថភាពស្ថាប័ន និងការសម្របសម្រួលផ្សេងៗ ៣) លទ្ធភាពទទួលបាន និងការប្រើប្រាស់ព័ត៌មាន និង៤) វាយតម្លៃសមត្ថភាពរបស់អ្នកអនុវត្តន៍ដើម្បីត្រៀមរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពឲ្យត្រូវតាមកម្រិតដែលអាចកែលម្អការអនុវត្តការងារបានទាន់ពេលវេលា។
- ដើម្បីធានាបានថាការអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិមានប្រសិទ្ធភាព ការត្រួតពិនិត្យតាមដានដ៏ទៀងទាត់គួរតែត្រូវបានធ្វើឡើង ដើម្បីពិនិត្យមើលពីវឌ្ឍនភាពនៅតាមមូលដ្ឋាន និងការគាំទ្រដែលត្រូវការចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ។ ការពិនិត្យតាមដាននេះក៏ធានាឲ្យមានការបន្សុីគ្នាប្រកបដោយប្រសិទ្ធភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។
- ភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ **គួរពិចារណាលើការផ្សព្វផ្សាយប្រកបដោយយុទ្ធសាស្ត្រនូវរបាយការណ៍ប្រចាំឆ្នាំ ឬរបាយការណ៍ដែលពាក់ព័ន្ធដូចជា វឌ្ឍនភាពនៃយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** ដែលរួមមាន សមិទ្ធផល ចំណុចរៀនសូត្រ និងផែនការឆ្ពោះទៅមុខដើម្បីជួយដល់ភាគីពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនឲ្យបានយល់ដឹងថាពួកគេគួររួមចំណែកបន្ថែមទៀតនៅត្រង់ចំណុចណា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាល។ ការផ្សព្វផ្សាយនេះអាចធ្វើបានតាមរយៈការបង្កើតវេទិកាចែករំលែកចំណេះដឹង ឬវេទិកាដែលភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់អាចមកជួបជុំគ្នាស្តាប់អំពីរបាយការណ៍ ឬបច្ចុប្បន្នភាពនៃការងារនេះក៏ដូចជាចែករំលែកចំណុចរៀនសូត្រពីគ្នាទៅវិញទៅមក ដើម្បីពង្រឹងចំណេះដឹងផងដែរ។ ការបន្តអនុវត្តកម្មវិធីស្រាវជ្រាវដើម្បីស្វែងយល់ពីផលប៉ះពាល់នានានៃការប្រែប្រួលអាកាសធាតុមកលើប្រជាជនកម្ពុជា ជាពិសេសស្វែងរកយុទ្ធសាស្ត្រទប់ទល់ និងបន្សាំទៅនឹងបញ្ហាកង្វះទឹក និងគ្រោះរាំងស្ងួតដែលមានប្រយោជន៍ខ្លាំងណាស់។

## ថ្នាក់ក្រោមជាតិ

- **ការបង្កើនសមត្ថភាព និងធនធានសម្រាប់ភាគីពាក់ព័ន្ធនានាដែលទទួលខុសត្រូវលើការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហានេះ។** អាជ្ញាធរមូលដ្ឋានគឺជាប្រភពព័ត៌មានដ៏គួរឲ្យទុកចិត្ត និងជាអ្នកមានឥទ្ធិពលក្នុងសហគមន៍ ហើយពួកគាត់អាចជួយជំរុញប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបាន។ ការជួយ

គាំទ្រដល់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានអាចជួយឲ្យការប្រាស្រ័យទាក់ទងជាមួយសហគមន៍កាន់តែមានប្រសិទ្ធភាពក្នុងការធ្វើសកម្មភាព និងជួយឲ្យសហគមន៍មានការឆ្លើយតបបានកាន់តែល្អប្រសើរជាងមុន។ មន្ត្រីថ្នាក់ក្រោមជាតិក៏ទាមទារសមត្ថភាពខ្ពស់ ក្នុងការរៀបចំផែនការ ផ្តល់ហិរញ្ញប្បទាន និងអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ស្របតាមក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលផ្តល់ដោយរាជរដ្ឋាភិបាលផងដែរ។

- ប្រជាជនបានកោតសរសើរចំពោះការដោះស្រាយបញ្ហាផ្នែកហេដ្ឋារចនាសម្ព័ន្ធដូចជា លទ្ធភាពទទួលបានទឹកប្រើប្រាស់ ពីព្រោះវាជាធនធានដ៏សំខាន់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនជាច្រើនជាពិសេសអ្នករស់នៅតំបន់ជនបទ។ រដ្ឋបាលថ្នាក់ក្រោមជាតិ **ក៏អាចពិចារណាអំពីការវិនិយោគទៅលើការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធអាចជួយប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតប**នឹងផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ។ ដូច្នេះជាអនុសាសន៍គេគួរពិចារណាលើការអភិវឌ្ឍផែនការចូលរួមជាក់លាក់ដើម្បីលើកទឹកចិត្តប្រជាជននៅថ្នាក់មូលដ្ឋានឲ្យធ្វើសកម្មភាពឆ្លើយតប។
- ការអភិវឌ្ឍសមត្ថភាពអាជ្ញាធរមូលដ្ឋានដើម្បីជួយសហគមន៍ក្នុងការរៀបចំអនុវត្ត និងតាមដានផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ អាជ្ញាធរមូលដ្ឋានមានសមត្ថភាពពិសេសក្នុងការឆ្លើយតបចំពោះបញ្ហាដែលប៉ះពាល់ដល់តំបន់រដ្ឋបាលគ្រប់គ្រងរបស់ពួកគាត់។ អាជ្ញាធរមូលដ្ឋានគួរតែធានាថាយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ឬកិច្ចអន្តរាគមន៍នានារបស់ពួកគាត់មានការផ្សារភ្ជាប់ជាមួយជីវិតរស់នៅប្រចាំថ្ងៃរបស់សមាជិក/ប្រជាជនក្នុងសហគមន៍ បទពិសោធន៍នៃផលប៉ះពាល់ដែលប្រជាជនជួបប្រទះ និងលើកកម្ពស់បច្ចេកទេស និងការអនុវត្តប្រកបដោយនិរន្តរភាព ដែលអាចឆ្លើយតប/ពាក់ព័ន្ធទៅនឹងតម្រូវការសហគមន៍ក៏ដូចជាជីវភាពរបស់ពួកគាត់ផងដែរ។ **ដូច្នេះ ការមានផែនការជំរុញការចូលរួមដើម្បីធ្វើសកម្មភាពឆ្លើយតបនៅកម្រិតមូលដ្ឋាន ជាអនុសាសន៍ដែលគួរតែធ្វើ។ ការលើកទឹកចិត្តសហគមន៍ឲ្យធ្វើសកម្មភាពនៅថ្នាក់មូលដ្ឋានគួរត្រូវបានពង្រឹងបន្ថែម តាមរយៈការបង្កើនការអប់រំក្រៅប្រព័ន្ធស្តីពីបរិស្ថានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែលសហគមន៍អាចចូលរួមបាន។** សម្រាប់ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធទី១ ស្តីពីយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង។

## អ្នកដឹកនាំសហគមន៍/អ្នកមានឥទ្ធិពលនៅមូលដ្ឋាន

- អ្នកដឹកនាំសហគមន៍ និងអ្នកមានឥទ្ធិពលនៅមូលដ្ឋានគឺជាភាគីដ៏សំខាន់ទីមួយដែលប្រជាជនក្នុងសហគមន៍តែងពឹងពាក់ពេលមានបញ្ហាអ្វីមួយ។ ការស្រាវជ្រាវនេះបានរកឃើញថាពួកគាត់គឺជាអ្នកពាក់ព័ន្ធសំខាន់ក្នុងការដោះស្រាយបញ្ហា ហើយពេលខ្លះពួកគាត់ត្រូវបានគេចាត់ទុកថាជាប្រភពព័ត៌មានសំខាន់ ឬជាបុគ្គលគំរូថែមទៀតផង។ **ដូច្នេះមេភូមិ ឬប្រធានក្រុមប្រឹក្សាឃុំក៏គួរតែទទួលបានការបណ្តុះបណ្តាល និងការគាំទ្រដើម្បីឲ្យមានការយល់ដឹងបន្ថែមអំពីបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែលប៉ះពាល់ដល់សហគមន៍របស់ពួកគាត់។** ជាងនេះទៅទៀតការស្វែងយល់ពីតម្រូវការ និងការយល់ឃើញនានារបស់សមាជិកនៅក្នុងសហគមន៍ រួមទាំងក្រុមងាយរងគ្រោះក៏សំខាន់សម្រាប់ពួកគាត់ផងដែរ។ ក្នុងនាមជាភាគីពាក់ព័ន្ធដែលគេមានទំនុកចិត្ត ពួកគាត់គឺជាតួអង្គសំខាន់ក្នុងការ

ជំរុញការចូលរួមរបស់សហគមន៍ កសាងទំនុកចិត្ត និងណែនាំគំនិតផ្តួចផ្តើមថ្មីៗ ឬការគាំទ្រដែលមានប្រយោជន៍ដល់សហគមន៍។

- សមាជិកនៅក្នុងសហគមន៍មានជំនឿចិត្តខ្ពស់ទៅលើបុគ្គលមានឥទ្ធិពលនៅក្នុងសហគមន៍ដូចជា គ្រូបង្រៀន ឬអ្នកដឹកនាំសាសនាជាដើម។ ប៉ុន្តែក្រុមទាំងនេះមិនទាន់ត្រូវបានគេចាត់ទុកថាជាប្រភពព័ត៌មានដ៏សំខាន់ស្តីពីការប្រែប្រួលអាកាសធាតុនៅឡើយទេ។ **រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀតគួរស្វែងរកភាពជាដៃគូជាមួយអ្នកដឹកនាំទាំងនេះ ដោយសារពួកគាត់ទទួលបានការជឿទុកចិត្តពីសំណាក់ប្រជាជននៅក្នុងសហគមន៍ដើម្បីផ្សព្វផ្សាយព័ត៌មាន និងជំរុញសកម្មភាពឆ្លើយតបចាំបាច់នានានៅតាមសហគមន៍។**

## អង្គការមិនមែនរដ្ឋាភិបាល/វិស័យឯកជន/គ្រឹះស្ថានឧត្តមសិក្សា

- ក្រៅពីភាគីរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ និងសាកលវិទ្យាល័យនានាក៏មានតួនាទីយ៉ាងសំខាន់ក្នុងការជួយដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងធ្វើការជាមួយប្រជាជនដើម្បីលើកកម្ពស់ការយល់ដឹង ចំណេះដឹង និងសកម្មភាពរបស់ពួកគាត់ផងដែរ។[87] ទោះបីជាយ៉ាងណាក៏ដោយ អ្នកពាក់ព័ន្ធទាំងនេះមានឱកាសតិចតួចក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងការរៀបចំកិច្ចអន្តរាគមន៍ឲ្យមានប្រសិទ្ធភាពជាងមុនដែលអាចផ្តល់ផលប្រយោជន៍ដល់សហគមន៍។ **វាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើតឲ្យមានការទទួលស្គាល់រួមគ្នាមួយដែលថាការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុគឺជាការទទួលខុសត្រូវរបស់អ្នកទាំងអស់គ្នា មិនមែនត្រឹមតែប្រជាជន និងរាជរដ្ឋាភិបាលប៉ុណ្ណោះនោះទេ។** វាក៏ជួយបង្កើតឱកាសក្នុងការភ្ជាប់បណ្តាញទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនានាឲ្យកាន់តែប្រសើរជាងមុនផងដែរ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុរវាងតួអង្គទាំងនេះ អាចជួយពង្រីកបន្ថែមនូវឥទ្ធិពលនៃគំនិតផ្តួចផ្តើមរបស់ភាគីនីមួយៗ។

- សមាជិកសហគមន៍ពឹងផ្អែកទាំងស្រុងលើការគាំទ្ររបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើសកម្មភាពឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ពួកគាត់ក៏មានទំនុកចិត្តខ្ពស់ចំពោះការឆ្លើយតបរបស់ភាគីពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហានេះផងដែរ។ **អង្គការមិនមែនរដ្ឋាភិបាលគួរបន្តកសាងទំនុកចិត្តជាមួយសមាជិកសហគមន៍ និងគាំទ្រពួកគាត់ឲ្យធ្វើសកម្មភាពឆ្លើយតបបន្ថែមទៀត។** អង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅតាមសហគមន៍អាចជួយប្រមូលសមាជិក/ប្រជាជនទាំងឡាយនៅតាមសហគមន៍ដើម្បីពិភាក្សាបំផុសគំនិតរួមគ្នា និងស្វែងរកដំណោះស្រាយក៏ដូចជាការចែករំលែកព័ត៌មាន និងដំណោះស្រាយសំខាន់ៗ ឬបច្ចេកទេសដែលមានសក្តានុពលជាមួយប្រជាជនផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅតាមបណ្តាសហគមន៍គួរ

[87] ជាឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយអាចជូនដំណឹងដល់ប្រជាជន សាកលវិទ្យាល័យក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ តាមរយៈការបង្រៀនរបស់ពួកគាត់ ហើយវិស័យឯកជនអាចស្វែងរកគំនិតផ្តួចផ្តើមនានារួមបញ្ចូលទាំងការប្រើប្រាស់ថាមពលឲ្យកាន់តែមានប្រសិទ្ធភាព និងពិពិធកម្មកសិកម្មជាដើម។

តែប្រកាន់យកនូវអភិក្រមប្រកបដោយបរិយាបន្ន (inclusive approach) ដើម្បីជួយគាំទ្រ និងចែករំលែកព័ត៌មានទៅដល់សមាជិកសហគមន៍។[88]

## តាក់តែងកម្មវិធីការប្រាស្រ័យទាក់ទង និងវិធានវាស់វែងគួរធ្វើឲ្យលើសពីម៉ាទ្រីកមូលដ្ឋាន

- ការសិក្សានេះមានគោលបំណងក្នុងការផ្តល់អនុសាសន៍ទៅលើបណ្ដុំសូចនាករសំខាន់ៗមួយចំនួន (ដោយផ្អែកទៅលើអញ្ញាតនានារបស់ KAP៣) ដើម្បីវាស់វែងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង និងការជំរុញការចូលរួមនាពេលអនាគត។ សូចនាករទាំងនេះគួរតែអាចប្រើក្នុងការតាមដានការផ្លាស់ប្ដូរចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនកម្ពុជា ចំពោះការប្រែប្រួលអាកាសធាតុបាន។ សូចនាករ ដែលត្រូវជ្រើសរើសគួរតែត្រូវបានធានាថាមានលក្ខណៈងាយស្រួលយល់សម្រាប់អ្នកអនុវត្តន៍ និងអ្នកធ្វើសេចក្ដីសម្រេចចិត្តលើគោលនយោបាយនានា ដូច្នេះវាអាចជួយពួកគាត់ក្នុងការវាយតម្លៃពីប្រសិទ្ធភាពរួមនៃការលើកកម្ពស់ការយល់ដឹង និងការខិតខំប្រឹងប្រែងកសាងសមត្ថភាពនៅក្នុងផ្នែកសំខាន់ៗនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបាន។
- យោងតាមការពិភាក្សានៅចំនុច ២.៥ នៃរបាយការណ៍នេះបានបង្ហាញថា ការសិក្សា KAP៣ បានប្រើវិធីសាស្ត្រ និងការអនុវត្តផ្សេងគ្នាពីការអង្កេតនៃ KAP មុនៗ។ ការសិក្សានេះបានសាកសួរប្រជាជនកម្ពុជាអំពីការប្រែប្រួលដែលពួកគាត់បានជួបប្រទះ ឬកត់សម្គាល់ពាក់ព័ន្ធនឹងធាតុអាកាស និងលទ្ធភាពទទួលបានធនធានសំខាន់ៗ ព្រមទាំងរបៀបដែលបញ្ហាដែលបានប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគាត់ផងដែរ។ ការប្រើប្រាស់វិធីសាស្ត្របែបនេះអាចផ្តល់ឱកាសដ៏មានប្រយោជន៍ក្នុងការប្រើប្រាស់ទិន្នន័យ KAP៣ សម្រាប់ជាមូលដ្ឋានថ្មីក្នុងការវាស់វែងសូចនាករនាពេលអនាគត។
- **ការវាស់វែងជារួម៖** សូចនាករវាស់វែងចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនកម្ពុជា និងការតាមដានការប្រែប្រួលទាក់ទងនឹងបញ្ហាទាំងនោះ គួរតែត្រូវបានកំណត់ឲ្យស្របទៅតាមយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុ កិច្ចអន្តរាគមន៍នានា និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងស្ដីពីការប្រែប្រួលអាកាសធាតុ។ ប្រសិនបើក្របខ័ណ្ឌនៃការវាស់វែងត្រូវបានតាក់តែងឲ្យកាន់តែស្របទៅនឹងយុទ្ធសាស្ត្រនោះវានឹងធ្វើឲ្យការវាស់វែង និងការយល់ដឹងអំពីផលប៉ះពាល់ទាំងនេះកាន់តែមានប្រសិទ្ធភាពជាងមុន។
- **ចំណេះដឹង៖** ការបន្តប្រើប្រាស់ម៉ាទ្រីកសម្រាប់ការវាស់វែងកម្រិតយល់ដឹងជារួមនៃពាក្យ «ការប្រែប្រួលអាកាសធាតុ» នឹងមានប្រយោជន៍ចំពោះតែកិច្ចខិតខំជារួម ដើម្បីជួយប្រជាជនកម្ពុជាឲ្យយល់ដឹងពីពាក្យគន្លឹះនេះ។ ការសិក្សា KAP៣ បានរកឃើញថា ស្របពេលដែលមានប្រជាជនចំនួនច្រើនយល់ដឹងអំពីពាក្យ «ការប្រែប្រួលអាកាសធាតុ» តែកម្រិតយល់ដឹងពីអត្ថន័យនៃពាក្យបច្ចេកទេសនេះ ហាក់ដូចនៅមានកម្រិតទាបនៅឡើយក្នុងចំណោមប្រជាជនកម្ពុជា។ ពួកគាត់មិនបានផ្សារភ្ជាប់ពាក្យបច្ចេកទេស

[88] ជាឧទាហរណ៍ ប្រជាជនមួយចំនួនយល់ថាការប្រជុំសហគមន៍ និងការពិភាក្សាមានប្រយោជន៍ ប៉ុន្តែអ្នកដទៃទៀតត្រូវបានដកចេញពីវេទិកាទាំងនេះ (ជាពិសេសគឺស្ត្រី និងជនពិការ)។ អង្គការមិនមែនរដ្ឋាភិបាលគួរតែមានគោលបំណងដែលធានាថាសកម្មភាពផ្សព្វផ្សាយរបស់ពួកគាត់បានផ្តល់ឱកាសដល់ប្រជាជនគ្រប់ប្រភេទក្នុងការចូលរួមដូចជា ការចុះជួបពួកគាត់ដល់ផ្ទះជាដើម។

នេះទៅនឹងការផ្លាស់ប្តូរដែលកើតឡើងក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ឡើយ។ ប្រសិនបើចំណេះដឹងស្តីពី «ការប្រែប្រួលអាកាសធាតុ» នឹងត្រូវតែបន្តប្រើប្រាស់ជាម៉ាទ្រីសសម្រាប់ការវាស់វែងកម្រិតនៃការយល់ដឹង ហេតុនេះត្រូវចំបាច់ស្វែងយល់អំពីមូលហេតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងចំណោមប្រជាជនកម្ពុជា។ ការតាមដានសូចនាករមួយចំនួនដូចជា កម្រិតនៃការយល់ដឹងអំពីពាក្យបច្ចេកទេសតាមរយៈការប្រើប្រាស់បញ្ជីសំណួរដែលផ្តោតសំខាន់លើចំណេះដឹង ឬធ្វើតេស្តចំណេះដឹងនឹងមានប្រសិទ្ធភាពច្រើនជាងមុនក្នុងការវាស់វែងពីការផ្លាស់ប្តូរ។

- **ការធ្វើសកម្មភាពឆ្លើយតប៖** ការវាស់វែង និងតាមដានសកម្មភាពឆ្លើយតបជាក់លាក់ណាមួយជាលក្ខណៈបុគ្គលអាចនឹងមានប្រសិទ្ធភាពច្រើនជាងមុនក្នុងតាមរយៈការជំរុញលើកទឹកចិត្តពីកម្មវិធី ឬកិច្ចអន្តរាគមន៍ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ក្រៅពីការវាស់វែងសកម្មភាពឆ្លើយតបទាំងមូលឬសកម្មភាពណាមួយដែលបានអនុវត្ត វានឹងកាន់តែមានប្រសិទ្ធភាពជាងមុន ប្រសិនបើសកម្មភាពឆ្លើយតបនានាអាចបែងចែកទៅតាមប្រភេទ និងក្រុមមនុស្សផ្សេងៗគ្នា ដូចមាននៅក្នុងការសិក្សា KAP៣ នេះ)ដូចជាសកម្មភាពឆ្លើយតបនឹងកង្វះខាតទឹក កង្វះខាតចំណីអាហារ ឬជីវភាពរស់នៅជាដើម(។ ការធ្វើបែបនេះនឹងបង្កើនការយល់ដឹងកាន់តែច្បាស់អំពីសកម្មភាពដែលប្រជាជនបានឆ្លើយតប និងអាចតាមដានស្វែងរកប្រភពនៃអន្តរាគមន៍ និងយុទ្ធសាស្រ្តជាក់លាក់ណាមួយផងដែរ។ ការវាស់វែងគួរផ្តោតសំខាន់ទៅលើប្រភេទសកម្មភាពជាលក្ខណៈបុគ្គល ប្រសើរជាងការរាយការណ៍អំពីសកម្មភាពឆ្លើយតបជាលក្ខណៈសហគមន៍ ដែលអាចកាត់បន្ថយកម្រិតនៃកំហុសក្នុងការវិនិច្ឆ័យ។
- **ប្រសិទ្ធភាព៖** ការវាស់វែងពីប្រសិទ្ធភាពផ្តោតសំខាន់លើកម្មវិធី ឬកិច្ចអន្តរាគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ សូចនាករសំខាន់មួយដើម្បីត្រួតពិនិត្យ តាមដានបន្តគឺថាតើបុគ្គលម្នាក់ៗមានទំនុកចិត្ត និងមានការជំរុញទឹកចិត្តក្នុងការអនុវត្តបែបណាចំពោះបញ្ហាទាក់ទងនឹងអាកាសធាតុទាំងនៅកម្រិតបុគ្គល និងកម្រិតសហគមន៍។
- **ការយល់ដឹងអំពីការគាំទ្រ និងការជឿជាក់លើស្ថាប័ននានា៖** ការបន្តការតាមដានឧបសគ្គរាំងផ្នែកធនធាន ផ្នែកសង្គម និងផ្នែកស្ថាប័ន ក្នុងការធ្វើសកម្មភាពឆ្លើយតបក៏ដូចជាការតាមដានអំពីគន្លឹះដែលធ្វើឲ្យឧបសគ្គទាំងនេះមានការថយចុះ ដើម្បីឲ្យការវាស់វែងដ៏មានប្រសិទ្ធភាពក្នុងការស្វែងយល់ពីទស្សនៈរបស់ប្រជាជនកម្ពុជាទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ការបង្កើនទំនាក់ទំនងរវាងឧបសគ្គនានាជាមួយនឹងកិច្ចអន្តរាគមន៍ ឬគម្រោងដោះស្រាយការប្រែប្រួលអាកាសធាតុ នឹងធ្វើឲ្យការវាស់វែងកាន់តែមានប្រសិទ្ធភាពផងដែរ។ ការយល់ដឹងរបស់ប្រជាជនអំពីប្រភេទនៃការគាំទ្រដែលមានស្រាប់ ឬការគាំទ្រដែលពួកគាត់អាចទទួលបានការគាំទ្រពីស្ថាប័នផ្សេងៗគ្នា) ស្ថាប័នរដ្ឋាភិបាល ឯកជន អង្គការសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាល (គឺជាការវាស់វែងដ៏មានប្រសិទ្ធភាពមួយផ្សេងទៀតក្នុងការស្វែងយល់ថាតើយុទ្ធសាស្រ្តរបស់ស្ថាប័នទាំងនេះ អាចជំរុញការចូលរួមរបស់ប្រជាជនកម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាពដែរឬយ៉ាងណា។

# ឯកសារយោង


ActionAid Cambodia. (2020). *The Cambodia Women's Resilience's Index.* Phnom Penh: ActionAid Cambodia. Retrieved 20 October 2020, from: https://cambodia.actionaid.org/publications/2019/cambodia-womens-resilience-index-2019#downloads

ADPC & UNDRR. (2019). *Disaster Risk Reduction in Cambodia: Status Report 2019.* United Nations Office for Disaster Risk Reduction (UNDRR), Regional Office for Asia and the Pacific.

Asian Development Bank (ADB). (2015). *Promoting Women's Empowerment in Cambodia.* Philippines: Asian Development Bank. Retrieved 12 February 2020, from: https://www.adb.org/sites/default/files/publication/156499/promoting-womens-economic-empowerment.pdf

BBC Media Action. (2019). *How the people of Cambodia live with climate change and what media and communication can do.* BBC Media Action.

DCC/GSSD. (2016). *Cambodia's National Climate Change M&E Framework.* Retrieved 10 January 2020, from: http://www.camclimate.org.kh/en/documents-and-media/library/category/140-climate-change-m-e-framework.html?download=727:cambodia-s-national-climate-change-m-e-framework-brief-en

Di Deodato, L., Erdogmus, G., & Detten, R. (2018) *Research and Development in Climate Change and Related Areas within Higher Education in Cambodia, Laos and Vietnam: Current Status and Trends.* Erasmus+ project REACT. Retrieved February 12, 2020, from: https://www.climate-react.eu/sites/default/files/react_-_rd_in_climate_change_en_web.pdf

Eckstein, D., Kunzel, V., Schafer, L., & Winges, M. (2020) *Global Climate Risk Index 2020.* Bonn: GermanWatch. Retrieved 12 October 2020, from: https://germanwatch.org/sites/germanwatch.org/files/20-2-01e%20Global%20Climate%20Risk%20Index%202020_14.pdf

Goh, A. H. (2012) *A Literature Review of The Gender-Differentiated Impacts of Climate Change on Women's and Men's Assets and Well-being in Developing Countries.* Washington DC: International Food Policy Research Institute. Retrieved 10 October 2020, from: https://ebrary.ifpri.org/digital/collection/p15738coll2/id/127247

Green Climate Fund. (n.d.). *National Committee for Sub-National Democratic Development Secretatiat.* Retrieved 23 November 2020, from: https://www.greenclimate.fund/ae/ncddsecretariat

GSSD. (2015). *Cambodia's Second National Communication under the United Nations Framework Convention on Climate Change.* Phnom Penh: GSSD/ME. Retrieved 20 October 2020, from: http://unfccc.int/resource/docs/natc/khmnc2.pdf

GSSD. (2017). *National Adaption Plan Process in Cambodia*. Phnom Penh: General Secretariat of National Council for Sustainable Development/Ministry of Environment, Cambodia. Retrieved 12 February 2020, from:

https://ncsd.moe.gov.kh/sites/default/files/phocadownload/POLICYFRAMEWORK/FINANCING/cambodia%20nap%20process%20document.pdf

IPCC. (2018). *Global Warming of 1.5°C.* Retrieved 7 December 2020, from: https://www.ipcc.ch/site/assets/uploads/sites/2/2019/06/SR15_AnnexI_Glossary.pdf

Käkönen, M., Lebel, L., Karhunmaa, K., Dany, V., & Try, T. (2014) Rendering climate change governable in the least-developed countries: Policy narratives and expert technologies in Cambodia. *Forum for Development studies, 41*(3), 351–376. DOI: 10.1080/08039410.2014.962599

Kem, K. (2016). *Progress of Women in Politics in Cambodia.* Phnom Penh: PIC. Retrieved 12 Frbruary 2020, from: https://www.pic.org.kh/images/2016Research/20170523%20Progress%20of%20Women%20in%20Politics_Eng.pdf

MAFF, NCSD & MoE. (2019). *Adaptation Technologies Guide – Agriculture.* Phnom Penh, Cambodia. Retrieved 12 Frbruary 2020, from: https://ncsd.moe.gov.kh/resources/document/adaptation-technologies-guide-agriculturejune-2019en

MAFF. (2020). *Annual Report of Ministry of Agriculture, Forestry and Fisheries.* Phnom Penh: MAFF.

MEF & GSSD. (2019). *Adressing Climate Change Impacts on Economic Growth in Cambodia.* MEF and GSSD. Retrieved 10 October 2020, from: https://www.kh.undp.org/content/cambodia/en/home/library/2019/addressing-climate-change-impacts-on-economic-growth-in-cambodia.html

MoE. (2011). *Understanding public perceptions of climate change in Cambodia (KAP1).* Phnom Penh: MoE.

MoE. (2016). *A Second Study on Understanding of Public Perception of Climate Change in Cambodia: Knowledge, Attitudes and Practices.* Phnom Penh: MoE

MoE & FAO. (2020). *Concept note: Public-Social-Private Partnerships for Ecologically-Sound Agriculture and Resilient Livelihood in Tonle Sap Basin (PEARL)*. Green Climate Fund. Retrieved 21 October 2020, from: https://www.greenclimate.fund/sites/default/files/document/23210-public-social-private-partnerships-ecologically-sound-agriculture-and-resilient-livelihood.pdf

MoEYS. (2018). *Climate Change Textbook for the Upper Secondary Scool.* Ministry of Education, Youth and Sport. Retrieved 12 February 2020, from: https://ncsd.moe.gov.kh/sites/default/files/2019-08/CC%20Textbook%20for%20Upper%20Secondary%20School_2018_kh.pdf

MoWA. (2014). *Attitude Gender Relations and Attitude Cambodia Gender Assessment*. Phnom Penh: MoWA.

NCDDS. (2017). *Concept note: Local Governments and Climate Change (LGCC)*. Green Climate Fund. Retrieved 21 October 2020, from: https://www.greenclimate.fund/sites/default/files/document/17610-local-governments-and-climate-change-lgcc.pdf

NCSD. (2019a). *NDC Roadmap and Stakeholder Engagement Plan 2019-2030.* Phnom Penh: National Council for Sustainable Development. Retrieved 10 February 2020, from: https://ncsd.moe.gov.kh/sites/default/files/2019-08/Cambodia%20NDC%20Roadmap%20and%20Stakeholder%20Engagement%20Plan_awaiting%20signature_2019_en.pdf

NCSD. (2019b) *Mid-term review of Cambodia Climate Change Strategic Plan 2014-2023.* Phnom Penh: General Secretariat of the National Council for Sustainable Development. Retrieved 12 February 2020, from: https://ncsd.moe.gov.kh/sites/default/files/2019-08/CCCSP%20MTR_Final%20Evaluation%20Report_final_cleared.pdf

Nicholson, K., & Dourng, K. (2019). *Addressing climate change impacts on economic growth in Cambodia.* Phnom Penh: MEF and GSSD. Retrieved 12 October 2020, from: https://www.kh.undp.org/content/cambodia/en/home/library/2019/addressing-climate-change-impacts-on-economic-growth-in-cambodia.html

OECD. (2014). *Guidelines for Resilience Systems Analysis*. OECD. Retrieved 23 December 2020, from: https://www.oecd.org/dac/Resilience%20Systems%20Analysis%20FINAL.pdf

Oxfam America. (2010). R*ural Women, Gender, and Climate Change: A Literature Review and Invited Perspectives on Climate Change Impacts and Processes of Adaptation in Cambodia.* Retrieved 12 February 2020, from: http://www.rrcap.ait.asia/Publications/LITERATURE_REVIEW_-_Rural_Women_Gender_and_Climate_Change.pdf

Oxfam. (n.d.). *Drought Management Considerations for Climate Change Adaptation: Focus on the Mekong Region.* Retrieved 12 February 2020, from: https://oxfamilibrary.openrepository.com/bitstream/handle/10546/112524/drought-management-considerations-climate-change-adaptation-cambodia-211008-en.pdf;jsessionid=D91D4DFE40F841D74CE228C6CE7341FC?sequence=1

RGC. (2013a). *Cambodia Climate Change Strategic Plan 2014–2023.* NCCC. Retrieved 12 February 2020, from: http://cambodiaip.gov.kh/DocResources/ab9455cf-9eea-4adc-ae93-95d149c6d78c_007729c5-60a9-47f0-83ac-7f70420b9a34-en.pdf

RGC. (2013b). *National Action Plan for Disaster Risk Reduction (NAP-DRR) 2014-2018.* The Royal Government of Cambodia. Retrieved 10 Januray 2020, from: https://www.rcrc-resilience-southeastasia.org/wp-content/uploads/2017/12/2014_national_action_plan_for_disaster_risk_reduction__nap-drr__2014-2018_english.pdf

RGC. (2018). *Rectangular Strategy for Growth, Employment, Equity, and Efficiency: Building The Foundation Toward Realizing the Cambodia Vision 2050 Phase IV.* Phnom Penh: RGC.

RGC. (2019). *National Strategic Development Plan 2019–2023.* Phnom Penh: RGC. Retrieved 29 January 2020, from: https://data.opendevelopmentmekong.net/dataset/087e8a03-f09d-4eb2-94f2-00d8d237b342/resource/bb62a621-8616-4728-842f-33ce7e199ef3/download/nsdp-2019-2023_en.pdf

RUA. (n.d). *Royal University of Agriculture*. Retrieved 23 December 2020, from: http://www.rua.edu.kh/index.php/view_divicen/137365694144

RUPP. (2020). *Master of Science in Climate Change. Curriculum brochure*, Royal University of Phnom Penh, Retrieved 29 January 2020, from: http://www.rupp.edu.kh/graduate/climate_change/

Sao, V., Gowland, S., Kim, L., Hor, O., & Ratan, A. (2020). *Participatory Action Research on Gender-based Vulnerabilities to Climate Change in Cambodia.* Phnom Penh: BBC Media Action.

Snow, C., & Taylor, W. (2015). Media, discussion and attitudes in fragile contexts. BBC Media Action. Retreived 3 December 2020, from: http://downloads.bbc.co.uk/mediaaction/pdf/research/media-discussion-attitudes-fragile-contexts-report.pdf

Talberth, J., & Reytar, K. (2014). *Climate change in the lower Mekong River Basin: An Analysis of Economic Value at Risk.* New York: USAID. Retrieved 20 October 2020, from: https://web.archive.org/web/20170221055112/http://mekongarcc.net/sites/default/files/usaid_marcc_values_at_risk_report_with_exesum-revised.pdf

UNICEF. (2017). Gender Equality: Glossary of Terms and Concepts. UNICEF Regional Office for South Asia. Retrieved 23 December 2020, from: https://www.unicef.org/rosa/media/1761/file/Gender%20glossary%20of%20terms%20and%20concepts%20.pdf

UNDP. (2012). *Cambodia Climate Public Expenditure and Institutional Review.* UNDP Regional Centre for Asia-Pacific. Retrieved 23 December 2020, from: https://www.climatefinance-developmenteffectiveness.org/sites/default/files/publication/attach/Cambodia%20CPEIR%20_web.pdf

UNDP. (2019). *Cambodia's Voluntary National Review 2019 of the Implementation of 2030 Agenda*. Retrieved 20 October 2020, from: https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_SDPM_Approved.pdf

Un, S. (2018) *Review of Implementation Challenges Posed by the Climate Change Action Plan 2014-2018 in Cambodia: Case Studies of Three Ministries.* Parliamentary Institute of Cambodia (PIC). Retrieved 8 January 8 2020, from: https://www.pic.org.kh/images/2018Research/20180611_Review%20of%20Implementation%20Challenges%20Posed%20by%20the%20Climate%20Change%20Action%20Plan%20in%20Cambodia.pdf

USAID. (2019). *Climate Risk Profile Cambodia.* USAID. Retrieved 12 October 2020, from: https://www.climatelinks.org/sites/default/files/asset/document/2019_USAID_Cambodia%20CRP.pdf

World Bank. (2020). *GDP growth (annual %) Cambodia*. World Bank. Retrieved 20 October 2020, from: https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?locations=KH

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ យុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង

### សេចក្តីផ្តើម

ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងជាឧបករណ៍ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការកសាងភាពធន់ និងជួយផ្លាស់ប្តូរជាវិជ្ជមានផ្នែកចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនស្តីពីការប្រែប្រួលអាកាសធាតុ។

ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងអាចជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើជីវិតរស់នៅរបស់ប្រជាជនកម្ពុជាតាមមធ្យោបាយជាច្រើនដូចជា៖

- ផ្សព្វផ្សាយព័ត៌មានបច្ចេកទេសឲ្យកាន់តែទូលំទូលាយ
- ដោះស្រាយបញ្ហាអវិជ្ជមាននៃបទដ្ឋានសង្គម និងការយល់ឃើញចំពោះបញ្ហានេះ
- គាំទ្រប្រជាជនឲ្យវាយតម្លៃជម្រើសរបស់ពួកគាត់ សម្របសម្រួលកិច្ចសន្ទនា/ពិភាក្សា និងជំរុញឲ្យមានការសម្រេចចិត្តជាវិជ្ជមាន

ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងមានសារៈសំខាន់ក្នុងការកសាងសមត្ថភាពរបស់អ្នកអនុវត្ត និងជំរុញការចូលរួមរបស់អ្នកតាក់តែងគោលនយោបាយ។ វាគឺជាអត្ថប្រយោជន៍ដែលគួរត្រូវបានប្រើប្រាស់ដើម្បីរួមចំណែកសម្រេចឲ្យបាននូវលទ្ធផលជាវិជ្ជមានទាក់ទងនឹងការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ការប្រើប្រាស់ទិន្នន័យ និងការយល់ដឹងដែលទទួលបានពីការសិក្សា KAP៣ ឧបសម្ព័ន្ធនេះមានគោលបំណងបង្ហាញមាគ៌ាដល់ភាគីពាក់ព័ន្ធជាច្រើនដូចជា រាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយនានា អំពីរបៀបនៃការប្រាស្រ័យទាក់ទងអាចត្រូវបានប្រើប្រាស់ដើម្បីជះឥទ្ធិពលដល់ការផ្លាស់ប្តូរជាវិជ្ជមានចំពោះចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនជុំវិញការប្រែប្រួលអាកាសធាតុ។ វាបង្ហាញពីជំហានខុសៗគ្នាដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងផ្តល់ឧទាហរណ៍ជាក់ស្តែងដោយផ្អែកទៅលើអនុសាសន៍ពីការសិក្សានេះផងដែរ។ ភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍អាចប្រើប្រាស់វិធីសាស្ត្រចង្អុលបង្ហាញ និងចំណុចចាប់ផ្តើមទាំងនេះដោយឯករាជ្យ ឬអាចប្រើប្រាស់ជាមួយផែនការ និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងផ្សេងទៀតក៏បាន។

### ការបន្សុីគ្នាជាមួយនឹងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងផ្សេងទៀត

វាពិតជាមានអត្ថប្រយោជន៍ណាស់ក្នុងការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងរួម និងអាចប្រើប្រាស់នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងផ្នែកប្រាស្រ័យទាក់ទងមានភាពសុីសង្វាក់គ្នាល្អនៅទូទាំងប្រទេសកម្ពុជា និងសម្រេចឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ច។ ការតាក់តែងយុទ្ធសាស្ត្រអាចធ្វើទៅបានតាមរយៈការស្វែងរកភាពសុីសង្វាក់គ្នា និងការបន្សុីគ្នានៃគោលបំណង និងសារសម្រាប់ការប្រាស្រ័យទាក់ទងផងដែរ។ ដើម្បីឲ្យមានការប្រាស្រ័យទាក់ទងបែបនេះបានគឺទាមទារឲ្យមានការវិភាគ

ទស្សនៈស៊ីជម្រៅជារួមទាំងកិច្ចខិតខំប្រឹងប្រែងនានាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបន្សាំនៅក្នុងប្រទេសកម្ពុជាដែលមានស្រាប់ និងគម្រោងផែនការនានាសម្រាប់ការអនុវត្តបន្ត ដូចនេះទស្សនៈទាំងនេះគឺមិនស្ថិតក្នុងវិសាលភាពនៃការសិក្សានេះទេ។ ឧទាហរណ៍ គោលបំណងនៃយុទ្ធសាស្ត្រទី ៥ របស់ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាដែលផ្តោតលើការពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ[89] គឺពាក់ព័ន្ធជាពិសេសទៅនឹងអនុសាសន៍នៃការសិក្សារបស់ KAP៣ ក៏ដូចជាតម្រូវការតាក់តែងកម្មវិធីលើកកម្ពស់ចំណេះដឹងឲ្យបានចំគោលដៅក្នុងការជួយគាំទ្រក្រុមប្រជាជនងាយរងគ្រោះបំផុត។

គោលបំណងនៃផែនការប្រាស្រ័យទាក់ទងរបស់ផែនការបន្សាំថ្នាក់ជាតិនៅប្រទេសកម្ពុជាគឺ ដើម្បី «ធ្វើយ៉ាងណាឲ្យភាគីពាក់ព័ន្ធសំខាន់នានា ក្លាយជាអ្នកដើរតួនាទីយ៉ាងសកម្មលើការអនុវត្តសកម្មភាពបន្សាំខ្លួននានាដូច្នេះ [...] វាអាចជួយកៀរគរធនធាន និងពង្រីកវិសាលភាពនៃការអនុវត្តក៏ដូចជាបង្កើនចំណេះដឹងផងដែរ»។[90] ដូចនេះហើយការលើកឡើងខាងដើមនេះមានវិសាលភាពខុសគ្នាពីការផ្តល់យោបល់ដែលបានលើកឡើងនៅក្នុងការសិក្សានៃរបាយការណ៍នេះដែលផ្តោតសំខាន់លើការគាំទ្រដល់ការផ្លាស់ប្តូរនានាតែក្នុងកម្រិតប្រជាជនប៉ុណ្ណោះ។ ទោះជាយ៉ាងណាវាអាចនឹងមានអត្ថប្រយោជន៍សម្រាប់លទ្ធផលនៃការប្រាស្រ័យទាក់ទងនាពេលអនាគត ប្រសិនបើការប្រាស្រ័យទាក់ទងនោះមានភាពស្របគ្នាជាមួយយុទ្ធសាស្ត្រដើម្បីបន្សុីគ្នាជាមួយការផ្សព្វផ្សាយព័ត៌មានទៅកាន់ក្រុមនានានៅទូទាំងប្រទេសកម្ពុជា។ យោបល់ណែនាំល្អៗមួយចំនួនអំពីវិធី ដែលអាចគ្របដណ្តប់ភាគីពាក់ព័ន្ធសំខាន់ៗត្រូវបានលើកឡើង។ ឧទាហរណ៍ក្នុងរូបភាពទី ៤៖ បណ្តាញ និងឧបករណ៍សម្រាប់ប្រាស្រ័យទាក់ទងនៅក្នុងផែនការបន្សាំថ្នាក់ជាតិនៅប្រទេសកម្ពុជា[91] ដែលត្រូវបានយកមកប្រើប្រាស់ក្នុងឧបសម្ព័ន្ធនេះ។ ដូចគ្នានេះដែរអ្នកអនុវត្តការងារផ្នែកប្រាស្រ័យទាក់ទងទៅនឹងដំណើរការផែនការបន្សាំថ្នាក់ជាតិនាពេលអនាគត ប្រហែលជាអាចដាក់បញ្ចូលអនុសាសន៍មួយចំនួនពីការសិក្សា KAP៣ ទៅក្នុងផែនការរបស់ខ្លួនបានផងដែរ។

[89] RGC NCCC (២០១៣) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤–២០២៣, ទំព័រទី១៦

[90] GSSD (២០១៩) ផែនការបន្សាំថ្នាក់ជាតិនៅប្រទេសកម្ពុជា។ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង. RGC GSSD, MoE, ភ្នំពេញ, ទំព័រទី៧

[91] Ibid, ទំព័រទី៩

## ធាតុផ្សំរបស់យុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពគឺដូចជាល្បែងផ្គុំរូបភាព (jigsaw) ដែលមានធាតុផ្សំផ្សេងៗ រួមគ្នាដើម្បីសម្រេចបានផែនការទាំងមូល។ ក្នុងផ្នែកនេះបង្ហាញអំពីក្រុមខុសគ្នានៅក្នុងសង្គមកម្ពុជា និងការផ្តល់យោបល់អំពីការបង្កើតយុទ្ធសាស្ត្រ ដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូរជាវិជ្ជមានខាងផ្នែកចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាជនកម្ពុជាជុំវិញការប្រែប្រួលអាកាសធាតុ។




**រូបភាពទី២៦៖ រូបផ្គុំ (jigsaw) នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង**

### *កំណត់គោលបំណងរបស់អ្នក*

វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ឲ្យបានច្បាស់នូវការផ្លាស់ប្តូរដែលចង់ទទួលបានថា តើវាជាការលើកកម្ពស់ការយល់ដឹង ការផ្លាស់ប្តូរឥរិយាបថ ការកសាងជំនាញ ឬការជំរុញឲ្យមានការពិភាក្សា។ នៅពេលដែលត្រូវដោះស្រាយប្រធានបទស្មុគស្មាញ និងមានច្រើនផ្នែកដូចជា ការប្រែប្រួលអាកាសធាតុ និងការពង្រឹងសិទ្ធិអំណាចដល់ប្រជាជនឲ្យធ្វើសកម្មភាពដោយឯករាជ្យ វាមានសារៈសំខាន់ណាស់ក្នុងការគិតឲ្យបានទូលំទូលាយលើសពីការបង្កើនការយល់ដឹង និងចំណេះដឹងទៅទៀត។ ឧទាហរណ៍ យុទ្ធសាស្ត្រនេះអាចរួមបញ្ចូលទាំងការបំបែកឧបសគ្គផ្នែកសង្គម និងបទដ្ឋានយេនឌ័រ ហើយជំរុញទឹកចិត្តប្រជាជនឲ្យពេញចិត្តក្នុងការធ្វើការរួមគ្នាជាសហគមន៍។ ដើម្បីបង្កើនលទ្ធភាពជោគជ័យ គោលបំណងនៃការប្រាស្រ័យទាក់ទងគួរតែផ្តោតសំខាន់លើសេចក្តីត្រូវការ និងអាទិភាពរបស់ប្រជាជន ឬក្រុមគោលដៅ។ ការបំបែកគោលបំណងធំទៅជាគោលដៅនានាដែលអាចវាស់វែងបាន និងអាចជួយវាយតម្លៃពីផលប៉ះពាល់នៃកិច្ចអន្តរាគមន៍នានាផងដែរ។ គោលដៅទាំងនេះអាចរួមបញ្ចូលនូវចំនួនប្រជាជនគោលដៅដែលគួរគ្របដណ្តប់ ការផ្លាស់ប្តូរឥរិយាបថជាក់លាក់ណាមួយដែលចង់ឃើញ ឬការផ្លាស់ប្តូរគោលនយោបាយណាមួយដែលគួរធ្វើជាដើម។

## ស្គាល់ក្រុមគោលដៅរបស់អ្នក

ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពធ្វើឲ្យក្រុមគោលដៅបង្កើនការយល់ដឹងស៊ីជម្រៅអំពីបញ្ហាទាំងអស់នេះ។ ឧទាហរណ៍ ក្នុងការប្រាស្រ័យទាក់ទងគេត្រូវស្គាល់/ដឹងពីគុណតម្លៃ ឥរិយាបថ ការយល់ឃើញ ការអនុវត្ត សេចក្តីត្រូវការ បញ្ហាអាទិភាព និងចំណង់ចំណូលចិត្ត ក៏ដូចជាទម្លាប់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុមគោលដៅផងដែរ។ ការសិក្សា KAP៣ បានផ្តល់នូវប្រភពទិន្នន័យដ៏សំបូរបែប និងការយល់ដឹងជាច្រើនដែលអាចយកមកប្រើប្រាស់ដើម្បីស្គាល់ក្រុមគោលដៅបាន។

ក្រុមមនុស្សផ្សេងគ្នាមានតម្រូវការផ្សេងៗគ្នាទៅតាមភេទ តំបន់/ទីតាំងរស់នៅ ភាពសម្បូរបែបកម្រិតនៃការអប់រំ និងស្ថានភាពជីវភាព។ ក្រុមនីមួយៗដែលបានចែងក្នុងផ្នែកទី៤.៩ នៅក្នុងរបាយការណ៍បានផ្តល់នូវការយល់ដឹងដ៏មានតម្លៃចំពោះឥរិយាបថ និងសេចក្តីត្រូវការរបស់ក្រុមនីមួយៗដែលផ្តោតសំខាន់មិនត្រឹមតែលើទិន្នន័យប្រជាសាស្ត្រប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវគំនិតជាយុទ្ធសាស្ត្រជាច្រើនទៀតផងដែរ។ ការធ្វើឲ្យប្រសើរឡើងនូវការឆ្លើយតបរបស់ប្រជាជនចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុតម្រូវឲ្យមានការទទួលស្គាល់ថាប្រជាជនមានភាពចម្រុះគ្នា និងផ្តល់អាទិភាពដល់ក្រុមដែលងាយរងគ្រោះជាងគេ។ ក្រុមងាយរងគ្រោះរួមមាន ប្រជាជនកម្ពុជាដែលរស់នៅតាមជនបទដាច់ស្រយាល កសិករ និងអ្នកនេសាទ និងជនពិការ។ កិច្ចអន្តរាគមន៍ផ្នែកទំនាក់ទំនងត្រូវការចំបាច់ក្នុងការជួយគាំទ្រក្រុមទាំងនេះដើម្បីបង្កើនចំណេះដឹងអំពីរបៀបធ្វើសកម្មភាពត្រៀមបង្ការ និងឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេសបង្ហាញអំពីផលប្រយោជន៍ដែលពួកគាត់នឹងទទួលបានក្នុងការរស់នៅប្រចាំថ្ងៃ។

## បង្កើតការប្រាស្រ័យទាក់ទងរបស់អ្នក

ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យមានអ្នកធ្វើផែនការ និងអ្នកអនុវត្តកំណត់ និងយល់នូវនិយមន័យឲ្យបានច្បាស់លាស់ថាតើអ្នកចង់ប្រាស្រ័យទាក់ទងអំពីអ្វី។ ការចង់ធ្វើការប្រាស្រ័យទាក់ទង វាអាចជាព័ត៌មានដែលអាចជួយដោះស្រាយបញ្ហារបស់ប្រជាជនកំពុងជួបប្រទះ ឬជាសាច់រឿងដែលផ្តល់ការលើកទឹកចិត្តដល់ប្រជាជនឲ្យធ្វើសកម្មភាពឆ្លើយតបដោយខ្លួនឯងជាដើម។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជុំវិញបញ្ហាការប្រែប្រួលអាកាសធាតុ មិនត្រឹមតែប្រាប់ដល់ក្រុមគោលដៅឲ្យធ្វើអ្វីមួយប៉ុណ្ណោះទេ តែវាចំបាច់ក្នុងការបង្ហាញពីសកម្មភាពនៃជីវិត ឥរិយាបថ និងគុណតម្លៃសម្រាប់ឲ្យប្រជាជនធ្វើការពិចារណាផងដែរ។ ការប្រាស្រ័យទាក់ទងទាមទារឲ្យមានភាពងាយស្រួល មានភាពពាក់ព័ន្ធ អាចអនុវត្តបាន និងគួរឲ្យទុកចិត្តបានផងដែរ ដើម្បីទទួលបានលទ្ធផលប្រសើរ។ ជាពិសេសការប្រាស្រ័យទាក់ទងគួរផ្តោតសំខាន់ទៅលើគុណតម្លៃ និងកត្តាជំរុញទឹកចិត្តប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាផងដែរ។

នៅពេលពិចារណាអំពីរបៀប នៃការជួយគាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាតាមរយៈការប្រាស្រ័យទាក់ទងដូចជា តាមរយៈការបង្កើនលទ្ធភាពទទួលបានទិន្នន័យ និងព័ត៌មានជាសាធារណៈសម្រាប់អ្នកអនុវត្ត និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ការផ្តល់ទិន្នន័យ និងបង្កើនការយល់ដឹងទាំងនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេក្នុងការដោះស្រាយបញ្ហានេះ។ ការដោះស្រាយឫសគល់នៃឧបសគ្គ និងកត្តាជំរុញទឹកចិត្តដែលត្រូវការចំបាច់សម្រាប់ការផ្លាស់ប្តូរដោយប្រើភាសា និងគោល

គំនិតដែលពាក់ព័ន្ធនឹងជីវិតប្រចាំថ្ងៃរបស់ប្រជាជនគឺជាវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពជាងគេក្នុងការជួយគាំទ្រដល់ប្រជាជន។ វាជាការល្អបំផុតដែលគួរចៀសវាងការបំភិតបំភ័យនៅក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនដោយសារតែវាអាចជះឥទ្ធិពលអាក្រក់ដល់ការលើកទឹកចិត្តប្រជាជនក្នុងការធ្វើការផ្លាស់ប្ដូរ។

លើសពីនេះទៀត ការដោះស្រាយឬសគល់នៃឧបសគ្គ និងកត្តាជំរុញទឹកចិត្តជាវិធីសាស្ត្រដែលប្រសិទ្ធភាពជាងវិធីសាស្ត្រធ្វើសារក្នុងការលើកទឹកចិត្តប្រជាជនឲ្យធ្វើសកម្មភាព។ ការយល់ដឹង និងចំណេះដឹងមិនមែនតែងតែនាំឲ្យមានការធ្វើការផ្លាស់ប្ដូរនោះទេ ព្រោះប្រជាជនប្រហែលជាដឹងច្បាស់អំពីអ្វីដែលត្រូវធ្វើ ប៉ុន្តែមានកត្តាផ្សេងទៀតដែលអាចរារាំងពួកគាត់មិនឲ្យធ្វើ ឬប្រើប្រាស់ចំណេះដឹងដែលគាត់មាន។

ការប្រើទិន្នន័យពីការសិក្សា KAP៣ នៃរបាយការណ៍នេះបានលម្អិតអំពីកត្តាអាទិភាពក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនកម្ពុជា ដើម្បីបង្កើនភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ អាទិភាពទាំងនេះ ត្រូវបានបកស្រាយយ៉ាងស៊ីជម្រៅនៅក្នុងផ្នែកអនុសាសន៍របស់របាយការណ៍គោលរួមមាន៖

- បង្ហាញពីផលប្រយោជន៍នៃការធ្វើសកម្មភាពពាក់ព័ន្ធនឹងកត្តាជំរុញទឹកចិត្តសំខាន់ៗរបស់ប្រជាជនដូចជា បញ្ហាសុខភាព ការអប់រំ និងការប្រកបរបរចិញ្ចឹមជីវិត
- ធ្វើឲ្យការពិភាក្សាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសកម្មភាពនានាដែលប្រជាជនកំពុងធ្វើការឆ្លើយតបទៅជារឿងធម្មតាសម្រាប់ពួកគាត់
- បង្ហាញអំពីជនគំរូល្អៗដែលបានអនុវត្តសកម្មភាពងាយៗ មិនចំណាយច្រើន និងអាចអនុវត្តតាមបានដើម្បីជួយឲ្យពួកគាត់ត្រៀមបង្ការ និងឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបាន

### *ជំរុញ/ស្វែងរកការចូលរួមពីដៃគូផ្សេងៗ*

ការធ្វើការជាមួយដៃគូអាចផ្ដល់នូវចំណេះដឹងបច្ចេកទេសដ៏ចាំបាច់ និងពង្រីកគោលបំណងនៃការប្រាស្រ័យទាក់ទង ឬសារទំនាក់ទំនង។ ការបន្ស៊ីយុទ្ធសាស្ត្រជាមួយអ្នកដទៃដូចដែលបានពិភាក្សានៅក្នុងផ្នែកខាងលើ និងការស្វែងរកភាពស៊ីសង្វាក់គ្នាគឺមានសារៈប្រយោជន៍ណាស់នៅក្នុងបរិបទដ៏ស្មុគស្មាញនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

### *ជ្រើសរើសមធ្យោបាយសម្រាប់ការប្រាស្រ័យទាក់ទង*

មធ្យោបាយប្រាស្រ័យទាក់ទងគឺជាវិធីសាស្ត្រដែលត្រូវបានប្រើដើម្បីចែកចាយសារនានានៃប្រាស្រ័យទាក់ទងហើយនេះអាចជាវិធីមួយ ឬច្រើនក្នុងការផ្ដល់ព័ត៌មានទៅកាន់ប្រជាជនកម្ពុជា។ បណ្ដាញទាក់ទងទាំងនេះមានដូចជា ទូរទស្សន៍ វិទ្យុជាតិ និងវិទ្យុក្នុងស្រុក បណ្ដាញសង្គម អ៊ិនធើណេត ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបុគ្គល កាសែត និងទូរស័ព្ទដៃជាដើម។ បណ្ដាញប្រាស្រ័យទាក់ទងខុសៗគ្នាត្រូវបានប្រើក្នុងគោលបំណងប្រាស្រ័យទាក់ទង និងដើម្បីផ្សព្វផ្សាយទៅដល់ក្រុមគោលដៅផ្សេងគ្នា។ យើងគួរពិចារណាពង្រឹងនូវមធ្យោបាយប្រាស្រ័យទាក់ទងដែលមានស្រាប់ដូចជា កម្មវិធីទូរទស្សន៍ដែល

ពេញនិយម សកម្មភាពនានាតាមសាលារៀន សកម្មភាពក្រុមយុវជន និងសេវាកម្មផ្សព្វផ្សាយជាដើម ក្នុងបរិបទដែលប្រទេសកម្ពុជាមានក្រុមគោលដៅផ្សេងៗដែលត្រូវប្រាស្រ័យទាក់ទង។

### *ជ្រើសរើសទម្រង់សម្រាប់ការប្រាស្រ័យទាក់ទង*

ទម្រង់សម្រាប់ការប្រាស្រ័យដែលបានជ្រើសរើស ហើយមានមាតិកាសម្រាប់ការចែកចាយព័ត៌មានអាចជះឥទ្ធិពលខុសគ្នាៗទៅលើក្រុមគោលដៅ។ ទម្រង់នៃការប្រាស្រ័យទាក់ទងផ្សេងគ្នាផ្តល់អត្ថប្រយោជន៍សម្រាប់ការសម្រេចគោលបំណងផ្សេងគ្នាដែរ។ ជាញឹកញាប់ទម្រង់នៃការប្រាស្រ័យទាក់ទងដែលមានភាពច្នៃប្រឌិតកាន់តែច្រើន វានឹងមានឥទ្ធិពលកាន់តែខ្លាំងទៅលើក្រុមគោលដៅ។ ឧទាហរណ៍ ជំនួសឲ្យការប្រកាសព័ត៌មានជូនប្រជាជនអំពីអត្ថប្រយោជន៍នៃការស្តុកទុកទឹកភ្លៀង គេអាចធ្វើឲ្យវាកាន់តែមានភាពទាក់ទាញតាមរយៈការបង្កើតជាចម្រៀង ឬការសម្តែងអំពីបញ្ហានេះ ដើម្បីបង្កើនចំណេះដឹងដល់ប្រជាជន។ ការផលិតជារឿងភាគទាក់ទងនឹងប្រធានបទដែលចង់ប្រាស្រ័យទាក់ទងក៏ជាមធ្យោបាយល្អមួយក្នុងការដោះស្រាយបញ្ហាជាច្រើន និងពិបាកផ្សេងៗផងដែរ។

ទម្រង់នៃការប្រាស្រ័យទាក់ទង និងគោលបំណងខុសៗគ្នាត្រូវប្រើប្រាស់មធ្យោបាយនៃប្រាស្រ័យទាក់ទងខុសៗគ្នាដែរ។ ឧទាហរណ៍ សេចក្តីជូនដំណឹងជាសាធារណៈអំពីព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដែលគេចង់ផ្សព្វផ្សាយទៅកាន់ក្រុមគោលដៅនៅតាមតំបន់ ដែលទទួលរងផលប៉ះពាល់គួរតែផ្សព្វផ្សាយតាមរយៈវិទ្យុដែលពេញនិយមក្នុងស្រុក។

ទម្រង់នៃការប្រាស្រ័យទាក់ទងផ្សេងៗក៏អាចបំពេញគ្នាទៅវិញទៅមកផងដែរ។ ឧទាហរណ៍ ប្រជាជនអាចរៀនសូត្របន្ថែមពីបច្ចេកទេសដាំដុះថ្មីៗ តាមរយៈការពិភាក្សានៅក្នុងសហគមន៍ដោយប្រើប្រាស់កម្មវិធីវិទ្យុដែលពួកគាត់និយមស្តាប់ប្រសើរជាងគ្រាន់តែស្តាប់កម្មវិធីនេះដោយមិនបានពិភាក្សា។ សូមពិចារណាថាតើទម្រង់នៃការប្រាស្រ័យទាក់ទងគួរបញ្ជូនសារទៅកាន់ក្រុមគោលដៅ ឬលើកទឹកចិត្តពួកគាត់បែបណាដើម្បីឲ្យមានពិភាក្សាអំពីបញ្ហានេះ។ តើការប្រាស្រ័យទាក់ទងទាំងនេះគួរប្រើប្រាស់ជាការផ្ទាល់មាត់ ឬប្រើប្រាស់រូបភាពជំនួយ?

### *វាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង*

ការវាស់ស្ទង់លទ្ធផលនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះគឺជាជំហានដ៏ចាំបាច់មួយ ដើម្បីកំណត់ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទង និងអនុញ្ញាតឲ្យមានការកែតម្រូវឡើងវិញប្រសិនបើវាមិនទទួលបានលទ្ធផលដែលចង់បាន។ បណ្តុំនៃសូចនាករសំខាន់ៗសម្រាប់ការវាស់វែងនេះ អាចត្រូវបានបង្កើតឡើងដើម្បីជួយតម្រង់ទិសក្នុងដំណើរការវាយតម្លៃ។ ការចែករំលែកលទ្ធផលនៃកិច្ចអន្តរាគមន៍ផ្នែកប្រាស្រ័យទាក់ទងស្តីពី ការប្រែប្រួលអាកាសធាតុនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។

### *បង្ហាញលទ្ធផលនៃការប្រាស្រ័យទាក់ទង*

វាមានសារៈសំខាន់ណាស់ក្នុងការពង្រីកវិធី ដែលមានប្រសិទ្ធភាពក្នុងការធ្វើការប្រាស្រ័យទាក់ទងទៅកាន់តំបន់ផ្សេងៗទៀត។ ការចែករំលែកលទ្ធផល និងសមិទ្ធផលនៃការប្រាស្រ័យទាក់ទងជាមួយភាគី

ពាក់ព័ន្ធដទៃទៀតក៏អាចជួយធានាដល់ការផ្សព្វផ្សាយ និងជះឥទ្ធិពលជាអតិបរមាទៅដល់ប្រជាជនគោលដៅផងដែរ។

## ក្របខ័ណ្ឌយុទ្ធសាស្រ្តនៃការប្រាស្រ័យទាក់ទង

ក្របខ័ណ្ឌយុទ្ធសាស្រ្តនៃការប្រាស្រ័យទាក់ទងបានប្រើប្រាស់ការយល់ដឹង និងទិន្នន័យពីការសិក្សា KAP៣ ដែលបានផ្តោតសំខាន់ទៅលើប្រជាជន និងក្រុមងាយរងគ្រោះ រួមទាំងភាគីពាក់ព័ន្ធដែលជាក្រុមគោលដៅនានាផងដែរ។ ភាគីពាក់ព័ន្ធទាំងនេះរួមមាន អ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយ និងមន្ត្រី/អ្នកតំណាងពីស្ថាប័នរាជរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ រដ្ឋបាលស្រុក និងខេត្ត មេដឹកនាំសាសនា តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ព្រមទាំងអ្នកពាក់ព័ន្ធ ផ្នែកប្រព័ន្ធផ្សព្វផ្សាយ។ ភាគីទាំងនេះជាក្រុមដែលមានឥទ្ធិពល ដែលអាចត្រូវបានកៀរគរក្នុងកិច្ចខិតខំប្រឹងប្រែងផ្នែកប្រាស្រ័យទាក់ទងដើម្បីនាំមកនូវការផ្លាស់ប្តូរវិជ្ជមាន ឬត្រូវបានប្រើជាបណ្តាញប្រាស្រ័យទាក់ទងផងដែរ។

ឧទាហរណ៍មួយចំនួននៃវិធីសាស្រ្តក្នុងការប្រាស្រ័យទាក់ទងរួមមាន ទម្រង់ និងមធ្យោបាយនានាដែលអាចផ្សព្វផ្សាយទៅដល់ក្រុមគោលដៅផ្សេងគ្នា ត្រូវបានដាក់បញ្ចូលនៅក្នុងតារាងខាងក្រោមទៅតាមប្រភេទនៃក្រុមគោលដៅនីមួយៗ ប៉ុន្តែវាមិនទាន់មានលក្ខណៈលម្អិតខ្លាំងនៅឡើយទេ។ អនុសាសន៍នៃការសិក្សារបស់ KAP៣ គួរតែជំរុញ និងបំផុសគំនិតឲ្យភាគីតាមវិស័យនីមួយៗបង្កើតក្របខណ្ឌយុទ្ធសាស្រ្តនៃការប្រាស្រ័យទាក់ទង និងកែតម្រូវឲ្យស្របតាមប្រភេទក្រុមគោលដៅជាក់លាក់ និងទៅតាមពេលវេលា និងធនធានដែលមានផងដែរ។

**តារាងទី ៦៖ ការប្រាស្រ័យទាក់ទងជាមួយក្រុមកសិករ និងអ្នកនេសាទ**

| ក្រុមគោលដៅ៖ | កសិករ និងអ្នកនេសាទ |
|---|---|
| គោលបំណង៖ | ជួយពួកគាត់ឲ្យសម្របខ្លួនទៅនឹងជីវភាពរស់នៅ ដូច្នេះពួកគាត់កាន់តែអាចមានស្ថេរភាពប្រាក់ចំណូល និងអាចត្រៀមបង្ការចំពោះព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរបាន។ |
| **ឧបសគ្គ** | **កត្តាជំរុញទឹកចិត្ត** |
| - ខ្វះចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ បើទោះបីជាបានធ្វើសកម្មភាពឆ្លើយតបខ្លះក៏ដោយ<br>- ប្រឈមនឹងការលំបាកក្នុងការប្រើប្រាស់ទឹកសម្រាប់ការងារកសិកម្ម<br>- មានការថយចុះនូវបរិមាណត្រីធម្មជាតិ<br>- មិនមានអារម្មណ៍ថាបានត្រៀមបង្ការ ឬត្រៀមខ្លួនរួចជាស្រេចសម្រាប់ធាតុអាកាសធ្ងន់ធ្ងរ | - មានទំនុកចិត្ត និងភាពជឿជាក់លើការប្រាស្រ័យទាក់ទងនិងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ស្ថាប័នដែលមានដូចជា ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋានជាដើម<br>- មានការជំរុញលើកទឹកចិត្តក្នុងការធ្វើសកម្មភាពឆ្លើយតប និងចង់រៀនសូត្រជំនាញថ្មីៗ<br>- បង្កើនសកម្មភាពឆ្លើយតបបន្ថែមទៀតដូចជាការស្វែងរកចំណូលបន្ថែមពីប្រភពផ្សេងៗ និងការសន្សំប្រាក់ជាដើម |
| **តម្រូវការក្នុងការប្រាស្រ័យទាក់ទង** | |
| **ចំណេះដឹង** | |

<table>
<tr><td colspan="2">
- ការយល់ដឹងអំពីការគាំទ្រដែលមានសម្រាប់ពួកគាត់<br>
- ជួយភ្ជាប់ទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុទៅនឹងផលប៉ះពាល់របស់វាមកលើជីវិតរស់នៅនិងសកម្មភាព ដែលពួកគាត់អាចធ្វើបាន<br>
ឥរិយាបថ<br>
- អត្ថប្រយោជន៍នៃការធ្វើសកម្មភាពរួមគ្នា និងវិធីរៀនសូត្រពីអ្នកដទៃ<br>
ការអនុវត្ត<br>
- បច្ចេកទេស វិធីសាស្ត្រ និងជំនាញ៖<br>
• វិធីក្នុងការឆ្លើយតបទៅនឹងការថយចុះនៃបរិមាណត្រី ឧទាហរណ៍ដូចជា ការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀតដែលអាចធ្វើបាន<br>
• របៀបត្រៀមបង្ការទៅនឹងអាកាសធាតុក្តៅ និងភាពតានតឹងរយៈពេលយូរ (ដូចជាគ្រោះរាំងស្ងួត) និងវិធីដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហាកង្វះទឹក<br>
• វិធីជួយឲ្យការអនុវត្តសកម្មភាពដែលមានស្រាប់កាន់តែមានប្រសិទ្ធភាពជាងមុនដូចជា វិធីប្រើប្រាស់ធនធានឲ្យកាន់តែអស់តិច និងមានប្រសិទ្ធភាព បច្ចេកទេសធ្វើកសិកម្ម និងនេសាទថ្មីៗ
</td></tr>
<tr><th>មធ្យោបាយនៃការប្រាស្រ័យទាក់ទង</th><th>ទម្រង់នៃការប្រាស្រ័យទាក់ទង</th></tr>
<tr><td>
១. ការងារផ្សព្វផ្សាយដល់សហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋាន<br>
[ដោយសារតួអង្គទាំងនេះគឺជាអ្នកមានឥទ្ធិពលគួរឲ្យទុកចិត្តបំផុតក្នុងការជំរុញឲ្យសកម្មភាពវិជ្ជមាន (៨៣% មានភាពជឿជាក់លើអាជ្ញាធរមូលដ្ឋាន/ក្រុមប្រឹក្សាឃុំ និង ៦៩% មានទំនុកចិត្តលើអង្គការក្រៅរដ្ឋាភិបាល]<br>
២. ទូរទស្សន៍<br>
[៦៩% នៃកសិករបានមើលទូរទស្សន៍ ជាពិសេសប៉ុស្តិ៍ហង្សមាស បាយ័ន និងស៊ីធីអិន]<br>
៣.វិទ្យុ<br>
[២៨% នៃកសិករស្តាប់វិទ្យុដែលមានច្រើនជាងក្រុមដទៃទៀតលើកលែងតែក្រុមអ្នកធ្វើការអាជីព]<br>
៤.ទូរស័ព្ទដៃ<br>
(តាមរយៈការផ្ញើសារ SMS / សារឆ្លើយតបជាសំលេង និងបណ្តាញសង្គម
</td><td>
១.១. មានឧបករណ៍សោតទស្សន៍ដើម្បីជួយបង្ហាញពីដំណោះស្រាយផ្នែកកសិកម្ម និងបង្ហាញករណីសិក្សានានាដែលមានលក្ខណៈច្នៃប្រឌិត<br>
១.២. បង្កើតកម្មវិធីសហគមន៍ ឬភ្ជាប់បណ្តាញទំនាក់ទំនងក្នុងការ៖<br>
• ក)ចែករំលែកព័ត៌មានស្តីពីការគាំទ្រដែលមានស្រាប់<br>
• ខ)សម្របសម្រួលការពិភាក្សាអំពីបញ្ហាដែលជួបប្រទះរួមគ្នា គំនិត និងដំណោះស្រាយដែលមានប្រសិទ្ធភាពក្នុងជីវិតប្រចាំថ្ងៃ និង<br>
• គ) ទាញចំណាប់អារម្មណ៍ឲ្យពួកគាត់ធ្វើការជាមួយគ្នា<br>
២.១. បង្ហាញអំពីសាច់រឿងពិត ឬរឿងភាគខ្លីៗដែលពន្យល់ពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងអ្វីដែលកំពុងកើតឡើងក្នុងជីវិតរបស់ពួកគាត់ ដែលអាចប្រើប្រាស់រឿងភាគខ្លីៗចាក់ផ្សាយក្នុងលក្ខណៈជាការផ្សាយដំណឹងនៅលើកញ្ចក់ទូរទស្សន៍និងសម្រាប់ផ្សព្វផ្សាយដល់សហគមន៍<br>
២.២. មានសាច់រឿងពិតរបស់កសិករ ឬអ្នកនេសាទគំរូដែលមើលទៅធ្វើឲ្យគេមានអារម្មណ៍ថា «ពួកគេដូចខ្ញុំដែរ» ក្នុងការធ្វើសកម្មភាពឆ្លើយតប ហើយសាច់រឿងគួរផ្តោតទៅលើបច្ចេកទេស និងមានជំហាននីមួយៗដែលគេអាចយកទៅអនុវត្តបន្តតាមបាន។ ការសម្តែងរឿងមានទ្រង់ទ្រាយវែងគួរតែដាក់បញ្ចូលព័ត៌មានអំពី
</td></tr>
</table>

| | |
|---|---|
| | បច្ចេកទេស និងរឿងរ៉ាវជីវិតពិតដែលមានឥទ្ធិពលក្នុងការជួយលើកទឹកចិត្តឲ្យប្រជាជនធ្វើសកម្មភាពឆ្លើយតប។<br>៣.១. មានកម្មវិធីជជែកពិភាក្សាតាមទូរស័ព្ទជាមួយអ្នកជំនាញ និងកសិករគំរូ ដើម្បីផ្តល់ព័ត៌មានអំពីដំណោះស្រាយបញ្ហាកសិកម្ម<br>៤.១. មានវីដេអូខ្លីដែលអាចចែករំលែកនៅលើហ្វេសប៊ុក និងយូធូប ដើម្បីបង្ហាញពីដំណោះស្រាយផ្នែកកសិកម្ម និងមានកម្មវិធីតាមទូរស័ព្ទដៃ ដែលអាចផ្តល់ជាកញ្ចប់ព័ត៌មានយ៉ាងលម្អិត និងស៊ីជម្រៅ។<br>៤.២.មានសេវាកម្មផ្ញើសារជូនដំណឹងជាមុនអំពីគ្រោះរាំងស្ងួត ទឹកជំនន់ និងព្យុះ |

តារាងទី ៧៖ ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជនក្រីក្របំផុត និងក្រីក្រ

| ក្រុមគោលដៅ៖ | ប្រជាជនក្រីក្របំផុត និងក្រីក្រ |
|---|---|
| គោលបំណង៖ | បង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះដែលពួកគាត់ជួបផ្ទាល់ និងការលើកទឹកចិត្តដើម្បីឲ្យពួកគាត់ធ្វើសកម្មភាពឆ្លើយតប |
| **ឧបសគ្គ** | **កត្តាជំរុញទឹកចិត្ត** |
| - កង្វះចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនិងវិធីត្រៀមបង្ការសម្រាប់អាកាសធាតុធ្ងន់ធ្ងរ<br>- កង្វះការលើកទឹកចិត្ត<br>- កង្វះការជឿទុកចិត្តលើការឆ្លើយតបរបស់ស្ថាប័នចំពោះការប្រែប្រួលអាកាសធាតុ<br>- មិនមានអារម្មណ៍ថាមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ<br>- មានភាពងាយរងគ្រោះទៅលើប្រាក់ចំណូលនិងតែងតែផ្លាស់ប្តូរការងារញឹកញាប់<br>- កង្វះលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ<br>- កង្វះការចូលរួមការប្រើប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសគឺទូរទស្សន៍ អ៊ិនធឺណិត និងបណ្តាញសង្គម<br>- មិនពិភាក្សាជាមួយអ្នកដទៃអំពីបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុនោះទេ<br>- ពិបាកធ្វើសកម្មភាពឆ្លើយតបដូចជា សន្សំប្រាក់ ឬស្តុកទុកចំណីអាហារ | - មានការជំរុញទឹកចិត្តនៅពេលទទួលបានផលប្រយោជន៍ពីការធ្វើសកម្មភាពឆ្លើយតបនិងឃើញភាពជោគជ័យរបស់អ្នកដទៃ<br>- ពង្រឹងការធ្វើសកម្មភាពឆ្លើយតបដែលបានធ្វើបន្ថែមទៀតដូចជា ផ្លាស់ប្តូរការងារ បង្ហាញពីអត្ថប្រយោជន៍នៃសកម្មភាពងាយៗ រួមមាន ការសន្សំប្រាក់ជាដើម<br>- ភ្ជាប់ទំនាក់ទំនងទៅនឹងបុគ្គលគំរូដែលអាចជួយលើកទឹកចិត្ត ឬបំផុសគំនិតដើម្បីធ្វើសកម្មភាព<br>- ពិភាក្សាជាមួយអ្នកដទៃដើម្បីជំរុញការលើកទឹកចិត្ត<br>- មានការលើកទឹកចិត្តខ្ពស់ដោយកត្តានានាដែលជំរុញដល់ការបង្កើនប្រាក់ចំណូល |

<table>
<tr><td>- ជួបប្រទះបញ្ហាលំបាកក្នុងការបំពេញតម្រូវការជាមូលដ្ឋានរបស់ពួកគាត់</td><td></td></tr>
<tr><th colspan="2">តម្រូវការក្នុងការប្រាស្រ័យទាក់ទង</th></tr>
<tr><td colspan="2">ចំណេះដឹង<br>- ជួយពួកគេក្នុងការកំណត់ស្វែងរកនូវភាពងាយរងគ្រោះរបស់ខ្លួន និងហានិភ័យដែលពួកគាត់ជួបប្រទះ<br>- បន្ថែមចំណេះដឹងអំពីព័ត៌មាន និងការយល់ដឹងអំពីថាតើផលប៉ះពាល់ទាំងនេះបានជះឥទ្ធិពលដល់ពួកគាត់ និងប្រាក់ចំណូលរបស់ពួកគេយ៉ាងដូចម្តេច<br>ឥរិយាបថ<br>- ផ្លាស់ប្តូរបទដ្ឋានយេនឌ័របែបអវិជ្ជមានដែលបានចាក់ឫសជ្រៅ<br>- បង្កើនការលើកទឹកចិត្តដើម្បីធ្វើសកម្មភាពឆ្លើយតប<br>ការអនុវត្ត<br>- ជួយគាំទ្រសកម្មភាពសាមញ្ញ និងងាយស្រួលដែលពួកគេអាចធ្វើបានដោយខ្លួនឯង</td></tr>
<tr><th>មធ្យោបាយនៃការប្រាស្រ័យទាក់ទង</th><th>ទម្រង់នៃការប្រាស្រ័យទាក់ទង</th></tr>
<tr><td>១. ការងារផ្សព្វផ្សាយដល់សហគមន៍ដែលដឹកនាំដោយមនុស្សដែលគេជឿទុកចិត្តដូចជា អ្នកដឹកនាំសាសនា និងមេដឹកនាំសហគមន៍<br>[៨៥% នៃអ្នកក្រីក្រខ្លាំង និង ៨២% នៃអ្នកក្រីក្រមានទំនុកចិត្តចំពោះអាជ្ញាធរមូលដ្ឋានរបស់ពួកគេ]</td><td>១.១. បង្កើតកម្មវិធីសហគមន៍ និងបណ្តាញទំនាក់ទំនងលក្ខណៈជាក្រុមតូចៗជាមួយបុគ្គលគំរូ ដើម្បីៈ<br>• ក) បង្ហាញករណីសិក្សាជោគជ័យ និងពិភាក្សាអំពីការផ្លាស់ប្តូរតិចតួចនានាដែលអាចជំរុញឲ្យមានការផ្លាស់ប្តូរក្នុងចំណោមពួកគាត់<br>• ខ) ព្យាយាមធ្វើឲ្យមានការប្រែប្រួលចំពោះបទដ្ឋានណាដែលមានភាពអវិជ្ជមាន ជាពិសេសជុំវិញតួនាទីរបស់ស្ត្រីក្នុងការចូលរួម<br>១.២. បង្កើតឲ្យមានឧបករណ៍សោតទស្សន៍សម្រាប់ប្រើប្រាស់ដោយបុគ្គលិកផ្សព្វផ្សាយ ឬមនុស្សដែលទទួលបានការជឿទុកចិត្តដូចជា មេដឹកនាំសាសនាដើម្បីបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងចង្អុលបង្ហាញអំពីការផ្លាស់ប្តូរតិចតួចនានាដែលអាចធ្វើឲ្យមានភាពវិជ្ជមាន<br>១.៣. បណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយបន្ថែមទៀតដើម្បីធ្វើឲ្យការប្រាស្រ័យទាក់ទងកាន់តែមានភាពច្បាស់លាស់ ភាពជាប់ពាក់ព័ន្ធ និងបង្កើនការចូលរួមរបស់សហគមន៍ដើម្បីជំរុញទឹកចិត្ត និងបង្កើតការយល់ដឹងដល់ពួកគាត់</td></tr>
</table>

**តារាងទី ៨៖ ការប្រាស្រ័យទាក់ទងជាមួយក្រុមប្រជាជនវ័យក្មេង (អ្នកមានការអប់រំខ្ពស់ និងរស់នៅតំបន់ទីក្រុង/ប្រជុំជន)**

| | |
|---|---|
| **ក្រុមគោលដៅ៖** | ប្រជាជនវ័យក្មេង (អ្នកមានកម្រិតនៃការអប់រំខ្ពស់ និងរស់នៅទីក្រុង/ប្រជុំជន) |
| **គោលបំណង៖** | ភ្ជាប់ទំនាក់ទំនងពួកគាត់ជាមួយនឹងរបៀបនៃការប្រែប្រួលអាកាសធាតុនឹងជះឥទ្ធិពលដល់អនាគតរបស់ពួកគាត់ និងប្រទេសកម្ពុជា ហើយត្រូវការឲ្យពួកគាត់ធ្វើសកម្មភាពឆ្លើយតប |
| **ឧបសគ្គ** | **កត្តាជំរុញទឹកចិត្ត** |
| - មិនខ្វល់ខ្វាយអំពីផលប៉ះពាល់នានាពីការប្រែប្រួលអាកាសធាតុដោយសារតែពួកគាត់មិនមានអារម្មណ៍ថាបានទទួលរងប៉ះពាល់ដោយផ្ទាល់នោះទេ<br>- គុណតម្លៃស្ដីពី «ការចុះសម្រុងជាមួយអ្នកដទៃ» គឺមិនសំខាន់សម្រាប់ពួកគាត់នោះទេ | - ឧបសគ្គរាំងផ្នែកសង្គមតិចជាងក្រុមប្រជាជនមានវ័យចាស់<br>- មានការយល់ដឹងល្អអំពីការប្រែប្រួលអាកាសធាតុ<br>- មានការចូលរួម និងមានឆន្ទៈក្នុងការធ្វើសកម្មភាពឆ្លើយតប<br>- ជាអ្នកប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធើណេតច្រើន |
| **តម្រូវការក្នុងការប្រាស្រ័យទាក់ទង** | |
| **ចំណេះដឹង**<br>- បង្កើនចំណេះដឹង និងការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលប្រជាជនទូទាំងប្រទេសកម្ពុជាបានជួបប្រទះ<br>**ឥរិយាបថ**<br>- បង្កើនការស្វែងយល់របស់ពួកគាត់ថាមានក្រុមប្រជាជនជាច្រើនដែលត្រូវពុះពារតស៊ូជាមួយនឹងផលប៉ះពាល់ពីមួយថ្ងៃទៅមួយថ្ងៃដោយសារតែការប្រែប្រួលអាកាសធាតុ<br>**ការអនុវត្ត**<br>- លើកទឹកចិត្តឲ្យពួកគាត់ទទួលស្គាល់តួនាទីរបស់ពួកគាត់ក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុសម្រាប់អនាគតប្រទេសកម្ពុជា និងចូលរួមក្នុងការធ្វើសកម្មភាព | |
| **មធ្យោបាយនៃការប្រាស្រ័យទាក់ទង** | **ទម្រង់នៃការប្រាស្រ័យទាក់ទង** |
| ១. ការងារផ្សព្វផ្សាយដល់សហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋាន<br>[៧៦% នៃក្រុមនេះត្រូវការការគាំទ្រពីរដ្ឋាភិបាល និង ៦៩% ទៀត ត្រូវការការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល]<br>២. ទូរទស្សន៍<br>[៦៨% នៃក្រុមនេះមានលទ្ធភាពប្រើប្រាស់ទូរទស្សន៍ដែលមានចំនួនច្រើនជាងក្រុមមនុស្សវ័យកណ្ដាល ប៉ុន្តែតិចជាងក្រុមដែលមានអាយុចាស់ជាងគេ]<br>៣.ទូរស័ព្ទដៃ<br>[៩២% នៃពួកគាត់មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃ និង៨៩% មានលទ្ធភាពប្រើប្រាស់បណ្ដាញសង្គម] | - បង្កើតការផ្លាស់ប្ដូរ ឬឱកាសការងារស្ម័គ្រចិត្តសម្រាប់យុវជននៅទីក្រុង/ប្រជុំជនដើម្បីទទួលបានបទពិសោធន៍អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅតាមតំបន់ជនបទ<br>- ការផ្សព្វផ្សាយសាច់រឿងមានទម្រង់វែងដែលប្រមូលផ្ដុំយុវជនដែលមិនទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកជួបជាមួយអ្នកដែលកំពុងទទួលរងផលប៉ះពាល់ដើម្បី៖<br>• ក) ស្វែងយល់ពីបញ្ហា និងបង្កើនការយល់ដឹងឲ្យកាន់តែទូលំទូលាយ និង<br>• ខ) ពង្រឹងការបញ្ចេញមតិយោបល់របស់យុវជន |

| | |
|---|---|
| | - ខ្សែភាពយន្តខ្លី ដែលបង្ហាញពីយុវវ័យគំរូឲ្យតម្លៃទៅលើបរិស្ថាន និងធ្វើសកម្មភាពដើម្បីលើកទឹកចិត្ត និងបំផុសអ្នកដទៃឲ្យធ្វើតាម |

តារាងទី៩៖ការប្រាស្រ័យទាក់ទងជាមួយក្រុមស្ត្រី

| ក្រុមគោលដៅ៖ | ស្ត្រី |
|---|---|
| គោលបំណង៖ | ផ្តល់អំណាចដល់ស្ត្រីឲ្យធ្វើសកម្មភាពឆ្លើយតបដោយមានការជួយគាំទ្រពីមនុស្សនៅជុំវិញខ្លួនរបស់ពួកគាត់ |
| ឧបសគ្គ | កត្តាជំរុញទឹកចិត្ត |
| - មិនមានលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គ្មានបណ្តាញគាំទ្រ និងមានចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុតិចតួច<br>- បទដ្ឋានយេនឌ័រដែលចាក់ឫសយ៉ាងជ្រៅបានរារាំងដល់ការសម្រេចចិត្តដោយឯករាជ្យលើការឆ្លើយតបទៅនឹងបញ្ហាអាកាសធាតុដែលបានប៉ះពាល់ដល់គ្រួសាររបស់ពួកគាត់<br>- មានទំនួលខុសត្រូវច្រើនទាំងក្នុងគ្រួសារ និងការងារកសិកម្មដែលរួមមានការមើលថែរក្សាក្រុមងាយរងគ្រោះដូចជា មនុស្សចាស់ និងកូនៗជាដើម | - មានការលើកទឹកចិត្តនៅពេលដែលគិតអំពីអនាគតសម្រាប់កូនៗរបស់ពួកគាត់<br>- បាន និងកំពុងធ្វើសកម្មភាពឆ្លើយតបខ្លះៗហើយ<br>- ប្រជាជនទាំងឡាយរួមទាំងបុរសបានគិតថាស្ត្រីគួរតែបញ្ចេញមតិយោបល់របស់ខ្លួនជាសាធារណៈឲ្យបានកាន់តែច្រើន |
| តម្រូវការក្នុងការប្រាស្រ័យទាក់ទង | |
| **ចំណេះដឹង**<br>- បង្កើនលទ្ធភាពទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយនានា និងបណ្តាញគាំទ្រផ្សេងៗផ្នែកចំណេះដឹង<br>**ឥរិយាបថ**<br>- បង្កើតឲ្យមានឥរិយាបថគាំទ្រក្នុងចំណោមមនុស្សមានឥទ្ធិពលរួមទាំងស្វាមី ដើម្បីឲ្យស្ត្រីអាចធ្វើការសម្រេចចិត្តដោយឯករាជ្យ<br>**ការអនុវត្ត**<br>- ផ្លាស់ប្តូរបទដ្ឋានយេនឌ័រដើម្បីធានាបាននូវទំនួលខុសត្រូវ និងទទួលបានព័ត៌មានប្រកបដោយសមធម៌ | |
| មធ្យោបាយនៃការប្រាស្រ័យទាក់ទង | ទម្រង់នៃការប្រាស្រ័យទាក់ទង |
| ១. ការងារផ្សព្វផ្សាយដល់សហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋាន<br>[៨១% នៃស្ត្រីត្រូវការការគាំទ្រពីរដ្ឋាភិបាល និង ៧៧% ទៀតត្រូវការការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល]<br>២. ទូរទស្សន៍ (នៅពេលល្ងាចជាពេលដែលស្ត្រីទំនេរជាមានពេលទំនេរ)<br>[ស្ត្រី ៦៥% មានលទ្ធភាពមើលទូរទស្សន៍] | ១.១. បង្កើតកម្មវិធីសហគមន៍ដែលមានការចូលរួមទាំងអស់គ្នាដើម្បីសម្របសម្រួលការពិភាក្សាលើសកម្មភាពដែលមានប្រសិទ្ធភាព និងការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តទាក់ទងនឹងការប្រែប្រួលអាកាសធាតុ<br>២.១. បង្កើតរឿងភាគដែលមានទម្រង់វែងដែលផ្សារភ្ជាប់ជាមួយនឹងជីវិតប្រចាំថ្ងៃ ដើម្បីបង្ហាញពីបញ្ហាប្រឈម និងភាពជោគជ័យនៃជីវិតរស់នៅក្នុង |

| | |
|---|---|
| | តំបន់ជនបទ និងបង្ហាញអំពីស្ត្រី និងបុរសដែលជាគំរូក្នុងការធ្វើសកម្មភាពឆ្លើយតបរួមគ្នា<br>២.២. មានខ្សែភាពយន្តភាគខ្លីៗដែលជំរុញឲ្យមានការពិភាក្សាអំពីបទដ្ឋានយេនឌ័រ និងផលប្រយោជន៍នៃទំនួលខុសត្រូវប្រកបដោយសមធម៌ច្រើនជាងមុន។ ខ្សែភាពយន្តនេះអាចត្រូវបានចែកចាយជាការចាក់ផ្សាយជាសាធារណៈនិងសម្រាប់សកម្មភាពផ្សព្វផ្សាយតាមសហគមន៍ |

### ឧបសម្ព័ន្ធទី ២៖ សំណួរសំខាន់ៗដែលអាចប្រើសម្រាប់សូចនាករនាពេលអនាគត

តារាងខាងក្រោមបង្ហាញអំពីសំណួរមួយចំនួនដែលដកស្រង់ចេញពីការអង្កេត KAP៣ ដែលក្រុមអ្នកស្រាវជ្រាវយល់ថាវាអាចយកទៅប្រើសម្រាប់រៀបចំសូចនាករនាពេលអនាគត។ គេអាចបង្កើតជាសូចនាករទោល ឬជាសូចនាករដែលផ្សំឡើងរួមបញ្ចូលជាមួយទិន្នន័យផ្សេងៗគ្នា។

**តារាងទី ១១៖ សំណួរមួយចំនួនរបស់ការអង្កេត KAP៣ សម្រាប់ការពិចារណាសូចនាករនាពេលអនាគត**

| សូចនាករ | សំណួរ | មើលឧបសម្ព័ន្ធទី៣ សម្រាប់សំណួរលម្អិត | ទិន្នន័យសំខាន់ៗតាមរយៈ KAP៣ |
|---|---|---|---|
| **I. ចំណេះដឹង** | | | |
| ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ | តើអ្នកធ្លាប់លឺពីឃ្លា «ការប្រែប្រួលអាកាសធាតុ» ដែរឬទេ? បើអ្នកតបសម្ភាសន៍ឆ្លើយធ្លាប់ឮ សូមសួរ តើអ្នកបានដឹងពីអត្ថន័យរបស់វាដែរឬទេ?<br><br>*ពាក្យ «ការប្រែប្រួលអាកាសធាតុ» មិនគួរអាន ពេលចាប់ផ្តើមសួរសំណួរនោះទេ។*<br><br>តើកត្តាអ្វីខ្លះដែលអ្នកគិតថាជាមូលហេតុចំបងនៃការប្រែប្រួលអាកាសធាតុ? (សូមមើលការសួរអំពី «សកម្មភាពមនុស្ស») | QK1a<br>QK1b<br><br><br><br>QK3 | **QK1a:**<br>**ធ្លាប់ឮ=៧២%**<br>▪ ធ្លាប់ឮ ប៉ុន្តែមិនដឹងពីអត្ថន័យ ៣៩%<br>▪ ធ្លាប់ឮ និងដឹងពីអត្ថន័យ ៣៣%<br>**មិនធ្លាប់ឮ= ២៨%**<br><br>**QK3:**<br>▪ ៥៣% យល់ស្រប<br>▪ ៤៧% មិនយល់ស្រប |
| **II. ឥរិយាបថ** | | | |
| ឥរិយាបថស្តីពីការប្រែប្រួលអាកាសធាតុ | តើអ្នកគិតថាសកម្មភាពរបស់អ្នកចូលរួមចំណែកដល់ការប្រែប្រួលអាកាសធាតុដែរឬទេ? | QK3Y | ▪ ៣៨% យល់ស្រប<br>▪ ៥៨% មិនយល់ស្រប<br>▪ ៤% មិនដឹង |
| **III. ការអនុវត្ត** | | | |
| សកម្មភាពនាពេលបច្ចុប្បន្នដែលត្រូវបានអនុវត្តដើម្បីឆ្លើយតប ឬដោះស្រាយបញ្ហាការប្រែប្រួលធាតុអាកាស និងលទ្ធភាពទទួលបានធនធានដែលមានស្រាប់ | តើអ្នកកំពុងធ្វើសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតប/ដោះស្រាយចំពោះការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ អាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងធាតុអាកាស? | QD4a | ៩១% កំពុងធ្វើសកម្មភាព |
| ឆន្ទៈក្នុងការចាត់វិធានការនៅពេលអនាគតដើម្បីឆ្លើយតប ឬដោះស្រាយជាមួយនឹងការប្រែប្រួលនៃធាតុអាកាស និងលទ្ធភាព | តើអ្នកនឹងធ្វើសកម្មភាពអ្វីខ្លះពេលអនាគត ដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ អាហារ | QD4b | ៨៦% បង្ហាញពីឆន្ទៈក្នុងការធ្វើសកម្មភាពនាពេលអនាគត |

| | | | |
|---|---|---|---|
| ទទួលបានធនធានដែលមានស្រាប់ | អគ្គិសនី និងប្រេងឥន្ធនៈ និងធាតុអាកាស? | | |
| សកម្មភាពនាពេលបច្ចុប្បន្នដែលត្រូវបានអនុវត្តដើម្បីឆ្លើយតប ឬដោះស្រាយបញ្ហាកង្វះខាតទឹក | តើសកម្មភាពអ្វីខ្លះដែលអ្នកកំពុងធ្វើបច្ចុប្បន្ននេះ ដើម្បីឆ្លើយតប ឬដោះស្រាយទៅនឹងការខ្វះខាតទឹក? | QE2a | ▪ ស្តុកទឹក ឬសន្សំសំចៃទឹក ៧៧%<br>▪ ធ្វើឲ្យទឹកមានសុវត្ថិភាពអាចហូបបាន ៧៧%<br>▪ ទិញទឹក ៥៧%<br>▪ ស្វែងរកប្រភពទឹកថ្មី ៤១%<br>▪ ប្រើប្រាស់ឡើងវិញទឹកដែលបានប្រើរួច ៣៧% |
| សកម្មភាពនាពេលបច្ចុប្បន្នដែលត្រូវបានអនុវត្តដើម្បីឆ្លើយតប ឬដោះស្រាយបញ្ហាកង្វះខាតស្បៀងអាហារ | តើសកម្មភាពអ្វីខ្លះដែលអ្នកកំពុងធ្វើបច្ចុប្បន្ននេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតស្បៀងអាហារ? | QF2a | ▪ កាត់បន្ថយកាកសំណល់អាហារ ៧៩%<br>▪ ដាំដំណាំប្រភេទផ្សេងទៀត ឬចិញ្ចឹមសត្វប្រភេទផ្សេងទៀត ៧៦%<br>▪ ការផ្លាស់ប្តូររបបអាហារ ៧០%<br>▪ រក្សាទុកម្ហូបឲ្យបានយូរ ៥១%<br>▪ ដាំដំណាំឆ្លាស់ ៤៣%<br>▪ ប្រើថ្នាំសម្លាប់កត្តាចង្រៃដើម្បីបង្កើនទិន្នផលដំណាំ ៤១% |
| សកម្មភាពនាពេលបច្ចុប្បន្ននេះត្រូវបានអនុវត្តដើម្បីឆ្លើយតប ឬដោះស្រាយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ | តើសកម្មភាពអ្វីខ្លះដែលអ្នកកំពុងធ្វើដើម្បីឆ្លើយតបទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ? | QG3a | ▪ មើល ឬស្តាប់ការព្យាករណ៍អាកាសធាតុ ៦៤%<br>▪ សន្សំលុយ ៥៨%<br>▪ រៀបចំទុកដាក់ម្ហូបអាហារសំរាប់ពេលមានអាសន្ន ៥៦%<br>▪ ធ្វើការកែសម្រួលទីលំនៅ (ផ្ទះ) ជាអចិន្ត្រៃយ៍ ៣៦%<br>▪ មានផែនការត្រៀមបង្ការគ្រោះមហន្តរាយ ៣៤%<br>▪ រៀនជំនាញថ្មី ១៩%<br>▪ ធ្វើការកែសម្រួលជាបណ្តោះអាសន្នទៅលើផ្ទះរបស់ខ្ញុំ ១៩% |
| ការត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ | ប្រសិនបើអាកាសធាតុក្តៅខ្លាំង (ក្តៅ/ត្រជាក់/ព្យុះ/ខ្យល់ខ្លាំង រន្ទះ/ផ្គរលាន់) នឹងកើតឡើងនៅក្នុងតំបន់របស់អ្នក តើអ្នកគិតថាអ្នកបានត្រៀមបង្ការក្នុងកម្រិតណា? | QD5 | ▪ មិនទាន់បានត្រៀមខ្លួនទាល់តែសោះ ២៣%<br>▪ មិនទាន់បានត្រៀមខ្លួនទេ ២០%<br>▪ បានត្រៀមខ្លះដែរ ៤២%<br>▪ បានត្រៀមខ្លួនរួចជាស្រេច ១៤%<br>▪ មិនដឹង ១% |
| សមត្ថភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនៃធាតុអាកាស និងលទ្ធភាពទទួលបានធនធានដែលមានស្រាប់ | តើអ្នកមានអារម្មណ៍ថាអ្នកអាចត្រៀមខ្លួនក្នុងការដោះស្រាយបញ្ហាទាំងនេះពោលគឺលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងការ | QX6 | ▪ មិនទាន់បានត្រៀមខ្លួនទាល់តែសោះ ១១%<br>▪ មិនទាន់បានត្រៀមខ្លួនទេ ១៧%<br>▪ ធម្មតា ១%<br>▪ បានត្រៀមខ្លះដែរ ៦៦%<br>▪ បានត្រៀមខ្លួនរួចជាស្រេច ៣% |

| | | | |
|---|---|---|---|
| | ប្រែប្រួលនៃធាតុអាកាស បានក្នុងកម្រិតណា? | | |
| សកម្មភាពសហគមន៍ក្នុងការដោះស្រាយ/ឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានធនធានដែលមានស្រាប់ និងការប្រែប្រួលនៃធាតុអាកាស | តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើសកម្មភាពអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាស? | QY5 | ▪ ៩១% បានរាយការណ៍ថាសហគមន៍របស់ពួកគាត់បានធ្វើសកម្មភាពឆ្លើយតប |
| IV. ឧបសគ្គ | | | |
| ការទទួលបានការជូនដំណឹងអំពីសកម្មភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានធនធានដែលមានស្រាប់ និងការប្រែប្រួលនៃធាតុអាកាស | តើអ្នកគិតថាអ្នកទទួលបានព័ត៌មានកម្រិតណាអំពីវិធីសាស្ត្រ/របៀបក្នុងការទប់ទល់/ដោះស្រាយនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាសដែលអ្នកអាចនឹងប្រឈមមុខ? | QJ3 | ▪ មិនបានទទួលទាល់តែសោះ ១៤%<br>▪ មិនសូវមានព័ត៌មានច្រើនទេ ២៩%<br>▪ ទទួលបានព័ត៌មានគួរសម/មធ្យម ៤៨%<br>▪ ទទួលបានព័ត៌មានគ្រប់គ្រាន់/ច្រើន ៩% |
| ទំនុកចិត្តលើស្ថាប័ន | តើអ្នកមានទំនុកចិត្តកម្រិតណាថាស្ថាប័ននីមួយៗដូចខាងក្រោមកំពុងធ្វើសកម្មភាពចាំបាច់ដើម្បីជួយឆ្លើយតបទៅនឹងការប្រែប្រួលលទ្ធភាពប្រើប្រាស់នៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាស? | QY2 | ▪ អាជ្ញាធរមូលដ្ឋាន/ក្រុមប្រឹក្សាឃុំ ៨៣%<br>▪ ស្ថាប័នថ្នាក់ជាតិ ខេត្ត និងស្រុក ៧៩%<br>▪ តំបន់/អ្នកជិតខាងខ្ញុំ ៧២%<br>▪ អង្គការមិនមែនរដ្ឋាភិបាល/អង្គការដទៃទៀត ៦៩%<br>▪ ក្រុមហ៊ុន/រោងចក្រនៅក្នុងតំបន់ ៤៣% |
| ផ្នត់គំនិតយេនឌ័រទាក់ទងនឹងសកម្មភាពឆ្លើយតប | ខ្ញុំនឹងអានប្រយោគមួយចំនួនដែលទាក់ទងទៅនឹងសមត្ថភាពរបស់ស្ត្រីក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងធាតុអាកាស។ | QS3 | ▪ ស្ត្រីគួរតែបញ្ចេញមតិរបស់ពួកគេឲ្យបានច្រើននៅក្នុងការសម្រេចចិត្តក្នុងសហគមន៍ និងការប្រជុំសាធារណៈ ប្រុស=៩៣%, ស្រី= ៩៤%<br>▪ ស្ត្រីមានតួនាទីមើលថែផ្ទះសម្បែង និងក្រុមគ្រួសារ ប្រុស=៨៨%, ស្រី=៩០%<br>▪ បុរសគួរតែជាអ្នកសម្រេចចិត្តចុងក្រោយនៅក្នុងគ្រួសារទាក់ទងនឹងសកម្មភាពបន្សាំទៅនឹងការប្រែប្រួលទាំងនោះ ប្រុស=៧៦%, ស្រី=៦៩% |
| ឧបសគ្គចំពោះសកម្មភាព | ទាំងនេះជាហេតុផលដែលមនុស្សខ្លះមិនឆ្លើយតប/ចាត់វិធានការ។ ចំពោះប្រយោគនីមួយៗដែលខ្ញុំបានអាន សូមឆ្លើយ តើអ្នកយល់ | QS1 | ▪ ត្រូវការការគាំទ្រពីរដ្ឋាភិបាលដើម្បីឆ្លើយតប/ដោះស្រាយ ឬធ្វើសកម្មភាព ៨០%<br>▪ ត្រូវការការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល/ក្រុមផ្សេងៗ ៧៥% |

| | | | |
|---|---|---|---|
| | ស្រប ឬមិនយល់ស្របនឹងមូលហេតុដែលអ្នកមិនឆ្លើយតប/ចាត់វិធានការ។ | | ▪ មិនមានធនធានគ្រប់គ្រាន់ (លុយ និង ឧបករណ៍) ដើម្បីឆ្លើយតប/ដោះស្រាយ ឬធ្វើសកម្មភាព ៧០%<br>▪ មិនទទួលបានព័ត៌មាន ៦៣%<br>▪ មិនដឹងពីរបៀបឆ្លើយតប/ដោះស្រាយ ឬធ្វើសកម្មភាព ៦៣%<br>▪ មានកិច្ចការសំខាន់ផ្សេងៗទៀតដែលត្រូវធ្វើ ៦១%<br>▪ មិនស្គាល់នរណាម្នាក់ដែលកំពុងឆ្លើយតប/ដោះស្រាយ ឬធ្វើសកម្មភាព ៥៩%<br>▪ មិនមែនជាបញ្ហាទេ ៤៧%<br>▪ មិនហ៊ានពិភាក្សាអំពីសកម្មភាពជាមួយអ្នកដទៃ ៤៧%<br>▪ មិនចង់សាកល្បងអ្វីថ្មី ៤៥%<br>▪ មិនមែនជាទំនួលខុសត្រូវក្នុងការឆ្លើយតប ឬធ្វើសកម្មភាព ៤៣%<br>▪ គ្រួសារនឹងមិនយល់ព្រម ៤២%<br>▪ មិនសមស្របនឹងសាសនា ឬជំនឿ/វប្បធម៌នៅក្នុងសហគមន៍ ៣៩%<br>▪ វាប្រថុយពេកក្នុងការសាកល្បងអ្វីដែលថ្មី ៣៨%<br>▪ ដោះស្រាយ ឬក៏អត់នឹងមិនមានអ្វីខុសប្លែកគ្នាទេ ៥៧% |
| ការជំរុញលើកទឹកចិត្តក្នុងការធ្វើសកម្មភាព | ប្រជាជនខ្លះបានផ្តល់ហេតុផលដែលពួកគេធ្វើការឆ្លើយតបចំពោះ/ឬដោះស្រាយផលប៉ះពាល់ដែលពួកគេបានជួបប្រទះ។ ចំពោះប្រយោគនីមួយៗដែលខ្ញុំបានអានសូមឆ្លើយ តើអ្នកយល់ស្រប ឬមិនយល់ស្របនឹងហេតុផលដែលធ្វើអ្នកឆ្លើយតប/ដោះស្រាយ ឬធ្វើសកម្មភាព។ | QS2 | ▪ ចង់បានអនាគតល្អប្រសើរ ឬភ្លឺស្វាងសម្រាប់កូនៗ ៩៨%<br>▪ ចង់មានសុខភាពល្អ ៩៨%<br>▪ យល់ថាត្រូវធ្វើអ្វីមួយដើម្បីរក្សារបៀបរស់នៅ/ជីវភាពឲ្យល្អប្រសើរ ៩៦%<br>▪ យល់ថាការយកចិត្តទុកដាក់ចំពោះ ឬគិតគូរពីបរិស្ថានធម្មជាតិមានសារៈសំខាន់ ៩៥%<br>▪ ដោះស្រាយបញ្ហាទាំងនោះក្នុងគោលបំណងដើម្បីរកលុយ/សន្សំប្រាក់អោយបានច្រើន ៩១%<br>▪ នឹងមានអារម្មណ៍ល្អប្រសិនបើអ្នកធ្វើសកម្មភាពឆ្លើយតប ៩១%<br>▪ ជាអ្វីដែលមនុស្សគ្រប់គ្នាកំពុងធ្វើ ៨៨%<br>▪ មានព័ត៌មានគ្រប់គ្រាន់ ៨២% |

| | | | |
|---|---|---|---|
| ការជឿជាក់លើសកម្មភាពរបស់សហគមន៍ក្នុងការឆ្លើយតប និងចំនុចមួយចំនួនដែលមិនសូវមានភាពទាក់ទាញក្នុងការធ្វើសកម្មភាពឆ្លើយតប | តើអ្នកយល់ស្រប ឬមិនយល់ស្របនឹងប្រយោគមួយចំនួនដូចខាងក្រោម? | QD6 | ▪ សហគមន៍របស់ខ្ញុំអាចធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាធាតុអាកាសមិនប្រក្រតីទាំងនោះបាន ៨៧%<br>▪ ជឿជាក់ថាខ្ញុំអាចជួយសហគមន៍របស់អ្នកឲ្យត្រៀមខ្លួនបានល្អប្រសើរសម្រាប់គ្រោះមហន្តរាយ/ធាតុអាកាសមិនប្រក្រតី ៨៣%<br>▪ ប្រសិនបើរឿងធាតុអាកាសមិនប្រក្រតីទាំងនោះកើតឡើងចំពោះខ្ញុំ ខ្ញុំមិនអាចធ្វើអ្វីបានច្រើនទេដើម្បីដោះស្រាយ ៦៥%<br>▪ ខ្ញុំចង់ធ្វើការតែម្នាក់ឯងដើម្បីដោះស្រាយបញ្ហាធាតុអាកាសមិនប្រក្រតីទាំងនោះ ២០% |
| សូចនាករដែលមានស្រាប់សម្រាប់វាស់វែងពីការប្រែប្រួលនៃសកម្មភាពឆ្លើយតបនឹងហានិភ័យនៃអាកាសធាតុ | តើអ្នកធ្លាប់ឮឃ្លា «ការប្រែប្រួលអាកាសធាតុ» ដែរឬទេ? | QK1a | ▪ ៧២% ធ្លាប់បានឮ |
| | តើប្រជាជននៅក្នុងសហគមន៍របស់អ្នកបានធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលទ្ធភាពទទួលបានទឹកប្រើប្រាស់ ចំណីអាហារ ការផ្គត់ផ្គង់ថាមពល ឬធាតុអាកាស? | QY5 | ▪ ៩១% បានរាយការណ៍ថាសហគមន៍របស់ពួកគេបានធ្វើសកម្មភាពឆ្លើយតប |

**ប្រសិនបើសូចនាករដែលផ្សំឡើងដោយសំណួរច្រើនជាងមួយ ជាតម្រូវការសម្រាប់ការវាស់វែងសំខាន់ៗនាពេលអនាគត អ្នកស្រាវជ្រាវអាចផ្តល់នូវគំនិតអនុវត្តដូចខាងក្រោម៖**

- សំណួរទាំងឡាយដែលបានចងក្រងនៅក្នុងតារាងខាងលើនេះអាចយកមកប្រើប្រាស់ ដើម្បីវិភាគជាលក្ខណៈសំណួរទោលដើម្បីធ្វើការតាមដាននូវនិន្នាការ ទស្សនៈ បញ្ហា និងតម្រូវការចាំបាច់នានា ដែលគួរតាមដាន។
- សំណួរទោលនីមួយៗដែលគួរតាមដានគួរមានភាពស៊ីគ្នាជាមួយនឹងកិច្ចអន្តរាគមន៍ និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ (ជាពិសេសផ្តោតសំខាន់លើភាពស៊ីគ្នាជាមួយនឹងយុទ្ធសាស្ត្រ នៃការប្រាស្រ័យទាក់ទងដែលបានដាក់ចេញ) ដែលមានគោលបំណងជួយគាំទ្រដល់ប្រជាជនឲ្យការឆ្លើយតបកាន់តែប្រសើរឡើងចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- ការវិភាគពីនិន្នាការសម្រាប់សំណួរ ឬចម្លើយជាក់លាក់នីមួយៗអាចផ្តល់អត្ថប្រយោជន៍ផងដែរចំពោះការវិភាគដែលត្រូវធ្វើដោយផ្អែកទៅលើក្រុមគោលដៅ ដែលជាធាតុសំខាន់សម្រាប់យុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង ឬសម្រាប់កិច្ចអន្តរាគមន៍ជាក់លាក់ណាមួយដែលគេចង់តាមដាន។ ឧទាហរណ៍សម្រាប់ការវិភាគនាពេលអនាគត ប្រសិនបើគេមានយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងមួយដែលបានផ្តោតសំខាន់លើការជំរុញទឹកចិត្តប្រជាជននៅតាមតំបន់ឆ្នេរឲ្យមានការត្រៀមបង្ការប្រកបដោយប្រសិទ្ធភាពនោះគេគួរតែពិនិត្យតាមដាន និងវាយតម្លៃពីប្រសិទ្ធភាពនៃការត្រៀមបង្ការតែក្នុងចំណោមប្រជាជន

ដែលនៅក្នុងតំបន់ធ្នេរនេះប៉ុណ្ណោះ ដោយមិនមានការតាមដានការត្រៀមបង្ការជារួមសម្រាប់ប្រជាជនទូទៅដែលមិនបានទទួលការគាំទ្រនោះទេ ។

- សម្រាប់សូចនាករទាំងឡាយដែលផ្សំឡើងដោយសំណួរច្រើនជាងមួយ ដែលគេចង់បង្កើតឡើងសម្រាប់ការតាមដានជារួម វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់ ឬរៀបចំសំណួរសម្រាប់ការអង្កេតឲ្យមានភាពស៊ីគ្នា/ជាប់ពាក់ព័ន្ធពីមួយទៅមួយ។ ឧទាហរណ៍ បើគេចង់តាមដានការប្រៀបធៀបសូចនាករនៃការឆ្លើយតបរបស់សង្គមចំពោះហានិភ័យអាកាសធាតុឲ្យមានប្រសិទ្ធភាព ការវាស់វែងជាភាគរយក្នុងមួយឆ្នាំដោយផ្អែកលើសមាមាត្រនៃអ្នកតបសម្ភាសន៍ដែលធ្លាប់ឮឃ្លា «ការប្រែប្រួលអាកាសធាតុ» ជាមួយនឹងសមាមាត្រនៃអ្នកតបសម្ភាសន៍រស់នៅក្នុងសហគមន៍ ដែលកំពុងឆ្លើយតបជាមួយវិសមរូបអាកាសធាតុ វាអាចនៅមិនទាន់មានភាពគ្រប់គ្រាន់សម្រាប់ការតាមដាននាពេលអនាគតនៅឡើយទេ ដោយសារគេមិនទាន់មានភាពច្បាស់លាស់នៅឡើយថា តើការវាស់វែងនៃសូចនាករទាំងពីរមានភាពពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច។ ដោយផ្អែកទៅលើបទពិសោធន៍នៃការសិក្សានេះវាអាចនឹងមានសារៈសំខាន់ក្នុងការកំណត់សូចនាករនាពេលអនាគតដែលផ្តុំទៅដោយសំណួរ ឬចម្លើយដែលមានជាប់ទាក់ទងគ្នាជាក់លាក់ពីមួយទៅមួយ។ ឧទាហរណ៍ បើសូចនាករមួយដែលចង់ពិនិត្យមើលពីកម្រិតនៃការជំរុញទឹកចិត្តរបស់ប្រជាជន និងកម្រិតនៃសកម្មភាពឆ្លើយតបដែលប្រជាជនបានអនុវត្ត វាមានសារៈសំខាន់ណាស់ដែលការវាស់វែងត្រូវមើលថា ការជំរុញទឹកចិត្តអាចនាំឲ្យមានការធ្វើសកម្មភាពច្រើនឡើងដែរឬទេ (ប្រសិនជាយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងដែលបានដាក់ចេញផ្តោតសំខាន់លើការបង្កើនការជំរុញទឹកចិត្តដល់ប្រជាជនក្នុងការធ្វើសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ)។

ឧទាហរណ៍សម្រាប់ការពិចារណាបន្ថែមមានដូចបានរៀបរាប់ចំណុចខាងក្រោម៖

- **ដើម្បីធ្វើឲ្យប្រសើរឡើងនូវការវាស់វែងអំពីការប្រែប្រួលចំណេះដឹង** គេត្រូវពិចារណាឲ្យបានវែងឆ្ងាយជាងការវាស់វែងទៅលើតែការស្គាល់/ឮពាក្យ «ការប្រែប្រួលអាកាសធាតុ» ឬ «ការឡើងកម្តៅភពផែនដី» មួយមុខ។ គេអាចវាយតម្លៃបន្ថែម ដោយស្វែងយល់ថាអ្នកដែលស្គាល់ ឬឮពាក្យទាំងនេះបានដឹងពីអត្ថន័យនៃពាក្យទាំងនេះដែរឬទេ។ អ្វីដែលសំខាន់រាល់ការវាស់វែងពីការផ្លាស់ប្តូរនានាត្រូវមានការផ្សារភ្ជាប់ជាមួយកិច្ចអន្តរាគមន៍អំពីចំណេះដឹង ដែលគេបានដាក់ចេញក្នុងគោលបំណងបង្កើនចំណេះដឹងរបស់ប្រជាជនអំពី អត្ថន័យរបស់ពាក្យនេះ និងមូលហេតុដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុជាដើម។
- **ដើម្បីវាស់វែងអំពីការប្រែប្រួលនៃឥរិយាបថ** ការប្រមូលយកបទពិសោធន៍នានារបស់ប្រជាជនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើជីវិតរស់នៅរបស់ពួកគាត់ (សំណួរQX1) ហានិភ័យដែលពួកគាត់យល់ឃើញ (សំណួរQG1) ធន្ធៈដែលពួកគាត់មាន (សំណួរQD3) ដំណោះស្រាយដែលពួកគាត់គិត និងបានធ្វើ (សំណួរQE1,QF1) ព្រមទាំងការយល់ឃើញអំពីលទ្ធភាពក្នុងការឆ្លើយតប (សំណួរQX6) ក៏ដូចជាការត្រៀមបង្ការ (សំណួរQD5,QG2) គឺជាធាតុសំខាន់សម្រាប់ការវាស់វែង។
- **ដើម្បីវាស់វែងអំពីការប្រែប្រួលនៃការអនុវត្ត** វាមានសារៈសំខាន់ណាស់ដែលការវាស់វែងត្រូវមើលទៅលើសូចនាករមួយចំនួន ដែលមានការផ្សារភ្ជាប់គ្នារវាងទស្សនៈ/ការយល់ឃើញអំពី

ផលប៉ះពាល់ (សំណួរ QX1) និងហានិភ័យ (សំណួរ QG1) និងរបៀបនៃការយល់ឃើញទាំងនេះដែលពាក់ព័ន្ធជាមួយសកម្មភាពឆ្លើយតបនានា (សំណួរ QD4a, QE2a, QF2a) ព្រមទាំងការយល់ឃើញពីសមត្ថភាពផ្ទាល់ខ្លួនក្នុងការឆ្លើយតប (សំណួរ QX6) ក៏ដូចជាការត្រៀមខ្លួន (សំណួរ QD5, QG2)។ ជាពិសេសការពិនិត្យមើលទៅលើគុណភាព ឬប្រភេទនៃសកម្មភាពឆ្លើយតបដែលប្រជាជនបានអនុវត្តគឺជាវិធី ដែលមានប្រសិទ្ធភាពខ្លាំងក្នុងការវាស់វែងអំពីប្រសិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែរបស់កិច្ចអន្តរាគមន៍ ឬយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងនានាដែលបានអនុវត្ត។ ឧទាហរណ៍ ប្រសិនបើគេមានយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងមួយដែលផ្តោតសំខាន់ទៅលើ ការជំរុញទឹកចិត្តប្រជាជនឲ្យការធ្វើសកម្មភាពឆ្លើយតបជាក់លាក់ណាមួយដែលគេបានកំណត់ (ដូចជាមានប្រជាជនជាច្រើនមានផែនការត្រៀមបង្ការគ្រោះមហន្តរាយ) នោះការពិនិត្យតាមដានអំពីកម្រិតនៃសកម្មភាពដែលចង់ធ្វើ និងសកម្មភាពដែលបានធ្វើក្នុងចំណោមប្រជាជន (ឬក្រុមគោលដៅសំខាន់ៗ) ពិតជាមានប្រសិទ្ធភាពខ្លាំងណាស់។

# ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរសម្រាប់ការអង្កេត (KAP៣)

**លេខសេរីផ្ទះ៖ ____________________________**

| | **ចំនួនដងនៃការចុះជួបសម្ភាសន៍** | | |
|---|---|---|---|
| | ជួបលើកទី 1 | ជួបលើកទី 2 | ជួបលើកទី 3 |
| **កាលបរិច្ឆេទ [ថ្ងៃ/ខែ/ឆ្នាំ]** | / / | / / | / / |
| **ឈ្មោះអ្នកសម្ភាសន៍** | | | |
| **លទ្ធផលនៃការសម្ភាស** | | | |
| **ការចុះលើកបន្ទាប់ កាលបរិច្ឆេទ [ថ្ងៃ/ខែ/ឆ្នាំ]** | / / | / / | |
| **ម៉ោង** | | | |

***កូដនៃលទ្ធផល៖**

1 = **ការសម្ភាស់បានចប់សព្វគ្រប់**
2 = **អ្នកតបសម្ភាសន៍បដិសេធក្នុងការសម្ភាស**
3 = **ណាត់ជួបពេលក្រោយ**
4 = **អ្នកតបសម្ភាសន៍មិននៅផ្ទះ**
5 = **ផ្សេងៗ (សូមបញ្ជាក់):** ____________________

**សួរសំណួរខាងក្រោមទៅកាន់មេគ្រួសារ ឬអ្នកដែលរកចំណូលចំបងក្នុងការផ្គត់ផ្គង់គ្រួសារ៖**

វាសំខាន់ណាស់ដែលអ្នកត្រូវពន្យល់ទៅកាន់អ្នកតំណាងនៃគ្រួសារនីមួយៗ (អ្នកដែលបាន និងកំពុងនិយាយជាមួយ និងសាកសួរនូវសំណួរមួយចំនួន) ដែលអ្នកអាចនិយាយថា អ្នកត្រូវសម្ភាសន៍ដោយធ្វើការជ្រើសរើសអ្នកឆ្លើយតបសម្ភាសន៍ដោយចៃដន្យ ហើយមូលហេតុនេះហើយដែលអ្នកត្រូវការកត់ត្រាឈ្មោះរបស់អ្នកតបសម្ភាសន៍។ ឈ្មោះនេះគឺសម្រាប់គោលបំណងនៃការសិក្សាខាងលើនេះប៉ុណ្ណោះ មិនមែនសម្រាប់អ្នកផ្សេងយកទៅប្រើប្រាស់នោះទេ។

**ការណែនាំខ្លួន**

ជម្រាបសួរ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ____________។ ខ្ញុំមកនេះតំណាងឲ្យក្រុមហ៊ុន កាន់តា ដែលជាក្រុមហ៊ុនស្រាវជ្រាវមួយនៅកម្ពុជា។ ពួកយើងកំពុងធ្វើការសិក្សាមួយ ដើម្បីស្វែងយល់ពីការយល់ឃើញរបស់ប្រជាពលរដ្ឋទៅលើបញ្ហាមួយចំនួនទាក់ទងនឹងសង្គម និងបរិស្ថាន រួមទាំងទម្លាប់ក្នុងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយ។ មូលហេតុនេះហើយបានជាក្រុមការងារខ្ញុំសុំមកទីនេះដើម្បីសាកសួរមតិយោបល់ពីប្រជាជននៅតំបន់របស់អ្នក។ សូមបញ្ជាក់ថាផ្ទះរបស់អ្នកត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីចូលរួមក្នុងការសម្ភាស ហើយការចូលរួមជួយឆ្លើយសំណួរក្នុងការសម្ភាសនេះពិតជាមានសារៈសំខាន់ណាស់។ ការចូលរួមរបស់អ្នកគឺជាការស្ម័គ្រចិត្ត។ រាល់ព័ត៌មានដែលអ្នកផ្តល់ឲ្យក្នុងការសម្ភាសនេះ នឹងត្រូវបានរក្សាអត្តសញ្ញាណជាការសម្ងាត់។

ប្រសិនបើអ្នកយល់ព្រមចូលរួម នោះខ្ញុំនឹងសួរសំណួរមួយចំនួនទាក់ទងនឹងបញ្ហាអាកាសធាតុ បរិស្ថាន និងទម្លាប់ក្នុងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយរបស់អ្នក។ មតិយោបល់របស់អ្នកគឺមានប្រយោជន៍ណាស់ក្នុងការជួយដល់ការអនុវត្តកម្មវិធីអន្តរាគមន៍ផ្នែកអាកាសធាតុ និងបរិស្ថាននាពេលអនាគត។ ដូច្នេះវាពិតជាសំខាន់មែនដែលអ្នកចូលរួមឆ្លើយតាមការគិតរបស់អ្នក។ សូមបញ្ជាក់ថានេះមិនមែនជាការសាកល្បងចំណេះដឹងនោះទេ ហើយចម្លើយរបស់អ្នកមិនមានត្រូវ ឬខុសនោះដែរ គឺពួកយើងគ្រាន់តែចង់ដឹងពីការយល់ឃើញរបស់អ្នកប៉ុណ្ណោះ។

ក្នុងគោលបំណងឲ្យក្រុមការងារផ្នែកពិនិត្យគុណភាពទិន្នន័យកិច្ចសម្ភាសន៍របស់យើងខ្ញុំអាចធ្វើការផ្ទៀងផ្ទាត់ថា ខ្ញុំពិតជាបានមកធ្វើការសម្ភាសប្រមូលទិន្នន័យពិតមែននោះ ខ្ញុំនឹងសួរសំណួរផ្ទាល់ខ្លួនរបស់អ្នកខ្លះៗដូចជា ឈ្មោះ និងព័ត៌មានទំនាក់ទំនងសម្រាប់ឲ្យក្រុមកាងារផ្នែកត្រួតពិនិត្យគុណភាពទាក់ទងដើម្បីបញ្ជាក់ថា ពួកខ្ញុំពិតជាបានមកសាកសួរពីអ្នកពិតប្រាកដមែន។ ពួកយើងនឹងលុបព័ត៌មាននេះក្រោយពីការសិក្សាស្រាវជ្រាវនេះបានបញ្ចប់សព្វគ្រប់។

## សំណួរផ្ទៀងផ្ទាត់សម្រាប់ជ្រើសរើសអ្នកតបសម្ភាសន៍

| Q# | សំណួរ | | | | | | កូដ |
|---|---|---|---|---|---|---|---|
| Q1 | សូមប្រាប់ឲ្យយើងដឹងថា តើមានមនុស្សប៉ុន្មាននាក់រស់នៅក្នុងគ្រួសាររបស់អ្នក? សូមរាប់សមាជិកគ្រួសារទាំងអស់ដែលបានស្នាក់នៅ និងទទួលទានអាហារជាមួយគ្នាក្នុងគ្រួសារ យ៉ាងតិចប្រាំមួយខែចុងក្រោយ - ក្នុងករណីនេះ សូមរាប់ទាំងអ្នកបម្រើ/កូនឈ្នួល និងភ្ញៀវបណ្តោះអាសន្ន។ *សរសេរលេខក្នុងប្រអប់* | | | | | | ☐☐ |
| Q2 | ក្នុងចំណោមអ្នកទាំងនេះ តើមានកុមារអាយុតិចជាង ១៥ ឆ្នាំប៉ុន្មាននាក់? *សរសេរលេខ* | | | | | | ☐☐ |
| Q3 | សូមអោយឈ្មោះ ឬអក្សរកាត់ អាយុ និងភេទរបស់មនុស្សម្នាក់ៗដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ក្នុងគ្រួសារ ដោយ**ចាប់ផ្តើមពីសមាជិកដែលមានអាយុតិចជាងគេ** (១៥ ឆ្នាំឡើងទៅ) ។ កុំភ្លេចរាប់បញ្ចូលខ្លួនអ្នកផង ប្រសិនបើអ្នកមានអាយុចាប់ពី ១៥ ឆ្នាំ។ | | | | | | |
| | No. | ឈ្មោះ | a) ភេទ | | b) អាយុ | ជ្រើសរើសសម្រាប់ចូលរួមក្នុងការសម្ភាសន៍នៅក្នុង Kish Grid (ធីក) | |
| | | | ប្រុស | ស្រី | | | |
| | 1 | | 1 | 2 | | | |
| | 2 | | 1 | 2 | | | |
| | 3 | | 1 | 2 | | | |
| | 4 | | 1 | 2 | | | |
| | 5 | | 1 | 2 | | | |
| | 6 | | 1 | 2 | | | |
| | 7 | | 1 | 2 | | | |
| | 8 | | 1 | 2 | | | |
| | 9 | | 1 | 2 | | | |
| | 10 | | 1 | 2 | | | |
| | 11 | | 1 | 2 | | | |
| | 12 | | 1 | 2 | | | |
| | 13 | | 1 | 2 | | | |
| | 14 | | 1 | 2 | | | |
| | 15 | | 1 | 2 | | | |

**ជ្រើសរើសអ្នកឆ្លើយតបដែលមានគ្រប់លក្ខខណ្ឌតែម្នាក់គត់ពីគ្រួសារមួយតាមការណែនាំដូចខាងក្រោម៖**

**តារាងឃីសគ្រីត (Kish-Grid Matrix)**

បន្ទាប់ពីបំពេញព័ត៌មានអំពីសមាជិកគ្រួសារទាំងអស់នៅខាងលើ សូមជ្រើសរើសអ្នកតបសម្ភាសន៍ដោយប្រើវិធីឃីសគ្រីដ **KISH GRID** ដូចខាងក្រោម។ វិធីឃីសគ្រីដ **KISH GRID** អនុញ្ញាតឲ្យមានការជ្រើសរើសអ្នកតបសម្ភាសន៍តែម្នាក់ដោយចៃដន្យក្នុងចំណោមសមាជិកគ្រួសារដទៃទៀត។

**សេចក្តីណែនាំអំពីដំណើរការឃីសគ្រីដ (Kish-Grid instructions)**

- ពិនិត្យយកលេខខ្ទង់ចុងក្រោយក្នុងជួរឈរនៅក្នុងលេខស៊េរីគ្រួសារ និងចំនួនមនុស្សដែលគ្រប់លក្ខខណ្ឌក្នុងជួរដេក
- លេខនៅក្នុងប្រអប់នៃជួរឈរ និងជួរដេកដែលជួបគ្នាគឺជាលេខបុគ្គលដែលត្រូវសម្ភាសន៍។ ឧទាហរណ៍៖ បើលេខសេរីគ្រួសារបញ្ចប់ដោយលេខ ២ មានមនុស្សពេញវ័យ ៣នាក់ ត្រូវសម្ភាសន៍សមាជិកគ្រួសារលេខរៀងទី២ នៅក្នុងតារាងគ្រួសារនៅសំណួរ Q3 គូសរង្វង់អ្នកតបសម្ភាសន៍ នឹងបើអាចពន្យល់អំពីគោលបំណងនៃការសម្ភាស ទទួលការយល់ព្រម នឹងចាប់ផ្តើម
- បើអ្នកដែលត្រូវជ្រើសរើសចូលរួម អាចផ្តល់ការសម្ភាសបាននៅថ្ងៃជ្រើសរើសហ្នឹង ប៉ុន្តែបើមិនទំនេរ/មិននៅផ្ទះក្នុងពេលដែលអ្នកសម្ភាសន៍ទាក់ទងទៅ អ្នកសម្ភាសន៍គួរតែធ្វើការទូរស័ព្ទមក/ណាត់ជួបយ៉ាងតិចចំនួន២ដងទៀត ដើម្បីមើលថាតើបុគ្គលម្នាក់នេះទំនេរ ឬបានត្រលប់មកផ្ទះឬនៅ មុនធ្វើការជ្រើសរើសគ្រួសារមួយផ្សេងទៀត
- ប្រសិនបើអ្នកតបសម្ភាសន៍ដែលត្រូវបានជ្រើសរើសមិនទំនេរនៅក្នុងថ្ងៃហ្នឹង ហើយការណាត់ជួបពីរដងមិនបានសម្រេច អ្នកសម្ភាសន៍គួរជ្រើសរើសគ្រួសារបន្ទាប់មួយទៀត តែមិនត្រូវជ្រើសរើសសមាជិកណាផ្សេងទៀតនៅក្នុងគ្រួសារតែមួយដដែលនោះមកជំនួសទេ។

| បុគ្គលគ្រប់លក្ខខណ្ឌ | លេខចុងក្រោយនៃលេខសេរីគ្រួសារ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **1** | **2** | **3** | **4** | **5** | **6** | **7** | **8** | **9** | **0** |
| 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | x | x |
| 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | x | x |
| 3 | 1 | 2 | 3 | 1 | 2 | 3 | 1 | 2 | x | x |
| 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | x | x |
| 5 | 1 | 2 | 3 | 4 | 5 | 3 | 4 | 5 | x | x |
| 6 | 1 | 2 | 3 | 4 | 5 | 6 | 3 | 6 | x | x |
| 7 | 1 | 2 | 3 | 4 | 5 | 6 | 7 | 4 | x | x |
| 8 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | x | x |
| 9 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | x | x |
| 10 ឬច្រើន | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | x | x |

**ការណែនាំខ្លួន (ប្រសិនជាអ្នកសម្ភាសន៍មិនទាន់បានអាន ឬជួបជាមួយអ្នកតបសម្ភាសន៍ដែលបានជ្រើសរើស)**

ជម្រាបសួរ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ____________។ ខ្ញុំមកនេះតំណាងឲ្យក្រុមហ៊ុន កាន់តា ដែលជាក្រុមហ៊ុនស្រាវជ្រាវមួយនៅកម្ពុជា។ ពួកយើងកំពុងធ្វើការសិក្សាមួយដើម្បីស្វែងយល់ពីការយល់ឃើញរបស់ប្រជាពលរដ្ឋទៅលើបញ្ហាមួយចំនួនទាក់ទងនឹងសង្គម និងបរិស្ថាន រួមទាំងទម្លាប់ក្នុងការប្រើប្រាស់បណ្ដាញផ្សព្វផ្សាយ។ មូលហេតុនេះហើយបានជាក្រុមការងារខ្ញុំសុំមកទីនេះដើម្បីសាកសួរមតិយោបល់ពីប្រជាជននៅតំបន់របស់អ្នក។ សូមបញ្ជាក់ថាផ្ទះរបស់អ្នកត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីចូលរួមក្នុងការសម្ភាស ហើយការចូលរួមជួយឆ្លើយសំណួរក្នុងការសម្ភាសនេះពិតជាមានសារៈសំខាន់ណាស់។ ការចូលរួមរបស់អ្នកគឺជាការស្ម័គ្រចិត្ត។ រាល់ព័ត៌មានដែលអ្នកផ្ដល់ឲ្យក្នុងការសម្ភាសនេះ នឹងត្រូវបានរក្សាអត្តសញ្ញាណជាការសម្ងាត់។

ប្រសិនបើអ្នកយល់ព្រមចូលរួម នោះខ្ញុំនឹងសួរសំណួរមួយចំនួនទាក់ទងនឹងបញ្ហាអាកាសធាតុ បរិស្ថាន និងទម្លាប់ក្នុងការប្រើប្រាស់បណ្ដាញផ្សព្វផ្សាយរបស់អ្នក។ មតិយោបល់របស់អ្នក គឺមានប្រយោជន៍ណាស់ក្នុងការជួយដល់ការអនុវត្តកម្មវិធីអន្តរាគមន៍ផ្នែកអាកាសធាតុ និងបរិស្ថាននាពេលអនាគត។ ដូច្នេះវាពិតជាសំខាន់មែនដែលអ្នកចូលរួមឆ្លើយតាមការគិតរបស់អ្នក។ សូមបញ្ជាក់ថានេះ មិនមែនការការសាកល្បងចំណេះដឹងនោះទេ ហើយចម្លើយរបស់អ្នកមិនមានត្រូវ ឬខុសនោះដែរ គឺពួកយើងគ្រាន់តែចង់ដឹងពីការយល់ឃើញរបស់អ្នកប៉ុណ្ណោះ។

ក្នុងគោលបំណងឲ្យក្រុមការងារផ្នែកពិនិត្យគុណភាពទិន្នន័យកិច្ចសម្ភាសន៍របស់យើងខ្ញុំអាចធ្វើការផ្ទៀងផ្ទាត់ថា ខ្ញុំពិតជាបានមកធ្វើការសម្ភាសប្រមូលទិន្នន័យពិតមែននោះ ខ្ញុំនឹងសួរសំណួរផ្ទាល់ខ្លួនរបស់អ្នកខ្លះៗ ដូចជាឈ្មោះ និងព័ត៌មានទំនាក់ទំនងសម្រាប់ឲ្យក្រុមកាងារផ្នែកត្រួតពិនិត្យគុណភាពទាក់ទង ដើម្បីបញ្ជាក់ថាពួកខ្ញុំពិតជាបានមកសាកសួរពីអ្នកពិតប្រកដមែន។ ពួកយើងនឹងលុបព័ត៌មាននេះ ក្រោយពីការសិក្សាស្រាវជ្រាវនេះបានបញ្ចប់សព្វគ្រប់។

**ទម្រង់នៃកិច្ចព្រមព្រៀងក្នុងការចូលរួម**

មុនពេលបំពេញទម្រង់នៃកិច្ចព្រមព្រៀងក្នុងការចូលរួមនេះ អ្នកចាំបាច់ត្រូវតែអានព័ត៌មាន និងអាចសួរសំណួរដែលអ្នកចង់ដឹងទៅកាន់អ្នកសម្ភាសន៍បាន។

ទោះបីជាអ្នកមិនទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីការចូលរួមក្នុងការសម្ភាសនេះដោយផ្ទាល់ក៏ដោយ ចម្លើយរបស់អ្នកជាការរួមចំណែកមួយដើម្បីជួយឲ្យយើងបានយល់ពីបញ្ហាសង្គម និងបរិស្ថាននានា ដែលអាចជួយឲ្យយើងអាចរៀបចំនូវយុទ្ធសាស្ត្រនានាក្នុងការដោះស្រាយបញ្ហាទាំងនោះដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នាពេលអនាគត។ ចម្លើយ និងអត្តសញ្ញាណរបស់អ្នកនឹងត្រូវបានរក្សាទុកជាការសម្ងាត់។ នេះមានន័យថាយើងនឹងលុបចោលនូវរាល់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់អ្នកតបសម្ភាសន៍ ដូចជា ឈ្មោះ និងភូមិ។ អ្នកអាចសម្រេចចិត្តមិនឆ្លើយទៅលើសំណួរណាមួយដែលអ្នកមិនចង់ឆ្លើយ ឬអាចបញ្ចប់ការសម្ភាសនៅពេលណាក៏បាន។ ការសម្ភាសន៍នឹងត្រូវចំណាយពេលប្រហែល ៦០ នាទី។

តើអ្នកបានយល់ពីអ្វីដែលខ្ញុំបានរៀបរាប់ដែរឬទេ? (គូសរង្វង់): បាទ/ចាស៎ / ទេ

ខ្ញុំពេញចិត្តជាមួយចម្លើយដែលខ្ញុំបានទទួលពីអ្នកសម្ភាសន៍ (គូសរង្វង់): បាទ/ចាស៎ / ទេ

តើអ្នកយល់ព្រមចូលរួមក្នុងការសម្ភាសនេះដែរ ឬទេ? (គូសរង្វង់): បាទ/ចាស៎ / ទេ

1. ខ្ញុំបានធ្វើការពន្យល់អ្នកតបសម្ភាសន៍ទៅតាមសេចក្ដីណែនាំខាងលើចប់សព្វគ្រប់ និង បានបញ្ជាក់ប្រាប់គាត់អំពីហានិភ័យផ្សេងៗ ដែលអាចកើតមានក្នុងកំឡុងពេលឆ្លើយសំណួរនៃការស្ទង់មតិនេះ។ ខ្ញុំក៏បានសួរអ្នកតបសម្ភាសន៍ថាតើគាត់មានសំណួរអ្វីដែរ ឬទេ ហើយក៏បានឆ្លើយតបរាល់សំណួរដែលគាត់បានសួរចប់សព្វគ្រប់រួចហើយដែរ។ អ្នកតបសម្ភាសន៍បានបញ្ជាក់ដោយផ្ទាល់មាត់ថាគាត់យល់ព្រមចូលរួមក្នុងកិច្ចសម្ភាសន៍នេះ។

   ឈ្មោះអ្នកសម្ភាសន៍: ______________________________

   ហត្ថលេខាអ្នកសម្ភាសន៍: ______________________________

   កាលបរិច្ឆេទ: ______________________________

| | |
|---|---|
| **2.** | **បើអ្នកតបសម្ភាសន៍ខាងក្រោមមានអាយុក្រោម១៨ឆ្នាំ យើងត្រូវការការអនុញ្ញាតពីអាណាព្យាបាល**<br>ក្នុងនាមជាអាណាព្យាបាលរបស់អ្នកតបសម្ភាសន៍ ខ្ញុំបានអាននឹងយល់អំពីព័ត៌មានខាងលើ សំណួរដែលខ្ញុំមានក៏ត្រូវបានឆ្លើយតបរួចរាល់ដែរ។ ខ្ញុំអនុញ្ញាតឲ្យអ្នកតបសម្ភាសន៍ដែលនៅក្រោមការមើលថែរបស់ខ្ញុំចូលរួមការសម្ភាសនេះ។<br>ឈ្មោះអាណាព្យាបាល: ______________________________<br>ហត្ថលេខាអាណាព្យាបាល: ____________________________<br>កាលបរិច្ឆេទ: ____________________________________ |
| **3.** | **បំពេញម៉ោងពេលដែលចាប់ផ្តើមការសម្ភាស:** \| \| \| \| \| \|<br>ម៉ោង នាទី |

**កំណត់សម្គាល់:** ទម្រង់នៃកិច្ចព្រមព្រៀងសម្រាប់ការសម្ភាសដែលមានចុះហត្ថលេខានេះ ត្រូវធ្វើឡើងជា២ច្បាប់៖ ១) ទុកជាឯកសាររបស់អ្នកសម្ភាសន៍១ច្បាប់ និង ២) ជូនទៅអ្នកតបសម្ភាសន៍១ច្បាប់។

**អ្នកសម្ភាសន៍ចាប់ផ្តើមកត់ត្រាពត៌មានលម្អិតអំពីអ្នកតបសម្ភាសន៍**

| | | |
|---|---|---|
| **Q4.** អាយុ | ឆ្នាំ | ___________ |
| | មិនដឹង | 88 |
| | បដិសេធ | 99 |
| **Q5.** ទីតាំង (គូសចម្លើយតែ១) | ទីក្រុង<br>ជនបទ | 1<br>2 |
| **Q6.** លេខសេរីផ្ទះ: | លេខគ្រួសារ | ____________ |
| **Q7.** ភេទ (គូសចម្លើយតែ១) | ប្រុស<br>ស្រី | 1<br>2 |

**ឥឡូវសូមចាប់ផ្តើមសម្ភាសន៍ជាមួយមនុស្សដែលត្រូវបានជ្រើសរើស**

## ផ្នែក A៖ តម្លៃជាទូទៅ និងអាទិភាពនានារបស់ប្រជាជន

កុំអានចម្លើយ «មិនដឹង» ឬ «បដិសេធ/គ្មានចម្លើយ» ដែលមាននៅក្នុងកម្រងសំណួរទាំងមូល ទៅកាន់អ្នកតបសម្ភាសន៍។

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**អាន៖** ឥឡូវខ្ញុំសុំសួរអ្នកអំពីអ្វីដែលសំខាន់នៅក្នុងជីវិតរបស់អ្នក។

**QA1.** ខាងក្រោមនេះគឺជាគុណតម្លៃដែលមនុស្សមួយចំនួនបាននិយាយថាមានសារៈសំខាន់ចំពោះពួកគេ។ ចំពោះគុណតម្លៃនីមួយៗនេះ យើងចង់ដឹងថាតើវាមានសារៈសំខាន់ ឬមិនសំខាន់សម្រាប់អ្នក។

សម្រាប់ចំណុចនីមួយៗ សូមអ្នកប្រាប់សិនថា តើវាសំខាន់ឬ មិនសំខាន់សម្រាប់អ្នក។ ប្រសិនបើវាសំខាន់ ខ្ញុំនឹងសួរថាតើវាមានសារៈសំខាន់ខ្លាំង ឬសំខាន់គួរសមសម្រាប់អ្នក? ប្រសិនបើវាមិនសំខាន់ ខ្ញុំនឹងសួរ តើវាមិនសំខាន់ ឬមិនសំខាន់ទាល់តែសោះ។

**កូដតែមួយគត់សម្រាប់ចម្លើយនីមួយៗ**

| សំខាន់ | | មិនសំខាន់ | |
|---|---|---|---|
| សំខាន់ខ្លាំងណាស់ | សំខាន់គួរសម | មិនសំខាន់ទេ | មិនសំខាន់ទាល់តែសោះ |

**បង្ហាញកាត កុំអានជម្រើស នៅកណ្តាល**

| QA1 | សំខាន់ខ្លាំងណាស់ | សំខាន់គួរសម | នៅកណ្តាល | មិនសំខាន់ទេ | មិនសំខាន់ទាល់តែសោះ | មិនដឹង | បដិសេធ/គ្មានចម្លើយ |
|---|---|---|---|---|---|---|---|
| a) ការប្រកាន់ខ្ជាប់នូវតម្លៃប្រពៃណី សាសនា និងជំនឿ | 5 | 4 | 3 | 2 | 1 | 88 | 99 |
| b) អាចបញ្ចេញមតិ ទៅលើបញ្ហាផ្សេងៗដែលទាក់ទងនឹងអ្នក | 5 | 4 | 3 | 2 | 1 | 88 | 99 |
| c) រកប្រាក់ចំណូលបានច្រើនតាមដែលអាចធ្វើទៅបាន | 5 | 4 | 3 | 2 | 1 | 88 | 99 |
| d) រស់នៅចុះសម្រុងជាមួយនឹងមនុស្សជុំវិញខ្លួនអ្នក | 5 | 4 | 3 | 2 | 1 | 88 | 99 |
| e) ទទួលបានការគោរពពីអ្នកជិតខាងរបស់ខ្ញុំ | 5 | 4 | 3 | 2 | 1 | 88 | 99 |
| f) ប្រើប្រាស់ទូរស័ព្ទទាន់សម័យ | 5 | 4 | 3 | 2 | 1 | 88 | 99 |
| g) ចូលចិត្តឬរីករាយជាមួយកន្លែងដែលមានធម្មជាតិ (ឧទាហរណ៍ ការទៅលេងព្រៃ ឬតំបន់សត្វព្រៃ) | 5 | 4 | 3 | 2 | 1 | 88 | 99 |
| h) ថែរក្សាសុខភាពរបស់អ្នកឬគ្រួសាររបស់អ្នកអោយមានសុខភាពល្អ | 5 | 4 | 3 | 2 | 1 | 88 | 99 |
| i) ទទួលការអប់រំសម្រាប់ខ្លួនអ្នកផ្ទាល់ ឬគ្រួសាររបស់អ្នក | 5 | 4 | 3 | 2 | 1 | 88 | 99 |

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QA2** បើប្រៀបធៀបទៅនឹង ៥ ឆ្នាំមុន តើអ្នកអាចនិយាយបានទេថាជីវិតរបស់អ្នកប្រសើរជាងមុន លំបាកជាងមុន ឬក៏ នៅដដែលដូចមុន?

**ចម្លើយតែមួយគត់**

**ប្រសិនបើ** អ្នកតបសម្ភាសន៍ឆ្លើយថា «ប្រសើរជាងមុន» សួរ - តើប្រសើរជាងមុនច្រើនរឺក៏ប្រសើរជាងមុនតិចតួច? ប្រសិនបើអ្នកតបសម្ភាសន៍ឆ្លើយថា លំបាកជាងមុន សួរ - តើលំបាកជាងមុនខ្លាំងរឺក៏លំបាកជាងមុនតិចតួច? កត់ត្រាទៅតាមលេខកូដខាងក្រោម ។

| QA2 | | |
|---|---|---|
| ប្រសើរជាងមុន | ប្រសើរជាងមុនច្រើន | 5 |
| | ប្រសើរជាងមុនតិចតួច | 4 |
| នៅដដែល | | 3 |
| ពិបាកជាងមុន | លំបាកជាងមុនតិចតួច | 2 |
| | លំបាកជាងមុនខ្លាំង | 1 |
| មិនដឹង | | 88 |
| បដិសេធ/គ្មានចម្លើយ | | 99 |

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QA3a** ក្នុងចំណោមចំណុចទាំងអស់នេះ តើអ្វី ជាការព្រួយបារម្ភធំបំផុតរបស់អ្នកនាពេលបច្ចុប្បន្ននេះ?

**QA3b** ហើយតើអ្វី ជាការព្រួយបារម្ភធំទីពីររបស់អ្នកនាពេលបច្ចុប្បន្ននេះ?

**បង្ហាញកាត អាន ចម្លើយមានតែមួយគត់សម្រាប់សំណួរនីមួយៗ** (QA3a **និង** QA3b)

| | QA3a | QA3b |
|---|---|---|
| មិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ | 1 | 1 |
| មិនមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ផឹក | 2 | 2 |
| មិនមានទីជំរក / ផ្ទះសមរម្យ | 3 | 3 |
| សុខភាពមិនល្អ | 4 | 4 |
| មិនមានអគ្គិសនី / ប្រេងឥន្ធនៈគ្រប់គ្រាន់ | 5 | 5 |
| មិនមានការងារ / មុខរបរគ្រប់គ្រាន់ | 6 | 6 |
| មិនមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើរបស់របរប្រើប្រាស់សម្រាប់ខ្លួនអ្នកផ្ទាល់ និងក្រុមគ្រួសាររបស់អ្នក (ដូចជា សម្លៀកបំពាក់ គ្រឿងសង្ហារិម ។ល។) | 7 | 7 |
| មិនមានលទ្ធភាពក្នុងការបញ្ជូនកូនទៅសាលា ឬក៏ មិនបានសន្សំប្រាក់សម្រាប់អនាគតកូនៗរបស់អ្នក | 8 | 8 |
| មិនបារម្ភអំពីរឿងទាំងនេះទេ | 9 | 9 |
| ផ្សេងៗ សូមបញ្ជាក់ | 10 | 10 |
| មិនដឹង | 88 | 88 |
| បដិសេធ/គ្មានចម្លើយ | 99 | 99 |

## ផ្នែក B៖ ការយល់ដឹងពីការទទួលបានទឹកស្អាត / ចំណីអាហារ / ថាមពល

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**អាន:** ខ្ញុំសុំសួរអ្នកអំពីបញ្ហាសង្គម និងបរិស្ថានដែលអាចប៉ះពាល់ដល់ការរស់នៅរបស់អ្នក

**QB1:** ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ តើអ្នកគិតថាចំណុចខាងក្រោមមានការប្រែប្រួលកម្រិតណា - បានកើនឡើង នៅដដែល ឬថយចុះ?

**ចម្លើយតែមួយគត់សម្រាប់ជួរដេកនីមួយៗ**

*ប្រសិនបើអ្នកតបសម្ភាសន៍ជ្រើសរើស កើនឡើង សូមសួរដេញថា កើនឡើងច្រើន ឬ បន្តិចបន្តួច។ ប្រសិនបើអ្នកតបសម្ភាសន៍ជ្រើសរើស ថយចុះ សូមសួរដេញថា ថយចុះច្រើន ឬ បន្តិចបន្តួច។*

| កើនឡើង | | នៅដដែល | ថយចុះ | |
|---|---|---|---|---|
| កើនឡើងច្រើន | កើនឡើងតិចតួច | | ថយចុះតិចតួច | ថយចុះច្រើន |

| QB1 | កើនឡើងច្រើន | កើនឡើងតិចតួច | នៅដដែល | ថយចុះតិចតួច | ថយចុះច្រើន | មិនដឹង | បដិសេធ/មិនឆ្លើយ |
|---|---|---|---|---|---|---|---|
| a) ទឹក (សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ដូចជាសម្រាប់ ផឹក ចម្អិនអាហារ ។ល។) | 5 | 4 | 3 | 2 | 1 | 88 | 99 |
| b) ម្ហូបអាហារដែលអ្នកមានលទ្ធភាពទិញ | 5 | 4 | 3 | 2 | 1 | 88 | 99 |
| c) ប្រភេទម្ហូបអាហារ និងបន្លែសម្បូរបែប (ផលិតក្នុងស្រុក / នាំចូល) | 5 | 4 | 3 | 2 | 1 | 88 | 99 |
| d) ត្រីធម្មជាតិ(ក្រៅពីត្រីចិញ្ចឹម) | 5 | 4 | 3 | 2 | 1 | 88 | 99 |
| e) អគ្គិសនី (ទាំងឯកជននិងរដ្ឋ) | 5 | 4 | 3 | 2 | 1 | 88 | 99 |
| f) ប្រេងឥន្ធនៈដែលអ្នកមានលទ្ធភាពទិញបាន | 5 | 4 | 3 | 2 | 1 | 88 | 99 |
| g) ផលិតភាពកសិកម្ម - ដែលមានដីជាតិ សម្រាប់ដាំដុះបន្លែ/ដំណាំផ្សេងៗ | 5 | 4 | 3 | 2 | 1 | 88 | 99 |

## ផ្នែក C៖ ការយល់ដឹងអំពី ការផ្លាស់ប្តូរ ធាតុអាកាស និងបរិស្ថាន

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**អាន៖** តទៅនេះ ខ្ញុំសុំសួរអំពីមតិយោបល់របស់អ្នកទៅលើការប្រែប្រួលសង្គម និងបរិស្ថាន។

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QC1** រយៈពេល ១០ ឆ្នាំចុងក្រោយនេះ តើចំណុចខាងក្រោមមានការប្រែប្រួលកម្រិតណានៅក្នុងតំបន់របស់អ្នក - កើនឡើង នៅដដែល ឬ ថយចុះ? ចម្លើយតែមួយសម្រាប់ជម្រើសនីមួយៗ

| កើនឡើង | | នៅដដែល | ថយចុះ | |
|---|---|---|---|---|
| កើនឡើងច្រើន | កើនឡើងតិចតួច | | ថយចុះតិចតួច | ថយចុះច្រើន |

| QC1 | កើនឡើងច្រើន | កើនឡើងតិចតួច | នៅដដែល | ថយចុះតិចតួច | ថយចុះច្រើន | មិនពាក់ព័ន្ធ សម្រាប់តំបន់/ សហគមន៍អ្នក | មិនដឹង | បដិសេធ/មិនឆ្លើយ |
|---|---|---|---|---|---|---|---|---|
| a) ចំនួនដើមឈើ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| b) ប្រភេទសត្វព្រៃ និងសត្វស្លាបផ្សេងៗ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| c) ប្រភេទត្រីផ្សេងៗ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| d) ចំនួនសត្វល្អិតបំផ្លាញដំណាំកសិកម្ម | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| e) ចំនួនសត្វល្អិតដូចជារុយ និងមូស | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| f) បរិមាណប្លាស្ទិក / សំរាម | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| g) រោងចក្រ / ឧស្សាហកម្មនៅក្នុងតំបន់របស់អ្នក | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| h) ខ្យល់អាកាសអាប់អួរ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QC2** ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ, តើចំណុចខាងក្រោមមានការប្រែប្រួលកម្រិតណានៅក្នុងតំបន់របស់អ្នក - កើនឡើង នៅដដែល ឬ ថយចុះ?

**ចម្លើយតែមួយគត់សម្រាប់ជម្រើសនីមួយៗ កូដ g សម្រាប់តែខេត្តដែលមានសមុទ្រ**

| កើនឡើង | | នៅដដែល | ថយចុះ | |
|---|---|---|---|---|
| កើនឡើងច្រើន | កើនឡើងតិចតួច | | ថយចុះតិចតួច | ថយចុះច្រើន |

| QC2 | កើនឡើងច្រើន | កើនឡើងតិចតួច | នៅដដែល | ថយចុះតិចតួច | ថយចុះច្រើន | មិនពាក់ព័ន្ធ | មិនដឹង | បដិសេធ/មិនឆ្លើយ |
|---|---|---|---|---|---|---|---|---|
| a) ទឹកភ្លៀង | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| b) សីតុណ្ហភាព | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| c) ទឹកជំនន់ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| d) គ្រោះរាំងស្ងួត / កង្វះខាតទឹក | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| e) ព្យុះ / ខ្យល់ខ្លាំង | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| f) រន្ទះ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |
| g) កម្ពស់ទឹកសមុទ្រ | 5 | 4 | 3 | 2 | 1 | 6 | 88 | 99 |

## ផ្នែក X៖ ផលប៉ះពាល់នៃការប្រែប្រួលធនធាននានា

**សូមអាន៖** អ្នកទើបតែបានឆ្លើយសំណួរមួយចំនួនអំពីការប្រែប្រួលខាងលើ ដូចជាទឹក ចំណីអាហារ អគ្គិសនី និងប្រេងឥន្ធនៈ និងធាតុអាកាស សំណួរតទៅនេះ ខ្ញុំនឹងសួរអ្នកអំពីផលប៉ះពាល់ទាំងនេះ ដែលមានមកលើការរស់នៅរបស់អ្នក។

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QX1** កម្រិតពី ១ ទៅ ១០ ដែល ១ មានន័យថា មិនប៉ះពាល់ និង១០មានន័យថា ប៉ះពាល់ខ្លាំងណាស់

a) សព្វថ្ងៃ តើអ្នកយល់ថាការប្រែប្រួលនៅក្នុងបរិយាកាសធម្មជាតិជុំវិញអ្នកទាំងនេះ (ដូចជាទឹក ម្ហូបអាហារ អគ្គីសនី ប្រេងឥន្ធនៈ និង ធាតុអាកាស) ប៉ះពាល់ដល់ការរស់នៅរបស់អ្នកកម្រិតណា? **បង្ហាញតារាង ចម្លើយតែមួយគត់**

| **QX1a** | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | មិនដឹង |
|---|---|---|---|---|---|---|---|---|---|---|---|

b) ចុះនៅពេលអនាគតវិញ តើអ្នកយល់ថាការប្រែប្រួលទាំងអស់នេះ (ដូចជាទឹក ម្ហូបអាហារ អគ្គីសនី ប្រេងឥន្ធនៈ និង ធាតុអាកាស) នឹងប៉ះពាល់ដល់អ្នកកម្រិតណា? **បង្ហាញតារាង ចម្លើយតែមួយគត់**

| **QX1b** | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | មិនដឹង |
|---|---|---|---|---|---|---|---|---|---|---|---|

**សួរទៅកាន់អ្នកតបសម្ភាសន៍ទាំងអស់**

**QX2** តាមគំនិតរបស់អ្នក តើអ្នកយល់ថាការប្រែប្រួលទាំងអស់នេះ (ដូចជាទឹក ម្ហូបអាហារ អគ្គីសនី ប្រេងឥន្ធនៈ និងធាតុអាកាស) ប៉ះពាល់ដល់លទ្ធភាពរបស់អ្នកក្នុងរឿងរ៉ាវខាងក្រោមកម្រិតណា? **សូមអានចម្លើយនីមួយៗម្តងមួយ លើកលែងចម្លើយ «នៅកណ្តាល ឬចាក់ខ្សែ»។ បើប៉ះពាល់ សួរដេញថាតើប៉ះពាល់ខ្លាំងឬមធ្យម, បើមិនប៉ះពាល់ សួរដេញថាតើមិនប៉ះពាល់ទេឬ មិនប៉ះពាល់ទាល់តែសោះ។ អានប្រយោគខាងក្រោម ចម្លើយតែមួយសម្រាប់ប្រយោគនីមួយៗ**

| ប៉ះពាល់ | | មិនប៉ះពាល់ | |
|---|---|---|---|
| ប៉ះពាល់ខ្លាំង | ប៉ះពាល់មធ្យម | មិនប៉ះពាល់ | មិនប៉ះពាល់ទាល់តែសោះ |

| QX2 | ប៉ះពាល់ខ្លាំង | ប៉ះពាល់មធ្យម | នៅកណ្ដាល | មិនប៉ះពាល់ទេ | មិនប៉ះពាល់ ទាល់តែសោះ | មិនដឹង | បដិសេធ/មិនឆ្លើយ |
|---|---|---|---|---|---|---|---|
| a) ប៉ះពាល់ដល់លទ្ធភាពក្នុងការរកប្រាក់ចំណូល ឬ ការងាររបស់អ្នកកម្រិតណា? | 5 | 4 | 3 | 2 | 1 | 88 | 99 |
| b) ប៉ះពាល់ដល់ការថែទាំសុខភាពរបស់អ្នកកម្រិតណា? | 5 | 4 | 3 | 2 | 1 | 88 | 99 |
| c) ប៉ះពាល់ដល់ការហូបចុកឬរបបអាហាររបស់អ្នកកម្រិតណា (ឧ. អ្នកចង់ហូបអ្វីមួយ តែមិនមាន) ? | 5 | 4 | 3 | 2 | 1 | 88 | 99 |
| d) ប៉ះពាល់ដល់ការប្រើប្រាស់ទឹកប្រចាំថ្ងៃ កម្រិតណា (ផឹក ដាំស្ល វ បោកគក់/លាងសំអាត, ទឹកសំរាប់ប្រើប្រាស់ផ្សេងទៀត)? | 5 | 4 | 3 | 2 | 1 | 88 | 99 |

**សួរសំណួរខាងក្រោម ចំពោះតែអ្នកដែលជ្រើសរើសកូដ 5 ឬ 4 នៅក្នុង QX2b (ប៉ះពាល់ដល់ការថែទាំសុខភាពរបស់អ្នក) ការផ្លាស់ប្តូរទាំងនេះអាចមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន។**

**QX3** អ្នកបានប្រាប់ថា ការប្រែប្រួលខាងលើ (ឧ. ទឹក ម្ហូបអាហារ អគ្គីសនី ប្រេងឥន្ធនៈ និង ធាតុអាកាស) ប៉ះពាល់ដល់សុខភាពរបស់អ្នក, តើសុខភាពរបស់អ្នក ឬ ក្រុមគ្រួសារអ្នករងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ?

**កុំអាន/បង្ហើបចម្លើយ ជ្រើសរើសកូដទាំងឡាយណា ដែលអ្នកតបសម្ភាសន៍បានឆ្លើយ**

| | |
|---|---|
| a) ឧស្សាហ៍រាករូស | 1 |
| b) ឧស្សាហ៍ទល់លាមក | 2 |
| c) ឧស្សាហ៍ក្អក | 3 |
| d) ឧស្សាហ៍គ្រុនក្តៅ | 4 |
| e) ក្អួតញឹកញាប់ | 5 |
| f) ស្រកទម្ងន់ | 6 |
| g) ឧស្សាហ៍អស់កម្លាំង | 7 |
| h) នោមតិច | 8 |
| i) មានពងបែក / ឈឺចាប់លើស្បែក | 9 |
| j) មិនសូវមានជំងឺផ្តាសាយច្រើន | 10 |
| k) ឡើងទម្ងន់ | 11 |
| l) ផ្សេងៗ (សូមបញ្ជាក់) | 12 |
| m) មិនដឹង | 88 |
| n) មិនឆ្លើយ / បដិសេធ | 99 |

**សួរសំណួរខាងក្រោមនេះចំពោះតែអ្នកដែលជ្រើសរើសកូដ 5, 4 ក្នុង QX2c (ប៉ះពាល់ដល់ការហូបចុកឬរបបអាហារ) ប៉ុណ្ណោះ**

**QX4** អ្នកបានប្រាប់ថា ការប្រែប្រួលខាងលើ (ឧ. ទឹក ម្ហូបអាហារ អគ្គិសនី ប្រេងឥន្ធនៈ និង ធាតុអាកាស) ប៉ះពាល់ដល់ការហូបចុករបស់អ្នក តើរបបអាហាររបស់អ្នក ឬ ក្រុមគ្រួសារអ្នករងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ? **កុំអាន/បង្ហើបចម្លើយ ជ្រើសរើសកូដទាំងឡាយណា ដែលអ្នកតបសម្ភាសន៍បានឆ្លើយ**

| | |
|---|---|
| a) ខ្ញុំមិនហូបខ្លួនឯងទេ ដើម្បីទុកឲ្យកូនខ្ញុំហូប | 1 |
| b) ខ្ញុំប្រើគ្រឿងផ្សំដែលធូរថ្លៃ | 2 |
| c) កូនខ្ញុំមិនមានអាហារហូបក្នុងពេលណាមួយ (ឧ. មិនហូបអាហារពេលព្រឹក) | 3 |
| d) របបអាហាររបស់ខ្ញុំមិនមានច្រើនមុខទេ | 4 |
| e) ខ្ញុំមានការយល់ដឹងកាន់តែច្រើនអំពីអាហារូបត្ថម្ភ | 5 |
| f) របបអាហាររបស់ខ្ញុំមានកាន់តែច្រើនមុខ | 6 |
| g) រាល់ពេលមានអាហារតិចតួចប៉ុណ្ណោះសម្រាប់គ្រួសារខ្ញុំ | 7 |
| h) ផ្សេងៗ (សូមបញ្ជាក់) | 8 |
| i) មិនដឹង | 88 |
| j) មិនឆ្លើយ/បដិសេធ | 99 |

**សួរសំណួរខាងក្រោមនេះចំពោះតែអ្នកដែលជ្រើសរើសកូដ 5, 4 ក្នុង QX2d (ប៉ះពាល់ដល់ការប្រើប្រាស់ទឹកប្រចាំថ្ងៃ) ប៉ុណ្ណោះ**

**QX5a** នៅចុងបញ្ចប់ អ្នកបានប្រាប់ថា ការប្រែប្រួលខាងលើ (ឧ. ទឹក ម្ហូបអាហារ អគ្គិសនី ប្រេងឥន្ធនៈ និង ធាតុអាកាស) ប៉ះពាល់ដល់ការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់អ្នក តើការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់អ្នក ឬ ក្រុមគ្រួសារអ្នករងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ?

**កុំអាន/បង្ហើបចម្លើយ ជ្រើសរើសកូដណា ដែលអ្នកតបសម្ភាសន៍បានឆ្លើយ**

| | |
|---|---|
| a) មិនសូវមានទឹកស្អាតផឹក | 1 |
| b) គ្រប់ពេលពីចេញពីបង្គន់ខ្ញុំមិនលាងដៃទេ | 2 |
| c) ពេលរៀបចំបាយម្ហូប / ចំណីអាហារ ខ្ញុំមិនលាងដៃទេ | 3 |
| d) មិនលាងដៃមុនពេលបរិភោគ | 4 |
